ហាមលក់
កម្មសិទ្ធិរបស់រដ្ឋ

ក្រសួងអប់រំ យុវជន និងកីឡា

# គណិតវិទ្យា



$P + P' = 1$

៩




$c^2 = a^2 + b^2$

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

2013

# អារម្ភកថា

គោលបំណងនៃគណិតវិទ្យាថ្នាក់ទី 9 ផ្ដល់ឱ្យសិស្សនូវបំណិនសំខាន់ៗដូចខាងក្រោម ។

## 1. ការគណនា

- ការរកឫសការេនិងឫសគូបនៃមួយចំនួន ការធ្វើប្រមាណវិធីទាំងបួនលើចំនួនអសនិទាន
- ការគណនាអត្រាការប្រាក់ អត្រាកំណើននិងតំហយ ការគណនាភាគរយនៃព្រឹត្តិការណ៍មួយដែលអាចកើតឡើងតាមការគណនាប្រូបាប
- ការធ្វើប្រមាណវិធីទាំងបួនលើពហុធានិងកន្សោមសនិទាន
- ការគណនារង្វាស់ជ្រុងមុំព្រមទាំងគណនាផ្ទៃក្រឡានិងមាឌនៃរូបធរណីមាត្រ ។

## 2. ដំណោះស្រាយចំណោទ

- ដំណោះស្រាយចំណោទដោយប្រើសមីការដឺក្រេទី 1 មានមួយអញ្ញាតនិងវិសមីការដឺក្រេទី 1 មានមួយអញ្ញាត
- ដំណោះស្រាយចំណោទដោយប្រើប្រព័ន្ធសមីការដឺក្រេទី 1 មានពីរអញ្ញាត ។

## 3. ការប្រើក្រាប

- ការបកស្រាយទិន្នន័យជាក្រាបសសរ អ៊ីស្តូក្រាម និងក្រាបនៃពហុកោណប្រេកង់
- ការបកស្រាយទំនាក់ទំនងរវាងទំហំពីរដោយបន្ទាត់ដែលមានសមីការ $y = ax + b$ ។

## 4. ការធ្វើវិចារគណិតវិទ្យា

- ការប្រើអនុមានរួម ដោយឱ្យឧទាហរណ៍ជាលេខចំពោះសមីការនៃបន្ទាត់ទាំងពីរ ដើម្បីបកស្រាយឱ្យឃើញថាបន្ទាត់ពីរកែងគ្នា កាលណាវាមានផលនៃមេគុណប្រាប់ទិសស្មើនឹង $-1$
- ការប្រើអនុមានញែក ដោយយករង្វាស់នៃធ្នូទូទៅណាមួយ ដើម្បីបកស្រាយឱ្យឃើញថា មុំចារឹកក្នុងរង្វង់មានរង្វាស់ស្មើនឹងកន្លះរង្វាស់នៃធ្នូដែលវាស្កាត់ ។

គណៈកម្មការនិពន្ធ

# បញ្ជីអត្ថបទ


មេរៀនទី 1 : ចំនួនអសនិទាន ........................................ 01

មេរៀនទី 2 : សមាមាត្រ ........................................ 17

មេរៀនទី 3 : កន្សោមពីជគណិត ........................................ 27

មេរៀនទី 4 : សមីការដឺក្រេទី 1 មានមួយអញ្ញាត ........................................ 41

មេរៀនទី 5 : វិសមីការដឺក្រេទី 1 មានមួយអញ្ញាត ........................................ 51

មេរៀនទី 6 : បំណែងចែកប្រេកង់ ........................................ 61

មេរៀនទី 7 : មធ្យមស្ថិតិ ........................................ 75

មេរៀនទី 8 : ប្រូបាប ........................................ 85

មេរៀនទី 9 : ចម្ងាយរវាងពីរចំណុច ........................................ 97

មេរៀនទី 10 : សមីការនៃបន្ទាត់ ........................................ 105

មេរៀនទី 11 : ប្រព័ន្ធសមីការដឺក្រេទី 1 មានពីរអញ្ញាត ........................................ 121

មេរៀនទី 12 : ទ្រឹស្តីបទពីតាគ័រ ........................................ 135

មេរៀនទី 13 : រង្វង់និងបន្ទាត់ ........................................ 143

មេរៀនទី 14 : លក្ខណៈមុំនៃរង្វង់ ........................................ 159

មេរៀនទី 15 : ទ្រឹស្តីបទតាលែស ........................................ 181

មេរៀនទី 16 : ត្រីកោណដូចគ្នា ........................................ 191

មេរៀនទី 17 : ពហុកោណ ........................................ 213

មេរៀនទី 18 : សូលីត ........................................ 223

មេរៀនទី

# 1 ចំនួនអសនិទាន

## វត្ថុបំណង

- ❑ រកឫសការេនៃមួយចំនួន ។
- ❑ រកឫសគូបនៃមួយចំនួន ។
- ❑ ធ្វើប្រមាណវិធីលើចំនួនអសនិទាន ។

## 1. ឫសការេ



រំលឹក 1. រក $x$ ដែល $x+5=3$

$x = 3-5 = -2$

2. រក $x$ ដែល $2x = 5$

$x = \frac{5}{2} = 2.5$

ចំនួន $-2$ , $\frac{5}{2}$ , $2.5$ ហៅថាចំនួនសនិទាន ។

មានករណីខ្លះចំនួនសនិទានពុំអាចបំពេញលក្ខខណ្ឌនៃសមីការបាន ។

***ឧទាហរណ៍ទី 1 :*** រក $x$ ដែល $x^2 = 9$

ដោយ $3^2 = 9$ , $(-3)^2 = 9$

ដូចនេះ $x = 3$ , $x = -3$

ចំនួន 3 និង $-3$ ជាឫសការេនៃ 9

ហេតុនេះការរកឫសការេនៃ 9 គឺរក $x$ ដែល $x^2 = 9$ ។

***ឧទាហរណ៍ទី 2 :*** រក $x$ ដែល $x^2 = \frac{25}{4}$

ដោយ $\left(\frac{5}{2}\right)^2 = \frac{25}{4}$ , $\left(-\frac{5}{2}\right)^2 = \frac{25}{4}$

ដូចនេះ $x = \frac{5}{2}$ , $x = -\frac{5}{2}$

ចំនួន $\frac{5}{2}$ , $-\frac{5}{2}$ ជាឬសការេនៃ $\frac{25}{4}$

គេអាចថា $\frac{25}{4}$ មានឬសការេពីរផ្ទុយគ្នាគឺ $\frac{5}{2}$ និង $-\frac{5}{2}$ ។

***ឧទាហរណ៍ទី 3 :*** រក $x$ ដែល $x^2 = 3$

បើឱ្យ $x = 1$ $\quad 1^2 = 1 < 3$

បើឱ្យ $x = \frac{3}{2} = 1.5$ $\quad \left(\frac{3}{2}\right)^2 = 2.25 < 3$

បើឱ្យ $x = \frac{5}{3} = 1.66$ $\quad \left(\frac{5}{3}\right)^2 = 2.77 < 3$

បើឱ្យ $x = 2$ $\quad 2^2 = 4 > 3$

យើងឃើញថាគ្មានចំនួនសនិទានណាដែលការេវាស្មើនឹង 3 ទេ ។

ក្នុងករណីនេះគេសន្មតតាង $\sqrt{3}$ ជាចំនួនមួយដែល $(\sqrt{3})^2 = 3$

មានន័យថា បើ $x^2 = 3$ , ឬសការេនៃ 3 គឺ $\sqrt{3}$ និង $-\sqrt{3}$

$\sqrt{3}$ ជាឬសការេវិជ្ជមាន ហើយ $-\sqrt{3}$ ជាឬសការេអវិជ្ជមាន ។

ចំនួន $\sqrt{3}$ ហៅថាចំនួនអសនិទានដែល $\sqrt{3} \approx 1.7320$

ចំពោះចំនួន $\sqrt{3}$ , សញ្ញា $\sqrt{\ }$ ហៅថារ៉ាឌីកាល់មានសន្ទស្សន៍ស្មើនឹង 2 ។

តាមពិតគេត្រូវសរសេរ $\sqrt[2]{3}$ ដើម្បីសំគាល់សន្ទស្សន៍នៃរ៉ាឌីកាល់ ហើយ 3 ហៅថារ៉ាឌីកង់ ។

***ឧទាហរណ៍ទី 4 :*** រក $x$ បើ $x^2 = -3$

គេដឹងថាគ្មានតម្លៃ $x$ ណាដែលនាំឱ្យ $x^2$ ជាចំនួនអវិជ្ជមានទេ

ដូចនេះចំនួនអវិជ្ជមានគ្មានឬសការេទេ ។

> ***ជាទូទៅ :*** បើ $a > 0$ , $x^2 = a$ គេបាន $x = \sqrt{a}$ និង $x = -\sqrt{a}$ ។

***លំហាត់គំរូ :*** រកឬសការេនៃសមីការខាងក្រោម ។

ក. $x^2 = 16$ $\quad$ ខ. $x^2 = 7$

គ. $x^2 = \frac{25}{4}$ $\quad$ ឃ. $x^2 = -81$

ង. $x^2 = 1$ $\quad$ ច. $x^2 = 0$ ។

***ចម្លើយ :***

ក. $4^2 = 16$ , $(-4)^2 = 16$ បើ $x^2 = 16$

ដូចនេះ $x = \sqrt{16} = 4$ , $x = -\sqrt{16} = -4$ ។

ខ. ពុំមានចំនួនសនិទានណាដែលការេវាស្មើនឹង 7

ដូចនេះឫសការេវាជាចំនួនអសនិទាន $x = \sqrt{7}$ និង $x = -\sqrt{7}$ ។

គ. $\left(\frac{5}{2}\right)^2 = \frac{25}{4}$ , $\left(-\frac{5}{2}\right)^2 = \frac{25}{4}$

ដូចនេះ $x = \sqrt{\frac{25}{4}} = \frac{5}{2}$ , $x = -\sqrt{\frac{25}{4}} = -\frac{5}{2}$ ។

ឃ. គ្មានចំនួនណាដែលការេវាជាចំនួនអវិជ្ជមាន

ដូចនេះ $-81$ គ្មានឫសការេ ។

ង. $1^2 = 1$ , $(-1)^2 = 1$

ដូចនេះ $x = \sqrt{1} = 1$ , $x = -\sqrt{1} = -1$ ។

ច. $0^2 = 0$ ដូចនេះ $x = 0$ ជាឫសការេនៃ 0 ។

***ប្រតិបត្តិ :*** រកឫសការេនៃចំនួន

$0.04$ , $0.01$ , $5$ , $-1$ , $\frac{25}{36}$ , $0.1$ ។

## 2. ឫសគូប

***ឧទាហរណ៍ទី 1 :*** រក $x$ ដែល $x^3 = 64$

$4^3 = 64$ , $(-4)^3 = -64$ ដូចនេះ $x = 4$ ជាឫសគូបនៃ 64

គេថា 64 មានឫសគូបតែមួយគត់គឺ $x = 4$

រកឫសគូបនៃ 64 គឺរក $x$ ដែល $x^3 = 64$ ។

***ឧទាហរណ៍ទី 2 :*** រក $x$ ដែល $x^3 = -27$

$3^3 = 27$ , $(-3)^3 = -27$ ដូចនេះ $x = -3$ ជាឫសគូបនៃ $-27$

$-27$ មានឫសគូបតែមួយគត់គឺ $x = -3$ ។

គេសង្កេតឃើញថាគ្រប់ចំនួនវិជ្ជមានឬអវិជ្ជមាន មានឫសគូបតែមួយគត់ ។ ឫសគូបនៃចំនួនវិជ្ជមានជាចំនួនវិជ្ជមាន ហើយឫសគូបនៃចំនួនអវិជ្ជមានជាចំនួនអវិជ្ជមាន ។

***ឧទាហរណ៍ទី 3 :*** រក $x$ ដែល $x^3 = 17$

$$2^3 = 8 \ , \ (2.5)^3 = 15.6 \ , \ (2.6)^3 = 17.5$$

យើងឃើញថាគ្មានចំនួនសនិទានណាដែលឫសគូបវាស្មើនឹង 17

ក្នុងករណីនេះ គេសន្មតតាង $\sqrt[3]{17}$ ជាឫសគូបនៃ 17

$\sqrt[3]{17}$ ជាចំនួនអសនិទាន

ចំពោះ $\sqrt[3]{17}$ សញ្ញា $\sqrt[3]{\ }$ ជារ៉ាឌីកាល់ដែលមានសន្ទស្សន៍ស្មើនឹង 3 ហើយ 17 ជារ៉ាឌីកង់ ។

***ឧទាហរណ៍ទី 4 :*** រក $x$ ដែល $x^3 = -17$

ឫសគូបនៃចំនួនអវិជ្ជមានជាចំនួនអវិជ្ជមាន ហេតុនេះឫសគូបនៃ $-17$ គឺ $-\sqrt[3]{17}$ ។

***ជាទូទៅ :*** បើ $x^3 = a$ គេបាន $x = \sqrt[3]{a}$ $a$ អាចវិជ្ជមាន ឬ អវិជ្ជមាន

***លំហាត់គំរូ :*** រកឫសគូបនៃចំនួនខាងក្រោម ។

ក. $x^3 = -64$ ខ. $x^3 = -1$ គ. $x^3 = 1$

ឃ. $x^3 = -8$ ង. $x^3 = 4$ ច. $x^3 = 0$

ឆ. $x^3 = \frac{1}{8}$ ជ. $x^3 = \frac{27}{125}$ ឈ. $x^3 = -\frac{1}{1\ 000}$ ។

***ចម្លើយ :***

ក. $(-4)^3 = -64$

ដូចនេះ $x = \sqrt[3]{-64} = -4$ ។

ខ. $(-1)^3 = -1$

ដូចនេះ $x = \sqrt[3]{-1} = -1$ ។

គ. $1^3 = 1$

ដូចនេះ $x = \sqrt[3]{1} = 1$ ។

ឃ. $(-2)^3 = -8$

ដូចនេះ $x = \sqrt[3]{-8} = -2$ ។

ង. គ្មានចំនួនសនិទានណាដែលឫសគូបវាស្មើនឹង 4

ហេតុនេះ $x = \sqrt[3]{4}$ ជាឫសគូបនៃ 4 ។

ច. $0^3 = 0$

ដូចនេះ $x = 0$ ។

ឆ. $\left(\frac{1}{2}\right)^3 = \frac{1}{8}$

ដូចនេះ $x = \sqrt[3]{\frac{1}{8}} = \frac{1}{2}$ ។

ជ. $\left(\frac{3}{5}\right)^3 = \frac{27}{125}$

ដូចនេះ $x = \sqrt[3]{\frac{27}{125}} = \frac{3}{5}$ ។

ឈ. $\left(-\frac{1}{10}\right)^3 = -\frac{1}{1\ 000}$

ដូចនេះ $x = \sqrt[3]{-\frac{1}{1\ 000}} = -\frac{1}{10}$ ។

*ប្រតិបត្តិ :* រកឫសគូបនៃចំនួន $0.008$ , $-0.001$ , $0.08$ , $-0.4$ ។

# 3. ប្រមាណវិធីលើរ៉ាឌីកាល់

## 3.1. វិធីគុណ

*ឧទាហរណ៍ទី 1 :* គេអាចប្រៀបធៀប $\sqrt{4}\times\sqrt{9}$ និង $\sqrt{4\times 9}$ ដូចខាងក្រោម

$\sqrt{4}\times\sqrt{9} = 2\times 3 = 6$ ហើយ $\sqrt{4\times 9} = \sqrt{36} = 6$

ដូចនេះ $\sqrt{4}\times\sqrt{9} = \sqrt{4\times 9}$ ។

*ឧទាហរណ៍ទី 2 :* គេអាចប្រៀបធៀប $\sqrt[3]{8}\times\sqrt[3]{27}$ និង $\sqrt[3]{8\times 27}$ ដូចខាងក្រោម

$\sqrt[3]{8}\times\sqrt[3]{27} = 2\times 3 = 6$ ហើយ $\sqrt[3]{8\times 27} = \sqrt[3]{216} = \sqrt[3]{6^3} = 6$

ដូចនេះ $\sqrt[3]{8}\times\sqrt[3]{27} = \sqrt[3]{8\times 27}$ ។

*ជាទូទៅ :* ផលគុណនៃរ៉ាឌីកាល់ដែលមានសន្ទស្សន៍ដូចគ្នាស្មើនឹងរ៉ាឌីកាល់នៃផលគុណ

$\sqrt{a}\times\sqrt{b} = \sqrt{ab}$ $\quad a\geq 0$ , $b\geq 0$

$\sqrt[3]{a}\times\sqrt[3]{b} = \sqrt[3]{ab}$ $\quad a$ , $b$ អាចវិជ្ជមានឬអវិជ្ជមាន ។

*លំហាត់គំរូ :* គណនាផលគុណនៃរ៉ាឌីកាល់ខាងក្រោម ។

ក. $\sqrt{2}\times\sqrt{8}$ $\qquad$ ខ. $\sqrt{3}\times\sqrt{27}$

គ. $\sqrt[3]{2}\times\sqrt[3]{4}$ $\qquad$ ឃ. $\sqrt[3]{2}\times\sqrt[3]{\frac{1}{16}}$

ង. $\sqrt{2}\times\sqrt{32}$ $\qquad$ ច. $\sqrt{50}\times\sqrt{2}$ ។

***ចម្លើយ :***

ក. $\sqrt{2}\times\sqrt{8} = \sqrt{2\times8} = \sqrt{16} = \sqrt{4^2} = 4$

ខ. $\sqrt{3}\times\sqrt{27} = \sqrt{3\times27} = \sqrt{81} = \sqrt{9^2} = 9$

គ. $\sqrt[3]{2}\times\sqrt[3]{4} = \sqrt[3]{2\times4} = \sqrt[3]{8} = \sqrt[3]{2^3} = 2$

ឃ. $\sqrt[3]{2}\times\sqrt[3]{\frac{1}{16}} = \sqrt[3]{2\times\frac{1}{16}} = \sqrt[3]{\frac{1}{8}} = \sqrt[3]{\left(\frac{1}{2}\right)^3} = \frac{1}{2}$

ង. $\sqrt{2}\times\sqrt{32} = \sqrt{64} = \sqrt{8^2} = 8$

ច. $\sqrt{50}\times\sqrt{2} = \sqrt{50\times2} = \sqrt{100} = \sqrt{10^2} = 10$ ។

***ប្រតិបត្តិ :*** គណនា $\sqrt{10}\times\sqrt{0.1}$ , $\sqrt[3]{10}\times\sqrt[3]{0.1}$ ។

## ១.២. វិធីចែករ៉ាឌីកាល់

***ឧទាហរណ៍ទី 1 :*** គេអាចប្រៀបធៀប $\frac{\sqrt{36}}{\sqrt{4}}$ និង $\sqrt{\frac{36}{4}}$ ដូចខាងក្រោម

$\frac{\sqrt{36}}{\sqrt{4}} = \frac{\sqrt{6^2}}{\sqrt{2^2}} = \frac{6}{2} = 3$ ហើយ $\sqrt{\frac{36}{4}} = \sqrt{9} = 3$ ហេតុនេះ $\frac{\sqrt{36}}{\sqrt{4}} = \sqrt{\frac{36}{4}}$ ។

***ឧទាហរណ៍ទី 2 :*** គេអាចប្រៀបធៀប $\frac{\sqrt[3]{27}}{\sqrt[3]{8}}$ និង $\sqrt[3]{\frac{27}{8}}$ ដូចខាងក្រោម

$\frac{\sqrt[3]{27}}{\sqrt[3]{8}} = \frac{\sqrt[3]{3^3}}{\sqrt[3]{2^3}} = \frac{3}{2}$ ហើយ $\sqrt[3]{\frac{27}{8}} = \sqrt[3]{\left(\frac{3}{2}\right)^3} = \frac{3}{2}$ ហេតុនេះ $\frac{\sqrt[3]{27}}{\sqrt[3]{8}} = \sqrt[3]{\frac{27}{8}}$ ។

***ជាទូទៅ :*** ផលចែកនៃរ៉ាឌីកាល់ដែលមានសន្ទស្សន៍ដូចគ្នាស្មើនឹងរ៉ាឌីកាល់នៃផលចែក

$$\frac{\sqrt{a}}{\sqrt{b}} = \sqrt{\frac{a}{b}} \quad , \ a\ge 0 \ , \ b>0 \text{ ។}$$

$$\frac{\sqrt[3]{a}}{\sqrt[3]{b}} = \sqrt[3]{\frac{a}{b}} \quad , \ b\ne 0 \text{ ។}$$

***លំហាត់គំរូ :*** គណនាផលចែកនៃរ៉ាឌីកាល់ខាងក្រោម ។

ក. $\frac{\sqrt{8}}{\sqrt{2}}$ ខ. $\frac{\sqrt[3]{48}}{\sqrt[3]{6}}$

គ. $\frac{\sqrt{3}}{\sqrt{27}}$ ឃ. $\frac{\sqrt{288}}{\sqrt{2}}$

ង. $\frac{\sqrt[3]{16}}{\sqrt[3]{2}}$ ច. $\frac{\sqrt[3]{\frac{1}{2}}}{\sqrt[3]{4}}$

ឆ. $\frac{\sqrt{10}}{\sqrt{0.1}}$ ជ. $\frac{\sqrt[3]{25}}{\sqrt[3]{0.2}}$ ។

*ចម្លើយ :*

ក. $\frac{\sqrt{8}}{\sqrt{2}} = \sqrt{\frac{8}{2}} = \sqrt{4} = \sqrt{2^2} = 2$

ខ. $\frac{\sqrt[3]{48}}{\sqrt[3]{6}} = \sqrt[3]{\frac{48}{6}} = \sqrt[3]{8} = \sqrt[3]{2^3} = 2$

គ. $\frac{\sqrt{3}}{\sqrt{27}} = \sqrt{\frac{3}{27}} = \sqrt{\frac{1}{9}} = \sqrt{\left(\frac{1}{3}\right)^2} = \frac{1}{3}$

ឃ. $\frac{\sqrt{288}}{\sqrt{2}} = \sqrt{\frac{288}{2}} = \sqrt{144} = \sqrt{12^2} = 12$

ង. $\frac{\sqrt[3]{16}}{\sqrt[3]{2}} = \sqrt[3]{\frac{16}{2}} = \sqrt[3]{8} = \sqrt[3]{2^3} = 2$

ច. $\frac{\sqrt[3]{\frac{1}{2}}}{\sqrt[3]{4}} = \sqrt[3]{\frac{\frac{1}{2}}{4}} = \sqrt[3]{\frac{1}{8}} = \sqrt[3]{\left(\frac{1}{2}\right)^3} = \frac{1}{2}$

ឆ. $\frac{\sqrt{10}}{\sqrt{0.1}} = \sqrt{\frac{10}{0.1}} = \sqrt{100} = \sqrt{10^2} = 10$

ជ. $\frac{\sqrt[3]{25}}{\sqrt[3]{0.2}} = \sqrt[3]{\frac{25}{0.2}} = \sqrt[3]{125} = \sqrt[3]{5^3} = 5$ ។

*ប្រតិបត្តិ :* គណនាផលចែក

$\frac{\sqrt{7}}{\sqrt{28}}$ , $\frac{\sqrt[3]{5}}{\sqrt[3]{0.2}}$ , $\frac{\sqrt{10}}{\sqrt{1\ 000}}$ , $\frac{\sqrt[3]{100}}{\sqrt[3]{0.1}}$ ។

## ៣.៣. ការបញ្ចេញមួយចំនួនពីរ៉ាឌីកាល់

***ឧទាហរណ៍ទី 1 :*** រក $x$ បើ $x^2 = 9$ , តាមរូបមន្ត $x = \sqrt{a}$ , $x = -\sqrt{a}$ , 9 មានឫសការេពីរ

គឺ $x = \sqrt{9}$ និង $x = -\sqrt{9}$

ម្យ៉ាងទៀត $3^2 = 9$ , $(-3)^2 = 9$ ដូចនេះ 3 , −3 ក៏ជាឫសការេនៃ 9

យើងទាញបាន $\sqrt{9} = 3$ , $-\sqrt{9} = -3$

គេសំគាល់ឃើញថា $\sqrt{9} = \sqrt{3^2} = 3$ មានន័យថាគេបានបញ្ចេញ 9 ពីរ៉ាឌីកាល់ ។

***ឧទាហរណ៍ទី 2 :*** រក $x$ បើ $x^3 = 8$ តាម $x^3 = a$ , $x = \sqrt[3]{a}$

ម្យ៉ាងទៀត $2^3 = 8$

យើងទាញបាន $\sqrt[3]{8} = 2$

គេសំគាល់ឃើញថា $\sqrt[3]{8} = \sqrt[3]{2^3} = 2$ មានន័យថាគេបានបញ្ចេញ 8 ពីរ៉ាឌីកាល់ ។

> ***ជាទូទៅ :*** ដើម្បីបញ្ចេញមួយចំនួនពីរ៉ាឌីកាល់ គេត្រូវបំប្លែងរ៉ាឌីកង់ជាស្វ័យគុណដែលមាននិទស្សន្តស្មើនឹងសន្ទស្សន៍នៃរ៉ាឌីកាល់ ។

ករណីរ៉ាឌីកង់ជាចំនួនអថេរ

ដោយ $\sqrt{5^2} = 5$ , $\sqrt{(-5)^2} = 5$ ដូចនេះ $\sqrt{x^2} = |x|$ ជាចំនួនវិជ្ជមាន

បើ $x \geq 0$ នោះ $\sqrt{x^2} = x$ , បើ $x \leq 0$ , $\sqrt{x^2} = -x$

ដោយ $\sqrt[3]{5^3} = 5$ , $\sqrt[3]{(-5)^3} = -5$ ដូចនេះ $\sqrt[3]{x^3} = x$ ។

*លំហាត់គំរូទី 1 :* បញ្ចេញមួយចំនួនពីរ៉ាឌីកាល់

ក. $\sqrt{121}$ ខ. $\sqrt{\frac{4}{9}}$ គ. $\sqrt[3]{125}$

ឃ. $\sqrt{16\times 81}$ ង. $\sqrt[3]{-27}$ ច. $\sqrt[3]{\frac{2}{2000}}$ ។

*ចម្លើយ :*

ក. $\sqrt{121}=\sqrt{11^2}=11$ ខ. $\sqrt{\frac{4}{9}}=\sqrt{\left(\frac{2}{3}\right)^2}=\frac{2}{3}$

គ. $\sqrt[3]{125}=\sqrt[3]{5^3}=5$ ឃ. $\sqrt{16\times 81}=\sqrt{(4\times 9)^2}=36$

ង. $\sqrt[3]{-27}=-\sqrt[3]{27}=-\sqrt[3]{3^3}=-3$ ច. $\sqrt[3]{\frac{2}{2000}}=\sqrt[3]{\frac{1}{1000}}=\sqrt[3]{\left(\frac{1}{10}\right)^3}=\frac{1}{10}$ ។

*លំហាត់គំរូទី 2 :* បញ្ចេញចំនួន $\sqrt{32}$ និង $\sqrt[3]{16}$ ពីរ៉ាឌីកាល់ ។

*ចម្លើយ :*

តាមលក្ខណៈនៃវិធីគុណ $\sqrt{32}=\sqrt{16\times 2}=\sqrt{16}\times\sqrt{2}=\sqrt{4^2}\times\sqrt{2}=4\sqrt{2}$

$\sqrt[3]{16}=\sqrt[3]{8\times 2}=\sqrt[3]{8}\times\sqrt[3]{2}=\sqrt[3]{2^3}\times\sqrt[3]{2}=2\sqrt[3]{2}$ ។

*ប្រតិបត្តិ :* បញ្ចេញមួយចំនួនពីរ៉ាឌីកាល់

$\sqrt{\frac{2}{8}}$ , $\sqrt[3]{\frac{81}{3}}$ , $\sqrt{12}$ , $\sqrt[3]{81}$ , $\sqrt{50}$ , $\sqrt{\frac{2}{25}}$ ។

## 3.4. ការបញ្ចូលមួយចំនួនក្នុងរ៉ាឌីកាល់

ការបញ្ចូលមួយចំនួនទៅក្នុងរ៉ាឌីកាល់ ជាវិធីច្រាសនៃការបញ្ចេញមួយចំនួនពីរ៉ាឌីកាល់ ។

*ឧទាហរណ៍ទី 1 :* គេមាន $4\sqrt{2}$ បញ្ចូល 4 ទៅក្នុងរ៉ាឌីកាល់

$4\sqrt{2}=\sqrt{4^2}\times\sqrt{2}=\sqrt{4^2\times 2}=\sqrt{16\times 2}=\sqrt{32}$ , $(4=\sqrt{4^2})$ ។

*ឧទាហរណ៍ទី 2 :* គេមាន $3\sqrt[3]{2}$ បញ្ចូល 3 ទៅក្នុងរ៉ាឌីកាល់

$3\sqrt[3]{2}=\sqrt[3]{3^3}\times\sqrt[3]{2}=\sqrt[3]{27\times 2}=\sqrt[3]{54}$ , $(3=\sqrt[3]{3^3})$ ។

*ជាទូទៅ :* ដើម្បីបញ្ចូលមួយចំនួនទៅក្នុងរ៉ាឌីកាល់ គេត្រូវលើកចំនួននោះជាស្វ័យគុណដោយឱ្យនិទស្សន្តនៃស្វ័យគុណស្មើនឹងសន្ទស្សន៍នៃរ៉ាឌីកាល់ ។

*លំហាត់គំរូ :* បញ្ចូលមួយចំនួនក្នុងរ៉ាឌីកាល់

ក. $\frac{2}{3}\sqrt{\frac{12}{5}}$ ខ. $5\sqrt{\frac{3}{50}}$ គ. $-7\sqrt{5}$

ឃ. $-5\sqrt[3]{\frac{4}{25}}$ ង. $2\sqrt[3]{\frac{5}{12}}$ ច. $\frac{1}{2}\sqrt[3]{4}$ ។

*ចម្លើយ :*

ក. $\frac{2}{3} = \sqrt{\frac{4}{9}}$ ដូចនេះ $\frac{2}{3}\sqrt{\frac{12}{5}} = \sqrt{\frac{4}{9}} \times \sqrt{\frac{12}{5}} = \sqrt{\frac{4\times 12}{9\times 5}} = \sqrt{\frac{4\times 4}{3\times 5}} = \sqrt{\frac{16}{15}}$

ខ. $5 = \sqrt{25}$ ដូចនេះ $5\sqrt{\frac{3}{50}} = \sqrt{25}\cdot\sqrt{\frac{3}{50}} = \sqrt{\frac{25\times 3}{50}} = \sqrt{\frac{3}{2}}$

គ. $7 = \sqrt{49}$ ដូចនេះ $-7\sqrt{5} = -\sqrt{49}\cdot\sqrt{5} = -\sqrt{49\times 5} = -\sqrt{245}$

ឃ. $5 = \sqrt[3]{5^3}$ ដូចនេះ $-5\sqrt[3]{\frac{4}{25}} = -\sqrt[3]{5^3}\times\sqrt[3]{\frac{4}{25}} = -\sqrt[3]{\frac{4\times 5^3}{25}} = -\sqrt[3]{20}$

ង. $2 = \sqrt[3]{2^3}$ ដូចនេះ $2\sqrt[3]{\frac{5}{12}} = \sqrt[3]{2^3}\times\sqrt[3]{\frac{5}{12}} = \sqrt[3]{\frac{2^3\times 5}{12}} = \sqrt[3]{\frac{10}{3}}$

ច. $\frac{1}{2} = \sqrt[3]{\frac{1}{8}}$ ដូចនេះ $\frac{1}{2}\sqrt[3]{4} = \sqrt[3]{\frac{1}{8}}\times\sqrt[3]{4} = \sqrt[3]{\frac{4}{8}} = \sqrt[3]{\frac{1}{2}}$ ។

*ប្រតិបត្តិ :* បញ្ចូលមួយចំនួនក្នុងរ៉ាឌីកាល់

$\sqrt[3]{\frac{1}{3}}$ , $\frac{1}{3}\sqrt{3}$ , $5\sqrt[3]{\frac{2}{25}}$ , $\frac{2}{11}\sqrt[3]{\frac{121}{7}}$ ។

## 3.5. វិធីបូក-ដកនៃរ៉ាឌីកាល់

ដូចគ្នានឹងវិធីបូកនិងវិធីដកលើឯកធាដែរ $3x + 4x = (3+4)x = 7x$

*ឧទាហរណ៍ទី 1 :*

$$2\sqrt{3} + 6\sqrt{3} = (2+6)\sqrt{3} = 8\sqrt{3}$$

$$7\sqrt{6} - 5\sqrt{6} = (7-5)\sqrt{6} = 2\sqrt{6}$$

$$\sqrt[3]{7} + 4\sqrt[3]{7} = (1+4)\sqrt[3]{7} = 5\sqrt[3]{7}$$

$$12\sqrt[3]{5} - 7\sqrt[3]{5} = (12-7)\sqrt[3]{5} = 5\sqrt[3]{5}$$ ។

*សំគាល់ :* $\sqrt{3} + \sqrt{7}$ មានរ៉ាឌីកង់ខុសគ្នាមិនអាចបូកបានទេ ។

ក្នុងករណីមានរ៉ាឌីកង់ខុសគ្នា គេត្រូវបំប្លែងឱ្យមានរ៉ាឌីកង់ដូចគ្នាសិន ។

*ឧទាហរណ៍ទី 2 :*

$$3\sqrt{2} + \sqrt{8} = 3\sqrt{2} + 2\sqrt{2} = (3+2)\sqrt{2} = 5\sqrt{2}$$

$$5\sqrt{12} - \sqrt{27} = 5\sqrt{4\times 3} - \sqrt{9\times 3}$$

$$= 10\sqrt{3} - 3\sqrt{3} = (10-3)\sqrt{3} = 7\sqrt{3}$$

$$3\sqrt[3]{16} + 5\sqrt[3]{2} = 3\sqrt[3]{8\times 2} + 5\sqrt[3]{2}$$

$$= 6\sqrt[3]{2} + 5\sqrt[3]{2} = (6+5)\sqrt[3]{2} = 11\sqrt[3]{2}$$ ។

**ជាទូទៅ :** ដើម្បីគណនាផលបូកនិងផលដករ៉ាឌីកាល់ដែលមានសន្ទស្សន៍ដូចគ្នា គេត្រូវបំប្លែងរ៉ាឌីកង់ឱ្យដូចគ្នា ។

ដើម្បីគណនាផលបូកនិងផលដករ៉ាឌីកាល់ដែលមានរ៉ាឌីកង់ដូចគ្នានិងមានសន្ទស្សន៍ដូចគ្នា គេបូក-ដកមេគុណនឹងមេគុណ ហើយរ៉ាឌីកាល់ទុកដដែល ។

**លំហាត់គំរូទី 1 :** គណនា

$A = 3\sqrt{11} + 5\sqrt{44} - 3\sqrt{99}$ , $B = 3\sqrt{18} - \sqrt{12} + \sqrt{75} + \sqrt{2}$

$C = 3\sqrt[3]{24} + 6\sqrt[3]{81}$ , $D = 6\sqrt[3]{8x^2} - 2\sqrt[3]{27x^2}$

$E = \sqrt{20} + \sqrt{80} - \sqrt{45}$ , $F = 14\sqrt{3} + 6\sqrt{2} - 11\sqrt{3}$ ។

**ចម្លើយ :**

$A = 3\sqrt{11} + 5\sqrt{4\times 11} - 3\sqrt{9\times 11} = 3\sqrt{11} + 10\sqrt{11} - 9\sqrt{11} = 4\sqrt{11}$

$B = 3\sqrt{9\times 2} - \sqrt{4\times 3} + \sqrt{25\times 3} + \sqrt{2}$

$= 9\sqrt{2} - 2\sqrt{3} + 5\sqrt{3} + \sqrt{2} = 10\sqrt{2} + 3\sqrt{3}$

$C = 3\sqrt[3]{8\times 3} + 6\sqrt[3]{27\times 3} = 6\sqrt[3]{3} + 18\sqrt[3]{3} = 24\sqrt[3]{3}$

$D = 12\sqrt[3]{x^2} - 6\sqrt[3]{x^2} = 6\sqrt[3]{x^2}$

$E = \sqrt{4\times 5} + \sqrt{16\times 5} - \sqrt{9\times 5} = 2\sqrt{5} + 4\sqrt{5} - 3\sqrt{5} = 3\sqrt{5}$

$F = 3\sqrt{3} + 6\sqrt{2}$ ។

**លំហាត់គំរូទី 2 :** សម្រួល

$A = \sqrt{128y} - \sqrt{2y} \quad (y>0)$ , $B = 5\sqrt{18x} + 2\sqrt{8x} \quad (x>0)$

$C = \sqrt{8n+8} + \sqrt{2n+2} \quad (n>0)$ , $D = \sqrt{200k^2} - \sqrt{98k^2} \quad (k>0)$

$E = \sqrt{8x^2} + \sqrt{2x^2} \quad (x>0)$ , $F = 2\sqrt{45x^3} - \sqrt{20x^3} \quad (x>0)$ ។

**ចម្លើយ :**

$A = \sqrt{128y} - \sqrt{2y} = \sqrt{64\times 2y} - \sqrt{2y} = 8\sqrt{2y} - \sqrt{2y} = 7\sqrt{2y}$

$B = 5\sqrt{18x} + 2\sqrt{8x} = 5\sqrt{9\times 2x} + 2\sqrt{4\times 2x} = 15\sqrt{2x} + 4\sqrt{2x} = 19\sqrt{2x}$

$C = \sqrt{8n+8} + \sqrt{2n+2} = \sqrt{4(2n+2)} + \sqrt{2n+2} = 2\sqrt{2n+2} + \sqrt{2n+2} = 3\sqrt{2n+2}$

$D = \sqrt{200k^2} - \sqrt{98k^2} = \sqrt{2\times 100k^2} - \sqrt{2\times 49k^2} = 10k\sqrt{2} - 7k\sqrt{2} = 3k\sqrt{2}$

$E = \sqrt{8x^2} + \sqrt{2x^2} = \sqrt{2\times 4x^2} + \sqrt{2x^2} = 2x\sqrt{2} + x\sqrt{2} = 3x\sqrt{2}$

$F = 2\sqrt{45x^3} - \sqrt{20x^3} = 2\sqrt{5\times 9x^3} - \sqrt{5\times 4x^3} = 6x\sqrt{5x} - 2x\sqrt{5x} = 4x\sqrt{5x}$

*ប្រតិបត្តិ : សម្រួល*

$5\sqrt{50}-8\sqrt{32}$ , $\sqrt{48x}-\sqrt{27x}$ , $\sqrt{5P}+3\sqrt{45P^3}$ $(P>0)$

$\sqrt{12x+12}+\sqrt{27x+27}$ , $\sqrt{72a}-3\sqrt{98a}$ ។

## ៣.៦. វិធីបំបាត់រ៉ាឌីកាល់ពីភាគបែង

ជាទូទៅគេមិនទុកឱ្យចំនួនដែលមានរ៉ាឌីកាល់នៅភាគបែងទេ ។ ខាងក្រោមនេះជាវិធីបំបាត់រ៉ាឌីកាល់ពីភាគបែង ។

***ឧទាហរណ៍ទី 1 :*** $\frac{3}{\sqrt{2}}$ ជាចំនួនដែលមានរ៉ាឌីកាល់នៅភាគបែងជាហេតុធ្វើឱ្យពិបាកស្គាល់មេគុណរបស់វា ។

ក្នុងករណីនេះគេអាចសរសេរ $\frac{3}{\sqrt{2}}=\frac{3\times\sqrt{2}}{\sqrt{2}\sqrt{2}}=\frac{3\sqrt{2}}{2}$ ធ្វើយ៉ាងនេះទើបស្គាល់ $\frac{3}{2}$ ជាមេគុណរបស់វា ។

ដូចគ្នានេះដែរ ចំពោះចំនួន $\frac{\sqrt[3]{3}}{\sqrt[3]{4}}$

$$\frac{\sqrt[3]{3}\sqrt[3]{2}}{\sqrt[3]{4}\sqrt[3]{2}}=\frac{\sqrt[3]{6}}{\sqrt[3]{8}}=\frac{\sqrt[3]{6}}{2}=\frac{1}{2}\sqrt[3]{6}$$

ក្នុងករណីដែលភាគបែងមានរ៉ាឌីកាល់ពីរតួ គេត្រូវគុណនឹងកន្សោមឆ្លាស់ ។

***ឧទាហរណ៍ទី 2 :*** បំបាត់រ៉ាឌីកាល់ពីភាគបែងនៃ $\frac{2}{\sqrt{7}-2}$

កន្សោមឆ្លាស់នៃ $\sqrt{7}-2$ គឺ $\sqrt{7}+2$ ដោយប្រើ $a^2-b^2=(a-b)(a+b)$

ដូចនេះ $\frac{2}{\sqrt{7}-2}=\frac{2(\sqrt{7}+2)}{(\sqrt{7}-2)(\sqrt{7}+2)}=\frac{2(\sqrt{7}+2)}{7-4}=\frac{2(\sqrt{7}+2)}{3}$ ។

***ឧទាហរណ៍ទី3 :*** បំបាត់រ៉ាឌីកាល់ពីភាគបែងនៃ $\frac{\sqrt{2}}{\sqrt{5}+\sqrt{2}}$

$$\frac{\sqrt{2}}{\sqrt{5}+\sqrt{2}}=\frac{\sqrt{2}(\sqrt{5}-\sqrt{2})}{(\sqrt{5}+\sqrt{2})(\sqrt{5}-\sqrt{2})}=\frac{\sqrt{10}-2}{5-2}=\frac{\sqrt{10}-2}{3}$$ ។

***លំហាត់គំរូទី 1 :*** សម្រួល

$A=\frac{\sqrt{3}+\sqrt{2}}{\sqrt{3}-\sqrt{2}}$ , $B=\frac{1+\sqrt{2}}{3-\sqrt{3}}$

$C=\frac{1+\sqrt{3}}{2+\sqrt{5}}$ , $D=\frac{8\sqrt{2}}{\sqrt{20}-\sqrt{18}}$

$E=\frac{2}{\sqrt[3]{7}}$ , $F=\frac{3}{\sqrt[3]{5}-\sqrt[3]{2}}$ ។

**ចម្លើយ :**

$$A = \frac{\sqrt{3}+\sqrt{2}}{\sqrt{3}-\sqrt{2}} = \frac{(\sqrt{3}+\sqrt{2})(\sqrt{3}+\sqrt{2})}{(\sqrt{3}-\sqrt{2})(\sqrt{3}+\sqrt{2})} = \frac{(\sqrt{3}+\sqrt{2})^2}{3-2}$$

$$= (\sqrt{3}+\sqrt{2})^2 = 3+2\sqrt{3}\times\sqrt{2}+2 = 5+2\sqrt{6}$$

$$B = \frac{1+\sqrt{2}}{3-\sqrt{3}} = \frac{(1+\sqrt{2})(3+\sqrt{3})}{(3-\sqrt{3})(3+\sqrt{3})} = \frac{3+\sqrt{3}+3\sqrt{2}+\sqrt{6}}{9-3} = \frac{3+\sqrt{3}+3\sqrt{2}+\sqrt{6}}{6}$$

$$C = \frac{1+\sqrt{3}}{2+\sqrt{5}} = \frac{(1+\sqrt{3})(2-\sqrt{5})}{(2+\sqrt{5})(2-\sqrt{5})} = \frac{2-\sqrt{5}+2\sqrt{3}-\sqrt{15}}{4-5} = -2+\sqrt{5}-2\sqrt{3}+\sqrt{15}$$

$$D = \frac{8\sqrt{2}}{\sqrt{20}-\sqrt{18}} = \frac{8\sqrt{2}(\sqrt{20}+\sqrt{18})}{(\sqrt{20}-\sqrt{18})(\sqrt{20}+\sqrt{18})} = \frac{8\sqrt{40}+8\sqrt{36}}{20-18}$$

$$= \frac{16\sqrt{10}+48}{2} = 8\sqrt{10}+24$$

$$E = \frac{2}{\sqrt[3]{7}} = \frac{2(\sqrt[3]{7})^2}{\sqrt[3]{7}(\sqrt[3]{7})^2} = \frac{2\sqrt[3]{49}}{7}$$

ចំពោះ $F = \dfrac{3}{\sqrt[3]{5}-\sqrt[3]{2}}$ ប្រើរូបមន្ត $(a-b)(a^2+ab+b^2) = a^3-b^3$

$$\frac{3}{\sqrt[3]{5}-\sqrt[3]{2}} = \frac{3[(\sqrt[3]{5})^2+\sqrt[3]{5}\sqrt[3]{2}+(\sqrt[3]{2})^2]}{(\sqrt[3]{5}-\sqrt[3]{2})[(\sqrt[3]{5})^2+\sqrt[3]{5}\times\sqrt[3]{2}+(\sqrt[3]{2})^2]}$$

$$= \frac{3(\sqrt[3]{25}+\sqrt[3]{10}+\sqrt[3]{4})}{5-2} = \frac{3(\sqrt[3]{25}+\sqrt[3]{10}+\sqrt[3]{4})}{3}$$

$$= \sqrt[3]{25}+\sqrt[3]{10}+\sqrt[3]{4}$$ ។

**ប្រតិបត្តិ : សម្រួល**

$$\frac{1}{\sqrt{5}+\sqrt{2}} \ , \ \frac{3\sqrt{2}+2\sqrt{3}}{\sqrt{12}-\sqrt{18}} \ , \ \frac{3}{\sqrt[3]{5}-\sqrt[3]{4}} \ , \ \frac{\sqrt[3]{3}}{\sqrt[3]{4}+\sqrt[3]{2}}$$ ។

## ? លំហាត់

1. ចូរគណនា

$\sqrt{9}$ , $\sqrt{16}$ , $\sqrt{36}$ , $-\sqrt{64}$ , $-\sqrt{100}$

$\sqrt{121}$ , $-\sqrt{144}$ , $\sqrt{625}$ , $\sqrt[3]{8}$ , $\sqrt[3]{-8}$

$-\sqrt[3]{27}$ , $-\sqrt[3]{64}$ , $\sqrt[3]{125}$ , $\sqrt[3]{216}$ , $\sqrt[3]{100}$ ។

2. ចូរគណនា

$\sqrt{\frac{9}{16}}$ , $\sqrt{\frac{49}{9}}$ , $-\sqrt{\frac{81}{4}}$ , $\sqrt{\frac{169}{49}}$ , $\sqrt{\frac{196}{25}}$

$-\sqrt{\frac{400}{225}}$ , $\sqrt[3]{\frac{1}{8}}$ , $\sqrt[3]{-\frac{8}{27}}$ , $\sqrt[3]{\frac{64}{125}}$ , $\sqrt[3]{\frac{512}{343}}$ , $\sqrt[3]{-\frac{216}{1000}}$ ។

3. ចូរសម្រួលរ៉ាឌីកាល់

$\sqrt{16^3}$ , $-\sqrt[3]{36^2}$ , $\sqrt{64^3}$ , $(\sqrt[3]{-8})^3$ , $\sqrt[3]{-27^3}$

$\sqrt[3]{1^5}$ , $\sqrt[3]{8^2}$ , $\sqrt[3]{64^2}$ , $\sqrt[3]{(-27)^2}$ ។

4. ចូរសម្រួលរ៉ាឌីកាល់

$\sqrt{y^2}$ , $\sqrt{x^4}$ , $\sqrt{x^2y^4}$ , $-\sqrt{y^6}$

$\sqrt{\frac{16}{x^2}}$ , $\sqrt{\frac{100}{n^4}}$ , $\sqrt[3]{8x^3}$ , $-\sqrt{64m^3}$ ។

5. ចូរសម្រួលកន្សោម

$\sqrt{(2x)^2}$ , $\sqrt[3]{(-5y)^3}$ , $\sqrt{(4-a)^2}$ , $\sqrt[3]{(x+3)^3}$ , $\sqrt{16b^2+24b+9}$

$\sqrt{9x^2-30x+25}$ , $\sqrt{4m^2-20mn+25n^2}$ , $\sqrt{49x^2-112xy+64y^2}$ ។

6. ចូរបញ្ចេញមួយចំនួនពីរ៉ាឌីកាល់

$\sqrt{18}$ , $-\sqrt{48}$ , $\sqrt{75}$ , $\sqrt{\frac{30}{49}}$ , $\sqrt{\frac{10}{121}}$ , $\sqrt[3]{40}$

$\sqrt[3]{54}$ , $-\sqrt[3]{128}$ , $\sqrt[3]{192}$ , $\sqrt[3]{\frac{3m}{8n^3}}$ , $\sqrt[3]{16a^5}$ ។

7. ចូរបញ្ចេញមួយចំនួនពីរ៉ាឌីកាល់

$\sqrt{36a^2b^3}$ , $\sqrt{27a^4b^3}$ , $\sqrt{72x^5y^2}$ , $-\sqrt{112a^3b^4}$ , $\sqrt{80m^4n^3}$

$\sqrt{64x^2y^3}$ , $\sqrt[3]{16m^3n^3}$ , $\sqrt[3]{-54x^4b^3}$ , $-\sqrt[3]{128a^5y^3}$ , $\sqrt[3]{24p^3q^5}$ ។

8. ចូរបញ្ចូលមួយចំនួនក្នុងរ៉ាឌីកាល់ $x$ , $y$ , $m$ , $n$ និង $p$ ជាចំនួនវិជ្ជមាន ។

$5\sqrt{6}$ , $2m\sqrt{m}$ , $\frac{\sqrt{23}}{y^3}$ , $2\sqrt[3]{5}$ , $2x\sqrt[3]{4}$ , $\frac{\sqrt[3]{3m}}{2n}$ ។

9. ចូរគណនា

$3\sqrt{2}-4\sqrt{2}+5\sqrt{2}-3\sqrt{2}$ , $5\sqrt{2}-3\sqrt{3}-6\sqrt{2}+5\sqrt{3}$

$3\sqrt{15}-4\sqrt{3}-3\sqrt{15}+6\sqrt{3}$ , $4\sqrt{3}-2\sqrt{17}+3\sqrt{17}-3\sqrt{3}-2\sqrt{3}$

$2\sqrt[3]{2}-8\sqrt[3]{3}+\sqrt[3]{2}+3\sqrt[3]{3}$ , $8\sqrt[3]{2}-3\sqrt[3]{3}-5\sqrt[3]{2}+2\sqrt[3]{3}$ ។

10. ចូរគណនា

$\frac{2}{3}\sqrt{27}-\frac{3}{4}\sqrt{48}$ , $\frac{1}{4}\sqrt{288}-\frac{1}{6}\sqrt{72}$ , $\frac{3}{5}\sqrt{75}-\frac{2}{3}\sqrt{27}$

$5\sqrt[3]{128}-3\sqrt[3]{250}$ , $3\sqrt[3]{81}-\frac{1}{2}\sqrt[3]{192}$ , $4\sqrt[3]{54}-3\sqrt[3]{128}$ ។

11. ចូរគណនា

$2\sqrt{8}-3\sqrt{98}-2\sqrt{200}$ , $-3\sqrt{50}-\sqrt{32}+5\sqrt{200}$

$3\sqrt{175}-2\sqrt{28}+3\sqrt{63}-\sqrt{112}$ , $\sqrt{108}-2\sqrt{27}-\sqrt{40}-5\sqrt{160}$

$2\sqrt[3]{16}+3\sqrt[3]{54}-2\sqrt[3]{128}$ , $3\sqrt[3]{81}+\frac{1}{2}\sqrt[3]{128}-3\sqrt[3]{192}+4\sqrt[3]{54}$

$4\sqrt[3]{54}-6\sqrt[3]{81}-4\sqrt[3]{16}+3\sqrt[3]{24}$ , $-2\sqrt[3]{40}-3\sqrt[3]{135}+5\sqrt[3]{320}+8\sqrt[3]{5}$ ។

12. ចូរគណនា

$-2(2\sqrt{12}-\sqrt{18})-5(3\sqrt{32}-\sqrt{27})$ , $3(3\sqrt[3]{40}-\sqrt[3]{135})+4(\sqrt[3]{320}-\sqrt[3]{40})$

$\frac{2\sqrt{27}}{3}-3\sqrt{48}+\frac{4\sqrt{50}}{5}-\frac{4\sqrt{18}}{3}$ , $\frac{2}{3}\sqrt[3]{81}-\frac{1}{2}\sqrt[3]{24}+\frac{2\sqrt[3]{135}}{3}-\frac{3\sqrt[3]{40}}{2}$ ។

13. ចូរគណនាកន្សោមខាងក្រោម $a$ , $b$ , $x$ , $y$ និង $z$ ជាចំនួនវិជ្ជមាន ។

$A = -3\sqrt{32x}+6\sqrt{8x}$ , $B = 2\sqrt{125x^2z}+8x\sqrt{80z}$

$C = 7a\sqrt{b^3}+b\sqrt{4a^2b}-\sqrt{4b}$ , $D = 8b\sqrt{49b}-7\sqrt{9b^3}+a\sqrt{4a}+\sqrt{a^3}$

$E = 3xy\sqrt{x^2y}-2\sqrt{x^4y^3}$ , $F = -3a\sqrt{a^3b^5}-2b\sqrt{a^5b^3}+5\sqrt{a^3b^3}$

$G = 8a\sqrt[3]{54a}+6\sqrt[3]{16a^4}$ , $H = 3\sqrt[3]{x^4y}-6x\sqrt[3]{xy^4}+2\sqrt[3]{x^4y^4}$ ។

14. ចូរគណនាតម្លៃលេខនៃកន្សោម $A$ ចំពោះ $a = 5$ , $b = 3$

$A = \sqrt{ab}-\sqrt{ab^3}-\sqrt{9a^3b^3}-\sqrt{a^3b}$ ។

15. ចូរគណនាតម្លៃលេខនៃកន្សោម $A = \sqrt{4a} + a\sqrt{a^2b} + \sqrt{b^2a} + b\sqrt{9b}$ ចំពោះ $a = 3$ , $b = 2$ ។

16. ចូរគណនា

$(2\sqrt{3})(3\sqrt{2})$ , $(4\sqrt{6})(-2\sqrt{5})$ , $(3\sqrt{5})(5\sqrt{3})$ , $(6\sqrt{2})(-12\sqrt{3})$

$(3\sqrt{8})(-3\sqrt{48})$ , $(-3\sqrt{75})(-2\sqrt{48})$ , $(2\sqrt[3]{3})\left(-\frac{1}{2}\sqrt[3]{2}\right)$ , $(3\sqrt[3]{2})(5\sqrt[3]{15})$

$(6\sqrt[3]{8})(-3\sqrt[3]{2})$ ។

17. ចូរគណនា

$3\sqrt{5}(2\sqrt{18} - 3\sqrt{48})$ , $-3\sqrt{3}(3\sqrt{6} - 3\sqrt{2})$ , $\frac{1}{2}\sqrt{3}(2\sqrt{48} - 3\sqrt{32})$

$\frac{3}{2}\sqrt{2}(2\sqrt{18} - 3\sqrt{48})$ , $-4\sqrt[3]{3}(2\sqrt[3]{6} - 2\sqrt[3]{5})$ , $2\sqrt[3]{5}(3\sqrt[3]{3} - 5\sqrt[3]{2})$

$3\sqrt[3]{3}(3\sqrt[3]{8} - 2\sqrt[3]{18})$ , $-3\sqrt[3]{5}(4\sqrt[3]{20} - 2\sqrt[3]{45})$ ។

18. ចូរគណនា

$(2\sqrt{3} - 8)(9 + 2\sqrt{5})$ , $(3\sqrt{5} - 2\sqrt{10})(\sqrt{50} - 2\sqrt{80})$

$(\sqrt{50} - \sqrt{75})(\sqrt{32} - \sqrt{48})$ , $(\sqrt{125} - \sqrt{75})(\sqrt{80} - \sqrt{48})$

$(3\sqrt[3]{18} + 3\sqrt[3]{27})(2\sqrt[3]{8} - 2\sqrt[3]{12})$ , $(\sqrt[3]{80} - 2\sqrt[3]{27})(-3\sqrt[3]{20} - 3\sqrt[3]{12})$ ។

19. គេឱ្យ $a = 3\sqrt{5} - 2\sqrt{10}$ , $b = 5\sqrt{7} + 2\sqrt{10}$ , $c = \sqrt[3]{18} - \sqrt[3]{27}$ និង $d = 3\sqrt[3]{6} + \sqrt[3]{8}$ ។

ចូរគណនា $-3ab$ , $a^2 + b^2$ , $a^2 - 2b^2$ , $b^2 - 2ab$ , $\frac{1}{2}cd$ , $c^2 - b^2$ , $c^2 + 2cd$ ។

20. ចូរគណនា

$\frac{\sqrt{33}}{11}$ , $\frac{-\sqrt{48}}{\sqrt{27}}$ , $2\sqrt{75} \div \sqrt{15}$ , $\frac{2\sqrt{84}}{-\sqrt{12}}$ , $\frac{5\sqrt{25}}{\sqrt{75}} \div \sqrt{5}$

$\frac{12\sqrt[3]{6}}{\sqrt[3]{2}}$ , $\frac{5\sqrt[3]{100}}{25\sqrt[3]{5}}$ , $\left(\frac{\sqrt[3]{72}}{2\sqrt[3]{8}}\right)\sqrt[3]{2}$ , $\frac{6\sqrt[3]{7}}{3\sqrt[3]{6}} \div \frac{4\sqrt[3]{21}}{2\sqrt[3]{3}}$ ។

21. ចូរសម្រួលកន្សោម

$A = \sqrt{\frac{b^2}{b^2 - 14b + 49}}$ , $B = \sqrt{\frac{49x^2 - 56x + 16}{36x^2}}$

$C = \sqrt{\frac{a^2 + 16ab + 64b^2}{a^2 + 10ab + 25b^2}}$ , $D = \sqrt{\frac{25b^2 + 10ab + a^2}{16b^2 + 24ab + 9a^2}}$ ។

22. ចូរបំបាត់រ៉ាឌីកាល់ពីភាគបែង

$\frac{3}{\sqrt{10}}$ , $\frac{3\sqrt{3}}{\sqrt{33}}$ , $\frac{6}{\sqrt{48}}$ , $\frac{8}{\sqrt{27}}$ , $\frac{9\sqrt{4}}{\sqrt{18}}$ , $\frac{5\sqrt{5}}{\sqrt{72}}$ , $\frac{\sqrt[3]{9}}{\sqrt[3]{10}}$ , $\frac{2\sqrt[3]{3}}{\sqrt[3]{30}}$ ,

$\frac{\sqrt[3]{18}}{\sqrt[3]{20}}$ , $\sqrt[3]{\frac{7m}{36n}}$ , $\sqrt[3]{\frac{11p}{49q}}$ , $\sqrt[3]{\frac{3}{4y^2}}$ ។

23. ចូរបំបាត់រ៉ាឌីកាល់ពីភាគបែង

$\frac{36-\sqrt{6}}{\sqrt{8}}$ , $\frac{\sqrt{3}+\sqrt{5}}{3\sqrt{20}}$ , $\frac{8}{2\sqrt{75}-3\sqrt{50}}$ , $\frac{2\sqrt{3}}{2\sqrt{80}-\sqrt{45}}$

$\frac{9-\sqrt[3]{3}}{2\sqrt[3]{32}}$ , $\frac{5\sqrt[3]{4}+\sqrt[3]{3}}{8\sqrt[3]{13}}$ , $\frac{2\sqrt[3]{6}}{2\sqrt[3]{27}-\sqrt[3]{9}}$ , $\frac{2\sqrt[3]{2}}{\sqrt[3]{16}-\sqrt[3]{12}}$ ។

24. ចូរបំបាត់រ៉ាឌីកាល់ពីភាគបែងដែលអថេរជាចំនួនវិជ្ជមាន

$\frac{3}{\sqrt{x}}$ , $\frac{3a}{\sqrt{8ab}}$ , $\frac{3\sqrt{x}}{5\sqrt{2x^3y}}$ , $\frac{8a}{\sqrt[3]{25ab}}$ , $\frac{27\sqrt[3]{m}}{7\sqrt[3]{m^2n}}$ , $\frac{15}{\sqrt{2a}-\sqrt{b}}$

$\frac{7\sqrt{2x}}{2\sqrt{x}+\sqrt{3y}}$ , $\frac{\sqrt[3]{11}}{\sqrt[3]{2m}-\sqrt[3]{12n}}$ , $\frac{7\sqrt[3]{7x}}{\sqrt[3]{x^2}+2\sqrt[3]{y}}$ ។

25. គេឱ្យត្រីកោណកែងមួយមានវិមាត្រ $a$ , $b$ , $c$ ដែល $c$ ជាប្រវែងនៃអ៊ីប៉ូតេនុស។ ចូរគណនាជ្រុងមួយនៃត្រីកោណកែងនេះ បើគេដឹងថា

ក. $a = 3$ , $b = 4$ ខ. $a = 5$ , $b = 12$ គ. $a = 6$ , $b = 8$

ឃ. $c = 26$ , $b = 10$ ង. $b = 30$ , $c = 50$ ។

26. គេឱ្យ $m = 3\sqrt{8}+\sqrt{5}$ និង $n = 3\sqrt{8}-\sqrt{5}$ ។

ចូរគណនា $\frac{mn+m^2}{m}$ , $\frac{m^2-n^2}{m+n}$ , $\frac{n^2-2mn}{n^2}$ ។

27. ចូរប្រៀបធៀបចំនួន $\sqrt{2}$ នឹង $\sqrt[3]{3}$ ។

28. ចូរសម្រួលកន្សោម $A = \sqrt{22-\sqrt{288}}$ ។

29. ចូរគណនាកាំ $r$ នៃស៊ីឡាំង បើមាឌវាមានរង្វាស់ $628\ 000cm^3$

គេឱ្យ $\pi = 3.14$ ។




30. ក. ចូរបង្ហាញថា $2^{17}+2^{17} = 2^{18}$

ខ. ចូរកំណត់ $x$ ដែល $2^x \cdot 2^{x+3} = 8^5$ ។

មេរៀនទី

# 2 សមាមាត្រ

**វត្ថុបំណង**

- ❑ ដោះស្រាយចំណោទដែលទាក់ទងនឹងសមាមាត្រ ។
- ❑ ដោះស្រាយចំណោទដែលទាក់ទងនឹងភាគរយ ។
- ❑ ដោយស្រាយចំណោទដែលទាក់ទងនឹងភាគរយកើនឬ ថយ ។
- ❑ ដោះស្រាយចំណោទដែលទាក់ទងនឹងអត្រាការប្រាក់ ។

## 1. ចំណោទដែលទាក់ទងនឹងសមាមាត្រ

ក្នុងសមាមាត្រ $\frac{a}{b} = \frac{c}{d}$ នោះគេទាញបាន $ad = bc$ ។

រូបមន្តនេះត្រូវបានប្រើប្រាស់ញឹកញាប់ក្នុងដំណោះស្រាយចំណោទ ដែលទាក់ទងនឹងការប្តូរឯកតានៃរង្វាស់រង្វាល់ ចំណោទភាគរយ ... ។

ប្រព័ន្ធនៃរង្វាស់រង្វាល់ដែលយើងធ្លាប់ប្រើមាន

$km$ សម្រាប់ចម្ងាយផ្លូវ

$kg$ សម្រាប់ម៉ាសនៃវត្ថុ

ប៉ុន្តែនៅប្រទេសដទៃក៏មានប្រព័ន្ធរង្វាស់រង្វាល់ផ្សេងទៀត ។

ដូចជា ម៉ាយ($mile$) អ៊ិញ($inch$) ហ្វីត($feet$) សម្រាប់ចម្ងាយ និងផោន($ld$) សម្រាប់ម៉ាស ។ ខាងក្រោមនេះជាភាពសមមូលរវាងឯកតានៃប្រព័ន្ធរង្វាស់រង្វាល់នៃប្រទេសផ្សេងៗ ។



1 ម៉ាយ ($1\ mile$) $= 1.609\ km$

1 អ៊ិញ ($1\ inch$) $= 2.54\ cmm$

1 ហ្វីត ($1\ feet$) $= 0.3048\ km$

1 ផោន ($1\ ld$) $= 0.453\ kg$

***លំហាត់គំរូទី 1 :***

ក. ប្តូរ $1m$ ទៅជា *inch*

ខ. ប្តូរ $100km$ ទៅជា *mile*

គ. ប្តូរ $6feet$ ទៅជា $m$

ឃ. ប្តូរ $1kg$ ទៅជា $ld$ ។

***ចម្លើយ :***

ក. $1inch \to 2.45cm$

$xinch \to 1m$ ឬ $100cm$
$$\frac{1}{x} = \frac{2.54}{100}$$
$$2.54x = 100 \ , \ x = \frac{100}{2.45} = 39.37$$

ដូចនេះ $1m$ ត្រូវជា $39.37inch$ ។

ខ. $1mile \to 1.609km$

$x \to 100km$
$$\frac{1}{x} = \frac{1.609}{100}$$
$$1.609x = 100 \ , \ x = \frac{100}{1.609} = 62.1$$

ដូចនេះ $100km$ ត្រូវជា 62.1 *miles* ។

គ. $1feet \to 0.3048m$

$6feet \to x$
$$\frac{1}{6} = \frac{0.3048}{x}$$
$$x = 6 \times 0.3048 = 1.8288 \approx 1.83$$

ដូចនេះ $6feet$ ត្រូវជា $1.83m$ ។

ឃ. $1ld \to 0.453kg$

$x \to 1kg$
$$\frac{1}{x} = \frac{0.453}{1}$$
$$x = \frac{1}{0.453} = 2.2$$

ដូចនេះ $1kg$ ត្រូវជា $2.2ld$ ។

***លំហាត់គំរូទី 2 :*** អាងមួយអាចចំណុះទឹក $7\ 650dm^3$ បើគេបញ្ចូលទឹកក្នុងល្បឿន $85dm^3$ ក្នុង 2 នាទី តើគេត្រូវប្រើពេលប៉ុន្មានទើបបញ្ចូលទឹកឱ្យពេញអាង ?

*ចម្លើយ :* បើ $t$ ជារយៈពេលសម្រាប់បញ្ចូលទឹកពេញអាង

$85dm^3$ ប្រើពេល $2mn$

$7\ 650dm^3$ ប្រើពេល $t\ mn$

$\frac{85}{7\ 650} = \frac{2}{t}$ , $85t = 2\times 7\ 650$ , $t = \frac{2\times 7\ 650}{85} = 180mn$

$t = 180mn$ ឬ $t = 3h$ ដូចនេះ $t = 3h$ ។

*លំហាត់គំរូទី3 :* បើកង់វិលបាន 1750 ជុំក្នុងរយៈពេល 5 វិនាទី តើក្នុងរយៈពេលមួយម៉ោងវាវិលបានប៉ុន្មានជុំ ?

*ចម្លើយ :* តាង $n$ ជាចំនួនជុំដែលកង់នោះវិលក្នុងមួយម៉ោង

1 750 ជុំប្រើពេល $5s$

$n$ ជុំប្រើពេល $3\ 600s$ (ព្រោះ $1h = 3\ 600s$ )

$\frac{1\ 750}{n} = \frac{5}{3\ 600}$ ឬ $5n = 1\ 750\times 3\ 600$

$n = \frac{1\ 750\times 3\ 600}{5} = 1\ 260\ 000$

ដូចនេះ កង់វិលបាន 1 260 000 ជុំក្នុងរយៈពេលមួយម៉ោង ។

*ប្រតិបត្តិ :* ពីភពព្រះចន្ទមកភពផែនដីមានចម្ងាយប្រមាណ 240 000 *mile* ។ បើគេប្រើវិទ្យុទាក់ទងដែលមានល្បឿន 186 000 *mile* ក្នុងមួយវិនាទីដើម្បីទាក់ទងគ្នា តើគេត្រូវប្រើពេលអស់ប៉ុន្មានទើបទទួលសញ្ញាចេញពីភពព្រះចន្ទ ?

## 2. ចំណោទដែលទាក់ទងនឹងភាគរយ

*ឧទាហរណ៍ទី1 :* នារីធ្វើតេស្តបានពិន្ទុ 8 ហើយបូណាបានពិន្ទុ 6 តើពិន្ទុបូណាត្រូវជាប៉ុន្មានភាគរយនៃពិន្ទុនារី ?

ពិន្ទុបូណាធៀបនឹងពិន្ទុនារីតាងដោយប្រភាគ $\frac{6}{8}$

ភាគរយនៃពិន្ទុបូណាធៀបនឹងពិន្ទុនារីតាងដោយប្រភាគ $\frac{n}{100}$

យើងបាន $\frac{6}{8} = \frac{n}{100}$ , $8n = 600$ , $n = \frac{600}{8} = \frac{6}{8}\times 100 = 75$

ដូចនេះពិន្ទុបូណាត្រូវជា 75% នៃពិន្ទុនារី ។

*ឧទាហរណ៍ទី 2 :* ពូសុខរកបានប្រាក់ចំណូល 30 000៛ ចំណែកឯមីងសំរកបាន 25 000៛

រកភាគរយនៃប្រាក់ចំណូលពូសុខធៀបនឹងមីងសំ ។

ប្រាក់ចំណូលនៃពូសុខធៀបនឹងមីងសំតាងដោយប្រភាគ $\frac{30\ 000}{25\ 000} = \frac{6}{5}$

ភាគរយនៃប្រាក់ចំណូលពូសុខធៀបនឹងមីងសំតាងដោយប្រភាគ $\frac{n}{100}$

យើងបាន $\frac{6}{5} = \frac{n}{100}$ , $5n = 600$ , $n = \frac{600}{5} = \frac{6}{5} \times 100 = 120$

ដូចនេះ ប្រាក់ចំណូលពូសុខត្រូវជា 120% នៃប្រាក់ចំណូលមីងសំ ។

> *ជាទូទៅ :* ភាគរយនៃ $a$ ធៀបនឹង $b$ ត្រូវជា $\frac{a}{b} \times 100\ \%$ ។

*លំហាត់គំរូទី 1 :* វិសាលរកប្រាក់បាន 300 000៛ ក្នុងមួយខែ ហើយសន្សំទុកបាន 60 000៛ រកភាគរយនៃប្រាក់ដែលវិសាលបានសន្សំទុក ។

*ចម្លើយ :* ភាគរយនៃប្រាក់ដែលវិសាលសន្សំទុកបាន

$$\frac{60\ 000}{300\ 000} \times 100\% = \frac{1}{5} \times 100\% = 20\%$$ ។

*លំហាត់គំរូទី 2 :* សុខឆ្លៀតពេលជួយលក់កាសែតឱ្យគេបានប្រាក់សរុប 75 000៛ ហើយទទួលបានប្រាក់កម្រៃ 6 000៛ ។ រកភាគរយនៃប្រាក់កម្រៃនេះ ។

*ចម្លើយ :* ភាគរយនៃប្រាក់កម្រៃធៀបនឹងប្រាក់ដែលគេលក់បាន

$$\frac{6\ 000}{75\ 000} \times 100\% = 8\%$$ ។

*លំហាត់គំរូទី 3 :* សុខត្រូវរកប្រាក់ឱ្យបាន 35 លានរៀលសម្រាប់សង់លំនៅស្ថានមួយ ឥឡូវនេះគាត់សន្សំបាន 60% នៃប្រាក់នេះហើយ ។ រកប្រាក់ដែលគាត់សន្សំបាន ។

*ចម្លើយ :* តាង $x$ ជាប្រាក់ដែលសន្សំបានគិតជាលានរៀល

ប្រាក់សន្សំបានធៀបនឹងប្រាក់ 35 លានរៀលតាងដោយប្រភាគ $\frac{x}{35}$

ដោយដឹងថាភាគរយនៃប្រាក់សន្សំធៀបនឹងប្រាក់ 35 លានរៀលស្មើនឹង 60% ហេតុនេះភាគរយនោះតាងដោយប្រភាគ $\frac{60}{100}$

យើងបាន $\frac{x}{35} = \frac{60}{100}$ , $\frac{x}{35} = \frac{6}{10}$ , $10x = 6 \times 35$ , $x = 21$

ដូចនេះ គាត់សន្សំបានប្រាក់ 21 លានរៀល ។

*លំហាត់គំរូទី 4 :* សុខនិងបូណាបានសហការជួយលក់ទំនិញឱ្យក្រុមហ៊ុនមួយ ។ ក្រុមហ៊ុនឱ្យប្រាក់កម្រៃទៅសុខចំនួន 10% នៃប្រាក់ដែលបានលក់ ហើយសុខចែករំលែកទៅបូណាចំនួន 20% នៃប្រាក់ដែលបានទទួលពីក្រុមហ៊ុន ។ តើបូណាត្រូវទទួលបានប្រាក់ប៉ុន្មាន បើប្រាក់ដែលលក់បានស្មើនឹង 4 លានរៀល ។

*ចម្លើយ :* ដំបូងរកប្រាក់ដែលសុខទទួលពីក្រុមហ៊ុនដែលតាងដោយ $x$ (ឯកតាគិតជាលានរៀល)

$\frac{x}{4} = \frac{10}{100}$ , $100x = 40$ , $x = \frac{40}{100} = 0.4$

សុខទទួលប្រាក់ពីក្រុមហ៊ុនបាន 0.4 លានរៀល បន្ទាប់មករកប្រាក់ដែលបូណាទទួលពីសុខតាងដោយ $y$ (ឯកតាគិតជាលានរៀល) $\frac{y}{0.4} = \frac{20}{100}$ , $100y = 8$ , $y = \frac{8}{100} = 0.08$

ដូចនេះ បូណាទទួលពីសុខចំនួនទឹកប្រាក់ 0.08 លានរៀល ឬ 80000 រៀល ។

*ប្រតិបត្តិ :* ក្រុមហ៊ុនអចលនវត្ថុលក់ដីឱ្យគេដោយទទួលប្រាក់កម្រៃ 1 800 $ ត្រូវជា 3% នៃថ្លៃដី ។ តើដីដែលត្រូវលក់ថ្លៃប៉ុន្មាន ?

## 3. ចំណោននៃភាគរយកើន ឬ ថយ

*ឧទាហរណ៍ទី 1 :* បើគេបង្កើនចំនួនពី 4 ទៅ 5 ។ តើគេបានបង្កើនប៉ុន្មានភាគរយ ?

- 4 ជាចំនួនដើម
- 5 ជាចំនួនកើន
- $5 - 4 = 1$ កំណើន

កំណើនធៀបនឹងចំនួនដើមតាងដោយប្រភាគ $\frac{1}{4}$

ភាគរយនៃកំណើនធៀបនឹងចំនួនដើមតាង ដោយប្រភាគ $\frac{n}{100}$

យើងបាន $\frac{1}{4} = \frac{n}{100}$ , $4n = 100$ , $n = 25$

នាំឱ្យ $n = 25\%$

ដូចនេះ ភាគរយនៃកំណើនស្មើនឹង 25% ។

*ឧទាហរណ៍ទី 2 :* បើគេបន្ថយចំនួនពី 5 មក 4 ។ តើគេបានបន្ថយអស់ប៉ុន្មានភាគរយ ?

- 5 ជាចំនួនដើម
- 4 ជាចំនួនថយ
- $5 - 4 = 1$ ជាតំហយ

តំហយធៀបនឹងចំនួនដើមតាងដោយប្រភាគ $\frac{1}{5}$

ភាគរយនៃតំហយធៀបនឹងចំនួនដើមតាងដោយប្រភាគ $\frac{n}{100}$

យើងបាន $\frac{1}{5} = \frac{n}{100}$ , $5n = 100$ , $n = 20$

នាំឱ្យ $n = 20\%$

ដូចនេះ ភាគរយនៃតំហយស្មើនឹង 20% ។

> ***ជាទូទៅ :***
>
> - បើគេបង្កើនពី $a$ ទៅ $b$ ភាគរយនៃកំណើន កំណត់ដោយ $\frac{b-a}{a}$ 100%
> - បើគេបន្ថយពី $b$ មក $a$ ភាគរយនៃតំហយកំណត់ដោយ $\frac{b-a}{b}$ 100%

***លំហាត់គំរូទី 1 :*** សុខទិញខោមួយថ្លៃ 32 000៛ ជាតម្លៃមួយដែលគេបានបញ្ចុះតម្លៃអស់ 60% ។ ចូរកំណត់ថ្លៃខោនេះទៅពេលដែលគេមិនទាន់បញ្ចុះតម្លៃ ។

***ចម្លើយ :*** $n$ ជាតម្លៃដើម

32 000 ៛ ជាតម្លៃបញ្ចុះថ្លៃ

$\frac{n-32\ 000}{n} = \frac{60}{100}$ ឬ $\frac{n-32\ 000}{n} = \frac{6}{10}$

$$10(n-32\ 000) = 6n$$

$$10n - 320\ 000 = 6n$$

$$4n = 320\ 000\ ,\ n = \frac{320\ 000}{4} = 80\ 000$$

ដូចនេះ តម្លៃដើមស្មើនឹង 80 000៛ ។

***លំហាត់គំរូទី 2 :*** ឆ្នាំមុនសាលារៀនមួយទទួលបានសិស្សចំនួន 840 នាក់ ។ នៅឆ្នាំនេះទទួលសិស្សបាន 945 នាក់ ។ ចូរកំណត់ភាគរយនៃកំណើនសិស្ស ។

***ចម្លើយ :*** កំណើននៃសិស្ស $945 - 840 = 105$

ភាគរយនៃកំណើន $\frac{105}{840} \times 100\% = 12.5\%$

ដូចនេះ នៅឆ្នាំនេះចំនួនសិស្សកើន 12.5% ។

***លំហាត់គំរូទី 3 :*** រកតម្លៃដើមនៃសម្ភារៈមួយដែលបន្ទាប់ពីបង្កើន 30% លក់ក្នុងតម្លៃ 780 ។

***ចម្លើយ :*** តាង $n$ ជាចំនួនដើម បន្ទាប់ពីបង្កើនដល់ 780

កំណើន $780-n$

ភាគរយនៃកំណើន $\frac{780-n}{n} = \frac{30}{100}$

$$\frac{780-n}{n} = \frac{3}{10}$$

$$7\ 800 - 10n = 3n$$

$$7\ 800 = 10n + 3n$$

$$13n = 7\ 800\ ,\ n = 600$$

ដូចនេះ តម្លៃដើមស្មើនឹង 600 ។

***លំហាត់គំរូទី 4 :*** រកតម្លៃដើមនៃសម្ភារៈមួយដែលបន្ទាប់ពីបញ្ចុះតម្លៃ 40% លក់ក្នុងតម្លៃ 3 600៛ ។

***ចម្លើយ :*** តាង $n$ ជាចំនួនដើម បន្ទាប់ពីថយស្មើនឹង 3 600

តំហយ $n-3\ 600$

ភាគរយនៃតំហយ $\frac{n-3\ 600}{n} = \frac{40}{100}$

$$\frac{n-3\ 600}{n} = \frac{4}{10}$$

$$10(n-3\ 600) = 4n$$

$$10n - 36\ 000 = 4n$$

$$10n - 4n = 36\ 000$$

$$6n = 36\ 000$$

$$n = 6\ 000$$

ដូចនេះ តម្លៃដើមស្មើនឹង 6 000៛ ។

***ប្រតិបត្តិ :***

ក. ប្រេងសាំងពីមុនលក់ 1 លីត្រថ្លៃ 4 800៛ ឥឡូវនេះលក់ថ្លៃតែ 4 200៛ ។ តើប្រេងសាំងចុះថ្លៃអស់ប៉ុន្មានភាគរយ ?

ខ. ឆ្នាំទៅសាលារៀនមួយទទួលសិស្សបានតែ 800 នាក់ ។ ប៉ុន្តែឆ្នាំនេះ ការទទួលសិស្សបានកើនឡើង 10% ។ រកចំនួនសិស្សនៃឆ្នាំនេះ ។

## 4. ការប្រាក់

បើគេយកប្រាក់ 100៛ ទៅចងការក្នុងមួយឆ្នាំ គេបានការប្រាក់ 8៛ ។

ការប្រាក់ធៀបនឹងប្រាក់ដើម តាងដោយប្រភាគ $\frac{8}{100}$ ឬ ជាភាគរយ 8% ហៅថាអត្រានៃការប្រាក់ ។

***ឧទាហរណ៍ :*** មីងសំយកប្រាក់ 400 000៛ ទៅដាក់យកការប្រាក់ ដោយទទួលបានអត្រាការប្រាក់ 6% ក្នុងមួយឆ្នាំ បើគាត់នៅតែបន្តដាក់យកការប្រាក់ជាបន្តបន្ទាប់រហូតដល់ឆ្នាំទី 4 តើប្រាក់គាត់នឹងកើនបានប៉ុន្មាន ? គាត់តម្កល់ទុកទាំងការប្រាក់និងប្រាក់ដើម ។

នៅឆ្នាំទី 1 ប្រាក់សរុប $P_1 = 400\ 000 + 400\ 000 \times \frac{8}{100} = 400\ 000 + 32\ 000 = 432\ 000$៛

នៅឆ្នាំទី 2 ប្រាក់សរុប $P_2 = 432\ 000 + 432\ 000 \times \frac{8}{100} = 432\ 000 + 34\ 560 = 466\ 560$ ៛

នៅឆ្នាំទី 3 ប្រាក់សរុប $P_3 = 466\ 560 + 466\ 560 \times \frac{8}{100} = 466\ 560 + 37\ 324.8 = 503\ 884.8$ ៛

នៅឆ្នាំទី 4 ប្រាក់សរុប $P_4 = 503\ 884.8 + 503\ 884.8 \times \frac{8}{100} = 503\ 884.8 + 40\ 310.7$

$= 544\ 195.5$ ៛

ឃើញថាប្រាក់របស់គាត់បានកើន $544\ 195.5 - 400\ 000 = 144\ 195.5$ ៛

បើធៀបនឹងប្រាក់ដើម $\frac{144\ 195.5}{400\ 000} \times 100\% = 36\%$

ប្រាក់គាត់បានកើនឡើង 36% ក្នុងរយៈពេល 4 ឆ្នាំនេះ ។

***ជាទូទៅ :***

- បើ $p_o$ ជាប្រាក់ដើម $r$ ជាអត្រាការប្រាក់ក្នុងមួយឆ្នាំ ហើយ $t$ ជារយៈពេលនៃការដាក់យកកម្រៃ ។

  ឆ្នាំទី 1 : $P_1 = P_o + rP_o = P_o(1+r)$

  ឆ្នាំទី 2 : $P_2 = P_o(1+r) + P_o(1+r)r = P_o(1+r)(1+r) = P_o(1+r)^2$

  ឆ្នាំទី 3 : $P_3 = P_o(1+r)^2 + P_o(1+r)^2 r = P_o(1+r)^2(1+r) = P_o(1+r)^3$

  ឆ្នាំទី t : $P_t = P_o(1+r)^t$

- ប្រាក់សរុប $P = P_o(1+r)^t$ ។

បើគេផ្ទៀងផ្ទាត់ជាមួយការគណនាខាងលើ $P = 400\ 000\left(1+\frac{8}{100}\right)^4 = 400\ 000(1.08)^4$

$= 400\ 000 \times 1.360\ 488\ 89$

$= 544\ 195.5$ ។

***លំហាត់គំរូ :*** ពូសុខយកប្រាក់ $p_o$ ទៅសន្សំយកការប្រាក់ដោយទទួលការប្រាក់ 10% ក្នុងមួយឆ្នាំ ។ តើគាត់ត្រូវដាក់រយៈពេលប៉ុន្មានឆ្នាំទើបបានប្រាក់សរុបស្មើនឹងទ្វេដងនៃប្រាក់ដើម ?

***ចម្លើយ :*** តាមរូបមន្ត $P = P_o(1+r)^t$

$p_o$ ជាប្រាក់ដើម

$r$ អត្រានៃការប្រាក់ $r = 0.1$

$t$ រយៈពេលដែលដាក់ដើម្បីឱ្យបាន $P = 2P_o$

$2P_o = P_o(1+0.1)^t$ ឬ $(1.1)^t = 2$

ដើម្បីរក $t$ គេគណនា $1.1 \times 1.1 \times 1.1 \times 1.1 \times 1.1 \times 1.1 \times 1.1 \times 1.1 \times 1.1 \times 1.1$

$(1.1)^9 = 2.1$ យើងបាន $t = 9$

ហេតុនេះគាត់ត្រូវដាក់ប្រាក់រយៈពេល 9 ឆ្នាំ ។

***ប្រតិបត្តិ :*** ពូសុខយកប្រាក់ 500 000 ៛ ទៅដាក់យកការប្រាក់ ពីរឆ្នាំក្រោយមកគេបានប្រាក់សរុប 605 000 ៛ ។ រកអត្រានៃការប្រាក់ក្នុងមួយឆ្នាំ ។

## ? លំហាត់

1. គណនា $n$ ដែល

   ក. 30% នៃ $n$ ស្មើនឹង 48

   ខ. 25% នៃ 28 ស្មើនឹង $n$

   គ. 17 ជា $n$ % នៃ 85

   ឃ. $n$ % នៃ 150 ស្មើនឹង 20

   ង. $n$ ស្មើនឹង 30% នៃ 400 ។

2. តេស្តមួយមាន 20 សំណួរ នារីធ្វើត្រូវបាន 17 សំណួរ ។ រកភាគរយនៃសំណួរដែលធ្វើត្រូវ ។

3. អាវមួយធ្លាប់លក់ថ្លៃ 25 000 រៀល ហើយឥឡូវលក់ 20 000 រៀល ។ ចូររកភាគរយនៃការលក់បញ្ចុះថ្លៃ ។

4. សាលារៀន $A$ មានសិស្ស 2 400 នាក់ ហើយសាលារៀន $B$ មានសិស្ស 3 000 នាក់ ។ ចូររកភាគរយនៃសិស្សសាលារៀន $A$ ធៀបនឹងសាលារៀន $B$ ។

5. វណ្ណាចង់ទិញកង់មួយថ្លៃ 350 000 រៀល ឥឡូវនេះគាត់សន្សំបាន 60% នៃថ្លៃកង់រួចហើយ ។ តើគាត់នៅខ្វះប្រាក់ប៉ុន្មានទៀតទើបទិញកង់នោះបាន ?

6. សុខសន្សំបានប្រាក់ 60$ ដែលត្រូវជា 80% នៃតម្លៃម៉ាស៊ីនថតរូប ។ តើម៉ាស៊ីននោះថ្លៃប៉ុន្មាន ?

7. ឆ្នាំនេះសាលារៀនទទួលសិស្សបាន 4200 នាក់ ចំនួននេះកើនជាងឆ្នាំមុន 20% ។ ចូររកចំនួនសិស្សនៃឆ្នាំចាស់ ។

8. ទំនិញមួយបានលក់បញ្ចុះតម្លៃ 16% ដោយលក់ក្នុងតម្លៃ 4 200 រៀល រកតម្លៃមុនបញ្ចុះតម្លៃ ។

9. មីងសំបានខ្ចីប្រាក់ពីធនាគារ 1 លានរៀល ដែលមានអត្រាការប្រាក់ 12% ។ គាត់យកប្រាក់ 600 000 ៛ ទៅរកស៊ីចំណេញបាន 180 000 ៛ ហើយប្រាក់ដែលនៅសល់ 400 000 ៛ យកទៅបន្តចងការឱ្យគេក្នុងអត្រា 14% ក្នុងមួយឆ្នាំ ។ នៅពេលដំណាច់ឆ្នាំ តើមីងសំចំណេញឬខាត ?

10. នៅឆ្នាំនេះគេផ្តល់អាហារូបករណ៍ឱ្យសិស្សចំនួន 8% នៃសិស្សដែលបានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីបន្តសិក្សានៅមហាវិទ្យាល័យ ។ ចូររកចំនួនសិស្សដែលបានទទួលអាហារូបករណ៍ បើការប្រឡងសញ្ញាប័ត្រទុតិយភូមិជាប់ត្រឹមតែ 70% ក្នុងចំណោមបេក្ខជន 80 000 នាក់ ។

មេរៀនទី

# 3 កន្សោមពីជគណិត

**វត្ថុបំណង**

- ពន្លាតកន្សោមពីជគណិត ។
- ដាក់កន្សោមពីជគណិតជាផលគុណនៃកត្តា ។
- ធ្វើប្រមាណវិធីលើកន្សោមសនិទាន ។

## 1. ផលគុណនៃកន្សោមពីជគណិត

***ឧទាហរណ៍ទី 1 :*** គណនាផ្ទៃក្រឡានៃចតុកោណកែងដែលមានវិមាត្រដូចរូបដែលឱ្យ ។

ចតុកោណកែងដែលមានវិមាត្រ $2x+5$ និង $3x-2$ មានផ្ទៃក្រឡាកំណត់ដោយ

$S = (2x+5)(3x-2)$




ដើម្បីគណនាផលគុណនៃពីរកត្តាគេប្រើលក្ខណៈ
បំបែកនៃវិធីគុណធៀបនឹងវិធីបូកដក $a(b\pm c) = ab\pm ac$

$$
\begin{aligned}
S &= (2x+5)(3x-2)\\
&= 2x(3x-2)+5(3x-2)\\
&= (2x)(3x)+(2x)(-2)+(5)(3x)+(5)(-2)\\
&= 6x^2-4x+15x-10\\
&= 6x^2+11x-10
\end{aligned}
$$

គេអាចគណនាផលគុណនៃកត្តាដោយប្រើរូបមន្ត

$(a+b)(a+b) = (a+b)^2 = a^2+2ab+b^2$

$(a-b)(a-b) = (a-b)^2 = a^2-2ab+b^2$

$(a-b)(a+b) = a^2-b^2$

$(a-b)(a^2+ab+b^2) = a^3-b^3$

$(a+b)(a^2-ab+b^2) = a^3+b^3$ ។

**ឧទាហរណ៍ទី 2 :** $(2x+3)^2 = 4x^2+12x+9$

$(5x-1)^2 = 25x^2-10x+1$

$(2x+7)(2x-7) = 4x^2-49$

$(x-1)(x^2+x+1) = x^3-1$

$(x+1)(x^2-x+1) = x^3+1$ ។

**លំហាត់គំរូទី 1 :** ចូរគណនា

$A = (k+4)(k^2-4k+1)$ , $B = (a-2)(a^2-3a+2)$

$C = (x+3)(x^2-4x-3)$ , $D = (a-b)(a^2-2ab-3b^2)$ ។

**ចម្លើយ :**

$A = (k+4)(k^2-4k+1)$

$= k(k^2-4k+1)+4(k^2-4k+1)$

$= k^3-4k^2+k+4k^2-16k+4$

$= k^3-15k+4$ ។

$B = (a-2)(a^2-3a+2)$

$= a(a^2-3a+2)-2(a^2-3a+2)$

$= a^3-3a^2+2a-2(a^2-3a+2)$

$= a^3-3a^2+2a-2a^2+6a-4$

$= a^3-5a^2+8a-4$ ។

$C = (x+3)(x^2+4x-3)$

$= x(x^2+4x-3)+3(x^2+4x-3)$

$= x^3+4x^2-3x+3x^2+12x-9$

$= x^3+7x^2+9x-9$ ។

$D = (a-b)(a^2-2ab-3b^2)$

$= a(a^2-2ab-3b^2)-b(a^2-2ab-3b^2)$

$= a^3-2a^2b-3b^2a-ba^2+2ab^2+3b^3$

$= a^3-3a^2b-ab^2+3b^3$ ។

**លំហាត់គំរូទី 2 : ចូរគណនា**

$A = (4x-9)(x^2+x-12)-(2x+1)(2x^2-9x+4)$

$B = (14x+20)(x^2+2x-3)-(2x+2)(7x^2+20x)$

$C = (-6x+1)(x^2-x-2)-(2x-1)(-3x^2+x+2)$ ។

**ចម្លើយ :**

$A = (4x-9)(x^2+x-12)-(2x+1)(2x^2-9x+4)$

$= 4x^3+4x^2-48x-9x^2-9x+108-(4x^3-18x^2+8x+2x^2-9x+4)$

$= 4x^3-5x^2-57x+108-(4x^3-16x^2-x+4)$

$= 11x^2-56x+104$ ។

$B = (14x+20)(x^2+2x-3)-(2x+2)(7x^2+20x)$

$= 14x^3+28x^2-42x+20x^2+40x-60-(14x^3+40x^2+14x^2+40x)$

$= 14x^3+48x^2-2x-60-(14x^3+54x^2+40x)$

$= 14x^3+48x^2-2x-60-14x^3-54x^2-40x$

$= -6x^2-42x-60$ ។

$C = (-6x+1)(x^2-x-2)-(2x-1)(-3x^2+x+2)$

$= -6x^3+6x^2+12x+x^2-x-2-(-6x^3+2x^2+4x+3x^2-x-2)$

$= -6x^3+7x^2+11x-2-(-6x^3+5x^2+3x-2)$

$= -6x^3+7x^2+11x-2+6x^3-5x^2-3x+2$

$= 2x^2+8x$ ។

**លំហាត់គំរូទី 3 : ចូរគណនា**

$A = (x-2)^2-(2x+5)^2$ , $B = 3(2-x)(2+x)-(x-1)^2$

$C = 4(x+1)^2-9(2x-1)^2$ , $D = 2(x+2)^2-(x+1)(x-1)$ ។

**ចម្លើយ :**

$A = (x-2)^2-(2x+5)^2$

$= x^2-4x+4-(4x^2+20x+25)$

$= x^2-4x+4-4x^2-20x-25$

$= -3x^2-24x-21$ ។

$B = 3(2-x)(2+x)-(x-1)^2$

$= 3(4-x^2)-(x^2-2x+1)$

$= 12-3x^2-x^2+2x-1$

$= -4x^2+2x+11$ ។

$C = 4(x+1)^2-9(2x-1)^2$

$= 4(x^2+2x+1)-9(4x^2-4x+1)$

$= 4x^2+8x+4-36x^2+36x-9$

$= -32x^2+44x-5$ ។

$D = 2(x+2)^2-(x+1)(x-1)$

$= 2(x^2+4x+4)-(x^2-1)$

$= 2x^2+8x+8-x^2+1$

$= x^2+8x+9$ ។

***ប្រតិបត្តិ :*** ចូរគណនា

$A = 2(x-2)(-x^2-x+3)-(-2x-1)(x-2)^2$

$B = (x-1)^2(x+2)-x(x+1)^2$ ។

## 2. ការដាក់កន្សោមពីជគណិតជាផលគុណនៃកត្តា

បើគេសរសេរ $S= (2x+5)(3x-2)$ ទៅជា $S= 6x^2+11x-10$ មានន័យថា គេបានពន្លាតកន្សោម $S$ ហើយច្រាសមកវិញ

បើគេសរសេរ $S= 6x^2+11x-10$ ទៅជា $S= (2x+5)(3x-2)$ មានន័យថា គេបានដាក់កន្សោម $S$ ជាផលគុណនៃកត្តា ។

ដើម្បីសរសេរកន្សោមពីជគណិតមួយជាផលគុណនៃកត្តា គេប្រើវិធីដូចខាងក្រោម

### 2.1. ដាក់ជាកត្តារួម

គេប្រើរូបមន្ត $ka \pm kb = k(a\pm b)$ ដែល $k$ ហៅថាកត្តារួម

***ឧទាហរណ៍ទី 1 :*** ដាក់ $A = 2x^2+4xy$ ជាផលគុណនៃកត្តា ។ តួទាំងពីរមាន $2x$ ដូចគ្នា

ហេតុនេះ $2x$ ជាកត្តារួម

$A = 2x(x+2y)$ ។

***ឧទាហរណ៍ទី 2 :*** ដាក់ $A = 2(x-1)+4(x-1)^2$ ជាផលគុណនៃកត្តា ។តួទាំងពីរមាន $2(x-1)$ ដូចគ្នា ហេតុនេះ $2(x-1)$ ជាកត្តារួម

$$A = 2(x-1)[1+2(x-1)]$$
$$= 2(x-1)(1+2x-2)$$
$$= 2(x-1)(2x-1) \text{ ។}$$

***លំហាត់គំរូ :*** ចូរដាក់កន្សោម $A$ និង $B$ ជាផលគុណនៃកត្តា

$A = (x^2-x)+(xy-y)$ , $B = (xz+10x)+(yz+10y)$ ។

***ចម្លើយ :***

$$A = (x^2-x)+(xy-y)$$
$$= x(x-1)+y(x-1)$$
$$= (x-1)(x+y) \text{ ។}$$
$$B = (xz+10x)+(yz+10y)$$
$$= x(z+10)+y(z+10)$$
$$= (z+10)(x+y) \text{ ។}$$

***ប្រតិបត្តិ :*** ចូរដាក់កន្សោមខាងក្រោមជាកត្តារួម

$A = 6x^2(x+1)-2x(x+1)$

$B = 3(x-1)(x+2)+(x^2-x)(x+2)$ ។

## 2.2. ប្រើរូបមន្តសំខាន់ៗ

**គេប្រើរូបមន្ត :** $a^2 \pm 2ab+b^2 = (a \pm b)^2$ , $a^2-b^2 = (a-b)(a+b)$

***ឧទាហរណ៍ :*** $x^2-6x+9 = x^2-2\cdot 3\cdot x+3^2 = (x-3)^2$

$$4x^2+4xy+y^2 = (2x)^2+2\cdot 2xy+y^2 = (2x+y)^2$$

$$9x^2-\frac{1}{4} = (3x)^2-\left(\frac{1}{2}\right)^2 = \left(3x-\frac{1}{2}\right)\left(3x+\frac{1}{2}\right) \text{ ។}$$

***លំហាត់គំរូទី 1 :*** ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា

$A = 2x^3+8x^2+8x$

$B = 4(x-2)^2-(1-3x)^2$ ។

**ចម្លើយ :**

$A = 2x^3 + 8x^2 + 8x$ ដាក់ $2x$ ជាកត្តារួម

$= 2x(x^2 + 4x + 4)$ ប្រើរូបមន្ត $a^2 + 2ab + b^2 = (a+b)^2$

$= 2x(x+2)^2$ ។

$B = 4(x-2)^2 - (1-3x)^2$

$= \left[2(x-2)\right]^2 - (1-3x)^2$ ប្រើរូបមន្ត $a^2 - b^2 = (a-b)(a+b)$

$= \left[2(x-2) - (1-3x)\right]\left[2(x-2) + (1-3x)\right]$

$= (2x - 4 - 1 + 3x)(2x - 4 + 1 - 3x)$

$= (5x-5)(-x-3)$

$= 5(x-5)(-x-3)$

$= -5(x-1)(x+3)$ ។

**លំហាត់គំរូទី 2 :** ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា

$A = 4x^2(x+1) - 9(x+1)$ ។

**ចម្លើយ :**

$A = 4x^2(x+1) - 9(x+1)$ ដាក់ $x+1$ ជាកត្តារួម

$= (x+1)(4x^2 - 9)$ ប្រើរូបមន្ត $a^2 - b^2 = (a-b)(a+b)$

$= (x+1)(2x-3)(2x+3)$ ។

**លំហាត់គំរូទី 3 :** គេឱ្យកន្សោម $A = 9(2x-3)^2 - 4(x+5)^2$

ក. ពន្លាតកន្សោម $A$ រួចគណនាតម្លៃ $A$ ទៅតាមតម្លៃ $x = 1$ ។

ខ. ដាក់កន្សោម $A$ ជាផលគុណនៃកត្តារួចគណនា $A$ ទៅតាមតម្លៃ $x = 1$ ។

**ចម្លើយ :**

ក. $A = 9(2x-3)^2 - 4(x+5)^2$

$= 9(4x^2 - 12x + 9) - 4(x^2 + 10x + 25)$

$= 36x^2 - 108x + 81 - 4x^2 - 40x - 100$

$= 32x^2 - 148x - 19$

ចំពោះ $x = 1$ , $A = 32 - 148 - 19 = -135$ ។

ខ. $A = 9(2x-3)^2 - 4(x+5)^2$

$= [3(2x-3)]^2 - [2(x+5)]^2$

$= [3(2x-3) - 2(x+5)][3(2x-3) + 2(x+5)]$

$= (6x - 9 - 2x - 10)(6x - 9 + 2x + 10)$

$= (4x - 19)(8x + 1)$

ចំពោះ $x = 1$ , $A = (4 - 19)(8 + 1) = (-15)(9) = -135$ ។

***ប្រតិបត្តិ :*** ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា

$A = x^2(x-1) + 4x(x-1) + 4x - 4$

$B = (3x-6)(4x^2-1) - (2x-4)(4x^2+4x+1)$ ។

## 2.3. វិធីគុណខ្វែង




ដាក់កន្សោម $A = x^2 + 5x + 6$

ជាផលគុណនៃកត្តា

តាមរូប : តួ $x^2$ បំបែកទៅជា $x \cdot x$

តួ $6$ បំបែកទៅជា $3 \cdot 2$

ប្រើតារាងគុណខ្វែងដើម្បី $\begin{matrix} x & 3 \\ x & 2 \end{matrix}$

ផ្ទៀងផ្ទាត់តួកណ្ដាល $5x$ $\quad 2x + 3x = 5x$

ដូចនេះ $A = (x+3)(x+2)$ ។

***លំហាត់គំរូទី 1 :*** ចូរដាក់កន្សោម $A = 2x^2 - 11x + 12$ ជាផលគុណនៃកត្តា ។

***ចម្លើយ :*** ផ្ទៀងផ្ទាត់តួកណ្ដាលដោយតារាងគុណខ្វែង តួកណ្ដាលស្មើ $-11x$

| | | | |
|---|---|---|---|
| $2x \quad 3$ | $2x \quad 4$ | $2x \quad -4$ | $2x \quad -3$ |
| $x \quad 4$ | $x \quad 3$ | $x \quad -3$ | $x \quad -4$ |
| $8x + 3x = 11x$ | $6x + 4x = 10x$ | $-6x - 4x = -10x$ | $-8x - 3x = -11x$ |

ដូចនេះ $A = (2x-3)(x-4)$ ។

***សំគាល់ :*** 12 អាចបំបែក $12 = 2 \times 6$ ឬ $12 = 1 \times 12$ ។

***លំហាត់គំរូទី 2 :*** ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា

$A = x^2 + 5x - 6$ ។

***ចម្លើយ :*** ផ្ទៀងផ្ទាត់តួកណ្ដាលដោយតារាងគុណខ្វែង

| | | | | | | | |
|---|---|---|---|---|---|---|---|
| $x$ | $-3$ | $x$ | $3$ | $x$ | $-6$ | $x$ | $6$ |
| $x$ | $2$ | $x$ | $-2$ | $x$ | $1$ | $x$ | $-1$ |
| $2x-3x=-x$ | | $-2x+3x=x$ | | $x-6x=-5x$ | | $-x+6x=5x$ | |

ដូចនេះ $A=(x+6)(x-1)$ ។

***ប្រតិបត្តិ :*** ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា

$x^2-4x-5$ , $x^2+2x-15$ , $x^2-11x+30$

$x^2-2x-8$ , $x^2+5x-14$ , $2x^2+5x+3$ ។

## 2.4. វិធីបំពេញនិងបន្ថយតួ

រកតួទី 3 នៃ $x^2+6x+\square$ ដើម្បីបំពេញឱ្យវាទៅជាការេនៃទ្វេធា

$a=x$ , $2ab=6x$ , $b=\dfrac{6x}{2a}=\dfrac{6x}{2x}=3$ ហើយ $b^2=9$

ដូចនេះ តួទី 3 ដែលត្រូវបំពេញស្មើនឹង 9

ខាងក្រោមនេះជាវិធីដាក់កន្សោមជាផលគុណនៃកត្តាដោយបំពេញនិងបន្ថយតួ ។

***ឧទាហរណ៍ :*** $A=x^2-2x-8$ ដោយតួបំពេញនៃ $x^2-2x$ គឺ 1

ហេតុនេះគេត្រូវបំពេញ 1 និងបន្ថយ 1 វិញ

$$A=\underbrace{x^2-2x+1}-1-8$$

$$=(x^2-2x+1)-9$$

$$=(x-1)^2-9$$

$$=(x-1-3)(x-1+3)$$

$$=(x-4)(x+2)$$ ។

***លំហាត់គំរូទី 1 :*** ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា

$$A=x^2+3x-4$$ ។

***ចម្លើយ :*** រកតួបំពេញ $a=x$ , $2ab=3x$ , $b=\dfrac{3x}{2x}=\dfrac{3}{2}$ , $b^2=\dfrac{9}{4}$

$$A=x^2+3x+\frac{9}{4}-\frac{9}{4}-4$$

$$=\left(x^2+3x+\frac{9}{4}\right)-\frac{25}{4}=\left(x+\frac{3}{2}\right)^2-\frac{25}{4}$$

$$=\left(x+\frac{3}{2}-\frac{5}{2}\right)\left(x+\frac{3}{2}+\frac{5}{2}\right)$$

$$=(x-1)(x+4)$$ ។

*សំគាល់ :* គេអាចប្រើវិធីគុណខ្វែង ដើម្បីដាក់កន្សោម $A$ ជាផលគុណនៃកត្តា ។

*ប្រតិបត្តិ :* ចូរដាក់កន្សោមជាផលគុណនៃកត្តា $x^2+6x-7$ , $x^2-5x+6$ ។

# 3. ប្រមាណវិធីលើកន្សោមសនិទាន

## 3.1. វិធីបូក ដក

*ឧទាហរណ៍ :* គណនាកន្សោមសនិទាន $A = \dfrac{1}{(x+1)^2}+\dfrac{1}{x^2-1}$

$$A = \frac{1}{(x+1)^2}+\frac{1}{x^2-1} = \frac{1}{(x+1)^2}+\frac{1}{(x-1)(x+1)}$$

$$= \frac{x-1}{(x+1)^2(x-1)}+\frac{x+1}{(x+1)^2(x-1)}$$ យក $(x+1)^2(x-1)$ ជាភាគបែងរួម

$$= \frac{x-1+x+1}{(x+1)^2(x-1)} = \frac{2x}{(x+1)^2(x-1)}$$ ។

*ជាទូទៅ :* ដើម្បីបូកឬដកកន្សោមសនិទាន

- ដាក់ភាគយកនិងភាគបែងនៃប្រភាគជាផលគុណនៃកត្តា
- សម្រួលប្រភាគនីមួយៗបើអាច
- តម្រូវភាគបែងរួម
- បូកឬដកភាគយកដោយរក្សាទុកភាគបែងរួម
- សម្រួលលទ្ធផលបើអាច ។ (ដោយឱ្យកត្តាសម្រួលខុសពីសូន្យ)

*សំគាល់ :* យើងចាត់ទុកកត្តាដែលត្រូវសម្រួលជាកត្តាមិនសូន្យ ហេតុនេះយើងមិនតម្រូវឱ្យមានការបញ្ជាក់តម្លៃអថេរដែលនាំឱ្យកត្តានោះស្មើនឹងសូន្យឡើយ ។

*លំហាត់គំរូទី 1 :* ចូរគណនា $A = \dfrac{x^2+7x}{x^2-49}-\dfrac{10}{2x+4}$ ។

*ចម្លើយ :* $A = \dfrac{x^2+7x}{x^2-49}-\dfrac{10}{2x+4}$

$$= \frac{x(x+7)}{(x-7)(x+7)}-\frac{10}{2(x+2)}$$ សម្រួលនឹង $x+7$ (ដោយ $x+7\neq 0$ ឬ $x\neq -7$ )

$$= \frac{x}{x-7}-\frac{5}{x+2}$$ ភាគបែងរួម $(x-7)(x+2)$

$$= \frac{x(x+2)}{(x-7)(x+2)}-\frac{5(x-7)}{(x-7)(x+2)}$$

$$= \frac{x(x+2)-5(x-7)}{(x-7)(x+2)}$$

$$= \frac{x^2+2x-5x+35}{(x-7)(x+2)} = \frac{x^2-3x+35}{(x-7)(x+2)}$$ ។

*លំហាត់គំរូទី 2 :* ចូរផ្ទៀងផ្ទាត់ថា $\frac{1}{n(n+1)(n+2)} = \frac{1}{2n(n+1)} - \frac{1}{2(n+1)(n+2)}$

ដោយឱ្យ $n = 1$ , $n = 2$ , $n = 3$ , .........

ដើម្បីគណនា $\frac{1}{1\cdot2\cdot3} + \frac{1}{2\cdot3\cdot4} + \ldots\ldots \frac{1}{n(n+1)(n+2)}$ ។

*ចម្លើយ :*

$$\frac{1}{2n(n+1)} - \frac{1}{2(n+1)(n+2)} = \frac{n+2}{2n(n+1)(n+2)} - \frac{n}{2n(n+1)(n+2)}$$

$$= \frac{n+2-n}{2n(n+1)(n+2)} = \frac{1}{n(n+1)(n+2)}$$

ឱ្យ $n = 1$ : $\frac{1}{1\cdot2\cdot3} = \frac{1}{4} - \frac{1}{12}$

ឱ្យ $n = 2$ : $\frac{1}{2\cdot3\cdot4} = \frac{1}{12} - \frac{1}{24}$ បូកអង្គនឹងអង្គ

ឱ្យ $n = 3$ : $\frac{1}{3\cdot4\cdot5} = \frac{1}{24} - \frac{1}{40}$

...........................

...........................

$$\frac{1}{n(n+1)(n+2)} = \frac{1}{2n(n+1)} - \frac{1}{2(n+1)(n+2)}$$

ដូចនេះ $\frac{1}{1\cdot2\cdot3} + \frac{1}{2\cdot3\cdot4} + \ldots\ldots \frac{1}{n(n+1)(n+2)} = \frac{1}{4} - \frac{1}{2(n+1)(n+2)}$ ។

*ប្រតិបត្តិ :* ចូរគណនា

$$1 - \frac{1}{x} + \frac{2}{x-1} \quad , \quad \frac{x^2-x}{x^2+x} + \frac{3x+2}{x+1} - \frac{2x^2-x}{x(x+1)}$$ ។

## 3.2. វិធីគុណនិងវិធីចែក

*ឧទាហរណ៍ទី 1 :* គណនា $\frac{a}{a+2} \times \frac{3a+6}{a^2-4a}$

$$\frac{a}{a+2} \times \frac{3a+6}{a^2-4a} = \frac{a}{a+2} \times \frac{3(a+2)}{a(a-4)}$$

$$= \frac{3a(a+2)}{a(a+2)(a-4)}$$ សម្រួលនឹង $a(a+2)$

$$= \frac{3}{a-4}$$ ។

*ឧទាហរណ៍ទី 2 :* គណនា $\frac{4t+6}{t} \div \frac{4t^2-9}{t^2}$

$$\frac{4t+6}{t} \div \frac{4t^2-9}{t^2} = \frac{2(2t+3)}{t} \div \frac{(2t-3)(2t+3)}{t^2}$$

$$= \frac{2(2t+3)}{t} \times \frac{t^2}{(2t-3)(2t+3)} = \frac{2t^2(2t+3)}{t(2t-3)(2t+3)} = \frac{2t}{2t-3}$$ ។

***ជាទូទៅ :*** ដើម្បីគុណឬចែកកន្សោមសនិទាន

- ដាក់ភាគយកនិងភាគបែងនៃប្រភាគជាផលគុណនៃកត្តា
- ចំពោះវិធីគុណគេគុណភាគយកនិងភាគយក ភាគបែងនិងភាគបែង
- ចំពោះវិធីចែកគេគុណប្រភាគតំណាងចែកនឹងចម្រាសនៃប្រភាគតួចែក ហើយ សម្រួលលទ្ធផលបើអាច ។

***លំហាត់គំរូ :*** ចូរគណនា

$$A = \frac{x^2-4}{2x^2-4x} \times \frac{x^2-9}{x^2+6x+9} \qquad B = \frac{ab-b^2}{a(a+b)^2} \div \frac{b^2}{a(a^2-b^2)} \text{ ។}$$

***ចម្លើយ :***

$$A = \frac{x^2-4}{2x^2-4x} \times \frac{x^2-9}{x^2+6x+9}$$

$$= \frac{(x-2)(x+2)}{2x(x-2)} \times \frac{(x-3)(x+3)}{(x+3)^2}$$

$$= \frac{x+2}{2x} \times \frac{x-3}{(x+3)}$$

$$= \frac{(x+2)(x-3)}{2x(x+3)} \text{ ។}$$

$$B = \frac{ab-b^2}{a(a+b)^2} \div \frac{b^2}{a(a^2-b^2)}$$

$$= \frac{b(a-b)}{a(a+b)^2} \div \frac{b^2}{a(a-b)(a+b)}$$

$$= \frac{b(a-b)}{a(a+b)^2} \times \frac{a(a-b)(a+b)}{b^2}$$

$$= \frac{ab(a-b)(a-b)(a+b)}{ab^2(a+b)^2}$$

$$= \frac{(a-b)^2}{b(a+b)} \text{ ។}$$

***ប្រតិបត្តិ :*** ចូរគណនា

$$A = \frac{x^2}{x^2-25} \div \frac{x^2+b}{x^2-20x+25} \quad , \quad B = \frac{a-2}{a^2b} \times \frac{a^3-a^2}{a(a-2)-(a-2)} \text{ ។}$$

## ? លំហាត់

1. ចូរពន្លាតកន្សោមខាងក្រោម ។

$A = (x+4)(x^2-4x+1)$ , $B = (x+3)(x^2+4x-3)$

$C = (a-b)(a^2-2ab-3b^2)$ , $D = (x+2)(x^2-5x-1)$

$E = (y+5)(y^2-3y-8)$ , $F = (3n+4)(n+5)$

$G = (x+3)(x-1)^2$ , $H = (y-1)(y+2)^2$ ។

2. ចូររក $a$ ដើម្បីឱ្យ

ក. $(x+a)(x-8) = x^2-12x+32$

ខ. $(2y-6)(y+a) = 2y^2+8y-42$ ។

3. ចូរដាក់កន្សោមជាផលគុណនៃកត្តា

$2x^4+8x$ , $7b^3+21b$ , $8ax^2-12a^2x^3$

$10x^3y^2-15xy^3$ , $6x^2-9y^2$ , $15x-20y^2$

$4x^3-2x^2+14x$ , $3a^4+9a^2-15$ , $2x^3+3x^2+4x$

$9xy-3x^2+4xy^2$ , $8abc^2-4b^2c+12a^2bc$

$6x^2yz+2xy^2z-4xyz$ , $12x^4y^3t^2-4x^3yt^2+8x^2t-16xy$ ។

4. ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា

$a(x+1)+b(x+1)$ , $z(y-3)+2(y-3)$ , $ab-3a+9b-27$

$ab+7a+4b+28$ , $xy+2x-7y-14$ , $ap-2pk+ya-2yk$

$am-mb-an+nb$ , $12xy+15x+4y+5$ , $2ab-8a+3b-12$

$3ab+12a-b-4$ , $xy-8x-3y+24$ ។

5. ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា

$A = at+bt+ct+2a+2b+2c$

$B = ax+2ay+3az-4x-8y-12z$

$C = ax+ay-az-bx-by+bz$

$D = y^2-cy-ay+ac-by+bc$ ។

6. ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា

$A = (x+y)^2 - z^2$ , $B = (x+y)^2 - (z+t)^2$

$C = (x^2 - 2xy + y^2) - t^2$ , $D = (a+b)^2 - (a-b)^2$ ។

7. ចូររកតម្លៃនៃ $a$ ដើម្បីផ្ទៀងផ្ទាត់សមភាពខាងក្រោម ។

ក. $4x^2 - 3ay^4 = (2x+9y^2)(2x-9y^2)$

ខ. $16x^2 + 5ay^4 = (4x+5y^2)(4x-5y^2)$ ។

8. ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា

$x^2 - 16$ , $y^2 - 121$ , $y^2 - 1$ , $4z^2 - 49$

$3a^2 - 12$ , $25b^2 - 64$ , $36x^4 - y^2$ , $84x^2 - 21$

$3x^2 - 75$ , $4m^2 - 144$ , $8x^2 - 160x + 800$ , $5x^2y^2 - 500$

$3t^2z^4 - 147$ , $2xy^2 - 32x$ , $3a^2b^4 - 192a^3$

$5ab^2 - 20a + 30b^2 - 120$ , $4cx^2 - 4c - 12x^2 + 12$ , $2xy^2 - 2x + 4y^2 - 4$ ។

9. ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា

$9(x-1)^2 - 4(2x+3)^2$ , $4(y+2)^2 - y^2$

$3(x+1) - x^2 - 2x - 1$ , $(2x-5)^2 - 4x^2 + 25$

$16(x+3)^2 - (x-1)^2$ , $x^3 - x$ , $t^4 - 1$ , $4x^2 - 16x$

$(x+1)^2 - (x^2-1) + 2x + 2$ , $x^5 - x$ , $x(y-1)^2 - 4x$ ។

10. ចូរកំណត់តម្លៃនៃ $a$ ដើម្បីឱ្យ $P = 2x^3 + 3x^2 - 8x + 3$ ស្មើនឹង $(x-1)(2x^2 + ax - 3)$ រួចដាក់ $P$ ជាផលគុណនៃកត្តាដឺក្រេទី 1 ។

11. ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា តាមវិធីបំពេញនិងបន្ថយតួ ឬតាមវិធីគុណខ្វែង ។

$x^2 + 5x + 4$ , $x^2 + 5x + 6$ , $t^2 + 8t + 15$

$x^2 - 10x + 9$ , $t^2 - 11t + 28$ , $x^2 + 7x - 8$

$x^2 + x - 6$ , $x^2 + 11x - 12$ , $b^2 + 6b - 7$

$x^2 + 3x - 4$ , $y^2 - y - 12$ , $y^2 - 2y - 35$

$n^2 - 4n - 12$ , $a^2 - 3a - 18$ , $x^2 - 6x - 7$

$5t^2 + 12t + 7$ , $2x^2 + 13x - 7$ , $2x^2 + 5x - 3$ ។

12. ចូរដាក់កន្សោមខាងក្រោមជាផលគុណនៃកត្តា

$2a^2+24a+70$ , $3x^2+21x+36$ , $5a^2-15a-90$

$2x^2-4x-160$ , $4bc^2+12bc-40b$ , $6xy^4+18xy^2-168x$ ។

13. ចូរគណនាកន្សោមសនិទានខាងក្រោម ។

$3x-\dfrac{x+2}{x}$ , $\dfrac{2x-5}{3x}+3x-1$ , $y+\dfrac{y-4}{3y+4}$

$a-3-\dfrac{5}{a+1}$ , $b+5+\dfrac{5}{b-5}$ , $3n+\dfrac{2n+3}{4n+5}$ ។

14. ចូរកំណត់ $a$ , $b$ , $c$ ដែល

$$\frac{2x^2-x+3}{x-1}=ax+b+\frac{c}{x-1}$$

15. ចូរគណនាកន្សោមសនិទានខាងក្រោម ។

$\dfrac{6x-1}{81-x^2}-\dfrac{2x}{x+9}$ , $\dfrac{10y-1}{100-y^2}-\dfrac{5y}{y+10}$ , $\dfrac{11}{121-x^2}-\dfrac{x^2}{x+11}$

$\dfrac{t}{2(t+3)}-\dfrac{2}{3(t+3)}$ , $\dfrac{4x+16}{(x+4)(x-4)}+\dfrac{-4}{x+4}$ , $\dfrac{4z+2}{16-z^2}+\dfrac{4}{z-4}$ ។

16. ចូរសម្រួលកន្សោមសនិទានខាងក្រោម ។

$\dfrac{\frac{1}{x}-\frac{3}{y}}{\frac{4}{y}}$ , $\dfrac{\frac{2}{x}+\frac{3}{y}}{-\frac{5}{x}}$ , $\dfrac{\frac{1}{x}-\frac{1}{y}}{-\frac{6}{5y}}$ , $\dfrac{\frac{4}{x}+5}{\frac{5}{y}}$

$\dfrac{\frac{8}{x}-9}{\frac{6}{y}}$ , $\dfrac{\frac{4}{a^2}+\frac{b}{a}}{\frac{2}{a}-12}$ , $\dfrac{\frac{3x}{x^2-49}+\frac{7}{x+7}}{\frac{1}{x-7}-\frac{7}{2x+14}}$

$\dfrac{\frac{2b}{b-4}-\frac{3}{b^2}}{\frac{5}{5b-20}+\frac{3}{4b^2-16b}}$ , $\dfrac{\frac{1}{a+1}}{a-\frac{1}{a+\frac{1}{a}}}$ , $\dfrac{2}{c+\frac{1}{1+\frac{c+1}{5-c}}}$ ។

17. គេឱ្យកន្សោមសនិទាន $A=\dfrac{2x^3-8x}{2x^3-8x^2+8x}$

ចូរគណនាតម្លៃនៃ $A$ ចំពោះ $x=2\ 011$ ។

មេរៀនទី

# 4 សមីការដឺក្រេទី១មានមួយអញ្ញាត

**វត្ថុបំណង**

- ដោះស្រាយសមីការដឺក្រេទី 1 ។
- ដោះស្រាយសមីការដែលមានភាគបែងជាលេខ ។
- ដោះស្រាយសមីការដែលអង្គទី 1 ជាផលគុណនៃកត្តា ។
- ដោះស្រាយចំណោទនៃសមីការដឺក្រេទី 1 ។

## 1. សមីការដឺក្រេទី 1 មានមួយអញ្ញាត

- ប្រើលក្ខណៈសមភាព បើ $a = b$ នោះ $a+c = b+c$

*ឧទាហរណ៍ទី 1:* កាលពី 6 ឆ្នាំមុនខ្ញុំមានអាយុ 40 ឆ្នាំ ។ តើឆ្នាំនេះខ្ញុំមានអាយុប៉ុន្មាន ?

តាង $x$ ជាអាយុខ្ញុំនៅបច្ចុប្បន្នកាលនេះ

$x-6 = 40$

$x-6+6 = 40+6$ បូកអង្គទាំងពីរនឹង 6

$x = 46$ ជាចម្លើយនៃសមីការ ។

- ប្រើលក្ខណៈសមភាព បើ $a = b$ នោះ $a-c = b-c$

*ឧទាហរណ៍ទី 2:* នៅ 4 ឆ្នាំទៀតខ្ញុំនឹងមានអាយុ 32 ឆ្នាំ ។ តើឆ្នាំនេះខ្ញុំមានអាយុប៉ុន្មាន ?

តាង $x$ ជាអាយុខ្ញុំនៅបច្ចុប្បន្នកាលនេះ

$x+4 = 32$

$x+4-4 = 32-4$ ដកអង្គទាំងពីរនឹង 4

$x = 28$ ជាចម្លើយនៃសមីការ ។

- ប្រើលក្ខណៈសមភាព បើ $a = b$ នោះ $ac = bc$

*ឧទាហរណ៍ទី 3:* ពាក់កណ្ដាលនៃអាយុខ្ញុំ ទើបស្មើនឹង 27 ឆ្នាំ ។ រកអាយុខ្ញុំ ។

តាង $x$ ជាអាយុខ្ញុំ

$\frac{x}{2} = 27$

$2\times\frac{x}{2} = 2\times 27$ គុណអង្គទាំងពីរនឹង 2

$x = 54$ ជាចម្លើយនៃសមីការ ។

- ប្រើលក្ខណៈសមភាព បើ $a = b$ នោះ $\frac{a}{c} = \frac{b}{c}$ $c\neq 0$

***ឧទាហរណ៍ទី 4:*** ពីរដងនៃអាយុខ្ញុំស្មើនឹង 50ឆ្នាំ ។ រកអាយុខ្ញុំ ។

តាង $x$ ជាអាយុខ្ញុំ

$2x = 50$

$\frac{2x}{2} = \frac{50}{2}$ ចែកអង្គទាំងពីរនឹង 2

$x = 25$ ជាចម្លើយនៃសមីការ ។

ក្នុងប្រតិបត្តិ គេអាចលើកតួមានអញ្ញាតទៅអង្គម្ខាងនិងតួគ្មានអញ្ញាតទៅអង្គម្ខាងទៀត ។ តួណាប្តូរអង្គត្រូវប្តូរសញ្ញារួចធ្វើប្រមាណវិធី ។

***លំហាត់គំរូទី 1 :*** ចូរដោះស្រាយសមីការ $7x+3 = 5x+13$ ។

***ចម្លើយ :***

$7x+3 = 5x+13$

$7x-5x = 13-3$

$2x = 10$

$x = \frac{10}{2} = 5$ ជាចម្លើយនៃសមីការ ។

***លំហាត់គំរូទី 2 :*** ចូរដោះស្រាយសមីការ $3-3x+5x = 2x+2$ ។

***ចម្លើយ :***

$3-3x+5x = 2x+2$

$3+2x = 2x+2$

$2x-2x = 2-3$

$0x = -1$ គ្មានតម្លៃ $x$ ដែលគុណនឹង 0 ស្មើនឹង $-1$ ទេ ហេតុនេះសមីការគ្មានចម្លើយ ។

***លំហាត់គំរូទី 3 :*** ចូរដោះស្រាយសមីការ $2x-4x+20 = 20-2x$ ។

***ចម្លើយ :***

$2x-4x+20 = 20-2x$

$-2x+20 = 20-2x$

$-2x+2x = 20-20$

$0x = 0$ ចំពោះគ្រប់តម្លៃនៃ $x$ អង្គទីមួយស្មើនឹង 0 ជានិច្ច

ហេតុនេះសមីការមានចម្លើយច្រើនអនេក ។

***ប្រតិបត្តិ :*** ចូរដោះស្រាយសមីការ

ក. $6(x-2) = 3(x-8)$ ខ. $3x+5 = 3(x+2)$ គ. $6x-4 = 2+6(x-1)$ ។

## 2. សមីការដែលមានភាគបែងជាលេខ

***ឧទាហរណ៍ទី 1 :*** ដោះស្រាយសមីការ $\frac{8x}{5}+3 = x$

- តម្រូវភាគបែងរួមនៃអង្គទាំងពីររបស់សមីការ
$\frac{8x}{5}+\frac{15}{5} = \frac{5x}{5}$
- លុបភាគបែងចោលគេបាន

$8x+15 = 5x$

$8x-5x = -15$

$3x = -15$ , $x = -5$ ជាចម្លើយនៃសមីការ ។

***វិធាន :*** ដើម្បីដោះស្រាយសមីការដឺក្រេទី 1 មានមួយអញ្ញាតដែលមានភាគបែងជាលេខ គេត្រូវ

- តម្រូវភាគបែងរួមនៃអង្គទាំងពីររបស់សមីការរួចលុបភាគបែងចោល ។
- លើកតួមានអញ្ញាតទៅអង្គម្ខាងនិងតួគ្មានអញ្ញាតទៅអង្គម្ខាងទៀត ។ តួណាប្តូរអង្គត្រូវប្តូរសញ្ញារួចធ្វើប្រមាណវិធី ។

***លំហាត់គំរូ :*** ចូរដោះស្រាយសមីការ $\frac{3x-1}{6}-\frac{x+1}{12} = \frac{x-5}{4}+\frac{x}{6}$ ។

***ចម្លើយ :***

ភាគបែងរួមស្មើនឹង 12

$\frac{3x-1}{6}-\frac{x+1}{12} = \frac{x-5}{4}+\frac{x}{6}$

$\frac{2(3x-1)}{12}-\frac{x+1}{12} = \frac{3(x-5)}{12}+\frac{2x}{12}$

$\frac{2(3x-1)-(x+1)}{12} = \frac{3(x-5)+2x}{12}$

$2(3x-1)-(x+1) = 3(x-5)+2x$

$6x-2-x-1 = 3x-15+2x$

$5x-3 = 5x-15$

$5x - 5x = -15 + 3$

$0x = -12$ ចំពោះគ្រប់តម្លៃនៃ $x$ អង្គទីមួយស្មើនឹង 0 ជានិច្ច

ដូចនេះសមីការគ្មានចម្លើយ ។

***ប្រតិបត្តិ :*** ចូរដោះស្រាយសមីការ $\frac{3x}{4} + 9 = \frac{x}{2} + 15$ , $\frac{x+7}{6} + \frac{2x-8}{2} = -4$ ។

## 3. សមីការដែលអង្គទី1ជាផលគុណនៃកត្តា

ពិនិត្យតារាងខាងក្រោម

| $A$ | $B$ | $A \times B$ |
|---|---|---|
| 3 | 0 | 0 |
| 0 | 3 | 0 |
| 0 | 0 | 0 |

ដើម្បីឱ្យផលគុណនៃកត្តា $A \times B$ ស្មើនឹង 0 លុះត្រាតែកត្តា $A = 0$ ឬ $B = 0$ គេអាចអនុវត្តលក្ខណៈនេះដើម្បីដោះស្រាយសមីការ ដែលអង្គទី 1 ជាផលគុណនៃកត្តា ។

***ឧទាហរណ៍ទី 1:*** ដោះស្រាយសមីការ $(x-1)(x-2) = 0$

ក្នុងករណីនេះគេឱ្យកត្តានីមួយៗស្មើនឹងសូន្យ

$x - 1 = 0$ , $x = 1$ ជាចម្លើយនៃសមីការ

$x - 2 = 0$ , $x = 2$ ជាចម្លើយនៃសមីការ

ដូចនេះសមីការមានចម្លើយពីរគឺ $x = 1$ និង $x = 2$

ព្រោះតម្លៃទាំងពីរបានផ្ទៀងផ្ទាត់សមីការ ។

***ឧទាហរណ៍ទី 2:*** ដោះស្រាយសមីការ $x^2 - 9 = 0$

សរសេរអង្គទី 1 ជាផលគុណនៃកត្តា

$x^2 - 9 = 0$ , $(x-3)(x+3) = 0$

$x - 3 = 0$ , $x = 3$

$x + 3 = 0$ , $x = -3$

$x = 3$ , $x = -3$ ជាចម្លើយនៃសមីការ ។

វិធាន ៖ ដើម្បីដោះស្រាយសមីការមានមួយអញ្ញាតដែលអង្គទី 1 មានអញ្ញាតជាដឺក្រេទី 2 គេត្រូវសរសេរអង្គទី 1 ជាផលគុណកត្តានៃដឺក្រេទី 1 ។

*លំហាត់គំរូ ៖* ចូរដោះស្រាយសមីការ $x^2-6x-7=0$ ។

*ចម្លើយ ៖*

$x^2-6x-7=0$

$x^2-6x+9-9-7=0$

$(x-3)^2-16=0$

$(x-3-4)(x-3+4)=0$

$(x-7)(x+1)=0$

$x-7=0\ ,\ x=7$

$x+1=0\ ,\ x=-1$

ហេតុនេះ $x=7$ និង $x=-1$ ជាចម្លើយនៃសមីការ ។

*ប្រតិបត្តិ ៖* ចូរដោះស្រាយសមីការខាងក្រោម ។

$x^2+2x-4x-8=0$ , $(2x-1)^2-(x+3)^2=0$ , $3x^2+9x=0$ , $2x^2+3x-5=0$ ។

## 4. ចំណោទសមីការដឺក្រេទី 1 មានមួយអញ្ញាត

*លំហាត់គំរូទី 1 ៖* បច្ចុប្បន្នកាលនេះឪពុកមានអាយុ 42 ឆ្នាំ ហើយកូនមានអាយុ 15 ឆ្នាំ តើនៅប៉ុន្មានឆ្នាំទៀតទើបអាយុឪពុកស្មើនឹងពីរដងនៃអាយុកូន ?

*ចម្លើយ ៖*

សម្មតិកម្ម ៖ បច្ចុប្បន្នកាលនេះអាយុឪពុកស្មើ 42 ហើយអាយុកូនស្មើ 15 ឆ្នាំ ។

សំណួរ ៖ រកចំនួនឆ្នាំទៅមុខទៀតដើម្បីឱ្យអាយុឪពុកស្មើនឹងពីរដងនៃអាយុកូន ។

ការតាងអញ្ញាត ៖ តាង $t$ ជាចំនួនឆ្នាំទៅមុខទៀត ។

គំនិតបន្ថែម ៖ ពីរឆ្នាំទៀតអាយុឪពុកត្រូវជា $42+2=44$ អាយុកូន $15+2=17$ ។

សមីការ ៖ $t$ ឆ្នាំទៀត

អាយុឪពុកស្មើ $42+t$ និងអាយុកូន $15+t$ ហើយពីរដងនៃអាយុកូនស្មើ $2(15+t)$

យើងបានសមីការ $42+t=2(15+t)$ ។

✍ *ដំណោះស្រាយ :*

$42+t = 2(15+t)$

$42+t = 30+2t$

$42-30 = 2t-t$

$t = 12$ ។

*ការផ្ទៀងផ្ទាត់ :*

នៅ $t = 12$ ឆ្នាំទៅមុខទៀត អាយុឪពុក $42+12 = 54$ អាយុកូន $15+12 = 27$ ហើយ $2\times 27 = 54$ ។

***លំហាត់គំរូទី 2 :*** ពីមុននំប៉័ងមួយលក់ថ្លៃ 500 រៀល បើគេចង់បង្កើនថ្លៃលក់ 18% តើគេត្រូវលក់ថ្លៃប៉ុន្មាន ?

***ចម្លើយ :***

សម្មតិកម្ម : តម្លៃដើមគ្រា 500 រៀល ភាគរយនៃកំណើនស្មើនឹង 18% ។

សំណួរ : រកតម្លៃលក់ថ្មី ។

ការតាងអញ្ញាត : តាង $x$ ជាតម្លៃលក់ថ្មី ។

សមីការ : $x-500$ ជាកំណើនថ្លៃលក់ ។

កំណើនថ្លៃលក់ធៀបនឹងតម្លៃដើមគ្រាតាងដោយប្រភាគ $\frac{x-500}{500}$ ហើយភាគរយនៃកំណើនតាងដោយប្រភាគ $\frac{18}{100}$ ។

ដូចនេះ $\frac{x-500}{500} = \frac{18}{100}$ ។

✍ *ដំណោះស្រាយ :*

$\frac{x-500}{500} = \frac{18}{100}$

$\frac{x-500}{500} = \frac{18\times 5}{500}$

$x-500 = 18\times 5$

$x = 90+500 = 590$ ៛ ។

*ការផ្ទៀងផ្ទាត់ :*

ថ្លៃលក់ដើមគ្រា 500 រៀល ហើយថ្លៃលក់ថ្មី 590 រៀល កំណើន $590-500 = 90$

$\frac{90}{500}\times 100\% = 18\%$ ជាភាគរយនៃកំណើនថ្លៃលក់ថ្មី ។

*លំហាត់គំរូទី 3 :* ចតុកោណកែងមួយដែលមានវិមាត្រ $x$ និង 2 (គិតជា $m$ ) ។ គេបង្កើនវិមាត្រទាំងពីររៀងគ្នា 2 និង 3 បន្ថែមទៀត ។ រកតម្លៃ $x$ ដើម្បីឱ្យផ្ទៃក្រឡានៃផ្នែកឆូតស្មើនឹងពីរដងនៃចតុកោណកែងដើម ។

***ចម្លើយ :***




សម្មតិកម្ម : 2 និង $x$ ជាវិមាត្រនៃចតុកោណកែងដើម $2+3$ និង $x+2$ ជាវិមាត្រនៃចតុកោណកែងចុងក្រោយ ។

សំណួរ : រកតម្លៃ $x$ ដើម្បីឱ្យ ផ្ទៃក្រឡានៃផ្នែកឆូតស្មើនឹងពីរដងនៃចតុកោណកែងដើម ។

ការតាងអញ្ញាត : មានស្រាប់គឺ $x$

គំនិតបន្ថែម : ផ្ទៃក្រឡាផ្នែកឆូត = ផ្ទៃក្រឡានៃចតុកោណធំ – ផ្ទៃក្រឡានៃចតុកោណតូច ។

សមីការ : ពីរដងនៃផ្ទៃក្រឡាចតុកោណកែងដើម $2\times 2x = 4x$

ផ្ទៃក្រឡាផ្នែកឆូត = ផ្ទៃក្រឡានៃចតុកោណធំ – ផ្ទៃក្រឡានៃចតុកោណតូច

$4x = 5(x+2)-2x$ ។

✍ ***ដំណោះស្រាយ :***

$4x = 5(x+2)-2x$

$4x = 5x+10-2x$

$4x = 3x+10$

$x = 10$ ដូចនេះ $x = 10m$ ។

***ការផ្ទៀងផ្ទាត់ :***

$x = 10$ , ផ្ទៃក្រឡានៃចតុកោណដើម $2\times 10 = 20m^2$

ផ្ទៃក្រឡានៃចតុកោណធំ $5\times 12 = 60m^2$

ផ្ទៃក្រឡានៃផ្នែកឆូត $60-20 = 40m^2$

$40m^2 = 2\times 20m^2$ ។

***ប្រតិបត្តិ :***

ក. ម៉ារីមានអាយុ 8 ឆ្នាំ ច្រើនជាងអាយុបូណា ។ ផលបូកអាយុរបស់ម៉ារីនិងបូណាស្មើនឹង 38 ឆ្នាំ ។ ចូររកអាយុរបស់បូណា ។

ខ. ថែម 7 លើពីរដងនៃមួយចំនួនស្មើរនឹងបន្ថយ 27 ពីបីដងនៃចំនួននោះ ។ ចូររកចំនួននោះ ។

## ? លំហាត់

1. ចូរដោះស្រាយសមីការ

ក. $4(x-5) = 2x-14$

ខ. $x+7 = -2(x+8)$

គ. $3(2y-1) = -8(6+y)$

ឃ. $-(z+12) = 5(2z-1)$

ង. $n-(8+4n) = 2(3n-4)$

ច. $(2m+3)^2-(2m+5) = 4m(m+4)+4$

ឆ. $5p-(8-p) = 2[-4-(3+5p)-13]$

ជ. $-[k-(4k+2)] = 2+(2k+7)$

ឈ. $2-4\{-2x+3[-1+5(1-x)]-1\} = 0$

ញ. $\sqrt{3}(x-2)-2x\sqrt{2} = 2(x\sqrt{3}-3-x\sqrt{2})$

ដ. $6(7x+8)-7(6x+4) = 5(6+7x)-35(x-1)$

ឋ. $8(3-2p)-16(1-p)-3(p-4) = 20-3p$ ។

2. ចូរដោះស្រាយសមីការ

ក. $\frac{5x}{3}+\frac{9}{8} = \frac{7x}{6}+\frac{3}{16}$

ខ. $\frac{2y+1}{3}+\frac{5-y}{4} = 1-\frac{3y+2}{6}$

គ. $\frac{2(3z-8)}{9}-\frac{5(z-3)}{3} = \frac{3(z-8)}{4}+\frac{17}{36}$

ឃ. $\frac{3t-5}{8}+\frac{t+12}{12} = 1$

ង. $\frac{x+4}{3}-\frac{x-4}{5} = 2+\frac{3x-1}{15}$

ច. $1+\frac{2n}{3}-\frac{1}{2}-n = \frac{1-n}{3}$

ឆ. $3k+\frac{5k-3}{2} = 37$

ជ. $2.4x+\frac{3(x-1.6)}{5} = \frac{8.4x-4.9}{2}$

ឈ. $\left(\frac{3}{4}x-\frac{2}{5}\right)+\left(\frac{2}{3}x+0.6\right)-\left(\frac{7}{12}x-0.3\right) = 5.8$

ញ. $x+\frac{3}{2}-\frac{4x-3}{4} = 1-\frac{5x-12}{6}$

ដ. $8(x-2)+3 = 7x+\frac{2x-1}{2}-3$

ឋ. $\frac{(2y+1)^2}{4}-\frac{3(y+2)^2}{6} = \frac{y(y-2)}{2}$

ឌ. $\frac{(z-2)^2}{3}+\frac{z(z-3)}{5} = \frac{(8z+7)(z-1)}{15}+\frac{4}{5}$ ។

3. ចូរដោះស្រាយសមីការ

ក. $x(x+3) = 0$

ខ. $(x+5)(x-1) = 0$

គ. $(x-1)^2-4 = 0$

ឃ. $4(x-1)^2-(2x-3)^2 = 0$

ង. $x^2-6x = 0$

ច. $2x^2-2 = 0$ ។

4. ចូរដោះស្រាយសមីការ

ក. $x^2 - 2x + 3 = 0$　　　　ខ. $x^2 - 12x + 32 = 0$

គ. $y^2 - 14 = 5y$　　　　ឃ. $x^2 - x = 3x + 12$ ។

5. កាណូតមួយបើកបណ្ដោយទឹកពីកំពង់ផែ $A$ ទៅកំពង់ផែ $B$ ដែលមានចម្ងាយ $57km$ ។ ពេលកាណូតបើកដល់ចំណុចមួយ គេត្រូវឈប់សម្រាកអស់ $1/3h$ ហើយទៅដល់កំពង់ផែ $B$ ត្រូវចំណាយពេលអស់ $10/3h$ ។ គេដឹងថាចរន្តទឹកមានល្បឿន $2km/h$ ។ ចូរគណនាល្បឿនកាណូត ផ្ទាល់ ។

6. ឧទ្ធម្ភាចក្រមួយគ្រឿងធ្វើដំណើរចេញពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញឆ្ពោះទៅទីរួមខេត្តសៀមរាបដោយល្បឿន $288km/h$ ។ 20 នាទីក្រោយមកមានយន្តហោះមួយគ្រឿងទៀតបានហោះចេញពីកន្លែងតែមួយទៅកាន់ទីរួមខេត្តសៀមរាបដែរក្នុងល្បឿន $480km/h$ ។ តើយន្តហោះនេះហោះអស់រយៈពេលប៉ុន្មាន ទើបតាមទាន់ឧទ្ធម្ភាចក្រ ?



7. គេយកសៀវភៅ 280 ក្បាល ទៅចែកដល់សិស្សមួយថ្នាក់ ។ ក្រោយពេលចែកសៀវភៅអស់ គេសង្កេតឃើញថា សិស្សម្នាក់ៗទទួលបានសៀវភៅ 4 ក្បាល ។ ចូរកំណត់ចំនួនសិស្សក្នុងថ្នាក់នោះ ?

8. អ្នកជិះកង់ម្នាក់ចេញពីទីក្រុង $A$ ទៅទីក្រុង $B$ ដែលមានចម្ងាយ $50km$ ។ មួយម៉ោងក្រោយមកអ្នកជិះម៉ូតូម្នាក់ចេញពីទីក្រុង $A$ ដែរ ហើយទៅដល់ទីក្រុង $B$ មុនអ្នកជិះកង់មួយម៉ោង ។ ចូរគណនាល្បឿននៃយានទាំងពីរ បើគេដឹងថាល្បឿនម៉ូតូស្មើនឹង 2.5 ដងនៃល្បឿនកង់ ។

9. គេយកសូលុយស្យុងអាស៊ីត 40 % ដែលមានមាឌ 20$l$ ទៅលាយជាមួយសូលុយស្យុងអាស៊ីត 70 % ។ តើគេត្រូវលាយសូលុយស្យុង 70% ប៉ុន្មានលីត្រ ដើម្បីបានល្បាយមួយដែលមានអាស៊ីត 50 % ?

10. អ្នកស្រីសុវត្ថិបានយកប្រាក់មួយចំនួនទៅចងការ ។ មួយផ្នែកនៃប្រាក់នេះគាត់ទទួលបានអត្រាការប្រាក់ 9 % និងមួយផ្នែកទៀតដែលលើសពីផ្នែកមុន 8 000 000៛ ទទួលបានអត្រាការប្រាក់ 10 % ។ ក្នុងមួយឆ្នាំគាត់ទទួលបានការប្រាក់ទាំងអស់ចំនួន 4 600 000៛ ។ តើគាត់មានប្រាក់ដើមក្នុងអត្រាការប្រាក់នីមួយៗប៉ុន្មានរៀល ?

11. ថ្នាក់រៀនមួយមានសិស្សប្រុស 30 នាក់ ក្នុងនោះសិស្ស 22 នាក់លេងបាល់ទាត់ ហើយសិស្ស 17 នាក់លេងបាល់បោះ មានសិស្ស 03 នាក់មិនលេងបាល់បោះនិងបាល់ទាត់ ។




សំណុំ $F$ តាងឱ្យអ្នកលេងបាល់ទាត់

សំណុំ $B$ តាងឱ្យអ្នកលេងបាល់បោះ

សំណុំ $F \cap B$ តាងឱ្យអ្នកលេងបាល់ទាត់និងបាល់បោះ

ចូររកចំនួនសិស្សដែលលេងបាល់ទាត់ផងនិងបាល់បោះផង ។

12. ក្នុងការប្រគល់មេដៃទៅឱ្យកីឡាករបានប្រព្រឹត្តទៅតាមលំដាប់ដូចខាងក្រោម ។

ថ្ងៃទី 1 គេបានប្រគល់អស់ពាក់កណ្ដាលនៃមេដៃ

ថ្ងៃទី 2 គេបានប្រគល់អស់ពាក់កណ្ដាលនៃមេដៃដែលសល់ពីថ្ងៃទី 1

ថ្ងៃទី 3 គេបានប្រគល់អស់ពាក់កណ្ដាលនៃមេដៃដែលសល់ពីថ្ងៃទី 2

ថ្ងៃទី 4 គេបានប្រគល់អស់ពាក់កណ្ដាលនៃមេដៃដែលសល់ពីថ្ងៃទី 3

ហើយនៅសល់មេដៃ 2 ។ តើចំនួនមេដៃសរុបមានចំនួនប៉ុន្មាន ?

13. ទូរសព្ទដៃមួយលក់បញ្ចុះតម្លៃ 30% នៃតម្លៃដែលលក់ពីមុន ដោយគិតទាំងពន្ធអាករបន្ថែម 10% នៃថ្លៃលក់ ។ ពូសុខត្រូវបង់ថ្លៃសរុបអស់ប្រាក់ 184 800៛ ។ ចូររកតម្លៃដែលបានលក់ពីមុន ។

មេរៀនទី

# 5 វិសមីការដឺក្រេទី១មានមួយអញ្ញាត

**វត្ថុបំណង**

- ស្រាយបញ្ជាក់វិសមភាពងាយៗ ។
- ដោះស្រាយវិសមីការ ។
- ដោះស្រាយចំណោទដែលទាក់ទងនឹងវិសមីការ ។

## 1. លក្ខណៈនៃវិសមភាព

*ឧទាហរណ៍ទី 1 :* $4>3$ , $4+6>3+6$

$4>3$ , $4-2>3-2$ ។

*ជាទូទៅ :* បើគេបូក ឬដកចំនួនតែមួយលើអង្គទាំងពីរនៃវិសមភាព គេបានវិសមភាពថ្មីដែលមានទិសដៅដូចវិសមភាពដើម ។

បើ $a>b$ នោះ $a+c>b+c$

$a-c>b-c$

*ឧទាហរណ៍ទី 2 :*

$7>5$ , $7\times 3>5\times 3$ គុណនឹង $3>0$

$7>5$ , $7\times(-3)<5\times(-3)$ គុណនឹង $-3<0$

$8>6$ , $8\div 2>6\div 2$ ចែកនឹង $2>0$

$8>6$ , $8\div(-2)<6\div(-2)$ ចែកនឹង $-2<0$ ។

*ជាទូទៅ :* បើគេគុណ ឬចែកអង្គទាំងពីរនៃវិសមភាពនឹងចំនួនវិជ្ជមានតែមួយ គេបានវិសមភាពថ្មីដែលមានទិសដៅដូចវិសមភាពដើម ។

បើគេគុណឬចែកអង្គទាំងពីរនៃវិសមភាពនឹងចំនួនអវិជ្ជមានតែមួយ គេបានវិសមភាពថ្មីមានទិសដៅផ្ទុយពីវិសមភាពដើម ។

$a>b\begin{cases}ac>bc\\ a\div c>b\div c\end{cases}$ បើ $c>0$ , $a>b\begin{cases}ac<bc\\ a\div c<b\div c\end{cases}$ បើ $c<0$

*លំហាត់គំរូ :* គេឱ្យ $a$ និង $b$ ជាចំនួនខុសពីសូន្យ

ក. ចូរស្រាយបញ្ជាក់ថា $a^2+b^2 \geq 2ab$

ខ. បើ $a$ និង $b$ មានសញ្ញាដូចគ្នា ។ ចូរស្រាយបញ្ជាក់ថា $\frac{a}{b}+\frac{b}{a} \geq 2$

គ. បើ $a$ និង $b$ មានសញ្ញាផ្ទុយគ្នា ។ ចូរស្រាយបញ្ជាក់ថា $\frac{a}{b}+\frac{b}{a} \leq 2$ ។

*ចម្លើយ :*

ក. $(a-b)^2$ ជាចំនួនវិជ្ជមាន ឬស្មើនឹង 0

យើងបាន $(a-b)^2 \geq 0$ ឬ $a^2+b^2-2ab \geq 0$ បូកអង្គទាំងពីរនឹង $2ab$

$$a^2+b^2-2ab+2ab \geq 2ab$$

ដូចនេះ $a^2+b^2 \geq 2ab$ ។

ខ. ដោយប្រើ $a^2+b^2 \geq 2ab$ បើ $a$ និង $b$ មានសញ្ញាដូចគ្នានោះ $ab>0$

ចែកអង្គទាំងពីរនឹង $ab>0$ វិសមភាពមិនប្តូរទិសដៅ

$\frac{a^2+b^2}{ab} \geq \frac{2ab}{ab}$ , $\frac{a^2}{ab}+\frac{b^2}{ab} \geq 2$ , $\frac{a}{b}+\frac{b}{a} \geq 2$ ។

គ. ដោយប្រើ $a^2+b^2 \geq 2ab$ បើ $a$ និង $b$ មានសញ្ញាផ្ទុយគ្នានោះ $ab<0$

ចែកអង្គទាំងពីរនឹង $ab<0$ វិសមភាពប្តូរទិសដៅ

$\frac{a^2+b^2}{ab} \leq \frac{2ab}{ab}$ , $\frac{a^2}{ab}+\frac{b^2}{ab} \leq 2$ , $\frac{a}{b}+\frac{b}{a} \leq 2$ ។

គេអាចបញ្ជាក់ដោយឧទាហរណ៍ជាលេខ

បើ $a=-4$ , $b=-2$ $\frac{a}{b}+\frac{b}{a} = \frac{-4}{-2}+\frac{-2}{-4} = 2+\frac{1}{2} > 2$

បើ $a=-4$ , $b=2$ $\frac{a}{b}+\frac{b}{a} = \frac{-4}{2}+\frac{2}{-4} = -2-\frac{1}{2} < 2$ ។

*ប្រតិបត្តិ :* $a$ និង $b$ ជាចំនួនមិនសូន្យហើយវិជ្ជមាន ។

ចូរស្រាយបញ្ជាក់ថា បើ $a>b$ គេបាន $a^2>b^2$ ។

## 2. វិសមីការដឺក្រេទី1 មានមួយអញ្ញាត

- វិសមីការនិងចម្លើយ

រក $x$ ដែល $x+4 = 7$ ជាសមីការដែលមានចម្លើយ $x = 7-4 = 3$

រក $x$ ដែល $x+4<7$ ជាវិសមីការដឺក្រេទី 1 មានមួយអញ្ញាត $x$

ចម្លើយ នៃវិសមីការជាតម្លៃ $x$ ដែលនាំឱ្យអង្គទី 1 តូចជាងអង្គទី 2

បើ $x = 4$ , $4+4>7$ មិនផ្ទៀងផ្ទាត់ គេថា $x = 4$ មិនមែនជាចម្លើយ

បើ $x = 3$ , $3+4 = 7$ មិនផ្ទៀងផ្ទាត់ គេថា $x = 3$ មិនមែនជាចម្លើយ

បើ $x = 2$ , $2+4<7$ ផ្ទៀងផ្ទាត់ គេថា $x = 2$ ជាចម្លើយ

បើ $x = 1$ , $1+4<7$ ផ្ទៀងផ្ទាត់ គេថា $x = 1$ ជាចម្លើយ

បើ $x = 0$ , $0+4<7$ ផ្ទៀងផ្ទាត់ គេថា $x = 0$ ជាចម្លើយ

បើ $x = -1$ , $-1+4<7$ ផ្ទៀងផ្ទាត់ គេថា $x = -1$ ជាចម្លើយ

មានតម្លៃ $x$ រាប់មិនអស់ដែលផ្ទៀងផ្ទាត់វិសមីការ ចម្លើយនៃវិសមីការអាចបកស្រាយដោយវិសមភាពគឺ $x<3$ ហើយគេក៏អាចបកស្រាយចម្លើយដោយក្រាបខាងក្រោម ។




គេប្រើវង់ក្រចកត្រង់ 3 បញ្ជាក់ថា 3 ពុំមែនជាចម្លើយទេ ។

- របៀបដោះស្រាយវិសមីការ

ដោះស្រាយវិសមីការគឺរកគ្រប់តម្លៃអញ្ញាតដែលផ្ទៀងផ្ទាត់វិសមីការ ។

គេដោះស្រាយវិសមីការដោយប្រើលក្ខណៈនៃវិសមភាព ។

***ឧទាហរណ៍ទី 1 :*** ដោះស្រាយវិសមីការ $x-2<5$

$x-2<5$

$x-2+2<5+2$

$x<7$ ។

ចម្លើយជាក្រាប




វង់ក្រចកបញ្ជាក់ថា $x$ មិនអាចស្មើនឹង 7

***ឧទាហរណ៍ទី 2 :*** ដោះស្រាយវិសមីការ $-3x+1<7$

$-3x+1<7$

$-3x+1-1<7-1$

$-3x<6$

$(-3x)\div(-3)>6\div(-3)$

$x>-2$ ។

ចម្លើយជាក្រាប




***ឧទាហរណ៍ទី 3 :*** ដោះស្រាយវិសមីការ $\frac{1}{2}x>4$

$\frac{1}{2}x>4$

$\left(\frac{1}{2}x\right)(2)>4(2)$

$x>8$ ។

ចម្លើយជាក្រាប



***ឧទាហរណ៍ទី 4 :*** ដោះស្រាយវិសមីការ $2x-4\le x+4$

$2x-4\le x+4$

$2x-4+4\le x+4+4$

$2x\le x+8$

$2x-x\le x+8-x$

$x\le 8$ ។

ចម្លើយជាក្រាប




ដង្កៀបបញ្ជាក់ថា $x$ អាចស្មើនឹង 8

ក្នុងប្រតិបត្តិ គេអាចដោះស្រាយវិសមីការដោយលើកតួពីអង្គមួយទៅអង្គមួយទៀត ។

***ឧទាហរណ៍ទី 5 :*** ដោះស្រាយវិសមីការ $3x-11\le 7x+1$

$3x-11\le 7x+1$

$3x-7x\le 1+11$

$-4x\le 12$

$x\ge \frac{12}{-4}$

$x\ge -3$ ។

ចម្លើយជាក្រាប




ដង្កៀបបញ្ជាក់ថា $x$ អាចស្មើនឹង $-3$

***លំហាត់គំរូ :*** ចូរដោះស្រាយវិសមីការ

ក. $2x+3\le 5x+7$

ខ. $3x+2x+5<8x+4-3x$

គ. $4x+2\le 6x+2-2x$ ។

***ចម្លើយ :***

ក. $2x+3\le 5x+7$

$2x-5x\le 7-3$

$-3x\le 4$

$x\ge -\frac{4}{3}$ ។

ចម្លើយជាក្រាប




ខ. $3x+2x+5<8x+4-3x$

ករណីគ្មានចម្លើយ គេមិនបកស្រាយជាក្រាបទេ

$5x+5<5x+4$

$5x-5x<4-5$

$0x<-1$ គ្មានតម្លៃ $x$ ដែលគុណនឹង 0 អាចតូចជាង $-1$

ដូចនេះ វិសមីការគ្មានចម្លើយ ។

គ. $4x+2 \le 6x+2-2x$

$4x+2 \le 4x+2$

$4x-4x \le 2+2$

$0x \le 0$

ចម្លើយជាក្រាប




ទោះ $x$ យកតម្លៃណាក៏អង្គទី 1 នៅតែស្មើនឹងអង្គទី 2 ដដែល

ដូចនេះ គេថាវិសមីការមានចម្លើយចំពោះគ្រប់តម្លៃនៃ $x$ ។

*ប្រតិបត្តិ :* ចូរដោះស្រាយវិសមីការ $\frac{x}{4}+2>7$

$2(x+3)>5x+5$ , $0.37x+0.17>3.5$ ។

## 3. ប្រព័ន្ធវិសមីការដឺក្រេទី1មានមួយអញ្ញាត

*ឧទាហរណ៍ :* រកមួយចំនួនបើថែមនឹង 5 ត្រូវធំជាង 10 ហើយពីរដងនៃចំនួននោះតូចជាង 30 ។

សម្មតិកម្មខាងលើមានលក្ខខណ្ឌពីរ

- ថែម 5 លើចំនួននោះត្រូវធំជាង 10 បកស្រាយដោយវិសមីការ (1) $x+5>10$
- ពីរដងនៃមួយចំនួននោះតូចជាង 30 បកស្រាយដោយវិសមីការ (2) $2x<30$

វិសមីការទាំងពីរខាងលើផ្តុំបានប្រព័ន្ធវិសមីការ $\begin{cases} x+5>10 & (1) \\ 2x<30 & (2) \end{cases}$

ចម្លើយនៃប្រព័ន្ធវិសមីការត្រូវតែផ្ទៀងផ្ទាត់វិសមីការ (1) និងសមីការ (2) ព្រមគ្នា

ក្នុងករណីនេះគេត្រូវរកចម្លើយរួមនៃវិសមីការទាំងពីរ

របៀបរកចម្លើយរួម

ចំពោះវិសមីការ (1) $x+5>10$ , $x>5$




ចំពោះវិសមីការ (2) $2x<30$ , $x<15$




ចម្លើយរួមជាប្រសព្វនៃចម្លើយទាំងពីរ




ក្រាបបង្ហាញឱ្យឃើញថា $x$ ត្រូវយកតម្លៃធំជាង 5 ហើយតូចជាង 15 គឺ $5<x<15$ ។

*លំហាត់គំរូ :* ចូរដោះស្រាយប្រព័ន្ធវិសមីការ $\begin{cases} 2x+5 \ge 5x-4 & (1) \\ x-7 \ge 2x-3 & (2) \end{cases}$ ។

***ចម្លើយ :***

ចំពោះវិសមីការទី (1) $2x+5\geq 5x-4$

$2x-5x\geq -4-5$

$-3x\geq -9$

$x\leq 3$




ចំពោះវិសមីការទី (2) $x-7\geq 2x-3$

$x-2x\geq -3+7$

$-x\geq 4$

$x\leq -4$




ចម្លើយរួមជាប្រសព្វនៃចម្លើយទាំងពីរ គឺ $x\leq -4$ ។




***ប្រតិបត្តិ :*** ចូរដោះស្រាយប្រព័ន្ធវិសមីការ

ក. $\begin{cases}2x-7\leq 6x+5\\4x-11\leq 4+x\end{cases}$ ខ. $\begin{cases}\dfrac{3x}{4}-\dfrac{2}{3}\leq\dfrac{4x-3}{12}\\2x-1>\dfrac{3x-4}{2}\end{cases}$ ។

## 4. ចំណោទ

***លំហាត់គំរូទី 1 :*** ចតុកោណកែងមួយដែលមានវិមាត្រគិតជាម៉ែត្រ ហើយមានវិមាត្រដូចរូបខាងក្រោមនេះ ។




ក. ចូរកំណត់តម្លៃ $x$ ដើម្បីឱ្យបរិមាត្រនៃចតុកោណកែងធំជាង $32m$ ។

ខ. ចូរកំណត់តម្លៃ $x$ ដើម្បីឱ្យបរិមាត្រនៃចតុកោណកែងតូចជាង $32m$ ។

***ចម្លើយ :***

ក. សម្មតិកម្ម : ចតុកោណកែងមានទទឹង $x$ និងបណ្តោយ $x+2$ , បរិមាត្រធំជាង $32m$

សំណួរ : រកតម្លៃ $x$

គំនិតបន្ថែម : $x$ ជារង្វាស់ជ្រុង ដូចនេះ $x>0$

វិសមីការ : បរិមាត្រធំជាង 32 និង $x>0$

$$\begin{cases}2[x+(x+2)]>32\\x>0\end{cases}$$

✍ *ដំណោះស្រាយ :*

$2[x+(x+2)]>32$

$4(x+1)>32$

$x+1>8$

$x>7$

ចម្លើយជាក្រាប




គិតទាំងលក្ខខណ្ឌ $x>0$ ចម្លើយនៃវិសមីការគឺ $x>7$ ។

***ការផ្ទៀងផ្ទាត់ :*** ឱ្យ $x=8$ បរិមាត្រ $4(x+1)=4(8+1)=36>32$

ខ. សម្មតិកម្ម : បរិមាត្រតូចជាង 32

វិសមីការ :

$$\begin{cases} 2[x+(x+2)]<32 \\ x>0 \end{cases}$$

✍ *ដំណោះស្រាយ :*

$$\begin{cases} 4(x+1)<32 \\ x>0 \end{cases} \text{ ឬ } \begin{cases} x+1<8 \\ x>0 \end{cases} \text{ ឬ } \begin{cases} x<7 \\ x>0 \end{cases}$$

សរុបមក $0<x<7$




***ការផ្ទៀងផ្ទាត់ :*** ឱ្យ $x=1$ បរិមាត្រ $4(x+1)=4(1+1)=8<32$

ឱ្យ $x=6$ បរិមាត្រ $4(6+1)=4(7)=28<32$ ។

***លំហាត់គំរូទី 2 :*** ពូសុខមានអាយុច្រើនជាងកូន 32 ឆ្នាំ ហើយមានអាយុតិចជាងឪពុក 33 ឆ្នាំ ។ បើគេដឹងថាផលបូកនៃអាយុអ្នកទាំងបីតិចជាង 103 ឆ្នាំ ។ ចូរកំណត់រកអាយុនៃពូសុខ ។

***ចម្លើយ :***

ក. សម្មតិកម្ម : ពូសុខមានអាយុច្រើនជាងកូន 32 ឆ្នាំ

ពូសុខមានអាយុតិចជាងឪពុក 33 ឆ្នាំ

អាយុនៃអ្នកទាំងបីតិចជាង 103 ឆ្នាំ

សំណួរ : រកអាយុនៃពូសុខ

ការតាងអញ្ញាត : តាង $x$ ជាអាយុនៃពូសុខ

គំនិតបន្ថែម : $x>32$ ព្រោះពូសុខត្រូវតែមានអាយុច្រើនជាង 32 ឆ្នាំ ហើយ $x$ ជាចំនួនគត់

វិសមីការ : បើ $x$ ជាអាយុនៃពូសុខ

អាយុកូន $x-32$

អាយុឪពុក $x+33$

យើងបានវិសមីការ $x+(x-32)+(x+33)<103$

✍ *ដំណោះស្រាយ :*

$$3x+1<103 \quad , \quad 3x<102 \quad , \quad x<34$$

គិតទាំងលក្ខខណ្ឌ : $32<x<34$

ដោយ $x$ ជាចំនួនគត់នោះ $x = 33$ ឆ្នាំ ។

***ការផ្ទៀងផ្ទាត់*** :បើសុខមានអាយុ $x = 33$ ឆ្នាំ

អាយុកូន $33-32 = 1$ ឆ្នាំ

អាយុឪពុក $33+33 = 66$ ឆ្នាំ

ផលបូកនៃអាយុអ្នកទាំងបី $33+1+66 = 100<103$ ។

***ប្រតិបត្តិ :*** ក. គេឱ្យចតុកោណកែងមួយមានវិមាត្រ $5m$ និង $x$ គិតជា $m$ ។ តើ $x$ ត្រូវយកតម្លៃណាខ្លះ ដើម្បីឱ្យចតុកោណកែងនេះមានបរិមាត្រធំជាង $18m$ និងមានផ្ទៃក្រឡាតូចជាង $50m^2$ ។

ខ. ផលបូកនៃបីចំនួនគត់តគ្នាតូចជាង 1918 តែធំជាង 1914 ។ ចូររកចំនួនគត់ទាំងបីនោះ ។

## ? លំហាត់

1. ចូរដោះស្រាយវិសមីការ

ក. $x+5>3$ , $3-x<7-2x$

ខ. $5x\geq 10$ , $-6x<12$ , $-5x>-20$

គ. $2x\leq -\frac{1}{3}$ , $\frac{x}{7}>\frac{1}{4}$ , $-3x\geq \frac{9}{2}$

ឃ. $5x-1>4$ , $-8x+9\geq -7$ , $x-1<x+2$

ង. $3x-5<x+7$ , $-2x+11>5x+31$

ច. $-4x+9\leq 8x-3$ , $-2x-1\geq 2\left(x+\frac{1}{2}\right)$

ឆ. $\frac{2}{3}x+3>\frac{5}{3}x-27$ , $\frac{x+1}{2}<\frac{2x-3}{4}$

ជ. $x-\frac{1+2x}{4}\geq \frac{1-3x}{3}$ , $\frac{x+1}{5}-\frac{1}{2}\leq \frac{3+2x}{2}$ ។

2. ចូរដោះស្រាយប្រព័ន្ធវិសមីការ

ក. $\begin{cases} 2x-3\leq 9 \\ 2x-3\geq -5 \end{cases}$ , $\begin{cases} 3x-4\leq 8 \\ 3x-4>-7 \end{cases}$

ខ. $\begin{cases} 2x+5>5x-4 \\ x-7<2x-3 \end{cases}$ , $\begin{cases} 2x-3>5x-1 \\ x+4\geq 3x-2 \end{cases}$

គ. $\begin{cases} \frac{3x}{4}-\frac{2}{3}\leq \frac{4x-3}{2} \\ 2x-1>\frac{3x-4}{4} \end{cases}$ , $\begin{cases} 2x+1<0 \\ -\frac{x}{2}+2<0 \end{cases}$ ។

3. គេដាំកូនឈើចំនួន 40 ដើមព័ទ្ធជុំវិញចំការមួយរាងចតុកោណកែង ។ តើចំការនោះអាចមានផ្ទៃក្រឡាធំបំផុតប៉ុន្មាន $m^2$ បើគេដឹងថា គេដាំកូនឈើឃ្លាតពីគ្នា $2m$ ?

4. ចូរបង្ហាញថាជ្រុងនីមួយៗនៃត្រីកោណ មានប្រវែងខ្លីជាងកន្លះបរិមាត្រនៃត្រីកោណនោះ ។

5. ពាក់កណ្ដាលនៃមួយចំនួនថែមនឹង 5 ធំជាងឬស្មើនឹង -3 ។ ចូររកចំនួននោះ ។

6. បច្ចុប្បន្ននេះឪពុកមានអាយុ 32ឆ្នាំ ហើយកូនគាត់មានអាយុ 12ឆ្នាំ ។ តើនៅក្នុងចន្លោះប៉ុន្មានឆ្នាំទៅមុខទៀត ទើបអាយុឪពុកតិចជាងបីដង ប៉ុន្តែច្រើនជាងពីរដងនៃអាយុកូន ?

7. សុខមានក្រដាសប្រាក់ពីរដុំ ។ ដុំទី 1 មានក្រដាសប្រាក់ 500៛ ចំនួន 20 សន្លឹក ដុំទី 2 មានក្រដាសប្រាក់ 1 000៛ ចំនួន 30 សន្លឹក ។ ថ្ងៃមួយសុខហូត 25 សន្លឹកពីក្រដាសប្រាក់ទាំងពីរដុំនោះ ។ បើសុខចង់បានប្រាក់យ៉ាងតិច 17 500៛ ហើយយ៉ាងច្រើន 20 000៛ តើសុខអាចមានក្រដាសប្រាក់ 500៛ ប៉ុន្មានសន្លឹក ?

8. ក្នុងការប្រឡងលើ 8 មុខវិជ្ជាដែលមុខវិជ្ជានីមួយៗមានពិន្ទុ 100 ។ គេកំណត់និទ្ទេស $A$ ចំពោះសិស្សណាដែលមានមធ្យមភាគយ៉ាងតិចស្មើនឹង 90 ហើយទទួលបាននិទ្ទេស $B$ ត្រូវមានមធ្យមភាគយ៉ាងតិចស្មើនឹង 80 ។ វិសាលប្រឡងបាន 7 មុខវិជ្ជាដោយទទួលបានពិន្ទុ 84 93 78 87 89 70 និង 81 ហើយនៅសល់មួយមុខវិជ្ជាទៀតដែលត្រូវប្រឡងបន្ត ។

ក. តើវិសាលអាចទទួលបាននិទ្ទេស $A$ ឬទេ ?

ខ. តើវិសាលអាចទទួលបាននិទ្ទេស $B$ ឬទេ ? ចូរកំណត់ពិន្ទុនៃមុខវិជ្ជាចុងក្រោយដើម្បីឱ្យគេទទួលនិទ្ទេស $B$ ។

9. សួនមួយរាងចតុកោណកែង ។ បណ្ដោយមានរង្វាស់លើស ៣ ដងនៃទទឹងប្រវែង $15m$ ។ ដោយដឹងថាបរិមាត្រនៃសួនវែងបំផុតស្មើនឹង $94m$ ចូររកវិមាត្រអតិបរមានៃសួននោះបើរង្វាស់ជ្រុងជាចំនួនគត់ ។

10. សំបុត្រដែលត្រូវលក់ឱ្យភ្ញៀវមានពីរប្រភេទ $A$ និង $B$ ដែលប្រភេទ $A$ មានចំនួនលើសប្រភេទ $B$ ចំនួន 5 សន្លឹក ។ បើគេលក់សំបុត្រយ៉ាងច្រើនបាន 37 សន្លឹក ។ ចូររកចំនួនសំបុត្រនៃប្រភេទនីមួយៗដែលអាចលក់បានច្រើនបំផុត ។

11. ផលបូកនៃពីរចំនួនគត់សេសតគ្នាធំជាង 72 ចូរកំណត់ចំនួនគត់សេសទាំងពីរដែលមានតម្លៃធំជាងគេ ។

12. លក្ខខណ្ឌក្នុងការជួលរថយន្តកំណត់ដូចខាងក្រោម ។

- អ្នកជួលជាអ្នកបើកបរនិងចេញប្រេងដោយខ្លួនឯង
- ឈ្នួលជួលក្នុង 1 ថ្ងៃគិតជាប្រាក់ 80 000៛ ព្រមទាំងប្រាក់បន្ថែមថ្លៃ 400៛ ក្នុងចម្ងាយផ្លូវ $1km$
- អ្នកជួលត្រូវកក់ប្រាក់ 400 000៛ សម្រាប់ជួល 1 ថ្ងៃ ។

តើអ្នកជួលត្រូវបើកបរចម្ងាយផ្លូវប៉ុន្មាន ដើម្បីកុំឱ្យឈ្នួលជួលលើសពីប្រាក់កក់ ។

13. គេឱ្យ $\Delta ABC$ ដែលមានជ្រុង $AB = 12cm$ , $AC = 3cm$ ។ តើជ្រុង $BC$ មានប្រវែងប៉ុន្មាន ? បើដឹងថាប្រវែងរបស់វាជាពហុគុណនៃ 3 (ប្រវែង $BC$ គិតជាចំនួនគត់) ?

14. ចូររកចំនួនគត់ដែលពីរដងនៃតម្លៃរបស់វាយ៉ាងតិចស្មើនឹង 8 ។

15. បូណាចង់កាត់ក្រដាស ឱ្យបានរាងចតុកោណកែងមួយ ដែលមានទទឹងប្រវែង $3cm$ និងមានផ្ទៃក្រឡានៅក្នុងចន្លោះពី $15cm^2$ ទៅ $24cm^2$ ។ តើបូណាត្រូវជ្រើសរើសបណ្ដោយប្រវែងប៉ុន្មានខ្លះ ? (ប្រវែងបណ្ដោយជាចំនួនគត់) ។

មេរៀនទី

# 6 បំណែងចែកប្រេកង់

**វត្ថុបំណង**

- ផ្តុំទិន្នន័យជាប្រេកង់ ។
- ផ្តុំទិន្នន័យជាប្រេកង់កើននិងចុះ ។
- ផ្តុំទិន្នន័យជាថ្នាក់ ។
- បកស្រាយទិន្នន័យជាក្រាបនៃពហុកោណ ។

## 1. ការផ្តុំទិន្នន័យជាប្រេកង់



ជារៀងរាល់ឆ្នាំ គេតែងតែស្រង់ចំនួនសាលាបឋមសិក្សាដែលបានពង្រីកទៅតាមជនបទនៃទូទាំងប្រទេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការនិងធានាឱ្យការចូលរៀនប្រកបដោយសមធម៌ ។ចំនួនសាលានិងចំនួនសិស្សដែលបានចូលរៀនតែងតែប្រែប្រួលទៅតាមឆ្នាំសិក្សានីមួយៗ ដើម្បីទាក់ទាញក៏ដូចជាងាយស្រួលដល់អ្នកអាន គេនិយមបកស្រាយចំនួនសិស្សនិងចំនួនសាលាដោយក្រាប ។




ក្រាបនេះបង្ហាញអំពីចំនួនសាលារៀននិងចំនួនសិស្សនៃបឋមសិក្សាចាប់ពីឆ្នាំសិក្សា 2002-2003 ដល់ឆ្នាំ 2006-2007 ។

**អំពីចំនួននៃសាលារៀន :** ចំនួននៃសាលារៀនបានកើនប្រមាណពី 5 900 រហូតដល់ជិត 6 400 សាលារៀន ។

**អំពីចំនួនសិស្ស :** ផ្ទុយទៅវិញចំនួនកុមារដែលបានចូលរៀនចាប់ថយចុះបន្តិចម្តងៗ គឺចាប់ចុះពីប្រមាណពី 2.7 លានមក 2.5 លាន ។

*ឧទាហរណ៍ទី 1:* ខាងក្រោមនេះជាលទ្ធផលពិន្ទុរបស់សិស្សនៃថ្នាក់រៀនមួយ ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 4 | 4 | 5 | 4 | 1 | 6 | 5 | 6 | 6 | 5 |
| 5 | 4 | 5 | 4 | 9 | 2 | 7 | 5 | 7 | 2 |
| 5 | 2 | 6 | 3 | 7 | 3 | 5 | 1 | 5 | 6 |
| 4 | 5 | 1 | 5 | 5 | 6 | 1 | 6 | 2 | 5 |
| 5 | 2 | 9 | 4 | 6 | 7 | 4 | 4 | 4 | 5 |

ពិន្ទុនីមួយៗឋិតនៅរប៉ាត់រប៉ាយពីគ្នា ក្នុងករណីនេះគេផ្តុំវាទៅតាមចំនួនដងរបស់វាហៅថាប្រេកង់ លើសពីនេះ គេក៏ត្រូវធៀបប្រេកង់ទៅនឹងប្រេកង់សរុបដើម្បីគិតជាភាគរយហៅថាប្រេកង់ធៀប ។

គេបានតារាងខាងក្រោម

| ពិន្ទុ $x$ | ប្រេកង់ $f$ | ប្រេកង់ធៀបជា % |
|---|---|---|
| 1 | 4 | 8 |
| 2 | 5 | 10 |
| 3 | 2 | 4 |
| 4 | 10 | 20 |
| 5 | 15 | 30 |
| 6 | 8 | 16 |
| 7 | 4 | 8 |
| 9 | 2 | 4 |
| សរុប | 50 | 100 |

ធ្វើយ៉ាងនេះហៅថាការរៀបទិន្នន័យទៅតាមប្រេកង់ ហើយទិន្នន័យដែលបានរៀបចំដូចខាងលើហៅថា **បំណែងចែកប្រេកង់** ។

តារាងប្រេកង់អាចឱ្យគេបកស្រាយទិន្នន័យដូចខាងក្រោម

- 1 ជាពិន្ទុទាបជាងគេ ហើយ 9 ជាពិន្ទុខ្ពស់បំផុត
- សិស្សសរុបមានចំនួន 50 នាក់
- សិស្សដែលបានពិន្ទុ 1 មានចំនួន 4 នាក់ត្រូវជា $\frac{4}{50} = 0.8$ ឬ 8%

- សិស្សដែលបានពិន្ទុ 9 មានចំនួន 2 នាក់ត្រូវជា 4%
- សិស្សភាគច្រើនបានពិន្ទុ 5 មានចំនួន 15 នាក់ត្រូវជា 30% ។

តារាងនេះក៏ឆ្លុះបញ្ចាំងឱ្យឃើញថាសិស្សភាគច្រើនមានពិន្ទុពី 4 ទៅ 6 ។

| |
|---|
| ***ជាទូទៅ :*** ប្រេកង់ធៀបនៃតម្លៃមួយជាផលធៀបរវាងប្រេកង់និងប្រេកង់សរុប ។ |

គេក៏អាចបកស្រាយទិន្នន័យនេះជាក្រាបដូចខាងក្រោម

- ពិន្ទុសិស្សតាងដោយអ័ក្សដេក
- ប្រេកង់តាងដោយអ័ក្សឈរ
- ពិន្ទុនីមួយៗ តាងដោយសសរមួយ
- ក្រាបដែលតាងទិន្នន័យហៅថាក្រាបសសរដែលគេនិយមប្រើជាងគេ ។




***លំហាត់គំរូ :*** ចូរបកស្រាយក្រាបសសរខាងស្តាំនេះ ។

***ចម្លើយ :*** ក្រាបបង្ហាញអំពីទិន្នន័យនៃសិស្សដែលបានមកប្រឡងនិងសិស្សដែលបានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិទៅតាមឆ្នាំសិក្សានីមួយៗ ។




- ចំនួនបេក្ខជនមកប្រឡង
  - ពីឆ្នាំ 2001-2002 ដល់ 2002-2003 បេក្ខជនបានថយចុះប្រមាណពី 48 000 នាក់មក 35 000 នាក់ ។
  - ពីឆ្នាំ 2002-2003 ដល់ 2005-2006 បេក្ខជនបានកើនឡើងប្រមាណពី 35 000 នាក់រហូតដល់ប្រមាណ 58 000 នាក់ ។

- ចំនួនសិស្សដែលបានប្រឡងជាប់

ចំនួនបានកើនប្រមាណពី 27 000 នាក់រហូតដល់ប្រមាណ 55 000 នាក់ បើគិតជាភាគរយគឺ ចំនួនសិស្សដែលបានប្រឡងជាប់បានកើនពី 40% រហូតដល់ប្រមាណ 78% ។

*ប្រតិបត្តិ :* ខាងក្រោមនេះ ជាទិន្នន័យនៃចំនួនថ្ងៃដែលបុគ្គលិកមិនបានមកបំពេញការងារក្នុងរយៈពេល 20 ថ្ងៃ ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 0 | 0 | 1 | 2 | 2 | 1 | 0 | 0 |
| 4 | 0 | 1 | 1 | 3 | 2 | 1 | 3 | 0 | 1 |

ចូរសង់ក្រាបសសរ ។

## 2. ការផ្ដុំទិន្នន័យជាប្រេកង់កើននិងចុះ

តារាងប្រេកង់ដែលយើងសិក្សានៅឧទាហរណ៍ 1 គ្រាន់តែប្រាប់ឱ្យដឹងនូវចំនួនសិស្សទៅតាមពិន្ទុនីមួយៗប៉ុណ្ណោះ ។ បើគេចង់ដឹងអំពីចំនួនសិស្សដែលទទួលបានពិន្ទុ 5 យ៉ាងច្រើន(ពិន្ទុពី 1 ដល់ 5) នោះគេត្រូវរកប្រេកង់កើនបន្ថែមទៀត ។

ប្រេកង់កើនបានដោយបូកប្រេកង់បន្តបន្ទាប់ $4+5=9$ , $9+2=11$ , $11+10=21$ , $21+15=36$ , $36+8=44$ , $44+4=48$

គេបានតារាងនៃបំណែងចែកប្រេកង់

| ពិន្ទុ | ប្រេកង់ | ប្រេកង់កើន | ប្រេកង់ធៀប % | ប្រេកង់កើនធៀប % |
|---|---|---|---|---|
| 1 | 4 | 4 | 8 | 8 |
| 2 | 5 | 9 | 10 | 18 |
| 3 | 2 | 11 | 4 | 22 |
| 4 | 10 | 21 | 20 | 42 |
| 5 | 15 | 36 | 30 | 72 |
| 6 | 8 | 44 | 16 | 88 |
| 7 | 4 | 48 | 8 | 96 |
| 9 | 2 | 50 | 4 | 100 |

តាមតារាងនេះ សិស្សដែលទទួលបានពិន្ទុ 5 យ៉ាងច្រើនមានចំនួន 36 នាក់ត្រូវជា 72% នៃចំនួនសិស្សសរុប ។

| *ជាទូទៅ :* ប្រេកង់កើន ជាប្រេកង់ដែលបានដោយបូកប្រេកង់បន្តបន្ទាប់ពីលើចុះក្រោម ។ |
|---|

គេអាចបកស្រាយប្រេកង់កើនដោយក្រាបសសរ




តាមក្រាបនេះបើគេរាប់ចំនួនសិស្សដែលទទួលបានពិន្ទុចាប់ពី 1 ដល់ 5 មានចំនួន 36 នាក់ ។

មានសំណួរមួយសួរថា តើគេអាចប្រើតារាងនេះដើម្បីរាប់ចំនួនសិស្សដែលទទួលបានពិន្ទុ 5 យ៉ាងតិចឬទេ ? ក្នុងករណីនេះគេត្រូវសង់ក្រាបនៃប្រេកង់ថយវិញទើបងាយរាប់រកចំនួនសិស្សនោះ ។

ប្រេកង់ថយជាផលដកនៃប្រេកង់សរុបនិងប្រេកង់បន្តបន្ទាប់ $50-4=46$ , $46-5=41$ , $41-2=39$ , $39-10=29$ , $29-15=15$ , $14-6=12$

គេបានតារាងនៃបំណែងចែកប្រេកង់

| ពិន្ទុ | ប្រេកង់ | ប្រេកង់ថយ | ប្រេកង់ធៀប | ប្រេកង់ធៀបថយ |
|---|---|---|---|---|
| 1 | 4 | 50 | 8 | 100 |
| 2 | 5 | 46 | 10 | 92 |
| 3 | 2 | 41 | 4 | 82 |
| 4 | 10 | 39 | 20 | 78 |
| 5 | 15 | 29 | 30 | 58 |
| 6 | 8 | 14 | 16 | 28 |
| 7 | 4 | 6 | 8 | 12 |
| 9 | 2 | 2 | 4 | 4 |

តាមតារាងខាងលើ គេឃើញសិស្សដែលបានពិន្ទុចាប់ពី 9 ថយចុះដល់ពិន្ទុ 5 បានកើនពីចំនួន 2 នាក់ទៅដល់ 29 នាក់ ដូចនេះសិស្សដែលបានពិន្ទុ 5 យ៉ាងតិចមានចំនួន 29 នាក់ត្រូវជា 58% ។

| |
|---|
| ***ជាទូទៅ :*** ប្រេកង់ថយ ជាប្រេកង់ដែលបានដោយដកប្រេកង់សរុបនឹងប្រេកង់បន្តបន្ទាប់ ។ |

គេអាចបកស្រាយប្រេកង់ថយដោយក្រាបសសរខាងក្រោម




តាមក្រាបសសរនេះ ពិន្ទុ 5 យ៉ាងតិចជាពិន្ទុចាប់ពី 5 ដល់ 9 ។ ដូចនេះគេរាប់ចំនួនសិស្សចាប់ពី 2 នាក់ឡើងដល់ 29 នាក់ ។

***លំហាត់គំរូ :*** ចូរសង់តារាងប្រេកង់កើននិងប្រេកង់ថយចំពោះទិន្នន័យខាងក្រោម ។

| $x$ | 1 | 3 | 5 | 6 | 7 | 11 |
|---|---|---|---|---|---|---|
| $f$ | 2 | 3 | 6 | 5 | 3 | 1 |

***ចម្លើយ :*** តារាងប្រេកង់កើន

| ទិន្នន័យ $x$ | ប្រេកង់ $f$ | ប្រេកង់កើន | ប្រេកង់ធៀប | ប្រេកង់ធៀបកើន |
|---|---|---|---|---|
| 1 | 2 | 2 | 10 | 10 |
| 3 | 3 | 5 | 15 | 25 |
| 5 | 6 | 11 | 30 | 55 |
| 6 | 5 | 16 | 25 | 80 |
| 7 | 3 | 19 | 15 | 95 |
| 11 | 1 | 20 | 5 | 100 |

តារាងប្រេកង់ថយ

| ទិន្នន័យ $x$ | ប្រេកង់ $f$ | ប្រេកង់ថយ | ប្រេកង់ធៀប | ប្រេកង់ធៀបថយ |
|---|---|---|---|---|
| 1 | 2 | 20 | 10 | 100 |
| 3 | 3 | 18 | 15 | 90 |
| 5 | 6 | 15 | 30 | 75 |
| 6 | 5 | 9 | 25 | 45 |
| 7 | 3 | 4 | 15 | 20 |
| 11 | 1 | 1 | 5 | 5 |

***ប្រតិបត្តិ :*** បើ $x$ ជាចំនួនកូន ហើយ $f$ ជាចំនួនគ្រួសារ ចូរសង់តារាងប្រេកង់កើននិងប្រេកង់ថយតាមទិន្នន័យខាងក្រោម ។

| $x$ | 0 | 1 | 2 | 3 | 4 |
|---|---|---|---|---|---|
| $f$ | 4 | 16 | 18 | 6 | 6 |

ក. រកចំនួនគ្រួសារដែលមានកូន 2 នាក់យ៉ាងច្រើន ។

ខ. រកចំនួនគ្រួសារដែលមានកូន 2 នាក់យ៉ាងតិច ។

## ៣. ការផ្ដុំទិន្នន័យជាថ្នាក់

បច្ចុប្បន្ននេះ ការថ្លឹងម៉ាសជាប្រចាំមានសារៈសំខាន់សម្រាប់ការតាមដានសុខភាព ។ ការស្រក ឬ កើនម៉ាសខ្លាំងជាសញ្ញាប្រាប់ឱ្យដឹងថាសុខភាពនឹងមានបញ្ហានៅពេលខាងមុខ ។

ខាងក្រោមនេះជាលទ្ធផលនៃការថ្លឹងម៉ាសគិតជា *kg* ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 38 | 42 | 48 | 41 | 52 | 55 | 59 | 62 | 62 | 63 |
| 63 | 68 | 69 | 70 | 73 | 74 | 37 | 45 | 61 | 65 |
| 75 | 76 | 77 | 78 | 79 | 81 | 83 | 84 | 85 | 86 |
| 87 | 92 | 95 | 91 | 58 | 52 | 41 | 43 | 67 | 64 |

ទិន្នន័យម៉ាសនីមួយៗពុំមានចំនួនដងច្រើនដូចទិន្នន័យពិន្ទុរបស់សិស្ស ជាហេតុធ្វើឱ្យគេមានការលំបាកក្នុងការប្រមូលផ្ដុំវាទៅតាមប្រេកង់ ។ ក្នុងករណីនេះគេអាចផ្ដុំវាជាថ្នាក់ដូចខាងក្រោម ។

ដំបូងគេផ្ដើមយកម៉ាសដែលនៅចន្លោះពី 30*kg* ទៅ 40*kg*

គេសន្មត $30 \le x < 40$ មានន័យថា $x$ អាចស្មើ 30 ប៉ុន្តែមិនអាចស្មើ 40

គេហៅ $30 \le x < 40$ ជាថ្នាក់ទី 1 ហើយគេសរសេរដោយខ្លី 30-40 គេបាន

| | |
|---|---|
| 30-40 | ជាថ្នាក់ទី 1 |
| 40-50 | ជាថ្នាក់ទី 2 |
| 50-60 | ជាថ្នាក់ទី 3 |
| 60-70 | ជាថ្នាក់ទី 4 |
| 70-80 | ជាថ្នាក់ទី 5 |
| 80-90 | ជាថ្នាក់ទី 6 |
| 90-100 | ជាថ្នាក់ទី 7 |

| ថ្នាក់ជាម៉ាស *kg* | ប្រេកង់ |
|---|---|
| 30-40 | 2 |
| 40-50 | 6 |
| 50-60 | 5 |
| 60-70 | 10 |
| 70-80 | 8 |
| 80-90 | 6 |
| 90-100 | 3 |

ធ្វើយ៉ាងនេះទើបអាចឱ្យគេផ្ដុំថ្នាក់នោះជាប្រេកង់បាន

តារាងនេះអាចឱ្យគេបកស្រាយ ។

- អ្នកដែលមានម៉ាសពី 60 ទៅ 70*kg* មានចំនួន 10 នាក់ដែលជា មនុស្សភាគច្រើន ។
- បន្ទាប់មកគឺជាអ្នកដែលមានម៉ាសពី 70-80*kg*

គេអាចបកស្រាយទិន្នន័យនេះជាក្រាបសសរ
តាងម៉ាសជាបន្ទាត់ដេក
តាងប្រេកង់ជាបន្ទាត់ឈរ ។
ថ្នាក់នីមួយៗ តាងដោយក្រាបសសរជាប់ៗគ្នា ។
ក្រាបប្រភេទនេះហៅថាអ៊ីស្តូក្រាម ។




ជួនកាលគេប្រើតម្លៃកណ្ដាលនៃថ្នាក់ មកតាងឱ្យតម្លៃនៃថ្នាក់ ។ តម្លៃកណ្ដាលនេះ ហៅថាផ្ចិតនៃថ្នាក់ វាជាមធ្យមនៃចុងទាំងពីរនៃថ្នាក់ ។

ចំពោះថ្នាក់ 30-40 ផ្ចិតវា $\frac{30+40}{2} = 35$

គេបានតារាងថ្មី

| ថ្នាក់ | ប្រេកង់ | ផ្ចិតនៃថ្នាក់ |
|---|---|---|
| 30-40 | 2 | 35 |
| 40-50 | 6 | 45 |
| 50-60 | 5 | 55 |
| 60-70 | 10 | 65 |
| 70-80 | 8 | 75 |
| 80-90 | 6 | 85 |
| 90-100 | 3 | 95 |




គេអាចប្រើផ្ចិតនៃថ្នាក់នេះដើម្បីភ្ជាប់បានជាខ្សែកាច់ហៅថា ក្រាបនៃពហុកោណ ។

តារាងប្រេកង់នៃថ្នាក់ទិន្នន័យគ្រាន់តែឱ្យគេដឹងអំពីចំនួនមនុស្សដែលមានម៉ាសក្នុងចន្លោះថ្នាក់តែប៉ុណ្ណោះ ។ គេពុំអាចដឹងអំពីមនុស្សដែលមានម៉ាសក្រោម $80kg$ ឬយ៉ាងតិចស្មើនឹង $80kg$ ទេ ។

ក្នុងករណីនេះគេត្រូវបង្កើតតារាងប្រេកង់កើន ឬ ប្រេកង់ថយ

| ថ្នាក់នៃម៉ាស | ប្រេកង់ | ប្រេកង់កើន | ប្រេកង់ថយ |
|---|---|---|---|
| 30-40 | 2 | 2 | 40 |
| 40-50 | 6 | 8 | 38 |
| 50-60 | 5 | 13 | 32 |
| 60-70 | 10 | 23 | 27 |
| 70-80 | 8 | 31 | 17 |
| 80-90 | 6 | 37 | 9 |
| 90-100 | 3 | 40 | 3 |

គេអាចបកស្រាយទិន្នន័យជាក្រាបនៃពហុកោណនៃប្រេកង់កើន ។ ក្នុងករណីនេះគេសង់ចំណុច (30 , 0) , (40 , 2) , (50 , 8) , (60 , 13) , (70 , 23) , (80 , 31) , (90 , 37) , (100 , 40) រួចភ្ជាប់អង្កត់ដែលកាត់តាមចំណុចទាំងនោះ ។




តាមតារាងក៏ដូចជាក្រាបនៃពហុកោណប្រេកង់កើនមនុស្សដែលមានម៉ាសក្រោម $80kg$ មានចំនួន 31 នាក់ មើលចំណុចដែលមានកូអរដោនេ (80 , 31) ។

បើចង់រកចំនួនមនុស្សដែលមានម៉ាសយ៉ាងតិច $80kg$ នោះគេត្រូវសង់ក្រាបនៃពហុកោណប្រេកង់ថយ ។

គេសង់ចំណុច (30 , 40) , (40 , 38) (50 , 32) , (60 , 27) , (70 , 17) (80 , 90) , (90 , 3) , (100 , 0)

រួចភ្ជាប់ចំណុចផ្គុំបានខ្សែកាច់ដែលជាក្រាបនៃពហុកោណប្រេកង់ថយ តាមក្រាបនេះអ្នកដែលមានម៉ាស $80kg$ យ៉ាងតិចគឺជាអរដោនេនៃចំណុច (80 , 9) ពោលគឺមានចំនួន 9 នាក់ ។



***លំហាត់គំរូ :*** ចូរសង់ក្រាបនៃពហុកោណប្រេកង់កើននិងថយ ក្នុងប្រព័ន្ធកូអរដោនេតែមួយ រួចប្រើចំណុចប្រសព្វរវាងខ្សែកាច់ទាំងពីរដើម្បីប៉ាន់ស្មានរកមេដ្យាននៃទិន្នន័យ ។

***ចម្លើយ :*** មេដ្យានជាចំណុចប្រសព្វរវាងខ្សែកាច់នៃពហុកោណប្រេកង់កើននិងប្រេកង់ថយ ។

អាប់ស៊ីសនៃចំណុចប្រសព្វប្រាប់អំពីថ្នាក់ម៉ាស 60-70




អរដោនេនៃចំណុចប្រសព្វប្រាប់អំពីចំនួនមនុស្សដែលនៅចន្លោះ 17 ទៅ 23 នាក់ ប្រហែលនឹងពាក់កណ្ដាលនៃមនុស្ស ដែលត្រូវជា 50% នៃមនុស្សសរុប ។

ដូចនេះថ្នាក់ម៉ាស 60-70 ជាមេដ្យាន ។

***ប្រតិបត្តិ :*** ខាងក្រោមនេះជាស្ថិតិនៃម៉ាសសិស្ស 200 នាក់ (គិតជា *kg* )នៅវិទ្យាល័យមួយ ។

| ម៉ាស | 30-40 | 40-50 | 50-60 | 60-70 |
|---|---|---|---|---|
| ប្រេកង់ | 35 | 45 | 55 | 65 |

ក. សង់តារាងប្រេកង់កើននិងផ្ចិតនៃថ្នាក់ ។

ខ. សង់ពហុកោណប្រេកង់កើន ។

គ. តើមានចំនួនសិស្សប៉ុន្មាននាក់ដែលមានម៉ាសក្រោម 50*kg* ?

## លំហាត់

1. ក្នុងថ្នាក់រៀនមួយគេស្រង់បានកំហុសអក្ខរាវិរុទ្ធនៃសិស្សម្នាក់ៗដូចខាងក្រោម ។

3 2 1 6 1 7 9 7 10 10 10 3 5 7 2 5 1 6 4 8 1

2 7 1 10 3 5 5 3 7 6 2 10 6 4 3 4 5 5 7

ក. ប្រមូលផ្តុំទិន្នន័យនេះជាតារាងបង្ហាញពីប្រេកង់ ប្រេកង់កើន និងថយ ប្រេកង់ធៀបនិងប្រេកង់ធៀបកើន និង ថយ ។

ខ. តើថ្នាក់នេះមានសិស្សប៉ុន្មាននាក់ ?

គ. តើសិស្សប៉ុន្មាននាក់ដែលមានកំហុស 10 ? ហើយសិស្សប៉ុន្មាននាក់ទៀតត្រូវជាប៉ុន្មានភាគរយដែលមានកំហុសយ៉ាងច្រើន 5 ?

ឃ. តើសិស្សប៉ុន្មាននាក់ត្រូវជាប៉ុន្មានភាគរយដែលមានកំហុសយ៉ាងតិច 9 ?

ង. សង់ក្រាបសសរនៃប្រេកង់ធៀបថយ ជាភាគរយ ។

2. គេស្រង់ស្ថិតិចំនួនកូនតាមគ្រួសារនីមួយៗ ក្នុងតំបន់មួយបានតារាងខាងក្រោម ។

| ចំនួនកូន $x$ | 0 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
|---|---|---|---|---|---|---|---|---|---|
| ចំនួនគ្រួសារ $f$ | 144 | 195 | 130 | 80 | 58 | 45 | 24 | 6 | 3 |

ក. បង្កើតតារាងដែលបង្ហាញពីប្រេកង់ ប្រេកង់កើននិងថយ ។

ខ. តើក្នុងតំបន់នេះមានប៉ុន្មានគ្រួសារ ? តើមានប៉ុន្មានគ្រួសារដែលមានកូនយ៉ាងច្រើន 5 នាក់ ? និងប៉ុន្មានគ្រួសារទៀតដែលមានកូនយ៉ាងតិច 7 នាក់ ?

គ. សង់ក្រាបសសរនៃប្រេកង់កើន ។

3. ការស្រង់ចំនួនកូន ដែលស្លាប់ក្នុងសង្គ្រាមតាមគ្រួសារនីមួយៗ ទទួលបានលទ្ធផលដូចខាងក្រោម ។

| ចំនួនកូនស្លាប់ $x$ | 1 | 2 | 3 | 4 | 5 | 6 |
|---|---|---|---|---|---|---|
| ចំនួនគ្រួសារ $f$ | 78 | 1270 | 680 | 320 | 150 | 133 |

ក. តាងទិន្នន័យខាងលើនេះជាក្រាបសសរនៃប្រេកង់ ប្រេកង់ធៀប ។

ខ. បកស្រាយនៅលើក្រាបទាំងពីរត្រង់ចំណុចនៃសសរ ដែលមានអាប់ស៊ីស $x = 3$ ។

4. ខាងក្រោមនេះ ជាស្ថិតិនៃអាយុកម្មករក្នុងសហគ្រាសមួយ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 25 | 22 | 30 | 45 | 28 | 51 | 30 | 32 | 34 | 33 |
| 18 | 30 | 15 | 20 | 24 | 17 | 24 | 41 | 38 | 27 |
| 16 | 25 | 28 | 31 | 41 | 28 | 26 | 15 | 25 | 19 |
| 32 | 36 | 21 | 18 | 34 | 41 | 53 | 25 | 42 | 41 |

ក. សរសេរទិន្នន័យខាងលើជាតារាង ដែលមាន 8 ថ្នាក់ ហើយថ្នាក់នីមួយៗមានប្រវែងចន្លោះស្មើនឹង 5 ដូចជា 15-20 20-25 ... ។

ខ. សង់អ៊ីស្តូក្រាម ។

គ. បំពេញក្នុងតារាងប្រេកង់កើន ប្រេកង់ធៀបកើន ជាភាគរយ រួចគូសក្រាបវា ។

ឃ. បកស្រាយលើក្រាបត្រង់ចំណុច ដែលមានអាប់ស៊ីស 25 ។

5. ក្នុងការប្រកួតបាល់បោះក្នុងថេរវេលា 45 នាទី ក្រុមកីឡាករទទួលជ័យជំនះបោះបាល់ចូលទីបានលទ្ធផលដូចតារាងខាងក្រោម ។

| រយៈពេល (នាទី) | 0 – 5 | 5 – 10 | 10 – 15 | 15 – 20 | 20 – 25 | 25 – 30 | 30 – 35 | 35 – 40 | 40 – 45 |
|---|---|---|---|---|---|---|---|---|---|
| ចំនួនបាល់ | 4 | 5 | 9 | 12 | 15 | 14 | 10 | 8 | 6 |

ក. តើក្រុមកីឡាករនេះ បោះចូលទីបានប៉ុន្មានបាល់ក្នុងរយៈពេល 45 នាទី ?

ខ. តើក្រុមកីឡាករនេះ បោះចូលទីបានប៉ុន្មានបាល់ក្នុងរយៈពេលក្រោម 15 នាទីដំបូង ? នៅកន្លះម៉ោងចុងក្រោយ តើគេបោះចូលទីបានប៉ុន្មានបាល់ហើយត្រូវជាប៉ុន្មានភាគរយ ?

គ. ចូរគូសក្រាបនៃពហុកោណប្រេកង់កើន ។

6. ខាងក្រោមនេះ ជាតារាងចំនួនដងនៃការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍ជាតិដែលប្រព្រឹត្តិទៅចាប់ពីម៉ោង 2 រសៀល (រយៈពេលផ្សាយគិតជានាទី) ។

| រយៈពេលផ្សាយ (នាទី) | ក្រោម 5 | 5 – 10 | 10 – 15 | 15 – 20 | 20 – 25 | 25 – 30 | 30 – 35 | 35 – 40 | 40 – 45 |
|---|---|---|---|---|---|---|---|---|---|
| ចំនួនដង | 5 | 1 | 1 | 3 | 2 | 6 | 8 | 12 | 12 |

ក. តើក្នុងល្ងាចនេះគេផ្សាយពាណិជ្ជកម្មបានប៉ុន្មានដង ? អស់រយៈពេលប៉ុន្មាននាទី ?

ខ. តើគេផ្សាយពាណិជ្ជកម្មបានប៉ុន្មានដង ក្នុងរយៈពេល 20 នាទីចុងក្រោយ ? ក្នុងរយៈពេលតិចជាង 30 នាទីដំបូង ?

គ. ចូរគូសក្រាបនៃពហុកោណប្រេកង់កើននិងថយ ។

7. តារាងខាងក្រោម ជាចំនួនប្រជាជនស្លាប់និងរបួសទៅតាមអាយុក្រោយពីចប់សង្គ្រាម ។

| អាយុ | 0-5 | 5-15 | 15-35 | 35-45 | 45-55 | 55-70 | 70-85 | 85-100 |
|---|---|---|---|---|---|---|---|---|
| ប្រជាជនស្លាប់ | 1 | 104 | 65 | 45 | 70 | 135 | 195 | 210 |
| ប្រជាជនរបួស | 12 | 3010 | 3645 | 1700 | 1175 | 1800 | 2400 | 1170 |

ក. ចូរសង់អ៊ីស្តូក្រាមនៃទិន្នន័យប្រជាជនស្លាប់និងរបួស ។

ខ. ចូរបង្កើតតារាងប្រេកង់ ប្រេកង់កើននៃប្រជាជនស្លាប់និងរបួស ។

គ. ចូរកំណត់រកចំនួនប្រជាជនស្លាប់និងរបួស ។

ឃ. តើប្រជាជនដែលមានអាយុតិចជាង 35 ឆ្នាំស្លាប់ប៉ុន្មាននាក់ ? និងរបួសប៉ុន្មាននាក់ ?

មេរៀនទី

# 7 មធ្យមស្ថិតិ

**វត្ថុបំណង**

- គណនាមធ្យម មេដ្យាន និងម៉ូត ។
- គណនាមធ្យម មេដ្យាន និងម៉ូតតាមតារាងនៃប្រេកង់កើន ។

## 1. មធ្យម

*ឧទាហរណ៍ទី 1 :* គេកត់ត្រាចំនួនភ្ញៀវដែលបានចូលមកកាត់សក់ជារៀងរាល់ថ្ងៃ ហើយទទួលបានលទ្ធផលដូចខាងក្រោម ។

| ថ្ងៃ | ចន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ | អាទិត្យ |
|---|---|---|---|---|---|---|---|
| ចំនួនភ្ញៀវ | 18 | 12 | 30 | 26 | 38 | 42 | 48 |

យើងសង្កេតឃើញថា ភ្ញៀវដែលបានចូលមកកាត់សក់មានចំនួនមិនស្មើគ្នាទេ ។ បើគេយកចំនួនភ្ញៀវសរុបមកចែកឱ្យ 7 ថ្ងៃ

$$\frac{18+12+30+26+38+42+48}{7} = 30.5$$

គេបង្គត់ចំនួននោះដោយ 30 ក្នុងករណីនេះម្ចាស់ហាងតែងតែប្រាប់គេថាហាងខ្ញុំមានភ្ញៀវជាមធ្យមចំនួន 30 នាក់ គេតាង $\bar{x}$ ជាមធ្យមនៃទិន្នន័យ $\bar{x} = 30$ ។

*ឧទាហរណ៍ទី 2 :* គេស្រង់ចំនួនភ្ញៀវដែលបានជិះរថយន្តឈ្នួលចំនួន 30 ថ្ងៃ ដោយទទួលបានលទ្ធផលដូចខាងក្រោម ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 20 | 16 | 18 | 10 | 20 | 16 | 18 | 20 | 14 | 16 |
| 10 | 16 | 20 | 18 | 12 | 12 | 10 | 18 | 16 | 20 |
| 14 | 16 | 17 | 20 | 12 | 14 | 18 | 20 | 16 | 14 |

គេផ្គុំទិន្នន័យនីមួយៗ ទៅតាមចំនួនដងហៅថាប្រេកង់ គេបានតារាងខាងក្រោម

គេអាចគណនាចំនួនភ្ញៀវជាមធ្យមដែលបានជិះរថយន្ត

$\bar{x} = \frac{431}{30} = 14.36$

គេបង្គត់ចំនួន $\bar{x} = 14$

- បើគេតាង $x$ ជាចំនួនភ្ញៀវនោះ

$x_1 = 10$ , $x_2 = 12$ , ...

- បើគេតាង $f$ ជាចំនួនប្រេកង់នោះ

$f_1 = 3$ , $f_2 = 3$ , ...

- បើគេតាង $x f$ ជាផលគុណនោះ

$x_1 f_1 = 10 \times 3 = 30$

$x_2 f_2 = 12 \times 3 = 36$

| ចំនួនភ្ញៀវ $x$ | ប្រេកង់ $f$ | ផលគុណ $x f$ |
|---|---|---|
| 10 | 3 | 30 |
| 12 | 3 | 36 |
| 14 | 4 | 26 |
| 16 | 7 | 102 |
| 17 | 1 | 17 |
| 18 | 5 | 18 |
| 20 | 7 | 140 |
| សរុប | 30 | 431 |

ក្នុងករណីនេះ $\bar{x} = \frac{x_1 f_1 + x_2 f_2 + x_3 f_3 + x_4 f_4 + x_5 f_5 + x_6 f_6 + x_7 f_7}{f_1 + f_2 + f_3 + f_4 + f_5 + f_6 + f_7}$

$= \frac{30 + 36 + 26 + 102 + 17 + 18 + 140}{3 + 3 + 4 + 7 + 1 + 5 + 7} = 14.36$

***ជាទូទៅ :*** មធ្យមកំណត់ $\bar{x} = \frac{x_1 f_1 + x_2 f_2 + \ldots + x_n f_n}{f_1 + f_2 + \ldots + f_n}$

***លំហាត់គំរូទី 1 :*** សុខបានប្រឡងលើមុខវិជ្ជាទាំង 9 ដោយទទួលបានពិន្ទុមធ្យម 78 ។ ដោយដឹងថាពិន្ទុលំអិតទៅតាមមុខវិជ្ជារួមមាន 90 95 75 80 85 65 70 60 ហើយនៅសល់ពិន្ទុនៃមុខវិជ្ជាមានមួយទៀតដែលសុខពុំបានចាំ ។ ចូរកំណត់រកពិន្ទុដែលភ្លេចនោះ ។

***ចម្លើយ :*** តាង $x$ ជាពិន្ទុនៃមុខវិជ្ជាដែលភ្លេច

យើងបាន $\frac{90 + 95 + 75 + 80 + 85 + 65 + 70 + 60 + x}{9} = 78$

$\frac{620 + x}{9} = 78$ , $620 + x = 702$ , $x = 82$ ។

***លំហាត់គំរូទី 2 :*** គេឱ្យសិស្សពីរថ្នាក់ដែលមានចំនួនសិស្ស 25 នាក់ ស្មើគ្នាដើម្បីប្រឡងមុខវិជ្ជាដូចគ្នាដោយទទួលបានពិន្ទុដូចខាងក្រោម ។

ថ្នាក់ $A$

| ពិន្ទុ $x$ | ប្រេកង់ $f$ | $xf$ |
|---|---|---|
| 2 | 4 | 8 |
| 3 | 8 | 24 |
| 5 | 6 | 30 |
| 7 | 2 | 14 |
| 8 | 2 | 16 |
| 9 | 3 | 27 |
| សរុប | 25 | 119 |

ថ្នាក់ $B$

| ពិន្ទុ $x$ | ប្រេកង់ $f$ | $xf$ |
|---|---|---|
| 3 | 2 | 6 |
| 5 | 10 | 50 |
| 4 | 8 | 32 |
| 6 | 4 | 24 |
| 9 | 1 | 9 |
| សរុប | 25 | 121 |

ចូរប្រៀបធៀបមធ្យមពិន្ទុនៃថ្នាក់ទាំងពីរ ។

***ចម្លើយ :*** $\bar{X}_A = \frac{119}{25} = 4.76$ $\qquad \bar{X}_B = \frac{121}{25} = 4.84$

នាំឱ្យ $\bar{X}_B > \bar{X}_A$ បញ្ជាក់ថាពិន្ទុមធ្យមនៃថ្នាក់ $B$ ខ្ពស់ជាងថ្នាក់ $A$ ។

***ប្រតិបត្តិ :*** ចូរគណនាមធ្យមនៃតារាងទិន្នន័យខាងក្រោម ។

| $x$ | 0 | 1 | 2 | 3 | 4 |
|---|---|---|---|---|---|
| $y$ | 3 | 6 | 5 | 2 | 2 |

## 2. មេដ្យាន

មានករណីខ្លះ មធ្យមមិនត្រូវបានគេប្រើប្រាស់ដើម្បីតាងឱ្យទិន្នន័យទេ ។

***ឧទាហរណ៍ :*** ចំពោះទិន្នន័យ 4 2 5 2 6 16 4 20 6

គណនាមធ្យម $\bar{X} = \frac{4+2+5+2+6+16+4+20+6}{9} = 7.2$

បើគេរៀបតួនៃទិន្នន័យពីតូចទៅធំ

$$2 \quad 2 \quad 4 \quad 4 \quad 5 \quad 6 \quad 6 \quad \overset{\bar{X}}{\vdots} \quad 16 \quad 20$$

គេសង្កេតឃើញថា មានទិន្នន័យប្រាំពីរតួដែលតូចជាងមធ្យម $\bar{X}$ ហើយមានតែទិន្នន័យពីរតួប៉ុណ្ណោះដែលធំជាង $\bar{X}$ ក្នុងករណីនេះគេអាចជ្រើសរើសទិន្នន័យ 5 ដែលមានទីតាំងឋិតនៅកណ្តាលនៃទិន្នន័យ ដើម្បីធ្វើជាតំណាងហៅថា មេដ្យាន ។

គេតាងមេដ្យានដោយ $m_e$ , $m_e = 5$

តម្លៃ 5 ជាតួទី 5 ក្នុងចំណោមតួទាំង 9

ទីតាំងនេះបានដោយ $\frac{9+1}{2} = 5$

ដូចនេះ បើ $n$ ជាចំនួនតួនៃទិន្នន័យនោះមេដ្យានត្រូវឋិតនៅទីតាំង $\frac{n+1}{2}$ ។ មានករណីខ្លះគេក៏អាចកំណត់មេដ្យាននៃទិន្នន័យដែលមានចំនួនតួដូចជា : 4 4 5 7 8 9

មេដ្យានត្រូវឋិតនៅចន្លោះ 5 និង 7

ហេតុនេះ $m_e = \frac{5+7}{2} = 6$

***ជាទូទៅ :*** បើទិន្នន័យមួយមាន $n$ តួ មេដ្យាននៃទិន្នន័យមួយដែលបានរៀបតាមលំដាប់មានទីតាំងឋិតនៅតួទី $\frac{n+1}{2}$ ។

- បើ $n$ ជាចំនួនសេស មេដ្យានជាតម្លៃនៃតួកណ្តាល
- បើ $n$ ជាចំនួនគូ មេដ្យានជាមធ្យមនៃតម្លៃកណ្តាលទាំងពីរ

***លំហាត់គំរូទី 1 :*** តាមតារាងទិន្នន័យនៃឧទាហរណ៍ 2 រកមេដ្យាននៃចំនួនភ្ញៀវដែលបានជិះរថយន្ត ។

***ចម្លើយ :*** ដើម្បីរកមេដ្យានគេត្រូវកំណត់ទីតាំងរបស់វា ។ ដោយទិន្នន័យមានចំនួនតួ $n = 30$ ទីតាំងនៃមេដ្យានគឺ $\frac{30+1}{2} = 15.5$ មានន័យថាមេដ្យានត្រូវឋិតនៅចន្លោះតួទី 15 និងតួទី 16 ។

| ចំនួនភ្ញៀវ $x$ | ប្រេកង់ $f$ | $x f$ |
|---|---|---|
| 10 | 3 | 30 |
| 12 | 3 | 36 |
| 14 | 4 | 26 |
| 16 | 7 | 102 |
| 17 | 1 | 17 |
| 18 | 5 | 18 |
| 20 | 7 | 140 |
| សរុប | 30 | 431 |

តាមតារាង

តួទី $10 = 3+3+4$ ទើបតែស្មើនឹង 14

ដូចនេះ គេបន្តរកតួទី 15 និងតួទី 16

ឃើញថា $x_{15} = 16$ : $x_{16} = 16$

ដូចនេះមេដ្យាន $m_e = \frac{16+16}{2} = 16$ ។

***ប្រតិបត្តិ :*** ចូររកមេដ្យាននៃប្រាក់បៀវត្សរ៍ (ឯកតាគិតជាពាន់រៀល)

| *ប្រាក់បៀវត្សរ៍* | 200 | 300 | 350 | 700 | 840 | 950 |
|---|---|---|---|---|---|---|
| *ប្រេកង់* | 6 | 2 | 2 | 1 | 1 | 1 |

## ៣. ម៉ូត

***ឧទាហរណ៍ :*** ខាងក្រោមនេះជាចំនួនទូរទស្សន៍ ដែលបានលក់ដាច់តាមថ្ងៃនីមួយៗ ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1 | 3 | 3 | 3 | 4 | 4 | 1 | 2 | 2 | 2 |
| 5 | 4 | 4 | 2 | 2 | 2 | 2 | 1 | 4 | 4 |
| 3 | 2 | 3 | 2 | 2 | 3 | 2 | 3 | 2 | 3 |

គេផ្គុំទិន្នន័យនីមួយៗទៅតាមប្រេកង់រួច សង់តារាងប្រេកង់ ដើម្បីរកចំនួនទូរទស្សន៍ដែលបានលក់ជាមធ្យមក្នុងមួយថ្ងៃ ។ គេគណនា $\overline{X} = \frac{80}{30} = 2.6$ ដោយចំនួនទូរទស្សន៍ត្រូវតែជាចំនួនគត់ ។

| ចំនួនទូរទស្សន៍ $x$ | ប្រេកង់ $y$ | $xf$ |
|---|---|---|
| 1 | 3 | 3 |
| 2 | 12 | 24 |
| 3 | 8 | 24 |
| 4 | 6 | 24 |
| 5 | 1 | 5 |
| សរុប | 30 | 80 |

ដូចនេះគេមិនអាចយក $\overline{X} = 2.6$ តាងឱ្យទិន្នន័យបានទេ ក្នុងករណីនេះគេត្រូវជ្រើសរើសយកទិន្នន័យណាដែលមានប្រេកង់ធំជាងគេ ។ តាមតារាងនៃទិន្នន័យមួយថ្ងៃលក់បានទូរទស្សន៍ 2 គ្រឿងមានប្រេកង់ធំជាងគេ ហេតុនេះ 2 ជាតំណាងឱ្យទិន្នន័យហៅថា ម៉ូត ។

> ***ជាទូទៅ :*** នៅក្នុងទិន្នន័យមួយម៉ូតជាតម្លៃនៃទិន្នន័យដែលមានប្រេកង់ធំជាងគេ ។

***លំហាត់គំរូ :*** តើទិន្នន័យមួយណាដែលគួរប្រើមធ្យម មេដ្យាននិងម៉ូត ?

ក. ស្បែកជើងដែលលក់ដាច់ជាងគេមានទំហំលេខ $9\frac{1}{2}$

ខ. វិក្កយបត្រភ្លើងក្នុងមួយខែជាមធ្យម 150 000 រៀល

គ. ពាក់កណ្ដាលនៃបុគ្គលិកទទួលបានប្រាក់ខែ 420 000 រៀល

***ចម្លើយ :***

ក. គេប្រើម៉ូតមកតាងឱ្យទំហំលេខនៃស្បែកជើង $m_o = 9\frac{1}{2}$

ខ. គេប្រើមធ្យមមកតាងឱ្យការចំណាយលើថ្លៃភ្លើង $\overline{X} = 150\ 000$ រៀល

គ. គេប្រើមេដ្យានមកតាងឱ្យប្រាក់ខែបុគ្គលិក $m_e = 420\ 000$ រៀល

***ប្រតិបត្តិ :*** ចូររកមធ្យម មេដ្យាន និងម៉ូតនៃទិន្នន័យខាងក្រោម ។

10 8 13 12 7

## 4. ការកំណត់មធ្យមស្ថិតិតាមតារាងប្រេកង់កើន

***ឧទាហរណ៍ទី 1 :*** ខាងក្រោមនេះជាលទ្ធផលនៃពិន្ទុសិស្សមួយថ្នាក់

| ពិន្ទុ $x$ | ប្រេកង់ $f$ | $x f$ | ប្រេកង់កើន |
|---|---|---|---|
| 1 | 4 | 4 | 4 |
| 2 | 5 | 10 | 9 |
| 3 | 2 | 6 | 11 |
| 4 | 10 | 40 | 21 |
| 5 | 15 | 75 | 36 |
| 6 | 8 | 48 | 44 |
| 7 | 4 | 28 | 48 |
| 9 | 2 | 18 | 50 |
| សរុប | | 229 | |

តារាងនេះផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់ឱ្យគេគណនាមធ្យមស្ថិតិ

ការកំណត់មធ្យម : $\bar{x} = \dfrac{x_1 f_1 + x_2 f_2 + \ldots\ldots + x_n f_n}{f_1 + f_2 + \ldots\ldots + f_n}$

តាមជួរឈរទី 3 : ផលបូកនៃ $x f = 229$

តាមជួរឈរទី 4 : ផលបូកប្រេកង់ $f = 50$

$\bar{x} = \dfrac{229}{50} = 4.58$

ការកំណត់មេដ្យាន :

មេដ្យានមានទីតាំងឋិតនៅចំកណ្តាលនៃទិន្នន័យ ក្នុងករណីនេះគេអាចប្រើជួរឈរទី 4

មានន័យថា មេដ្យានឋិតនៅទីតាំង $\dfrac{50+1}{2} = 25.5$ តាមតារាងទីតាំងទី 21 ត្រូវនឹងពិន្ទុ 4

ដូចនេះទីតាំងទី 25.5 ត្រូវនឹងពិន្ទុ 5 , $m_e = 5$ ។

ការកំណត់ម៉ូត : ទិន្នន័យដែលមានប្រេកង់ធំជាងគេគឺ 5 ដូចនេះ $m_o = 5$ ។

***ឧទាហរណ៍ទី 2 :*** ខាងក្រោមនេះជាលទ្ធផលពិន្ទុនៃសិស្សមួយថ្នាក់

| ម៉ាសជា $kg$ | 30-40 | 40-50 | 50-60 | 60-70 | 70-80 | 80-90 | 90-100 |
|---|---|---|---|---|---|---|---|
| ប្រេកង់ | 2 | 6 | 5 | 10 | 8 | 6 | 3 |

- **ការកំណត់ម៉ូត :** ថ្នាក់ដែលមានប្រេកង់ធំជាថ្នាក់ 60-70 មានន័យថាមនុស្សភាគច្រើនមានម៉ាស ចន្លោះពី 60 ទៅ $70kg$ ។
- **ការកំណត់មធ្យម $\bar{x}$ :** គេត្រូវរកតម្លៃដែលតាងឱ្យថ្នាក់នីមួយៗ ជាមធ្យមនៃតួចុងទាំងពីរនៃថ្នាក់ ហៅថា ផ្ចិតនៃថ្នាក់ ។

ផ្ចិតនៃថ្នាក់ទី 1 : $\frac{30+40}{2} = 35$ , ផ្ចិតនៃថ្នាក់ទី 2 : $\frac{40+50}{2} = 45$ $\bar{X} = \frac{2\ 660}{40} = 66.5$

ម្យ៉ាងវិញទៀត គេក៏ត្រូវសង់ប្រេកង់កើន ដើម្បីងាយស្រួលក្នុងការកំណត់មេដ្យាន

| ថ្នាក់នៃម៉ាស | ប្រេកង់ $f$ | ផ្ចិតនៃថ្នាក់ $x$ | $xf$ | ប្រេកង់កើន |
|---|---|---|---|---|
| 30-40 | 2 | 35 | 70 | 2 |
| 40-50 | 6 | 45 | 270 | 8 |
| 50-60 | 5 | 55 | 275 | 13 |
| 60-70 | 10 | 65 | 650 | 23 |
| 70-80 | 8 | 75 | 600 | 31 |
| 80-90 | 6 | 85 | 510 | 37 |
| 90-100 | 3 | 95 | 285 | 40 |
| | | | 2660 | |

- **ការកំណត់មេដ្យាន :**

ប្រើជួរឈរទី 5 : មេដ្យានមានទីតាំង $\frac{40+1}{2} = 20.5$ ហេតុនេះមេដ្យានចំថ្នាក់ 60-70

***លំហាត់គំរូ :*** ក្នុងការបំពេញសំណួរ សិស្សខ្លះអាចបញ្ចប់លឿន ហើយខ្លះទៀតយឺត ។ ខាងក្រោមនេះជារយៈពេលគិតជានាទី $x$ ដែលសិស្សបានបំពេញសំណួរ

| ថ្នាក់នៃពេល (គិតជានាទី) | 10-15 | 15-20 | 20-25 | 25-30 | 30-35 |
|---|---|---|---|---|---|
| ប្រេកង់ $f$ | 2 | 5 | 10 | 12 | 3 |

ចូរកំណត់ មធ្យម មេដ្យាន និងម៉ូត ។

***ចម្លើយ :*** តាមតារាងនេះអ្នកដែលអាចប្រើពេលពី 10 ហើយតិចជាង 15 នាទី ដើម្បីបញ្ចប់សំណួរមានតែ 2 នាក់ ។

រកផ្ចិតនៃថ្នាក់នីមួយៗ

$\frac{10+15}{2} = 12.5$ , $\frac{15+20}{2} = 17.5$ , $\frac{20+25}{2} = 22.5$ , $\frac{25+30}{2} = 27.5$ , $\frac{30+35}{2} = 32.5$

| ថ្នាក់នៃពេល | ប្រេកង់ $f$ | ផ្ចិតនៃថ្នាក់ $x$ | $xf$ | ប្រេកង់កើន |
|---|---|---|---|---|
| 10-15 | 2 | 12.5 | 25 | 2 |
| 15-20 | 5 | 17.5 | 87.5 | 7 |
| 20-25 | 10 | 22.5 | 225 | 17 |
| 25-30 | 12 | 27.5 | 330 | 29 |
| 30-35 | 3 | 32.5 | 97.5 | 32 |
| | | | 765 | |

ការកំណត់មធ្យម : $\bar{x} = \frac{765}{32} = 23.9$

ការកំណត់ម៉ូត : 25-30 ជាម៉ូត ព្រោះមានប្រេកង់ 12 ធំជាងគេ

ការកំណត់មេដ្យាន : មេដ្យានមានទីតាំង $\frac{32+1}{2} = 16.5$

ដូចនេះ ថ្នាក់ 20-25 ជាមេដ្យាន

***ប្រតិបត្តិ :*** ចូរគណនាមធ្យម មេដ្យាន និងម៉ូតនៃទិន្នន័យ ។

| *ថ្នាក់* | 21-28 | 28-35 | 35-42 | 42-49 | 49-56 | 56-63 | 63-70 |
|---|---|---|---|---|---|---|---|
| *ប្រេកង់* | 3 | 7 | 12 | 15 | 12 | 7 | 3 |

## ? លំហាត់

1. គេធ្វើការសិក្សាលើចំនួនសិស្សទៅតាមកម្រិតថ្នាក់ ហើយទទួលបានទិន្នន័យដូចខាងក្រោម ។

| ថ្នាក់ | ចំនួនសិស្ស |
|---|---|
| ថ្នាក់មត្តេយ្យ | 20 20 21 21 |
| ថ្នាក់ទី 1 | 22 23 22 23 |
| ថ្នាក់ទី 2 | 20 19 21 20 |
| ថ្នាក់ទី 3 | 22 23 23 23 |
| ថ្នាក់ទី 4 | 27 27 26 |
| ថ្នាក់ទី 5 | 20 19 22 20 |
| ថ្នាក់ទី 6 | 23 24 24 24 |

ចូររកមធ្យម មេដ្យាន និងម៉ូតនៃចំនួនសិស្សក្នុងមួយថ្នាក់ ។

2. មនុស្សមួយក្រុមសាកល្បងហាត់ប្រាណដើម្បីបញ្ចុះម៉ាសគិតជា $kg$ ហើយទទួលបានលទ្ធផលដូចខាងក្រោម ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| 4 | 6 | 2 | 10 | 8 | 5 | 1 | 4 |
| 8 | 10 | 5 | 4 | 3 | 7 | 2 | 4 |
| 6 | 8 | 7 | 4 | 5 | 3 | 6 | 4 |

គណនាមធ្យម មេដ្យាន និងម៉ូត ។

3. ចូរគណនាមធ្យម មេដ្យាន និងម៉ូតតាមទិន្នន័យខាងក្រោម ។

| $x$ | 16 | 18 | 19 | 20 | 21 | 30 |
|---|---|---|---|---|---|---|
| $f$ | 1 | 4 | 9 | 3 | 2 | 1 |

4. ចូរគណនាមធ្យម មេដ្យាន និងម៉ូតតាមទិន្នន័យខាងក្រោម ។

ក.




ខ.




គ.




5. ទិន្នន័យខាងក្រោមជាចំនួនកូនរបស់បុគ្គលិកនៃរោងចក្រមួយ

0 0 0 1 3 3 1 1 1 3 0 0 4 3 3 1 1 0 5 6 2 2
3 2 2 4 1 6 5 6 0 1 1 2 3 5 1 3 2 1 1 1 1 2
1 3 3 4 1 1 0 3 1 1 1 3 3 6 0 0 3 4 1 3 2 3
0 2 4 1 3 4 1 5 6 3 ។

ក. ចូរបង្កើតតារាងប្រេកង់ ប្រេកង់ធៀបកើនជាភាគរយ ។

ខ. ចូរគណនាមេដ្យាន ។

6. តារាងខាងក្រោមនេះ ជាបំណែងចែកសីតុណ្ហភាពតាមខែនីមួយៗ ។

| ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| $^oC$ | $14^o$ | $14^o$ | $23^o$ | $32^o$ | $35^o$ | $30^o$ | $30^o$ | $29^o$ | $25^o$ | $22^o$ | $18^o$ | $15^o$ |

ក. ចូរគណនាម៉ូត ។

ខ. ចូរគណនាសីតុណ្ហភាពមធ្យម ។

7. នៅឆមាសទី 1 សុខប្រឡង 8 មុខវិជ្ជាទទួលបានមធ្យមភាគពិន្ទុ 89 ។ តើនៅឆមាសទី 2 នេះសុខត្រូវប្រឹងបង្កើនពិន្ទុប៉ុន្មានទៀតទើបធានាឱ្យមធ្យមភាគពិន្ទុរបស់គេស្មើនឹង 90 ។

8. ក្នុងការពិសោធបណ្តុះកូនប៉េងប៉ោះ ដោយប្រើជីតិមីអស់រយៈពេល មួយសប្តាហ៍គេទទួលបានលទ្ធផលនៃបម្រែបម្រួល កម្ពស់កូនប៉េងប៉ោះដូចតារាងខាងក្រោម ។

| កម្ពស់ (*mm*) | 0-5 | 5-10 | 10-15 | 15-20 | 20-25 | 25-30 | 30-35 |
|---|---|---|---|---|---|---|---|
| ចំនួនកូនប៉េងបោះ | 3 | 15 | 72 | 15 | 91 | 35 | 8 |

ក. ចូរបង្កើតតារាងដែលបង្ហាញពីប្រេកង់ ប្រេកង់កើន និងថយ ។

ខ. ចូររកចំនួនកូនប៉េងប៉ោះដែលមានកម្ពស់យ៉ាងតិច 20*mm* និង 35*mm* ។

គ. ចូររកម៉ូត មេដ្យាន និងកម្ពស់មធ្យមនៃកូនប៉េងបោះ ។ ចូរប្រៀបធៀបមេដ្យាននិងមធ្យម ។

9. តារាងខាងក្រោមជាបរិមាណទឹកដោះគោម្សៅ ដែលទារកបៅអស់ក្នុងមួយថ្ងៃ ។

| ទឹកដោះគោម្សៅគិតជា *g* | 40 – 45 | 45 – 50 | 50 – 55 | 55 – 60 | 60 – 65 | 65 – 70 | 70 – 75 | 75 – 80 | 80 – 85 | 85 – 90 |
|---|---|---|---|---|---|---|---|---|---|---|
| ចំនួនក្មេង | 8 | 11 | 31 | 61 | 54 | 58 | 43 | 25 | 17 | 7 |

ក. ចូររកចំនួនទារកដែលបៅទឹកដោះគោក្នុងមួយថ្ងៃ ។

ខ. តើក្នុងមួយថ្ងៃគិតជាមធ្យមទារកម្នាក់បៅទឹកដោះគោម្សៅអស់ប៉ុន្មានក្រាម ?

គ. ចូរគណនាម៉ូត ។

ឃ. ចូរគណនាមេដ្យាន រួចបកស្រាយតាមក្រាប ។

10. ក្រោយពីវាស់កម្ពស់សិស្សនៃវិទ្យាល័យមួយ គេបានលទ្ធផលដូចតារាងខាងក្រោម ។

| កម្ពស់ *cm* | 145 – 150 | 150 – 155 | 155 – 160 | 160 – 165 | 165 – 170 | 170 – 175 | 175 – 180 |
|---|---|---|---|---|---|---|---|
| ចំនួនសិស្ស | 31 | 95 | 131 | 272 | 120 | 77 | 48 |

ក. ចូរបង្កើតតារាងប្រេកង់ ប្រេកង់កើន ។

ខ. ចូរសង់ក្រាប នៃពហុកោណប្រេកង់កើន ។

គ. ចូរគណនាមេដ្យាន រួចបកស្រាយនៅលើក្រាប ។

មេរៀនទី

# 8 ប្រូបាប

**វត្ថុបំណង**

- ❑ កំណត់ប្រូបាបនៃព្រឹត្តិការណ៍ដែលពិសោធន៍មួយដង
- ❑ កំណត់ប្រូបាបនៃព្រឹត្តិការណ៍បំពេញ
- ❑ កំណត់ប្រូបាបនៃព្រឹត្តិការណ៍ដែលពិសោធន៍ច្រើនដង ។

## 1. ប្រូបាបនៃព្រឹត្តិការណ៍

*ឧទាហរណ៍ :* បើគេពិសោធចាប់យកអក្សរមួយចេញពីពាក្យ *BANANA* តើលទ្ធផលដែលអាចកើតមានឡើងមានប៉ុន្មានរបៀប ?

ក្នុងពាក្យ *BANANA* មានអក្សរ $B$ តែមួយគឺ $B$ មានអក្សរ $A$ ដូចគ្នាបីគឺ $A$ , $A$ , $A$ មានអក្សរ $N$ ពីរគឺ $N$ , $N$



*BANANA*

ហេតុនេះលទ្ធផលដែលអាចកើតមានឡើងគឺ $\{B, A, A, A, N, N\}$

- លទ្ធផលដែលអាចកើតមានឡើង $\{B, A, A, A, N, N\}$ ហៅថាព្រឹត្តិការណ៍អាច ព្រឹត្តិការណ៍អាចមាន 6 ករណី នោះហៅថាចំនួនករណីអាច
- បើគេប្រាថ្នាចាប់បានអក្សរ $A$ នោះការចាប់បានអក្សរ $A$ ហៅព្រឹត្តិការណ៍ស្រប ព្រឹត្តិការណ៍ស្របមាន 3 ករណី នោះ 3 ហៅថាចំនួនករណីស្រប

គណនាផលធៀបរវាងចំនួនករណីស្របនឹងចំនួនករណីអាច

$$\frac{\text{ចំនួនករណីស្រប}}{\text{ចំនួនករណីអាច}} = \frac{3}{6} = \frac{1}{2} = 0.5 \text{ ឬ } 50\%$$

ទូរលេខនេះបកស្រាយថាគេនឹងមានក្ដីសង្ឃឹម 50% ក្នុងការចាប់បានអក្សរ $A$ ។ តទៅគេប្រើអក្សរ $P$ តាងឱ្យប្រូបាបនៃព្រឹត្តិការណ៍មួយ ។ ប្រូបាបដែលចាប់បានអក្សរ $A$ គណនាដោយ

$$P = \frac{\text{ចំនួនករណីស្រប}}{\text{ចំនួនករណីអាច}} = \frac{3}{6} = \frac{1}{2} = 0.5 \text{ ឬ } 50\%$$

*ជាទូទៅ :* ប្រូបាបនៃព្រឹត្តិការណ៍មួយកំណត់ដោយ

$$P = \frac{\text{ចំនួនករណីស្រប}}{\text{ចំនួនករណីអាច}} = \frac{n(A)}{n(S)}$$

*លំហាត់គំរូទី 1 :* ថង់មួយមានឃ្លីបួនដែលបង់អក្សរ $a$ , $A$ , $b$ , $B$ ។គេចាប់យកឃ្លីម្តងពីរចេញពីថង់ ។




ចូររៀបរាប់ព្រឹត្តិការណ៍ដែលអាចកើតមានឡើងរួចគណនាប្រូបាបដែលចាប់បានឃ្លីពីរដែលមានអក្សរតូចមួយនិងអក្សរធំមួយ ។

*ចម្លើយ :*

បើគេផ្សំគូអក្សរម្តងពីរគេបានព្រឹត្តិការណ៍អាចដូចខាងក្រោម

$\{aA \ , \ ab \ , \ aB \ , \ Ab \ , \ AB \ , \ bB\}$ មាន 6 ករណី ។

*សំគាល់ :* ឃ្លីពីរ Ⓐ ⓐ និង ⓐ Ⓐ ជាព្រឹត្តិការណ៍តែមួយព្រោះគេចាប់ឃ្លីម្តងពីរមានន័យថាពុំគិតឃ្លីមួយណាចេញមុនឬក្រោយនោះទេ ។

ព្រឹត្តិការណ៍ដែលចាប់បានអក្សរតូច 1 និងអក្សរធំមួយ

$\{aA \ , \ aB \ , \ Ad \ , \ bB\}$ មាន 4 ករណី

ប្រូបាបដែលចាប់បានឃ្លីពីរដែលមានអក្សរតូចមួយនិងអក្សរធំមួយ

$$P = \frac{\text{ចំនួនករណីស្រប}}{\text{ចំនួនករណីអាច}} = \frac{4}{6} = \frac{2}{3} \text{ ឬ } 66\,\%$$

ផលធៀបនេះបកស្រាយថា គេនឹងមានក្តីសង្ឃឹម 66% ក្នុងការសម្រេចព្រឹត្តិការណ៍នេះ ។

*លំហាត់គំរូទី 2 :* គេធ្វើតេស្តលើអំពូលភ្លើង 500 គ្រឿង ហើយបានរកឃើញមានអំពូល 4 ដែលខូច ។



1. ចូររកប្រូបាបនៃការរកឃើញអំពូលភ្លើងខូចនេះ ។
2. បើក្រុមហ៊ុនត្រូវលក់អំពូលភ្លើងចំនួន 8500 គ្រឿង តើត្រូវត្រៀមអំពូលប៉ុន្មាន ដើម្បីត្រៀមទុកថែមឱ្យអតិថិជន ?

*ចម្លើយ :*

1. ប្រូបាបដែលគេស្ដួឃើញអំពូលខូច

- ចំនួនករណីអាចជាចំនួនអំពូលដែលយកមកសាកត្រូវជា 500 អំពូល
- ចំនួនករណីស្រួបជាចំនួនអំពូលដែលខូចត្រូវជា 4 អំពូល

$P = \dfrac{\text{ចំនួនករណីស្រប}}{\text{ចំនួនករណីអាច}} = \dfrac{4}{500} = 0.08$ ឬ $0.8\%$

2. ចំនួនអំពូលដែលត្រូវថែម

បើគេលក់ឱ្យអតិថិជនចំនួន 8 500 អំពូលនោះត្រូវគ្រោងទុកថានឹងមានចំនួនអំពូលដែលត្រូវខូច

$0.8\% \times 8\ 500 = 68$

ដូចនេះ គេត្រូវថែមឱ្យ 68 អំពូល ។

*លំហាត់គំរូទី3 :* គេស្ទាបស្ទង់ចំណង់ចំណូលចិត្តនៃភ្ញៀវទេសចរទៅតាមកំរិតអាយុចំពោះរមណីយដ្ឋានបីសំខាន់ៗរួមមាន ប្រាសាទអង្គរវត្ត ឆ្នេរសមុទ្រ តំបន់ជនជាតិ ហើយទទួលបានលទ្ធផលខាងក្រោម ។

1. ចូររកប្រូបាបអ្នកដែលមានអាយុក្រោម 30 ឆ្នាំដែលចូលចិត្តដើរកំសាន្តនៅឆ្នេរសមុទ្រ ។
2. ចូរកប្រូបាបដែលអ្នកមានអាយុ 30 ឆ្នាំ ឬ លើសពី 30 ឆ្នាំដែលចូលចិត្តទៅកំសាន្តនៅអង្គរវត្ត ឬតំបន់ជនជាតិ ។

| អាយុ$X$ | អង្គរវត្ត | ឆ្នេរសមុទ្រ | តំបន់ជនជាតិ |
|---|---|---|---|
| $x < 30$ | 46 | 92 | 5 |
| $30 \le x < 50$ | 72 | 61 | 34 |
| $50 \le x$ | 67 | 20 | 48 |

*ចម្លើយ :*

1. គេត្រូវស្គាល់ចំនួនករណីអាចនិងចំនួនករណីស្រប

ព្រឹត្តិការណ៍អាច ជាមនុស្សដែលមានអាយុក្រោម 30 ឆ្នាំ

ចំនួនករណីអាច $= 46 + 92 + 5 = 143$

ព្រឹត្តិការណ៍ស្រប ជាមនុស្សចូលចិត្តទៅកំសាន្តនៅឆ្នេរសមុទ្រហើយស្ថិតក្នុងវ័យក្រោម 30 ឆ្នាំ

ចំនួនករណីស្រប $= 92$

$P = \dfrac{92}{143} = 0.64$ ឬ $64\%$ ។

2. ព្រឹត្តិការណ៍អាច ជាមនុស្សដែលមានអាយុចាប់ពី 30 ឆ្នាំឡើង

ចំនួនករណីអាច $72+61+34+67+20+48 = 302$

ព្រឹត្តិការណ៍ស្រប ជាមនុស្សដែលចូលចិត្តទៅកំសាន្តនៅអង្គរវត្ត ឬនៅតំបន់ជនជាតិដែលឋិតក្នុងវ័យនោះ

ចំនួនករណីស្រប $= 72+67+34+48 = 221$

$P = \frac{221}{302} = 0.73$ ឬ 73% ។

*លំហាត់គំរូទី 4 :* ថង់មួយមានឃ្លីពណ៌សនិងពណ៌ខ្មៅសរុប 15 គ្រាប់ ។ គេឱ្យសិស្សចាប់យកឃ្លីម្តងមួយចេញពីថង់ហើយកត់ត្រាលទ្ធផលដែលចេញឃ្លីខ្មៅនៅលើក្តារខៀន ។ ឃ្លីដែលចាប់បានហើយត្រូវដាក់ចូលក្នុងថង់វិញមុននឹងបន្តចាប់ឃ្លីជាលើកទី 2 រហូតដល់គ្រប់ 100 ដង ។ គេឃើញឃ្លីខ្មៅចេញ 40 ដងក្នុងការចាប់ឃ្លី 100 ដង ។ ចូររកចំនួនឃ្លីពណ៌ខ្មៅនិងពណ៌ស ។

*ចម្លើយ :*



តាង $x$ ជាចំនួនឃ្លីពណ៌ខ្មៅបើក្នុងថង់មានឃ្លីសរុប 15 នោះប្រូបាបដែលចាប់បានឃ្លីខ្មៅ $P = \frac{x}{15}$

ម្យ៉ាងវិញទៀត $\frac{40}{100}$ គឺជាប្រូបាបនៃការចាប់បានឃ្លីពណ៌ខ្មៅ

យើងបាន$\frac{x}{15} = \frac{40}{100}$ , $x = 6$ ចំនួនឃ្លីពណ៌ស $15-6 = 9$

*សំគាល់ :* ក្នុងពិសោធន៍ 100 ដង ចំនួនឃ្លីពណ៌ខ្មៅដែលចាប់បានអាចតិចជាង ឬច្រើនជាង 40 ដងបន្តិចបន្តួច ។

- ករណីចាប់បានឃ្លីខ្មៅ 38 ដង យើងបាន $\frac{x}{15} = \frac{38}{100}$ , $x = 5.7$ ដោយ $x$ ជាចំនួនគត់នោះគេអាចបង្គត់ចំនួន $x = 6$
- ករណីចាប់បានឃ្លីខ្មៅ 41 យើងបាន $\frac{x}{15} = \frac{41}{100}$ , $x = 6.15$ គេអាចបង្គត់ចំនួន $x = 6$

*សន្និដ្ឋាន :* ឱ្យតែដឹងចំនួនឃ្លីសរុប គេអាចដឹងចំនួនឃ្លីនៃពណ៌នីមួយៗដោយពិសោធចាប់ឃ្លីចេញពីថង់ច្រើនដង ។



*ប្រតិបត្តិ :* ថង់មួយមានឃ្លីពណ៌ខ្មៅ 4 និងឃ្លីពណ៌ស 2

1. បើគេឱ្យឈ្មោះ ក ចាប់យកឃ្លី 1 ពីថង់ ចូររកប្រូបាបដែលឈ្មោះ ក ចាប់បានឃ្លីពណ៌ខ្មៅ ។
2. ឧបមាថាឈ្មោះ ក ចាប់បានឃ្លីខ្មៅ ។ ដោយមិនដាក់ឃ្លីនោះចូលថង់វិញដោយឱ្យឈ្មោះ ខ បន្តចាប់យកឃ្លីមួយចេញពីថង់ ។ ចូររកប្រូបាបដែលចាប់បានឃ្លីពណ៌ខ្មៅ ។

## 2. ប្រូបាបនៃព្រឹត្តិការណ៍បំពេញ



*ឧទាហរណ៍ទី 1* : កាក់មួយដែលម្ខាងជាអក្សរ $H$ និងម្ខាងទៀតជាអក្សរ $T$ ។ បើគេពិសោធបោះកាក់នោះព្រឹត្តិការណ៍ដែលអាចកើតមានឡើងគឺ $\{H, T\}$

បើ $H$ ជាព្រឹត្តិការណ៍ស្រប នោះ $T$ ជាព្រឹត្តិការណ៍បំពេញនៃ $H$ ព្រោះមានតែព្រឹត្តិការណ៍ពីរ $T$ និង $H$ ។

ប្រូបាបនៃព្រឹត្តិការណ៍ស្របតាងដោយ $P = \frac{1}{2}$

ប្រូបាបនៃព្រឹត្តិការណ៍បំពេញតាងដោយ $P' = \frac{1}{2}$

យើងបាន $P + P' = \frac{1}{2} + \frac{1}{2} = 1$ ។




*ឧទាហរណ៍ទី 2* : ថាសមួយមានបីចំណែកប៉ុនគ្នាកំណត់ដោយអក្សរ $B, A, A$ បន្ទាប់ពីបង្វិលថាសនោះឱ្យវិលគេប្រើព្រួញគប់លើផ្ទៃថាស ។ បើគប់បានអក្សរ $B$ ជាព្រឹត្តិការណ៍ស្របនោះព្រឹត្តិការណ៍បំពេញគឺជាព្រឹត្តិការណ៍ដែលគប់បានអក្សរ $A$ ។

ប្រូបាបដែលគប់បានអក្សរ $B$ តាងដោយ $P = 1/3$

ប្រូបាបគប់បានអក្សរ $A$ តាងដោយ $P' = \frac{2}{3}$ យើងបាន $P + P' = \frac{1}{2} + \frac{2}{3} = 1$ ។

| |
|---|
| *ជាទូទៅ :* បើ $P'$ ជាប្រូបាបបំពេញនៃ $P$ នោះ $P + P' = 1$ ។ |

***លំហាត់គំរូទី 1 :*** គេបោះកាក់ម្តងពីរ ចូររកប្រូបាបដែលបោះបានអក្សរពីរផ្សេងគ្នារួចទាញរកប្រូបាបដែលបោះបានអក្សរពីរដូចគ្នា ។




***ចម្លើយ :***

បើគេបោះកាក់ម្តងពីរនោះព្រឹត្តិការណ៍ដែលអាចកើតមានឡើងមាន

$\{HH, TT, HT, TH\}$

ប្រូបាបដែលបោះបានអក្សរពីរផ្សេងគ្នា

$P = \frac{2}{4} = \frac{1}{2}$

បើ $P'$ ជាប្រូបាបដែលចេញអក្សរពីរដូចគ្នា

$P' + P = 1\ ,\ P' = 1 - P = 1 - \frac{1}{2} = \frac{1}{2}$ (ព្រោះ $P'$ បំពេញនៃ $P$ )

***លំហាត់គំរូទី 2 :*** តាមលំហាត់គំរូ 1 នៃទំព័រទី 86 រកប្រូបាបដែលចាប់បានឃ្លីដែលមានអក្សរតូចមួយយ៉ាងតិច ។

***ចម្លើយ :***

ព្រឹត្តិការណ៍អាច $\{aA, ab, aB, Ab, AB, bB\}$

តាង $P$ ជាប្រូបាបដែលចាប់បានអក្សរធំទាំងពីរ $P = \frac{1}{6}$

តាង $P'$ ជាប្រូបាបដែលចាប់បានអក្សរតូចមួយយ៉ាងតិច : $P'$ និង $P$ ជាប្រូបាបបំពេញគ្នា

$P' + P = 1\ ,\ P' = 1 - P = 1 - \frac{1}{6} = \frac{5}{6}$ ។

***ប្រតិបត្តិ :***

ក្រុមហ៊ុនមួយមានបុគ្គលិកចំនួន 250 នាក់ ។ គេដឹងថាអ្នកដែលធ្វើដំណើរដោយរថយន្តផ្ទាល់ខ្លួនមានចំនួន 50 នាក់ ។ រកប្រូបាបដែលធ្វើដំណើរដោយមធ្យោបាយដទៃទៀត ។

## 3. ប្រូបាបនៃព្រឹត្តិការណ៍ដែលពិសោធច្រើនដង

***ឧទាហរណ៍ទី 1 :*** បើគេពិសោធបោះកាក់មួយដងបន្ទាប់មកបោះពីរដងរួចបោះបីដង ព្រឹត្តិការណ៍ដែលអាចកើតមានឡើងកំណត់ដោយ

- ករណីបោះកាក់មួយដង

ព្រឹត្តិការណ៍អាច $\{T, H\}$

- ករណីបោះកាក់ពីរដង ព្រឹត្តិការណ៍អាចកំណត់ដោយ




ព្រឹត្តិការណ៍អាចមាន 4 ករណី

$\{TT, HT, HT, HH\}$

$HT$ លើកទី 1 បោះបាន $H$ ហើយលើកទី 2 បោះបាន $T$

$TH$ លើកទី 1 បោះបាន $T$ ហើយលើកទី 2 បោះបាន $H$

- ករណីបោះកាក់បីដង ព្រឹត្តិការណ៍អាចកំណត់ដោយ




ព្រឹត្តិការណ៍អាចមាន 8 ករណី

$\{TTT, TTH, THT, THH, HTT, HTH, HHT, HHH\}$

*ឧទាហរណ៍ទី 2 :* គេបោះគ្រាប់ឡុកឡាក់ពីរដង ព្រឹត្តិការណ៍អាចកំណត់ដូចខាងក្រោម ។




ព្រឹត្តិការណ៍អាចរួមមាន 36 ករណី

(1 , 1)(1 , 2)(1 , 3)(1 , 4)(1 , 5)(1 , 6)

(2 , 1)(2 , 2)(2 , 3)(2 , 4)(2 , 5)(2 , 6)

(3 , 1)(3 , 2)(3 , 3)(3 , 4)(3 , 5)(3 , 6)

(4 , 1)(4 , 2)(4 , 3)(4 , 4)(4 , 5)(4 , 6)

(5 , 1)(5 , 2)(5 , 3)(5 , 4)(5 , 5)(5 , 6)

(6 , 1)(6 , 2)(6 , 3)(6 , 4)(6 , 5)(6 , 6)

*លំហាត់គំរូទី 1 :*

គេបោះកាក់មួយដង ចូររកប្រូបាបដែលបោះបានអក្សរ $T$ ។

ក្នុងករណីបោះកាក់ពីរដង ចូររកប្រូបាបដែលបោះបានអក្សរ $TT$ ។

ក្នុងករណីបោះកាក់បីដង ចូររកប្រូបាបដែលបោះបានអក្សរ $TTT$ ។

តាមលំនាំនេះ ចូររកប្រូបាបដែលបោះបានអក្សរ $TTTT$ ។

*ចម្លើយ :*

ករណីបោះកាក់មួយដង ព្រឹត្តិការណ៍អាច $\{T, H\}$

ប្រូបាបដែលបោះបានអក្សរ $T$ គឺ $P = \frac{1}{2}$

ករណីបោះកាក់ពីរដង ព្រឹត្តិការណ៍អាច $\{TT, TH, HT, HH\}$

ប្រូបាបដែលបោះបានអក្សរ $TT$ គឺ $P = \frac{1}{4}$

ករណីបោះកាក់បីដង ព្រឹត្តិការណ៍អាច $\{TTT, TTH, THT, THH, HTT, HTH, HHT, HHH\}$

ប្រូបាបដែលបោះបានអក្សរ $TTT$ គឺ $P = \frac{1}{8}$

រកប្រូបាបដែលបោះបានអក្សរ $TTTT$ , $P(T) = \frac{1}{2}$ , $P(TT) = \frac{1}{4} = \frac{1}{2^2}$ $P(TTT) = \frac{1}{8} = \frac{1}{2^3}$

ដូចនេះ $P(TTTT) = \frac{1}{2^4} = \frac{1}{16}$ ។

*លំហាត់គំរូទី 2 :*

គ្រួសារមួយចង់បានបុត្រតាមលំដាប់លំដោយ ដូច $BGB$ ($B$ ជាប្រុសហើយ $G$ ជាស្រី) ។ តើគេអាចមានក្តីសង្ឃឹមប៉ុន្មានភាគរយ ?

*ចម្លើយ :*







ព្រឹត្តិការណ៍អាច $BGG, BGB, BBG, BBB, GGG, GGB, GBG, GBB$

ប្រូបាប $P(BGB) = \frac{1}{8}$

*ប្រតិបត្តិ :* គេបោះគ្រាប់ឡុកឡាក់មួយពីរដង

1. ចូររកប្រូបាបដែលចេញលេខដូចគ្នា ។
2. ចូររកប្រូបាបដែលផលបូកគ្រាប់ទាំងពីរស្មើនឹង 10 ។

## លំហាត់

1. គេចាប់យកអក្សរមួយនៃពាក្យ *PHNOM PENH* ដោយចៃដន្យ ។
   ចូររកប្រូបាបដែលចាប់បាន
   ក. អក្សរ *P*  ខ. អក្សរ *H*  គ. អក្សរ *O* ឬ *M*  ឃ. អក្សរ *P* ឬ *N* ។
2. សុខនិយាយថា "ខ្ញុំកំពុងនឹករកចំនួនសេសមួយដែលឋិតក្នុងចន្លោះពី 1 ដល់ 21" ។ សៅនិយាយថា "ខ្ញុំក៏កំពុងនឹករកចំនួនគូមួយដែលឋិតក្នុងចន្លោះពី 1 ដល់ 21 ដែរ" ។ តើប្រូបាបនៃចំនួនដែលសុខនិងសៅកំពុងនឹករកស្មើគ្នា ឬទេ ?
3. ចូររកប្រូបាបនៃគ្រាប់ឡុកឡាក់ដែលចេញលេខ 1 ដល់លេខ 4 ។
4. ក្នុងវិញ្ញាសាគប់ព្រួញមួយ តើប្រូបាបដែលគប់លើផ្ទៃឆ្នូតស្មើនឹងផ្ទៃមិនឆ្នូត ឬទេ ?



5. ការអង្កេតលើមធ្យោបាយធ្វើដំណើររវាងអ្នកក្នុងក្រុងនិងអ្នករស់នៅជាយក្រុងទទួលបានទិន្នន័យដូចខាងក្រោម ។

| | អ្នកនៅក្នុងក្រុង | អ្នកនៅជាយក្រុង | សរុប |
|---|---|---|---|
| រថយន្ត | 182 | 52 | 234 |
| ម៉ូតូ | 254 | 338 | 592 |

ក. ចូររកប្រូបាបនៃអ្នកធ្វើដំណើរដោយម៉ូតូ ។
ខ. ចូររកប្រូបាបនៃអ្នកធ្វើដំណើរដោយរថយន្ត ។
គ. បើគេអញ្ជើញភ្ញៀវ 1200 នាក់ដើម្បីចូលរួមក្នុងពិធីផ្សព្វផ្សាយពាណិជ្ជកម្មក្នុងនោះភ្ញៀវ 760 នាក់ជាអ្នករស់នៅក្នុងក្រុងហើយភ្ញៀវ 440 ជាអ្នករស់នៅជាយក្រុង ។ តើគេត្រូវត្រៀមចំណតរថយន្តប៉ុន្មានកន្លែង ?

6. ការស្ទាបស្ទង់រកសំឡេងគាំទ្រដល់បេក្ខជន 3 នាក់ $A, B, C$ ដោយទទួលបានលទ្ធផលដូចខាងក្រោម ។

| | គាំទ្រ | មិនគាំទ្រ | គ្មានយោបល់ | សរុប |
|---|---|---|---|---|
| $A$ | 1420 | 74 | 182 | 1676 |
| $B$ | 846 | 26 | 122 | 994 |
| $C$ | 570 | 41 | 60 | 671 |
| សរុប | 2836 | 141 | 364 | 3341 |

ក. ចូររកប្រូបាបនៃសំឡេងដែលមិនគាំទ្របេក្ខជន $A$

ខ. ចូររកប្រូបាបនៃសំឡេងមិនគាំទ្របេក្ខជន $B$ ឬ $C$

គ. ចូររកប្រូបាបនៃការគ្មានយោបល់ចំពោះបេក្ខជន $A$

ឃ. ចូររកប្រូបាបនៃការគ្មានយោបល់ចំពោះបេក្ខជន $B$ ឬ $C$

ង. ចូរប្រៀបធៀបប្រូបាបនៃសំឡេងដែលគាំទ្របេក្ខជន $A$ និងប្រូបាបនៃសំឡេងដែលគាំទ្របេក្ខជន $B$ ឬ $C$ ។

7. ខាងក្រោមនេះជាព្រឹត្តិការណ៍អាចនៃការបោះកាក់ 4 ដង

$HHHH, HTHH, THHH, TTHH$

$HHHT, HTHT, THHT, TTHT$

$HHTH, HTTH, THTH, TTTH$

$HHTT, HTTT, THTT, TTTT$

ក. ចូររកប្រូបាបដែលបោះបានអក្សរ $H$ ពីរ ។

ខ. ចូររកប្រូបាបដែលបោះបាន អក្សរ $T$ ពីរមុនគេ ។

គ. ចូររកប្រូបាបដែលបោះបានអក្សរ $H$ មួយមុនគេ ។

ឃ. ចូររកប្រូបាបដែលបោះបានអក្សរ $H$ ទាំងបួន ។

ង. ចូររកប្រូបាបដែលបោះបានអក្សរ $T$ មួយយ៉ាងតិច ។

8. ក្នុងថង់មួយដែលមានតែឃ្លីពណ៌សនិងខ្មៅ ។ ចូររកប្រូបាបដែលចាប់បានឃ្លីពណ៌សដោយដឹងថា ប្រូបាបដែលចាប់បានឃ្លីពណ៌ខ្មៅស្មើនឹង $\frac{2}{5}$ ។

9. ក្រុមហ៊ុនមួយបានកត់ត្រាលើចំនួនថ្ងៃអវត្តមានរបស់បុគ្គលិកប្រចាំឆ្នាំ ។

| ចំនួនថ្ងៃអវត្តមាន | 0 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
|---|---|---|---|---|---|---|---|---|---|
| ចំនួនបុគ្គលិក | 6 | 1 | 15 | 12 | 24 | 18 | 16 | 10 | 7 |

បើគេធ្វើសម្ភាសន៍ជាមួយបុគ្គលិកមួយដោយចៃដន្យ

ក. ចូររកប្រូបាបដែលបុគ្គលិកនោះ បានឈប់យ៉ាងច្រើនបីថ្ងៃ ។

ខ. ចូររកប្រូបាបដែលបុគ្គលិកនោះ បានឈប់យ៉ាងតិចមួយថ្ងៃ ។

គ. ចូររកប្រូបាបដែលបុគ្គលិកនោះ បានឈប់ចន្លោះពី 4 ទៅ 6 ថ្ងៃ ។

ឃ. ចូររកប្រូបាបដែលបុគ្គលិកនោះ បានឈប់ច្រើនជាង 6 ថ្ងៃ ។

10. ថង់មួយមានឃ្លី 6 ក្នុងនោះមានឃ្លីពណ៌ខ្មៅ 4 និងពណ៌ស 2 ដើម្បីងាយសិក្សាឃ្លីពណ៌ខ្មៅបង់ដោយអក្សរ $ABCD$ និងឃ្លីពណ៌ស 2 បង់ដោយអក្សរ $X$ និង $Y$ ។ គេចាប់ឃ្លីម្តងពីរចេញពីថង់ ។



ក. ចូររកប្រូបាបដែលចាប់បានឃ្លីពណ៌សទាំងពីរ ។

ខ. ចូររកប្រូបាបដែលចាប់ឃ្លីពណ៌ខ្មៅមួយយ៉ាងតិច ។

11. គ្រូដាក់សំណួរមេរៀន 6 តាងដោយអក្សរ $A$ , $B$ , $C$ , $D$ , $E$ និង $F$ ហើយគ្រូនិងដកស្រង់យក 3 សំណួរដើម្បីដាក់ឱ្យសិស្សប្រឡងយកពិន្ទុ ។ បើសិស្សម្នាក់បានរៀនតែ 4 សំណួរ

ក. ចូររកប្រូបាបដែលសិស្សនោះត្រូវបានពីរសំណួរគត់ ។

ខ. ចូររកប្រូបាបដែលសិស្សនោះត្រូវបានពីរសំណួរយ៉ាងតិច ។

12. គេបោះកាក់ម្តងបី ។ ចូររកប្រូបាបដែលបោះបានមុខ $H$ ទាំងបី ។

13. ថង់មួយមានឃ្លី 12 គ្រាប់ដែលមានតែឃ្លីពណ៌សនិងពណ៌ខ្មៅ ។ គេចាប់ឃ្លីម្តងមួយចេញពីថង់ ។

ក. ចូររកចំនួននៃឃ្លីពណ៌ខ្មៅបើប្រូបាបនៃការចាប់បានឃ្លីពណ៌ខ្មៅស្មើនឹង $\frac{1}{3}$ ។

ខ. ចូររកប្រូបាបដែលចាប់បានឃ្លីពណ៌ស ។

14. ក្នុងការិយាល័យមួយមានបុរស 3 នាក់និងនារី 2 នាក់ ។ គេជ្រើសរើស 2 នាក់ដោយធ្វើការចាប់ឆ្នោតដោយចៃដន្យ ។ ចូររកប្រូបាបដែលគេជ្រើសរើសបាននារីទាំងពីរនាក់ ។

15. ផ្ទៃថាសមួយខណ្ឌដោយបីផ្នែកប៉ុនគ្នាដែលតាងដោយអក្សរ $A_1$ , $A_2$ , $B$ គេបង្វិលថាសឱ្យវិលរួចប្រើព្រួញគប់លើផ្ទៃថាសនោះពីរដង ។ ចូររកប្រូបាបដែលគប់បានអក្សរ $A$ ទាំងពីរលើក ។




16. ថង់មួយមានឃ្លីពណ៌ក្រហមនិងពណ៌ខៀវ ក្នុងនោះឃ្លីពណ៌ក្រហមមានចំនួន 15 គ្រាប់ ។ គេចាប់យកឃ្លីមួយពីថង់ដោយចៃដន្យដោយដឹងថាប្រូបាបដែលចាប់បានឃ្លីមួយពណ៌ក្រហមស្មើនឹង $\frac{3}{5}$ ។

ចូរគណនា

ក. ចំនួនឃ្លីពណ៌ខៀវនៅក្នុងថង់នោះ ។

ខ. ចំនួនឃ្លីពណ៌ក្រហមដែលត្រូវដាក់ចូលបន្ថែមក្នុងថង់ ដើម្បីឱ្យប្រូបាបដែលចាប់បានឃ្លីមួយមានពណ៌ក្រហមស្មើនឹង $\frac{2}{3}$ ។

មេរៀនទី

# 9 ចម្ងាយរវាងពីរចំណុច

## វត្ថុបំណង

- ❑ គណនាចម្ងាយរវាងពីរចំណុច ។
- ❑ គណនាកូអរដោនេនៃចំណុចកណ្ដាល ។

## 1. ចម្ងាយរវាងពីរចំណុច




បើគេស្គាល់កូអរដោនេនៃចំណុច $A(x_1\ ,\ y_1)$ និង $B(x_2\ ,\ y_2)$ នោះគេអាចបកស្រាយអង្កត់ $[AB]$ នៅក្នុងប្លង់កូអរដោនេ ហើយគេក៏អាចគណនាប្រវែងនៃអង្កត់នេះដែរ ។

***ឧទាហរណ៍ទី 1 :*** គេឱ្យពីរចំណុច $A(2\ ,5)$ និង $B(6\ ,2)$ ដើម្បីគណនាប្រវែងនៃអង្កត់ $[AB]$ គេប្រើទ្រឹស្ដីបទពីតាគ័រក្នុងត្រីកោណ $ABC$




ក្នុងករណីនេះ

$BC = 6-2 = 4$

$AC = 5-2 = 3$

យើងបាន $AB^2 = BC^2+AC^2$

$= 4^2+3^2$

$= 16+9= 25$

ដូចនេះ $AB = \sqrt{25} = 5$ ឯកតា

ជាទូទៅរូបមន្តនៃចម្ងាយរវាងពីរចំណុច $A(x_1\ ,\ y_1)$ និង $B(x_2\ ,\ y_2)$ កំណត់ដូចខាងក្រោម

$AC = x_2-x_1$ ; $BC = y_2-y_1$

$AB^2 = AC^2+BC^2$

$= (x_2-x_1)^2+(y_2-y_1)^2$

$AB = \sqrt{(x_2-x_1)^2+(y_2-y_1)^2}$ ។

| |
|---|
| ចម្ងាយរវាងពីរចំណុច $A(x_1\ ,\ y_1)$ , $B(x_2\ ,\ y_2)$ កំណត់ដោយ $AB = \sqrt{(x_2-x_1)^2+(y_2-y_1)^2}$ |

*លំហាត់គំរូទី 1 :* ចូរគណនាចម្ងាយរវាងពីរចំណុច $(3\ ,7)$ និង $(8\ ,-5)$ ។

***ចម្លើយ :***

$$AB = \sqrt{(8-3)^2+(-5-7)^2}$$

$$= \sqrt{5^2+(-12)^2}$$

$$= \sqrt{25+144}$$

$$= \sqrt{169} = 13$$ ឯកតា ។

*លំហាត់គំរូទី 2 :* ចូរគណនាចម្ងាយរវាងពីរចំណុច $(-1\ ,-2)$ ; $(3\ ,4)$ ។

***ចម្លើយ :***

$$AB = \sqrt{[3-(-1)]^2+[4-(-2)]^2}$$

$$= \sqrt{(3+1)^2+(4+2)^2}$$

$$= \sqrt{16+36}$$

$$= \sqrt{52} = 2\sqrt{13}$$ ឯកតា ។

*លំហាត់គំរូទី 3 :* គេឱ្យត្រីកោណមួយដែលមានកំពូល $A(-2\ ,6)$ ; $B(-1\ ,-1)$ និង $C(1\ ,0)$ ។ ចូរគណនាប្រវែងជ្រុងទាំងបីនៃត្រីកោណ រួចបង្ហាញថាវាជាត្រីកោណកែង ។

***ចម្លើយ :***

$A(-2\ ,6)$ ; $B(-1\ ,-1)$ ; $C(1\ ,0)$

$$AB = \sqrt{[-1-(-2)]^2+(-1-6)^2}$$

$$= \sqrt{1+49}$$

$$= \sqrt{50} = 5\sqrt{2}$$

$$AC = \sqrt{[1-(-2)]^2+(0-6)^2}$$

$$= \sqrt{9+36} = \sqrt{45} = 3\sqrt{5}$$

$$BC = \sqrt{[1-(-1)]^2+[0-(-1)]^2}$$

$$= \sqrt{4+1} = \sqrt{5}$$




ត្រីកោណ $ABC$ ទំនងជាកែងត្រង់ $C$ ក្នុងករណីនេះគេត្រូវផ្ទៀងផ្ទាត់ $AC^2+BC^2 = AB^2$

$AB^2 = 50$ ; $AC^2 = 45$ ; $BC^2 = 5$ $AC^2+BC^2 = 45+5 = 50$ ស្មើនឹង $AB^2$ ហេតុនេះ $ABC$ ជាត្រីកោណកែងត្រង់ $C$ ។

***ប្រតិបត្តិ :*** ចូរគណនាចម្ងាយរវាងពីរចំណុច

ក. $A(0\ ,0)$ និង $B(8\ ,-15)$ ខ. $A(-2\ ,6)$ និង $B(3\ ,-6)$

គ. $A(-3\ ,-5)$ និង $B(-1\ ,-8)$ ឃ. $A(5\ ,3)$ និង $B(11\ ,11)$ ។

## 2. កូអរដោនេនៃចំណុចកណ្ដាល

***ឧទាហរណ៍ទី1 :*** គេមាន $A(3\ ,0)$ ; $B(9\ ,0)$ គណនាកូអរដោនេនៃចំណុចកណ្ដាលនៃអង្កត់ $[AB]$ ។ ចំណុច $A$ និង $B$ ឋិតនៅលើអ័ក្ស $x'x$ ដែល $M$ ជាចំណុចកណ្ដាលនៃអង្កត់ $[AB]$




តាង $M(x\ ,0)$ គេបាន :

$$AM = MB$$

$$x_M - x_A = x_B - x_M$$

$$x - 3 = 9 - x$$

$$2x = 9 + 3$$

$$2x = 12$$

$$x = 6$$

ដូចនេះ $M(6\ ,0)$ ជាចំណុចកណ្ដាលនៃអង្កត់ $[AB]$ ។

***ឧទាហរណ៍ទី2 :*** គេឱ្យ $A(0\ ,2)$ និង $B(0\ ,8)$

គណនាកូអរដោនេនៃចំណុចកណ្ដាលនៃអង្កត់ $[AB]$

ចំណុច $A$ និង $B$ ឋិតនៅលើអ័ក្ស $y'y$ ដែល $M$ ជាចំណុចកណ្ដាលនៃអង្កត់ $[AB]$




តាង $M(0\ ,\ y)$ គេបាន

$$AM = MB$$

$$y_M - y_A = y_B - y_M$$

$$y - 2 = 8 - y$$

$$2y = 8 + 2$$

$$2y = 10$$

$$y = 5$$

ដូចនេះ $M(5\ ,0)$ ជាចំណុចកណ្ដាលនៃអង្កត់ $[AB]$ ។

***ឧទាហរណ៍ទី 3 :*** គេឱ្យ $A(2\ ,1)$ និង $B(8\ ,4)$ គណនាកូអរដោនេនៃចំណុចកណ្ដាលអង្កត់ $[AB]$ តាង $M(x\ ,\ y)$ ជាចំណុចកណ្ដាលនៃអង្កត់ $[AB]$




$A_1(2\ ,0)\ ;\ B_1(8\ ,0)\ ;\ M_1(x\ ,0)$

$M_1$ ជាចំណុចកណ្ដាលនៃអង្កត់ $[A_1B_1]$

$A_1M_1 = M_1B_1$

$x-2 = 8-x\ ;\ 2x = 10\ ;\ x = 5$

$A_2(0\ ,1)\ ;\ B(0\ ,4)\ ;\ M_2(0\ ,y)$

$A_2M_2 = M_2B_2$

$y-1 = 4-y$

$2y = 4+1\ ,\ y = \dfrac{5}{2}$

ហេតុនេះ $M = (5\ ,5/2)$ ជាចំណុចកណ្ដាលនៃអង្កត់ $[AB]$




ជាទូទៅ $A(x_1\ ,\ y_1)$ និង $B(x_2\ ,\ y_2)$ ជាពីរចំណុច ហើយ $M(x\ ,\ y)$ ជាចំណុចកណ្ដាលនៃអង្កត់ $[AB]$ យើងបាន

នៅលើអ័ក្ស $x'x$

$x-x_1 = x_2-x$

$2x = x_1+x_2\ ,\ x = \dfrac{x_1+x_2}{2}$

នៅលើអ័ក្ស $y'y$

$y-y_1 = y_2-y$

$2y = y_1+y_2$

$y = \dfrac{y_1+y_2}{2}$

| |
|---|
| កូអរដោនេនៃចំណុចកណ្ដាល $A(x_1\ ,\ y_1)$ និង $B(x_2\ ,\ y_2)$ កំណត់ដោយ $M\left(\dfrac{x_1+x_2}{2}\ ;\ \dfrac{y_1+y_2}{2}\right)$ |

***លំហាត់គំរូទី 1 :*** គេឱ្យ $M(4\ ,3)\ ;\ N(-2\ ,8)$ គណនាកូអរដោនេនៃចំណុចកណ្ដាលនៃអង្កត់ $[MN]$ ។

***ចម្លើយ :***

តាង $I(x\ ,\ y)$ ជាចំណុចកណ្ដាលនៃអង្កត់ $[MN]$

$$x = \frac{x_1 + x_2}{2} = \frac{4+(-2)}{2} = \frac{4-2}{2} = \frac{2}{2} = 1$$

$$y = \frac{y_1 + y_2}{2} = \frac{3+8}{2} = \frac{11}{2}$$

ចំណុចកណ្ដាលនៃអង្កត់ $[MN]$ គឺ $I\left(1\ ,\frac{11}{2}\right)$ ។

***លំហាត់គំរូទី 2 :*** ត្រីកោណមួយមានកំពូលកំណត់ដោយចំណុច $A(2\ ,1)$ ; $B(10\ ,7)$ និង $C(8\ ,9)$ ។ ស្រាយបញ្ជាក់ថា ត្រីកោណដែលផ្គុំដោយចំណុចកណ្ដាលនៃជ្រុងទាំងបី ជាត្រីកោណសមបាត ។ តាង $M$ , $N$ និង $P$ ជាចំណុចកណ្ដាលរៀងគ្នានៃអង្កត់ $[AB]$ ; $[BC]$ និង $[AC]$ ។

***ចម្លើយ :***




$M$ ជាចំណុចកណ្ដាលនៃ $A(2\ ,1)$ និង $B(10\ ,7)$

$$x_M = \frac{10+2}{2} = 6$$

$$y_M = \frac{7+1}{2} = 4\ ,\ M(6\ ,4)$$

$N$ ជាចំណុចកណ្ដាលនៃ $B(10\ ,7)$ និង $C(8\ ,9)$

$$x_N = \frac{10+8}{2} = \frac{18}{2} = 9$$

$$y_N = \frac{7+9}{2} = \frac{16}{2} = 8\ ,\ N(9\ ,8)$$

$P$ ជាចំណុចកណ្ដាលនៃ $A(2\ ,1)$ និង $C(8\ ,9)$

$$x_P = \frac{2+8}{2} = 5\ ,\ y_P = \frac{1+9}{2} = 5\ ,\ P(5\ ,5)$$

ប្រៀបធៀបប្រវែង $MN$ និង $NP$

$$MN = \sqrt{(x_N - x_M)^2 + (y_N - y_M)^2} = \sqrt{(9-6)^2 + (8-4)^2} = \sqrt{9+16} = 5$$

$$NP = \sqrt{(x_P - x_N)^2 + (y_P - y_N)^2} = \sqrt{(5-9)^2 + (5-8)^2} = \sqrt{16+9} = 5$$

$MN = NP = 5$ ឯកតា

ត្រីកោណ $MNP$ មានជ្រុងពីរប៉ុនគ្នាជាត្រីកោណសមបាត ។

## ? លំហាត់

1. ចូរគណនាចម្ងាយរវាងពីរចំណុចដែលមានកូអរដោនេដូចខាងក្រោម ។

ក. (9 , 2) និង (6 , 8)
ខ. (5 , –3) និង (–2 , 4)
គ. (2 , 5) និង (0 , 0)
ឃ. (–6 , –3) និង (2 , 1)
ង. (8 , 7) និង (8 , –6)
ច. (3 , 12) និង (7 , 12)
ឆ. (100 , –203) និង (97 , –200)
ជ. (–3 , 8) និង (–4 , 7) ។

2. ចុងទាំងពីរនៃអង្កត់ផ្ចិតរង្វង់មួយមានកូអរដោនេរៀងគ្នា (3 , 1) និង (–2 , 5) ។ ចូរគណនាកាំរង្វង់រួចសង់រង្វង់នេះ ។

3. ចូរគណនាប្រវែងអង្កត់ទ្រូងនៃចតុកោណ $PQRS$ ដែល $P(-2\ ,3)$ , $Q(5\ ,5)$ , $R(6\ ,-6)$ និង $S(-3\ ,-3)$ ។

4. ចូរបង្ហាញថាត្រីកោណ $KLM$ ដែល $K(2\ ,8)$ , $L(10\ ,11)$ និង $M(5\ ,0)$ ជាត្រីកោណសមបាត ។

5. ចូរគណនាបរិមាត្រនៃត្រីកោណ $ABC$ ដែល $A(3\ ,7)$ , $B(5\ ,2)$ និង $C(-7\ ,3)$ ។ ចូរបង្ហាញថា $ABC$ ជាត្រីកោណកែង រួចគណនាផ្ទៃក្រឡារបស់វា ។

6. ចូររកតម្លៃ $y$ ដើម្បីឱ្យចម្ងាយរវាងពីរចំណុចដែលមានកូអរដោនេ (4 , 2) និង (4 , $y$) ស្មើនឹង 5 ឯកតា ។

7. ចូររកចំណុច $C(x, 1)$ ក្នុងកាដ្រង់ទី 1 ដើម្បីឱ្យត្រីកោណដែលមានកំពូល $A(1\ ,1)$ , $B(4\ ,7)$ និង $C(x\ ,1)$ ជាត្រីកោណសមបាតដែល $AB = AC$ ។

8. កំពូលនៃត្រីកោណមួយមានកូអរដោនេ (–3 , 2) , (9 , 2) និង (3 , 10) ។
   ក. ចូរគណនាប្រវែងជ្រុងទាំងបីនៃត្រីកោណ ។
   ខ. ចូរប្រាប់ប្រភេទនៃត្រីកោណនេះ ។

9. កំពូលនៃចតុកោណមួយមានកូអរដោនេ (–1 , –2) , (5 , –2) , (–1 , 4) និង (5 , 4) ។
   ក. ចូរគណនាប្រវែងជ្រុងនិងប្រវែងអង្កត់ទ្រូងនៃចតុកោណ ។
   ខ. តើគេសន្និដ្ឋានដូចម្តេចចំពោះចតុកោណនេះ ?

10. កូអរដោនេកំពូលរបស់ចតុកោណមួយមាន $(2,-1)$ , $(6,4)$ , $(2,9)$ និង $(-2,4)$ ។

ក. ចូរគណនាប្រវែងជ្រុងនិងប្រវែងអង្កត់ទ្រូងនៃចតុកោណ ។

ខ. ចូរប្រាប់ប្រភេទនៃចតុកោណនេះ ។

11. ចតុកោណមួយមានកំពូល $(-2,-3)$ , $(-3,1)$ , $(5,-1)$ និង $(4,3)$ ។ តើចតុកោណនេះមានរាងជាអ្វី ?

12. ចូរគណនាកូអរដោនេនៃចំណុចកណ្ដាលនៃ $[AB]$ រួចដៅចំណុចក្នុងតម្រុយអរតូណរមេតាមករណីនីមួយៗដូចខាងក្រោម ។

ក. $A(5,8)$ និង $B(5,12)$ ខ. $A(-5,2)$ និង $B(-5,14)$ ។

13. ប្រើរូបមន្តកូអរដោនេនៃចំណុចកណ្ដាលអង្កត់ ។ ចូរគណនាកូអរដោនេចំណុចកណ្ដាលនៃអង្កត់ $[AB]$ ក្នុងករណីនីមួយៗដូចខាងក្រោម ។

ក. $A(-3,-5)$ និង $B(7,-5)$ ខ. $A(-8,-6)$ និង $B(4,2)$

គ. $A(3t+5,-7)$ និង $B(t+7,7)$ , $(t\neq 1)$ ឃ. $A(a,b)$ និង $B(a,c)$ ។

14. ចូរគណនាកូអរដោនេនៃចំណុចកណ្ដាល $M$ នៃអង្កត់រវាងពីរចំណុច $A(-3,-1)$ និង $B(5,7)$ ។ ចូរគណនាប្រវែង $AM$ និង $BM$ ។

15. គេឱ្យ $M(1,-2)$ ជាចំណុចកណ្ដាលនៃអង្កត់ $[AB]$ ដែល $A(-2,2)$ ។ ចូរគណនាកូអរដោនេនៃចំណុច $B$ ។

16. រង្វង់មួយមានផ្ចិត $F(-2,6)$ ។ អង្កត់ផ្ចិតរង្វង់នេះមានចំណុចចុងមួយត្រង់ $V(3,8)$ ។ គណនាកូអរដោនេនៃចំណុច $T$ ដែលជាចំណុចចុងម្ខាងទៀតនៃអង្កត់ផ្ចិត $[TV]$ រួចសង់រង្វង់នេះ ។

17. កូអរដោនេនៃកំពូលប្រលេឡូក្រាមមួយស្មើ $(1,1)$ ; $(2,-3)$ ; $(-3,-1)$ និង$(-2,-5)$ ។ ចូរគណនាកូអរដោនេនៃចំណុចកណ្ដាលនៃអង្កត់ទ្រូងទាំងពីរ ។ តើគេអាចសន្និដ្ឋានបានយ៉ាងដូចម្ដេច ?

18. ចតុកោណមួយមានកំពូល $E(5,3)$ ; $F(5,-5)$ ; $G(-3,-3)$ និង $H(-1,5)$ ។ ចូរគណនាកូអរដោនេនៃចំណុចកណ្ដាល $A, B, C$ និង $D$ នៃជ្រុង $[EF]$ ; $[FG]$ ; $[GH]$ និង $[EH]$ ។ តើចតុកោណ $ABCD$ មានរាងជាអ្វី ?

19. ចតុកោណកែងមួយកំណត់ដោយចំណុច $A(3\ ,2)$ ; $B(9\ ,2)$ ; $C(9\ ,6)$ និង $D(3\ ,6)$ ។ ចូរស្រាយបញ្ជាក់ថាចតុកោណដែលកំណត់ដោយចំណុចកណ្តាលនៃជ្រុងទាំងបួនរបស់ចតុកោណកែងខាងលើជាចតុកោណស្មើ ។

20. ចតុកោណមួយមានកំពូល $P(-3\ ,-2)$ ; $Q(-1\ ,5)$ ; $R(3\ ,1)$ និង $S(5\ ,-4)$ ។ បើ $A, B, C$ និង $D$ ជាចំណុចកណ្តាលរៀងនៃជ្រុង $[PQ]$ ; $[QR]$ ; $[RS]$ និង $[SP]$ ។ ចូរបង្ហាញថា $ABCD$ ជាប្រលេឡូក្រាម ។

21. គេមានអង្កត់ $[P_1P_2]$ ដែល $P_1(x_1\ ,\ y_1)$ និង $P_2(x_2\ ,\ y_2)$ ។ ចូរគណនាកូអរដោនេនៃចំណុច $A$ និង $B$ ជាចំណុចដែលចែកអង្កត់ $[P_1P_2]$ ជាបីផ្នែកស្មើៗគ្នា ។

22. គេមានចំណុច $P_1(x_1\ ,\ y_1)$ , $P_m\left(\frac{x_1+x_2}{2}\ ;\ \frac{y_1+y_2}{2}\right)$ និង $P_2(x_2\ ,\ y_2)$ ។

ចូរបង្ហាញថា $P_1P_m + P_mP_2 = P_1P_2$ ។

23. គេឱ្យ $A(1\ ,\ 0)$ និង $B(3\ ,\ 2)$ រួចសង់រង្វង់ដែលមានអង្កត់ផ្ចិត $AB$ ។

ក. ចូររកកូអរដោនេនៃផ្ចិតរង្វង់ដែលតាងដោយចំណុច $I$ ។

ខ. $M$ ជាចំណុចមួយដែលមានកូអរដោនេ $\left(\frac{5}{2}\ ,\ y\right)$ ចូរកំណត់ $y$ ដើម្បីឱ្យ $M$ ឋិតនៅលើរង្វង់រួចបញ្ជាក់តើ $M$ មានទីតាំងប៉ុន្មាន ?



មេរៀនទី

# 10 សមីការនៃបន្ទាត់

**វត្ថុបំណង**

- សង់បន្ទាត់នៃសមីការ $y = ax+b$ ។
- រកសមីការនៃបន្ទាត់ដែលកាត់តាមពីរចំណុច ។
- រកសមីការនៃបន្ទាត់ដែលស្រប ឬកែងនឹងបន្ទាត់មួយទៀត ។
- អនុវត្តសមីការនៃបន្ទាត់ ។

## 1. ការសង់បន្ទាត់

### 1.1. ការសង់បន្ទាត់តាមតារាងតម្លៃលេខ

***ឧទាហរណ៍ទី1 :*** សមីការ $y = 2x+1$ ជាសមីការដែលមានពីរអញ្ញាត

បើគេជំនួស $x = 0$ , $y = 1$ ក្នុងសមីការនោះ $1 = 2\times 0+1$ គេបាន $1 = 1$

គេថា $(0\ ;\ 1)$ ជាគូចម្លើយនៃសមីការ

ដូចគ្នានេះដែរ ចំពោះ $x = 1$ , $y = 3$ $3 = 2\times 1+1$ គេបាន $3 = 3$

តាមវិធីនេះ ឃើញថាសមីការមានគូចម្លើយរាប់មិនអស់

គូចម្លើយបកស្រាយដោយតារាងតម្លៃលេខ

| $x$ | $-3$ | $-2$ | $-1$ | $0$ | $1$ | $2$ | $3$ |
|---|---|---|---|---|---|---|---|
| $y$ | $-5$ | $-3$ | $-1$ | $1$ | $3$ | $5$ | $7$ |

តាមតារាងតម្លៃលេខនេះគេសំគាល់ឃើញថាតម្លៃ $y$ ប្រែប្រួលទៅតាមតម្លៃ $x$

បម្រែបម្រួលនៃ $x$ $3-2 = 2-1 = 1-0 = 0-(-1) = 1$

បម្រែបម្រួលនៃ $y$ $7-5 = 5-3 = 3-1 = 1-(-1) = 2$

មានន័យថាបើ $x$ កើន 1 ឯកតា នោះ $y$ កើន 2 ឯកតាជានិច្ច

គេអាចបកស្រាយគូចម្លើយនៃសមីការដោយបន្ទាត់
គេដៅចំណុច $(-3\ ,\ -5)$ , $(-2\ ,\ -3)$ , $(-1\ ,\ -1)$ , $(0\ ,\ 1)$ , $(1\ ,\ 3)$ , $(2\ ,\ 5)$ , $(3\ ,\ 7)$ ។

នៅក្នុងប្លង់នៃប្រព័ន្ធកូអរដោនេ ចម្លើយនៃសមីការជាបន្ទាត់ដែលកាត់តាមចំណុចទាំងនេះ ។




ហើយផលធៀប $\dfrac{\text{បម្រែបម្រួលនៃ } y}{\text{បម្រែបម្រួលនៃ } x} = \dfrac{2}{1}$ ជាមេគុណប្រាប់ទិសនៃបន្ទាត់ $y = 2x + 1$

- សញ្ញាវិជ្ជមាននៃមេគុណប្រាប់ទិសឱ្យដឹងថាតម្លៃ $y$ កើន កាលណាតម្លៃ $x$ កើន
- ចំនួន $\frac{2}{1}$ ឱ្យដឹងថា បើ $x$ កើន 1ឯកតានោះ $y$ នឹងកើន 2ឯកតា ។

***ឧទាហរណ៍ទី 2 :*** សង់ក្រាបនៃសមីការ $y = -3x + 1$
ដោយឱ្យតម្លៃលេខនៃ $x$ យកពី $-2$ , $-1$ , $0$ , $1$ , $2$
គេបានតារាងខាងក្រោម ។

| $x$ | $-2$ | $-1$ | $0$ | $1$ | $2$ |
|---|---|---|---|---|---|
| $y$ | $7$ | $4$ | $1$ | $-2$ | $-5$ |

បម្រែបម្រួលនៃ $x$ ស្មើនឹង 1
បម្រែបម្រួលនៃ $y$ ស្មើនឹង $-3$
មានន័យថាបើ $x$ កើន 1 ឯកតា
នោះ $y$ នឹងថយចុះ 3 ឯកតា




$$\frac{\text{បម្រែបម្រួលនៃ } y}{\text{បម្រែបម្រួលនៃ } x} = \frac{-3}{1}$$ ជាមេគុណប្រាប់ទិសនៃបន្ទាត់ $y = -3x + 1$

- សញ្ញាអវិជ្ជមាននៃមេគុណប្រាប់ទិសឱ្យដឹងថា តម្លៃ $y$ ចុះ កាលណាតម្លៃ $x$ កើន
- ចំនួន $-\frac{3}{1}$ ឱ្យដឹងថា បើ $x$ កើន 1ឯកតានោះ $y$ នឹងថយចុះ 3ឯកតា ។

***ឧទាហរណ៍ទី3 :*** រកមេគុណប្រាប់ទិសនៃបន្ទាត់កាត់តាមពីរចំណុច $A(-2\ ,\ 1)$ , $B(3\ ,\ 4)$

ក្នុងករណីនេះគេគណនាបម្រែបម្រួលនៃ $x$ និង $y$

បម្រែបម្រួលនៃ $x$ គឺ $x_B - x_A = 3-(-2) = 5$

បម្រែបម្រួលនៃ $y$ គឺ $y_B - y_A = 4-1 = 3$

$\frac{y_B - y_A}{x_B - x_A} = \frac{3}{5}$ ជាមេគុណប្រាប់ទិសនៃបន្ទាត់ $AB$ ។

***ជាទូទៅ :***

- បន្ទាត់មានសមីការ $y = ax+b$ ដែល $a$ ជាមេគុណប្រាប់ទិស
- មេគុណប្រាប់ទិសនៃបន្ទាត់កាត់តាមពីរចំណុច $A(x_1\ y_1)$ , $B(x_2\ y_2)$ កំណត់ដោយ $\frac{y_2 - y_1}{x_2 - x_1}$ ។




***លំហាត់គំរូទី1 :*** ចូរសង់បន្ទាត់ដែលកាត់តាមចំណុច $A(2\ ,\ 1)$ ហើយមានមេគុណប្រាប់ទិសស្មើនឹង 2 ។

***ចម្លើយ :*** ដំបូងគេសង់ចំណុច $A(2\ ,\ 1)$

បន្ទាត់មានមេគុណប្រាប់ទិសស្មើនឹង 2 មានន័យថា បើ $x$ កើន 1ឯកតា នោះ $y$ នឹងកើន 2ឯកតា ។ គូសមួយឯកតាចេញពី $A$ តាមទិស $ox$ បន្ទាប់មកគូសឡើងលើ 2ឯកតាតាមទិស $oy$ ។ គេបានចំណុចមួយ $B$ បន្ទាត់ដែលត្រូវសង់កាត់តាមចំណុច $A$ និង $B$ ។




***លំហាត់គំរូទី2 :*** ចូរសង់បន្ទាត់ដែលកាត់តាមចំណុច $A(0\ ,\ 3)$ និងមានមេគុណប្រាប់ទិស $-\frac{1}{2}$

***ចម្លើយ :*** ដំបូងគេសង់ចំណុច $A(0\ ,\ 3)$

មេគុណប្រាប់ទិសស្មើនឹង $-\frac{1}{2}$ មានន័យថាបើ $x$ កើន 1 ឯកតា នោះ $y$ នឹងថយចុះ 2ឯកតា ។

គូសមួយឯកតាចេញពី $A$ តាមទិស $ox$ បន្ទាប់មកគូសចុះក្រោម 2ឯកតាតាមទិស $oy'$ ។




គេបានចំណុច $B$ បន្ទាត់ដែលត្រូវសង់កាត់តាមចំណុច $A$ និង $B$ ។

***លំហាត់គំរូទី3 :*** ចូរកំណត់មេគុណប្រាប់ទិសនៃបន្ទាត់ដែលកាត់តាមពីរចំណុចដូចខាងក្រោម

ក. ពីរចំណុច $A(-4\ ,\ -1)$ , $B(0\ ,\ -5)$

ខ. ពីរចំណុច $C(7\ ,\ 8)$ , $D(-2\ ,\ 5)$ ។

***ចម្លើយ :***

ក. $\dfrac{y_B - y_A}{x_B - x_A} = \dfrac{(-5)-(-1)}{0-(-4)} = \dfrac{-5+1}{4} = \dfrac{-4}{4} = -1$

ខ. $\dfrac{y_D - y_C}{x_D - x_C} = \dfrac{5-8}{-2-7} = \dfrac{-3}{-9} = \dfrac{1}{3}$ ។

***លំហាត់គំរូទី4 :*** ចូរសង់តារាងតម្លៃលេខនិងតាងក្រាបនៃទំនាក់ទំនង $y = -\frac{3}{4}x$ រួចបកស្រាយមេគុណប្រាប់ទិស ។




***ចម្លើយ :*** ឱ្យ $x$ យកតម្លៃ

$-8$ , $-4$ , $0$ , $4$ , $8$ រួចរកតម្លៃ ។

| $x$ | $-8$ | $-4$ | $0$ | $4$ | $8$ |
|---|---|---|---|---|---|
| $y$ | $-6$ | $3$ | $0$ | $-3$ | $-6$ |

តាមតារាងតម្លៃលេខខាងលើ

បម្រែបម្រួលនៃ $x$ ស្មើ $8 - 4 = 4$

បម្រែបម្រួលនៃ $y$ ស្មើ $-6-(-3) = -3$

$\dfrac{\textbf{បម្រែបម្រួលនៃ } x}{\textbf{បម្រែបម្រួលនៃ } y} = \dfrac{-3}{4} < 0$

មានន័យថាបើ $x$ កើន 4ឯកតា នោះ $y$ នឹងថយចុះ 3ឯកតា ឬ $x$ ថយ 4ឯកតា នោះ $y$ នឹងកើន 3ឯកតា ។

***ប្រតិបត្តិ :***

1. ចូរសង់បន្ទាត់ដែលមានសមីការ $y = -\dfrac{x}{2}$
2. ចូរសង់បន្ទាត់ដែលកាត់តាមចំណុច $A(0\ ,\ 1)$ និងមានមេគុណប្រាប់ទិសស្មើ $-\dfrac{1}{3}$
3. ចូរគណនាមេគុណប្រាប់ទិសនៃបន្ទាត់កាត់តាមពីរចំណុច $A(-2\ ,\ 0)$ និង $B(-1\ ,\ 4)$ ។

## 1.2. ការសង់បន្ទាត់កាត់តាមពីរចំណុច

គេដឹងថាបន្ទាត់មួយកាត់តាមពីរចំណុច ដើម្បីងាយដៅចំណុចគេកំណត់កូអរដោនេនៃចំណុចដែលបន្ទាត់កាត់អ័ក្ស $x'x$ និងអ័ក្ស $y'y$ ។

*ឧទាហរណ៍ទី 1 :* សង់បន្ទាត់ដែលមានសមីការ $y = -2x+4$ ។ បន្ទាត់កាត់អ័ក្ស $y'y$ ត្រង់ចំណុច

ឱ្យ $x = 0$ , $y = 2\times0+4 = 4$ , $(0\ ,\ 4)$

បន្ទាត់កាត់អ័ក្ស $x'x$ ត្រង់ចំណុច

ឱ្យ $y = 0$ , $2x+4 = 0$ , $x = -2$ , $(-2\ ,\ 0)$

គេបានតារាងតម្លៃលេខ

| $x$ | 0 | $-2$ |
|---|---|---|
| $y$ | 4 | 0 |




*ឧទាហរណ៍ទី 2 :* សង់បន្ទាត់ដែលមាន-សមីការ $y = \frac{-x}{2}$ ។

បើ $x = 0$ , $y = 0$ បន្ទាត់កាត់តាមគល់ 0

ក្នុងករណីនេះគេដៅយកតែចំណុចមួយទៀតដោយឱ្យ $x = 2$ , $y = -1$

គេបានតារាងតម្លៃលេខ

| $x$ | 0 | 2 |
|---|---|---|
| $y$ | 0 | $-1$ |




*ជាទូទៅ :*

- បន្ទាត់មានសមីការ $y = ax+b$ កាត់អ័ក្ស $y'y$ និង $x'x$
- បន្ទាត់មានសមីការ $y = ax$ កាត់តាមគល់ 0

គេក៏មានបន្ទាត់ដែលមានសមីការ $x = 4$ និង $y = 3$

$x = 4$ ជាបន្ទាត់ដែលស្របនឹងអ័ក្ស $y'y$ ហៅថា បន្ទាត់ឈរ ។

$y = 3$ ជាបន្ទាត់ដែលស្របនឹងអ័ក្ស $x'x$ ហៅថា បន្ទាត់ដេក ។



**ជាទូទៅ :** $x = h$ ជាបន្ទាត់ឈរ (បន្ទាត់ស្របអ័ក្ស $oy$ ហើយកាត់អ័ក្ស $ox$ ត្រង់ $x = h$ ) ។

$y = k$ ជាបន្ទាត់ដេក (បន្ទាត់ស្របអ័ក្ស $ox$ ហើយកាត់អ័ក្ស $oy$ ត្រង់ $y = k$ ) ។

***លំហាត់គំរូទី 1 :*** ចូរសង់បន្ទាត់ $y = \frac{x}{2} + 1$ និង $y = \frac{-2x}{3} + 3$ ក្នុងប្លង់តែមួយ ។

***ចម្លើយ :***




សង់តារាងតម្លៃលេខនៃ $y = \frac{x}{2} + 1$

| $x$ | 0 | $-2$ |
|---|---|---|
| $y$ | 1 | 0 |

ឬ

| $x$ | 0 | 2 |
|---|---|---|
| $y$ | 1 | 2 |

សង់តារាងតម្លៃលេខនៃ $y = \frac{-2x}{3} + 3$

| $x$ | 0 | 4.5 |
|---|---|---|
| $y$ | 3 | 0 |

ឬ

| $x$ | 0 | 3 |
|---|---|---|
| $y$ | 3 | 1 |

***លំហាត់គំរូទី 2 :*** ចូរសង់បន្ទាត់ $2y + x = 1$ និង $y + x = 0$ ក្នុងប្លង់តែមួយ ។

***ចម្លើយ :***




ចំពោះសមីការ $3y + x = 1$

ឱ្យ $x = 0$ , $y = -\frac{1}{2}$

ឱ្យ $y = 0$ , $x = 1$

| $x$ | 0 | 1 |
|---|---|---|
| $y$ | $-\frac{1}{2}$ | 0 |

ចំពោះសមីការ $y + x = 0$

ឱ្យ $x = 0$ , $y = 0$

ឱ្យ $x = 1$ , $y = -1$

| $x$ | 0 | 1 |
|---|---|---|
| $y$ | 0 | $-1$ |

***ប្រតិបត្តិ :*** ចូរសង់បន្ទាត់ $y = \frac{-x + 4}{2}$ , $y = 2$ និង $x = 4$ ក្នុងប្លង់តែមួយ រួចគណនាផ្ទៃក្រឡានៃត្រីកោណដែលខណ្ឌដោយបន្ទាត់ទាំងបីនេះ ។

## 2. សមីការនៃបន្ទាត់

### 2.1. សមីការនៃបន្ទាត់កាត់តាមពីរចំណុច




***ឧទាហរណ៍ :*** សង់ពីរចំណុច $A(2\ ,\ 2)\ ,\ B(4\ ,\ 3)$

រួចកំណត់រកសមីការនៃបន្ទាត់នោះ ។

បើ $M(x\ ,\ y)$ ជាចំណុចមួយនៃបន្ទាត់ $AB$ នោះ

បន្ទាត់ $AB$ និង $BM$ មានមេគុណប្រាប់ទិសស្មើគ្នា

មេគុណប្រាប់ទិសនៃ $AB$ : $\frac{y_B - y_A}{x_B - x_A} = \frac{3-2}{4-2} = \frac{1}{2}$

មេគុណប្រាប់ទិសនៃ $BM$ : $\frac{y-3}{x-4}$

យើងបាន $\frac{y-3}{x-4} = \frac{1}{2}$ , $2(y-3) = x-4$ , $2y-6 = x-4$ , $2y = x+2$ , $y = \frac{x}{2}+1$

***លំហាត់គំរូ :*** ចូររកសមីការបន្ទាត់កាត់តាមចំណុច $A(-1\ ,\ 1)\ ,\ B(3\ ,\ 7)$ ។




***ចម្លើយ :*** តាង $M(x\ ,\ y)$ ជាចំណុចនៃបន្ទាត់ $AB$

បន្ទាត់ $AB$ និង $AM$ មានមេគុណប្រាប់ទិសស្មើគ្នា

$$\frac{y_B - y_A}{x_B - x_A} = \frac{y_M - y_A}{x_M - x_A}$$

$$\frac{7-1}{3-(-1)} = \frac{y-1}{x-(-1)}$$

$$\frac{6}{4} = \frac{y-1}{x+1}$$

$4(y-1) = 6(x+1)$ , $4y-4 = 6x+6$ , $y = \frac{3}{2}x+\frac{5}{2}$

***ប្រតិបត្តិ :*** ចូររកសមីការបន្ទាត់កាត់តាមពីរចំណុច $(-2\ ,\ 7)\ ,\ (-2\ ,\ 7)$ ។

### 2.2. លក្ខខណ្ឌនៃបន្ទាត់ស្រប




***ឧទាហរណ៍ :*** សង់បន្ទាត់ពីរដែលមានមេគុណប្រាប់ទិសស្មើគ្នា

$d_1 : y = \frac{x}{2}+2$ និង $d_2 : y = \frac{x}{2}-1$

តារាងតម្លៃលេខនៃ $d_1$

| $x$ | 0 | $-4$ |
|---|---|---|
| $y$ | 2 | 0 |

តារាងតម្លៃលេខនៃ $d_2$

| $x$ | 0 | 2 |
|---|---|---|
| $y$ | $-1$ | 0 |

ដោយមេគុណប្រាប់ទិសស្មើនឹង $\frac{1}{2}$ ដូចគ្នា

មានន័យថាកាលណា $x$ កើន 2 នោះ $y$ និងកើន 1 ។

ត្រីកោណកែង $ABC$ និង $A'B'C'$ ប៉ុនគ្នា

វិបាក : $\angle C'A'y = \angle CAy$ នាំឱ្យ $d_1 \ // \ d_2$

ហេតុនេះ បន្ទាត់ $d_1$ និង $d_2$ មានមេគុណប្រាប់ទិសស្មើគ្នាជាបន្ទាត់ស្របគ្នា ។

> ***ជាទូទៅ :*** $d_1 : y = ax + b$ , $d_2 : y = a'x + b'$
>
> $d_1 \ // \ d_2$ លុះត្រាតែ $a = a'$

***លំហាត់គំរូទី 1 :*** $d : y = \frac{3}{2}x - 3$ និងដៅពីរចំណុច $A(-1 \ , \ 1)$ និង $B(1 \ , \ 4)$ ។

ចូរបញ្ជាក់ថា $d \ // \ AB$ ។




***ចម្លើយ :*** តារាងចំណុចនៃ $d$

ឱ្យ $x = 0$ , $y = -3$

$y = 0$ , $\frac{3}{2}x = 3$ , $x = 2$

| $x$ | 0 | 2 |
|---|---|---|
| $y$ | $-3$ | 0 |

មេគុណប្រាប់ទិសនៃ $AB$

$$\frac{y_B - y_A}{x_B - x_A} = \frac{4-1}{1-(-1)}$$

$$= \frac{3}{2}$$

មេគុណប្រាប់ទិសនៃបន្ទាត់ $AB$ ស្មើនឹងមេគុណប្រាប់ទិសនៃ $d$ នាំឱ្យ $AB \ // \ d$ ។

***លំហាត់គំរូទី 2 :*** គេឱ្យបួនចំណុច $A(-1 \ , \ 0)$ , $B(0 \ , \ 2)$ , $C(3 \ , \ 2)$ , $D(4 \ , \ 4)$

ចូរគណនាមេគុណប្រាប់ទិសនៃបន្ទាត់ $AB$ និង $CD$ ហើយបញ្ជាក់ថាវាជាបន្ទាត់ស្របគ្នា ។

***ចម្លើយ :***




បើ $a$ ជាមេគុណប្រាប់ទិសនៃបន្ទាត់ $AB$

$$a = \frac{y_B - y_A}{x_B - x_A} = \frac{2-0}{0-(-1)} = \frac{2}{1} = 2$$

បើ $a'$ ជាមេគុណប្រាប់ទិសនៃបន្ទាត់ $CD$

$$a = \frac{y_D - y_C}{x_D - x_C} = \frac{4-2}{4-3} = \frac{2}{1} = 2$$

$a = a' = 2$ បញ្ជាក់ថា $AB \parallel CD$ ។

***លំហាត់គំរូទី3 :*** ចូររកសមីការបន្ទាត់ដែលកាត់តាម $A(2\ ,\ 5)$ ហើយស្របនឹងបន្ទាត់ $d : y = 3x+4$ រួចសង់បន្ទាត់ទាំងពីរនេះ ។

***ចម្លើយ :*** តាង $M(x\ \ y)$ ឋិតនៅលើបន្ទាត់ដែលកាត់តាម $A$




បើ $d \parallel AM$ នោះមេគុណប្រាប់ទិសស្មើគ្នា

$$\frac{y-5}{x-2} = 3\ ,\ y-5 = 3(x-2)\ ,\ y = 3x-1$$

ការសង់បន្ទាត់ទាំងពីរ :

បន្ទាត់ $d : y = 3x+4$ កាត់អ័ក្ស $y'y$ ត្រង់ $x = 0\ ,\ y = 4$

គេអាចសង់ចំណុចមួយទៀតដោយឱ្យ $x = -1\ ,\ y = 1$

ព្រោះចំណុចកាត់អ័ក្ស $x'x$ ជាប្រភាគ $-\frac{4}{3}$

ចំពោះបន្ទាត់ $AM : y = 3x-1$ វាកាត់អ័ក្ស $y'y$ ត្រង់ $x = 0\ ,\ y = -1$ ។

***ប្រតិបត្តិ :*** ចូររកសមីការនៃបន្ទាត់ដែលកាត់តាមចំណុចមួយ ហើយស្របនឹងបន្ទាត់មួយទៀត ។

ក. កាត់តាមចំណុច $(0\ ,\ 0)$ ហើយស្របនឹងបន្ទាត់ $y = 3x-1$

ខ. កាត់តាមចំណុច $(6\ ,\ 3)$ ហើយស្របនឹងបន្ទាត់ $x-3y = 9$ ។

## 2.3. លក្ខខណ្ឌនៃបន្ទាត់កែង




***ឧទាហរណ៍ :*** សង់បន្ទាត់ $d_1 : y = 2x+4$

និង $d_2 : y = -\frac{1}{2}x-1$ ហើយបញ្ជាក់ថាវាជាបន្ទាត់កែងគ្នា ។

ចំពោះបន្ទាត់ $d_1$

| $x$ | 0 | −2 |
|---|---|---|
| $y$ | 4 | 0 |

ចំពោះបន្ទាត់ $d_2$

| $x$ | 0 | −2 |
|---|---|---|
| $y$ | −1 | 0 |

បន្ទាត់ $d_1$ កាត់អ័ក្ស $x'x$ ត្រង់ $A$ ហើយកាត់អ័ក្ស $y'y$ ត្រង់ $B$

បន្ទាត់ $d_2$ កាត់អ័ក្ស $x'x$ ត្រង់ $A$ ហើយកាត់អ័ក្ស $y'y$ ត្រង់ $C$

ដើម្បីបញ្ជាក់ថា $d_1 \perp d_2$ នោះគេត្រូវមាន $BC^2 = AB^2+AC^2$

$AC^2 = 1^2+2^2 = 5$ , $AB^2 = 2^2+4^2 = 5+16 = 20$

$BC^2 = 5^2 = 25$ , $25 = 20+5$ បញ្ជាក់ថាបន្ទាត់ $d_1 \perp d_2$

គេអាចសំគាល់លើមេគុណប្រាប់ទិសរបស់បន្ទាត់ $d_1$ និង $d_2$

បន្ទាត់ $d_1 : y = 2x+4$ មានមេគុណប្រាប់ទិស $a = 2$

បន្ទាត់ $d_2 : y = -\frac{1}{2}x-1$ មានមេគុណប្រាប់ទិស $a' = -\frac{1}{2}$

ផលគុណមេគុណប្រាប់ទិស $a' \times a = 2\left(-\frac{1}{2}\right) = -1$ ។

> ***ជាទូទៅ :*** បន្ទាត់ពីរ $y = ax+b$ និង $y = a'x+b'$ កែងគ្នាកាលណា $aa' = -1$ ។

***លំហាត់គំរូទី 1 :*** ចូររកតម្លៃ $a$ ដើម្បីឱ្យបន្ទាត់ $y = ax+3$ និង $y-2x = 1$ កែងគ្នា ។

***ចម្លើយ :*** បន្ទាត់ $y-2x = 1$ អាចសរសេរ $y = 2x+1$ វាកែងនឹងបន្ទាត់ $y = ax+3$

លុះត្រាតែផលគុណនៃមេគុណប្រាប់ទិសទាំងពីរស្មើនឹង $-1$

$2 \times a = -1$ , $a = -\frac{1}{2}$ ។

*លំហាត់គំរូទី 2 :* ចូររកសមីការនៃបន្ទាត់កាត់តាមចំណុច $A(-1\ ;\ 2)$ ហើយកែងនឹងបន្ទាត់ $y = 3x$ ។

*ចម្លើយ :* $M(x\ y)$ ជាចំណុចមួយនៃបន្ទាត់ដែលកាត់តាម $A$ ហើយកែងនឹងបន្ទាត់ $y = 3x$




បន្ទាត់ពីរកែងគ្នាកាលណាផលគុណនៃមេគុណប្រាប់ទិសស្មើនឹង $-1$ ។

$$\frac{y-2}{x+1}\times 3 = -1 \quad , \quad \frac{3(y-2)}{x+1} = -1$$

$$3(y-2) = -x-1 \quad , \quad 3y-6 = -x-1$$

$$y = \frac{-x}{3}+\frac{5}{3} \text{ ។}$$

*លំហាត់គំរូទី 3 :* គេឱ្យបីចំណុច $A(0\ ,\ 3)$ , $B(2\ ,\ 0)$ និង $C\left(4\ ,\ \frac{17}{3}\right)$ ។

ចូរបញ្ជាក់ថា $AB \perp AC$ ។

*ចម្លើយ :* $AB$ មានមេគុណប្រាប់ទិស $\frac{y_B-y_A}{x_B-x_A} = \frac{-3}{2}$

$AC$ មានមេគុណប្រាប់ទិស $\frac{y_C-y_A}{x_C-x_A} = \frac{\frac{17}{3}-3}{4-0} = \frac{2}{3}$

$\left(-\frac{3}{2}\right)\left(\frac{2}{3}\right) = -1$ នាំឱ្យ $AB \perp AC$ ។

*ប្រតិបត្តិ :* ចូររកសមីការបន្ទាត់ដែលកាត់តាមចំណុចមួយ ហើយកែងនឹងបន្ទាត់មួយទៀត

ក. កាត់តាម $A(2\ ,\ -1)$ ហើយកែងនឹងបន្ទាត់ $2y-x-1 = 0$

ខ. កាត់តាម $A\left(\frac{-1}{2}\ ,\ 0\right)$ ហើយកែងនឹងបន្ទាត់ $y = 2x$ ។

## 3. អនុវត្តន៍

ក្នុងជីវភាពរស់នៅគេនិយមប្រើសមីការបន្ទាត់ដើម្បីប៉ាន់ស្មាននូវចំណូលនិងចំណាយក្នុងជំនួញ ឬបម្រែបម្រួលនៃបាតុភូតអ្វីមួយ ។

*ឧទាហរណ៍ :* ចាប់ពីឆ្នាំ 1994 ដល់ 1999 ការចំណាយរបស់សាលាក្រុងបានកើនពី 2.3 ពាន់លាន ដល់ 4.8 ពាន់លានរៀល ។ គេអាចបកស្រាយទិន្នន័យខាងលើជាសមីការដែលទាក់ទងទៅនឹងប្រាក់ចំណាយតាមឆ្នាំនីមួយៗ ។

- គេប្រើ $x$ តាងឱ្យឆ្នាំ 1994 1995 1996 1997 1998 1999 ដោយ 1994 ជាឆ្នាំចាប់ផ្ដើម គេកំណត់ឆ្នាំ 1994 ជាឆ្នាំដែលត្រូវនឹង $x = 0$ ហើយឆ្នាំ 1999 ជាឆ្នាំដែល $x = 5$

• គេប្រើ $y$ តាងប្រាក់ចំណាយ

ឆ្នាំ 1994 ជាឆ្នាំដែលត្រូវនឹងប្រាក់ចំណាយ $y = 2.3$

ឆ្នាំ 1999 ជាឆ្នាំដែលត្រូវនឹងប្រាក់ចំណាយ $y = 4.8$

• បម្រែបម្រួលនៃឆ្នាំនិងប្រាក់ចំណាយ

ពីឆ្នាំ 1994 ដល់ 1999 ជាបម្រែបម្រួលនៃ $x$ $5 - 0 = 5$

ពី 2.3 ដល់ 4.8 ជាបម្រែបម្រួលនៃ $y$ $4.8 - 2.3 = 2.5$

$\frac{\text{បម្រែបម្រួលនៃ } y}{\text{បម្រែបម្រួលនៃ } x} = \frac{2.5}{5} = 0.5$ ជាមេគុណប្រាប់ទិសនៃសមីការ

• សមីការមានរាង $y = ax + b$ ដែល $a = 0.5$

$y = 0.5x + b$ ដើម្បីកំណត់ $b$ គេត្រូវឱ្យ $x = 0$

បើ ប្រាក់ចំណាយនៅឆ្នាំ 1994 គឺ $y = 2.3$ ដូចនេះ $2.3 = 0.5 \times 0 + b$ , $b = 2.3$

សរុបមកគេបានសមីការ $y = 0.5x + 2.3$

*ផ្ទៀងផ្ទាត់ :* បើ $x = 0$ , $y = 2.3$ ត្រូវនឹងការចំណាយនៃឆ្នាំ 1994

បើ $x = 5$ , $y = 0.5 \times 5 + 2.3 = 4.8$ ត្រូវនឹងការចំណាយនៃឆ្នាំ 1999

របៀបសង់ក្រាប

• ឆ្នាំតាងដោយអ័ក្ស $x'x$

• ប្រាក់ចំណាយតាងដោយអ័ក្ស $y'y$

នៅឆ្នាំ 1994 , $x = 0$ , $y = 3.2$

នៅឆ្នាំ 1999 , $x = 5$ , $y = 4.8$

បន្ទាត់កាត់តាមពីរចំណុចខាងលើ ។




*លំហាត់គំរូ :* ថាសចម្រៀងដ៏ល្បីមួយបានផ្ដើមលក់ពីខែមករា បន្ទាប់ពីលក់បានច្រើននៅខែមករានោះមក ថាសនេះនៅតែលក់បានជាបន្តបន្ទាប់ទៅតាមខែនីមួយៗ ដោយអត្រា 500 ថាសក្នុងមួយខែរហូតដល់នៅដំណាច់ខែធ្នូនាឆ្នាំដដែល គេសរុបឃើញលក់បាន 9 700 ថាស ។

ក. ចូរសរសេរសមីការដែលតាងឱ្យការលក់ថាសតាមខែនីមួយៗ ។

ខ. ចូររកចំនួនថាសដែលលក់នៅខែមករា ។

គ. គិតត្រឹមខែសីហា គេលក់ជាក់ស្ដែងបានតែថាសសរុប 7 600 តើចំនួនលក់ជាក់ស្ដែងមានលំអៀងជាមួយចំនួនថាសដែលគណនាតាមសមីការប៉ុន្មាន ?

*ចម្លើយ :*

ក. សរសេរសមីការដែលមាន $x$ និង $y$

- តាង $x$ ជាខែ

ខែមករាត្រូវនឹង $x = 0$ ហើយខែធ្នូត្រូវនឹង $x = 11$

- តាង $y$ ជាចំនួនថាសដែលបានលក់

$y = 9\ 700$ ត្រូវនឹង $x = 11$

- អត្រា 500 ថាសក្នុងមួយខែជាមេគុណប្រាប់ទិស

- សមីការ មានរាង $y = ax + b$ , $y = 500x + b$ រកតម្លៃ $b$

ផ្ទៀងផ្ទាត់សមីការ

$x = 11$ , $y = 9\ 700$ , $9\ 700 = 500 \times 11 + b$ , $b = 4\ 200$

ដូចនេះ សមីការសរសេរ $y = 500x + 4\ 200$ ។

ខ. ចំនួនលក់នៅខែមករា

ខែមករាត្រូវនឹង $x = 0$

$x = 0$ , $y = 500 \times 0 + 4\ 200 = 4\ 200$ ។

គ. ប្រៀបធៀបការលក់ជាក់ស្តែងនិងការលក់តាមសមីការត្រឹមខែសីហា

ការលក់តាមសមីការ $x = 7$ , $y = 500 \times 7 + 4\ 200 = 7\ 700$ (ខែសីហាជាខែដែលត្រូវនឹង $x = 7$ )

ការលក់ជាក់ស្តែង $y = 7\ 600$

លំអៀង $7\ 700 - 7\ 600 = 100$ ថាស

មានន័យថាចំនួនថាសដែលប៉ាន់ស្មានដោយសមីការលើសពីការលក់ជាក់ស្តែង100ថាស ។

*ប្រតិបត្តិ :* នៅម៉ោង 12ថ្ងៃត្រង់កំដៅមានសីតុណ្ហភាព 40° ។ សីតុណ្ហភាពនេះនឹងចុះវិញក្នុងអត្រា 2° ក្នុងមួយម៉ោង ។ តើនៅម៉ោងប៉ុន្មានទើបមានសីតុណ្ហភាពស្មើនឹង 26° ។

## លំហាត់

1. ចូរសង់បន្ទាត់ដែលកាត់តាមមួយចំណុចនិងមានមេគុណប្រាប់ទិស

ក. $a = 2$ , $(-4 , 1)$ ខ. $a = -\frac{2}{3}$ , $(1 , 5)$ ។

2. ចូររកមេគុណប្រាប់ទិសនៃបន្ទាត់ដែលកាត់តាមពីរចំណុច

ក. $(3 , 1)$ , $(5 , 4)$ ខ. $(3 , 0)$ , $(-3 , -6)$

គ. $(-2 , -1)$ , $(-4 , -4)$ ឃ. $(1 , 4)$ , $(4 , -2)$ ។

3. ចូររកសមីការនៃបន្ទាត់ដែលកាត់តាមពីរចំណុច

ក. $(-6 , 1)$ , $(6 , -2)$ ខ. $(3 , -4)$ , $(-9 , 2)$

គ. $(2 , 0)$ , $(1 , -8)$ ឃ. $(-4.2 , -4)$ , $(-2.2 , 6)$

ង. $(2.5 , -1)$ , $(0.5 , 1)$ ច. $(0 ; 5)$ , $(3 , -2.5)$ ។

4. ការរីកចម្រើននៃផ្នែកឧស្សាហកម្មនិងសេវាកម្មនានាបានបណ្តាលឱ្យចំនួនកសិករថយចុះជាលំដាប់ទៅតាមអត្រា 0.8% ក្នុងមួយឆ្នាំ ។ បើកសិករមានចំនួន 80% នៅឆ្នាំ 2000 ចូររកសមីការដែលទាក់ទងទៅនឹងភាគរយនៃកសិករដែលបានថយចុះទៅតាមឆ្នាំ ។ ប្រើសមីការនេះដើម្បីប៉ាន់ស្មានរកចំនួនកសិករនៅឆ្នាំ 2008 ។

5. ការយល់ដឹងអំពីគ្រោះថ្នាក់នៃបារី បណ្តាលឱ្យចំនួនអ្នកជក់បានថយចុះចាប់ពីឆ្នាំ 1992 មក ។ បើអ្នកជក់មានចំនួន 38% នៅឆ្នាំ 1992 ហើយចំនួននេះបានថយចុះមកត្រឹម 15.5% នៅឆ្នាំ 2007 ។ ចូររកសមីការដែលទាក់ទងនឹងចំនួនអ្នកជក់និងចំនួនឆ្នាំ ។

6. សរសេរសមីការនិងសង់បន្ទាត់ដែលមានមេគុណប្រាប់ទិស $m$ ហើយកាត់តាមចំណុច $P$ រួចរកកូអរដោនេនៃចំណុចប្រសព្វរវាងបន្ទាត់និងអ័ក្ស ។

ក. $m = 1$ , $P(0 , 2)$ ខ. $m = -1$ , $P(1 , 0)$ គ. $m = -2$ , $P(3 , -1)$

ឃ. $m = \frac{3}{5}$ , $P(-1 , -4)$ ង. $m = 0$ , $P(2 , 1)$ ច. $m = -\frac{3}{2}$ , $P(0 , 3)$ ។

7. ក្នុងចំណោមបន្ទាត់បីខាងក្រោម តើមួយណាស្របគ្នា ?

ក. $2x + 3y = -11$ ខ. $4x + 8y - 1 = 0$ គ. $y = -\frac{2}{3}x + 1$ ។

8. ចូររកមេគុណប្រាប់ទិសនៃបន្ទាត់តាងសមីការខាងក្រោម រួចប្រាប់ថាតើគូសមីការណាខ្លះដែលមានបន្ទាត់ស្របគ្នា ។

ក. $y = x+4$ , $x-y+5 = 0$ ខ. $y = 2x-3$ , $x+2y+1 = 0$

គ. $3x-y+4 = 0$ , $y-2 = 3(x+1)$ ឃ. $2y = 5x+6$ , $5x+2y-1 = 0$ ។

9. តើគូសមីការណាខ្លះដែលមានបន្ទាត់កែងគ្នា ?

ក. $y = 3x+1$ , $y = -\frac{1}{3}x$

ខ. $y = 2x+5$ , $x-2y+6 = 0$

គ. $y = 5x-4$ , $x+5y-1 = 0$ ។

10. ចូរកំណត់សមីការបន្ទាត់ដែលស្របនឹង

ក. $y = 3x-4$ ហើយកាត់តាមចំណុច $(5\ ,\ 1)$

ខ. $3x-2y+5 = 0$ ហើយកាត់តាមចំណុច $(-2\ ,\ 4)$

គ. $2x+2y+9 = 0$ ហើយកាត់តាមចំណុច $\left(-\frac{5}{3}\ ,\ 0\right)$

ឃ. $x-5y+6 = 0$ ហើយកាត់តាមចំណុច $(0\ ,\ 0)$ ។

11. ចូរកំណត់សមីការបន្ទាត់កែងនឹង

ក. $y = \frac{1}{2}x+4$ ហើយកាត់តាមចំណុច $(5\ ,\ 0)$

ខ. $x-y+5 = 0$ ហើយកាត់តាមចំណុច $(0\ ,\ 0)$

គ. $8x+3y+1 = 0$ ហើយកាត់តាមចំណុច $(-1\ ,\ 4)$

ឃ. $y = -x+6$ ហើយកាត់តាមចំណុច $\left(-4\ ,\ -\frac{2}{3}\right)$ ។

12. ក. ចូរកំណត់សមីការនៃបន្ទាត់ $d_1$ កាត់តាមចំណុច $A(-3\ ,\ 5)$ ដែលមានមេគុណប្រាប់ទិសស្មើនឹង $-2$ រួចសង់បន្ទាត់នេះ ។

ខ. គេមានសមីការបន្ទាត់ $d_2 : y = (m-1)x+2$ ។ ចូរកំណត់តម្លៃ $m$ ដើម្បីឱ្យបន្ទាត់ $d_2$ ស្រប $d_1$ ។ តើមានតម្លៃ $m$ ដែលឱ្យ $d_2$ កែងនឹង $d_1$ ឬទេ ? ចូរសរសេរសមីការនៃបន្ទាត់ត្រូវនឹងតម្លៃ $m$ នីមួយៗ រួចសង់បន្ទាត់ទាំងនោះ ។

គ. $B$ ជាចំណុចដែលមានកូអរដោនេ $(6\ ,\ 0)$ ។ ចូរសរសេរសមីការនៃបន្ទាត់កាត់តាម $A$ និង $B$ រួចបញ្ជាក់ចំណុចជួបនឹងអ័ក្ស $y'y$ ។

13. ក្នុងតម្រុយអរតូណរមេ គេឱ្យបីចំណុច $A(0\ ,\ 6)$ , $B(-3\ ,\ 0)$ និង $C(6\ ,\ 0)$ ។

ក. ចូររកសមីការនៃបន្ទាត់ $AB$ និង $AC$ ។

ខ. ចូររកសមីការនៃបន្ទាត់ $D$ កាត់តាមចំណុច $C$ ហើយកែងនឹងបន្ទាត់ $AB$ ។

គ. ចូររកសមីការនៃបន្ទាត់ $D'$ កាត់តាមចំណុច $B$ ហើយស្របនឹងបន្ទាត់ $AC$ ។

14. ក. ក្នុងតម្រុយអរតូណរមេ រកសមីការនៃបន្ទាត់កាត់តាមចំណុច $A(6\ ,\ 2)$ និង $B(2\ ,\ -2)$ ។ ចូររកសមីការនៃខ្សែមេដ្យាទ័ររបស់ $[AB]$ ។

ខ. គេឱ្យចំណុច $C(-2\ ,\ 6)$ ។ ចូរបង្ហាញថា $CAB$ ជាត្រីកោណសមបាត ។

គ. ចូររកសមីការនៃបន្ទាត់ $C_2$ កាត់តាម $C$ ហើយស្របនឹង $AB$ ។

ឃ. ចូរបង្ហាញថាបន្ទាត់ $C_2$ កាត់តាម $M(-5\ ,\ 3)$ ។

15. ក្នុងតម្រុយអរតូណរមេ គេឱ្យចំណុច $A(-6\ ,\ 0)$ , $B(6\ ,\ 0)$ និង $C(3\ ,\ 9)$ ។

ក. ចូររកសមីការនៃជ្រុងត្រីកោណ $ABC$ ។

ខ. ចូរសរសេរសមីការនៃខ្សែមេដ្យាទ័ររបស់ជ្រុងត្រីកោណ $ABC$ ។

16. បើចំណុច $(a\ ,\ 6)$ និង $(2\ ,\ a)$ ឋិតនៅលើបន្ទាត់ $4x+2y=b$ ។ ចូរកំណត់តម្លៃ $a$ និង $b$ រួចសង់បន្ទាត់នោះ ។

17. តាមការអង្កេតរោងចក្រនានាលើសកលលោកដែលប្រើថាមពលពីប្រេងបានថយចុះពីមួយឆ្នាំទៅមួយឆ្នាំ ។ នៅឆ្នាំ 1973 រោងចក្រដែលប្រើថាមពលពីប្រេងមានតែ 47% ហើយនៅឆ្នាំ 1990 ចំនួននេះបានថយមកត្រឹម 38% ។ ចូរកំណត់សមីការដែលទាក់ទងទៅនឹងការប្រើថាមពលពីប្រេងទៅតាមឆ្នាំ $x$ ។ គេកំណត់យក $x=0$ ត្រូវនឹងឆ្នាំ 1970 ។

មេរៀនទី

# 11 ប្រព័ន្ធសមីការដឺក្រេទី១មានពីរអញ្ញាត

**វត្ថុបំណង**

- ដោះស្រាយប្រព័ន្ធសមីការតាមក្រាភិច ។
- ដោះស្រាយប្រព័ន្ធសមីការតាមវិធីជំនួស ។
- ដោះស្រាយប្រព័ន្ធសមីការតាមវិធីបំបាត់ ។
- ដោះស្រាយចំណោទ ។

## 1. ដំណោះស្រាយប្រព័ន្ធសមីការតាមក្រាភិច

*ឧទាហរណ៍ទី 1 :* ដោះស្រាយសមីការ $2x+y=2$

សមីការមានពីរអញ្ញាត $x$ និង $y$ វាមានគូចម្លើយរាប់មិនអស់

គេអាចបានគូចម្លើយដោយជំនួសតម្លៃ $x$ ណាមួយក្នុងសមីការ $y=-2x+2$ រួចរក $y$

បើ $x=-2$ , $y=-2(-2)+2=6$

បើ $x=-1$ , $y=-2(-1)+2=4$

បើ $x=0$ , $y=-2(0)+2=2$

បើ $x=1$ , $y=-2(1)+2=0$

បើ $x=2$ , $y=-2(2)+2=-2$




គេអាចបកស្រាយគូចម្លើយដោយបន្ទាត់មួយ

ដែលមានសមីការ $2x+y=2$ ឬ $y=-2x+2$

| $x$ | 0 | 1 |
|---|---|---|
| $y$ | 2 | 0 |

កូអរដោនេនៃគ្រប់ចំណុចដែលឋិតនៅលើបន្ទាត់ជាគូចម្លើយនៃសមីការ $2x+y=2$ ។

***ឧទាហរណ៍ទី 2 :*** ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} x-y=4 & (1) \\ 2x+y=2 & (2) \end{cases}$$

ចម្លើយនៃប្រព័ន្ធសមីការជាចម្លើយរួមនៃសមីការ (1) និងសមីការ (2) ។ ដោយសមីការ (1) និងសមីការ (2) តាងដោយបន្ទាត់រៀងគ្នា $x-y=4$ និង $2x+y=2$

ក្នុងករណីនេះគេត្រូវសង់បន្ទាត់ទាំងពីរ




ចំពោះសមីការ $x-y=4$ (1)

| $x$ | 0 | 4 |
|---|---|---|
| $y$ | −4 | 0 |

ចំពោះសមីការ $2x+y=2$ (2)

| $x$ | 0 | 1 |
|---|---|---|
| $y$ | 2 | 0 |

ដោះស្រាយប្រព័ន្ធគឺរកកូអរដោនេនៃចំណុច ដែលឋិតនៅលើបន្ទាត់ (1) ផងនិងបន្ទាត់ (2) ផង

មានន័យថាជាកូអរដោណេនៃចំណុចប្រសព្វរវាងបន្ទាត់ទាំងពីរ ។

$I$ ជាចំណុចប្រសព្វ ដើម្បីរកកូអរដោនេរបស់វា គេគូសចំណោលកែងពី $I$ មកលើអ័ក្សទាំងពីរ

តាមក្រាបគេបាន $x=2$ , $y=-2$

ដូចនេះ $(2\ ,\ -2)$ ជាគូចម្លើយនៃប្រព័ន្ធសមីការ

***ផ្ទៀងផ្ទាត់ :*** ជំនួស $(2\ ,\ -2)$ ក្នុងសមីការ (1) និង (2)

ចំពោះសមីការ (1) : $2-(-2)=2+2=4$

ចំពោះសមីការ (2) : $2(2)+(-2)=4-2=2$ ។

***លំហាត់គំរូទី 1 :*** ចូរដោះស្រាយប្រព័ន្ធសមីការ $\begin{cases} x+3y=6 & (1) \\ x+3y=-3 & (2) \end{cases}$ ។

***ចម្លើយ :***

សង់បន្ទាត់ (1) និង (2) រួចដោះស្រាយប្រព័ន្ធសមីការតាមក្រាប ។ ក្នុងករណីនេះគេត្រូវរកកូអរដោនេនៃចំណុចប្រសព្វរវាងបន្ទាត់ទាំងពីរដោយធ្វើចំណោលកែងនៃចំណុចប្រសព្វមកលើអ័ក្សទាំងពីរ ។

ចំពោះសមីការ $x+3y = 6$ (1)

| $x$ | 0 | 6 |
|---|---|---|
| $y$ | 2 | 0 |

ចំពោះសមីការ $x+3y = -3$ (2)

| $x$ | 0 | −3 |
|---|---|---|
| $y$ | −1 | 0 |




តាមក្រាប បន្ទាត់ទាំងពីរស្របគ្នាគឺគ្មានចំណុចប្រសព្វទេ ។ ក្នុងករណីនេះ គេថាប្រព័ន្ធសមីការគ្មានចម្លើយ ។

បើគេពិនិត្យមេគុណប្រាប់ទិសនៃបន្ទាត់ទាំងពីរក៏ឃើញថាវាស្របគ្នាដែរ ។

(1) $x+3y = 6$ ឬ $y = -\frac{x}{3}+2$

(2) $x+3y = -3$ ឬ $y = -\frac{x}{3}+1$

ឃើញថា $a = a' = -\frac{1}{3}$

***លំហាត់គំរូទី 2 :*** ចូរដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} y = 4-x & (1) \\ \frac{x}{2}+\frac{y}{2} = 2 & (2) \end{cases}$$ ។

***ចម្លើយ :*** សង់បន្ទាត់នៃសមីការ (1) និង (2)

ចំពោះសមីការ $y = 4-x$ (1)

| $x$ | 0 | 4 |
|---|---|---|
| $y$ | 4 | 0 |

ចំពោះសមីការ $\frac{x}{2}+\frac{y}{2} = 2$ (2)

| $x$ | 0 | 4 |
|---|---|---|
| $y$ | 4 | 0 |




តាមក្រាបបន្ទាត់ (1) និងបន្ទាត់ (2) ត្រួតស៊ីគ្នា មានន័យថាវាមានចំណុចរួមច្រើនរាប់មិនអស់ ក្នុងករណីនេះគេថាប្រព័ន្ធសមីការមានគូចម្លើយច្រើនរាប់មិនអស់ ។

***ប្រតិបត្តិ :*** ចូរដោះស្រាយប្រព័ន្ធសមីការតាមក្រាប

$$\begin{cases} 4x+3y = 4 \\ 3x+y = -2 \end{cases}$$ ។

## 2. ដំណោះស្រាយប្រព័ន្ធសមីការតាមវិធីជំនួស

ក្នុងប្រព័ន្ធសមីការមានពីរអញ្ញាត គេអាចគណនាតម្លៃនៃអញ្ញាតណាមួយក្នុងសមីការ (1) រួចយកទៅជំនួសក្នុងសមីការទី (2) ធ្វើយ៉ាងនេះគេនឹងបានសមីការមួយដែលមានតែមួយអញ្ញាត ។

***ឧទាហរណ៍ :*** ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} y = 7-3x & (1) \\ 2x-3y = 12 & (2) \end{cases} ។$$

ជំនួសតម្លៃ $y = 7-3x$ ក្នុងសមីការ (2)

$$2x-3(7-3x) = 12\ ,\ 2x-21+9x = 12$$

$$11x = 12+21$$

$$11x = 33 \text{ ឬ } x = 3$$

ជំនួសតម្លៃ $x = 3$ ក្នុងសមីការ (1)

$$y = 7-3(3) = 7-9 = -2$$

ដូចនេះ (3 , −2) ជាគូចម្លើយនៃប្រព័ន្ធសមីការ ។




គេអាចផ្ទៀងផ្ទាត់តាមក្រាប

សមីការ (1) $y = 7-3x$

| $x$ | 0 | 1 |
|---|---|---|
| $y$ | 7 | 4 |

សមីការ (2) $2x-3y = 12$

| $x$ | 0 | 6 |
|---|---|---|
| $y$ | −4 | 0 |

ធ្វើចំណោលកែងនៃចំណុចប្រសព្វ គេបាន (3 , −2)

***លំហាត់គំរូទី 1 :*** ចូរដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} x-2y = 17 & (1) \\ 3x-6y = 11 & (2) \end{cases} ។$$

*ចម្លើយ :*

(1) $x-2y = 17$ , $x = 17+2y$ ជំនួស $x = 17+2y$ ក្នុងសមីការ (2)

$3(17+2y)-6y = 11$

$51+6y-6y = 11$

$oy = -41$ ទោះ $y$ យកតម្លៃស្មើប៉ុន្មានក៏ដោយក៏អង្គទី 1 មិនអាចស្មើនឹង $-41$

ដូចនេះសមីការ $oy = -41$ គ្មានចម្លើយ នាំឱ្យប្រព័ន្ធសមីការគ្មានចម្លើយ ។

*លំហាត់គំរូទី 2 :* ចូរដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} -x+3y = -1 & (1) \\ x-3y = 1 & (2) \end{cases}$$ ។

*ចម្លើយ :*

(1) $-x+3y = -1$ , $x = 3y+1$ យកតម្លៃ $x$ ជំនួសក្នុងសមីការ (2)

$3y+1-3y = 1$ , $oy = 0$ ទោះ $y$ យកតម្លៃយ៉ាងណាក៏អង្គទី 1 នៅតែស្មើនឹង 0

គេថាសមីការ $oy = 0$ មានចម្លើយរាប់មិនអស់ នាំឱ្យប្រព័ន្ធសមីការមានចម្លើយរាប់មិនអស់ ។

*ប្រតិបត្តិ :* ចូរដោះស្រាយប្រព័ន្ធសមីការ

ក. $\begin{cases} y+6 = 3x & (1) \\ 9x-2y = 3 & (2) \end{cases}$ ខ. $\begin{cases} 3x-4y = 8 & (1) \\ 4x+y = 17 & (2) \end{cases}$ ។

# 3. ដំណោះស្រាយប្រព័ន្ធសមីការតាមវិធីបូក

*ឧទាហរណ៍ទី 1 :* ដោះស្រាយប្រព័ន្ធសមីការ $\begin{cases} -2x+y = -11 & (1) \\ 5x-y = 26 & (2) \end{cases}$

គេសង្កេតឃើញថាអញ្ញាត $y$ មានសញ្ញាផ្ទុយគ្នា ហើយមានមេគុណស្មើគ្នាទៀត ។ បើគេបូកអង្គនៃសមីការ (1) និងសមីការ (2) នោះអញ្ញាត $y$ នឹងត្រូវបាត់ក្នុងករណីនេះ គេបានសមីការមួយមានតែមួយអញ្ញាត ។

$$\begin{cases} -2x+y = -11 & (1) \\ 5x-y = 26 & (2) \end{cases}$$

$3x = 15$ , $x = 5$ ជំនួស $x = 5$ ក្នុង (1)

$-2(5)+y = -11$ , $-10+y = -11$ , $y = -11+10 = -1$

ហេតុនេះ $(5\ ,\ -1)$ ជាគូចម្លើយនៃប្រព័ន្ធសមីការ ។

***ផ្ទៀងផ្ទាត់ :*** ជំនួស (5 , −1) ក្នុងសមីការ (1) និង (2)

(1) $-2(5)+(-1) = -10-1 = -11$

(2) $5(5)-(-1) = 25+1 = 26$ ។

***ឧទាហរណ៍ទី 2 :*** ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} 2x+3y = 21 & (1) \\ 3x+2y = 19 & (2) \end{cases}$$ ។

ដើម្បីបំបាត់អញ្ញាត $y$ គេត្រូវធ្វើវាឱ្យមានមេគុណស្មើគ្នាហើយមានសញ្ញាផ្ទុយគ្នា ក្នុងករណីនេះ គេត្រូវគុណ (1) នឹង −2 ហើយគុណ (2) នឹង 3

$$\begin{cases} 2x+3y = 21 & \times -2 \\ 3x+2y = 19 & \times 3 \end{cases} \quad , \quad \begin{cases} -4x-6y = -42 \\ 9x+6y = 57 \end{cases}$$

$$5x = 15 \ , \ x = 3$$

ជំនួស $x = 3$ ក្នុងសមីការ (1)

$2(3)+3y = 21 \ , \ 6+3y = 21 \ , \ 3y = 15 \ , \ y = 5$

ដូចនេះ (3 , 5) ជាគូចម្លើយនៃប្រព័ន្ធសមីការ ។

***លំហាត់គំរូទី 1 :*** ចូរដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} \frac{x}{2}-\frac{y}{5} = 1 & (1) \\ y-\frac{x}{3} = 8 & (2) \end{cases}$$ ។

***ចម្លើយ :***

(1) អាចសរសេរ $\frac{x}{2}-\frac{y}{5} = 1 \ , \ 5x-2y = 10 \quad (1)$

(2) អាចសរសេរ $y-\frac{x}{3} = 8 \ , \ 3y-x = 24 \quad (2)$

យើងបាន $\begin{cases} 5x-2y = 10 & \\ -x+3y = 24 & \times 5 \end{cases} \quad , \quad \begin{cases} 5x-2y = 10 \\ -5x+15y = 120 \end{cases}$

$$13y = 130 \ , \ y = 10$$

ជំនួស $y = 10$ ក្នុង (2)

$3(10)-x = 24 \ , \ x = 3(10)-24 = 30-24 = 6$

ដូចនេះ (6 , 10) ជាគូចម្លើយនៃប្រព័ន្ធសមីការ ។

*ផ្ទៀងផ្ទាត់ :*

(1) $\frac{6}{2}-\frac{10}{5} = 3-2 = 1$

(2) $10-\frac{6}{3} = 10-2 = 8$ ។

***លំហាត់គំរូទី 2 :*** ចូរដោះស្រាយប្រព័ន្ធ $\begin{cases} 3(x-y)-\frac{1}{3}(x+y) = 30 & (1) \\ x+y+\frac{5}{3}(x-y) = 22 & (2) \end{cases}$ ។

***ចម្លើយ :*** គេអាចសម្រួលសមីការនីមួយៗ ឱ្យងាយរួចធ្វើវិធីបំបាត់ដោយបូក ប៉ុន្តែគេសង្កេតឃើញមានតួ $(x-y)$ និងតួ $(x+y)$ ឋិតក្នុងសមីការ (1) និង (2) ដូចគ្នា ។

ក្នុងករណីនេះគេតាង $a = x+y$ , $b = x-y$

ប្រព័ន្ធសមីការទៅជា $\begin{cases} 3b-\frac{1}{3}a = 30 & (3) \\ a+\frac{5}{3}b = 22 & (4) \end{cases}$ ឬ $\begin{cases} 9b-a = 90 & (5) & \times 3 \\ 5b+3a = 66 & (6) \end{cases}$

$$\begin{cases} 27b-3a = 270 \\ 5b+3a = 66 \end{cases}$$

$$32b = 336 \ , \ b = \frac{21}{2}$$

ជំនួស $b = \frac{21}{2}$ ក្នុង (5)

$$9\times\frac{21}{2}-a = 90 \ , \ a = 9\times\frac{21}{2}-90$$

$$= \frac{189-180}{2} = \frac{9}{2}$$

ដោយ $a = \frac{9}{2}$ , $b = \frac{21}{2}$ នោះ $\begin{cases} x+y = a \\ x-y = b \end{cases}$ ឬ $\begin{cases} x+y = \frac{9}{2} \\ x-y = \frac{21}{2} \end{cases}$

$$2x = 15 \ , \ x = \frac{15}{2}$$

$$y = \frac{9}{2}-x = \frac{9}{2}-\frac{15}{2} = -\frac{6}{2} = -3$$

ដូចនេះ $\left(\frac{15}{2}\ ,\ -3\right)$ ជាគូចម្លើយនៃប្រព័ន្ធសមីការ

*ផ្ទៀងផ្ទាត់ :* ជំនួស $\left(\frac{15}{2}\ ,\ -3\right)$ ក្នុងសមីការ (1) និង (2)

(1) $3\left(\frac{15}{2}+3\right)-\frac{1}{3}\left(\frac{15}{2}-3\right) = 3\left(\frac{21}{2}\right)-\frac{1}{3}\left(\frac{9}{2}\right) = \frac{63}{2}-\frac{3}{2} = \frac{60}{2} = 30$

(2) $\frac{15}{2}-3+\frac{5}{3}\left(\frac{15}{2}+3\right) = \frac{9}{2}+\frac{5}{3}\left(\frac{21}{2}\right) = \frac{9}{2}+\frac{35}{2} = \frac{44}{2} = 22$ ។

*លំហាត់គំរូទី3 :* ចូរដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} \dfrac{x}{2} = \dfrac{y}{5} & (1) \\ x+y = 21 & (2) \end{cases} \text{ ។}$$

***ចម្លើយ :*** គេអាចប្រើលក្ខណៈនៃសមាមាត្រ ដើម្បីដោះស្រាយប្រព័ន្ធសមីការ

$$\frac{x}{2} = \frac{y}{5} = \frac{x+y}{2+5} = \frac{21}{7} = 3$$

$$\frac{x}{2} = 3 \;,\; x = 6 \;,\; \frac{y}{5} = 3 \;,\; y = 15$$

$(6 \;,\; 15)$ ជាគូចម្លើយ

គេក៏អាចដោះស្រាយតាមវិធីបំបាត់ដោយបូក

$(1)\quad 2y = 5x \;,\; 5x - 2y = 0$

យើងបានប្រព័ន្ធ $\begin{cases} 5x-2y = 0 \\ x+y = 21 \end{cases}$ ឬ $\begin{cases} 5x-2y = 0 \\ 2x+2y = 42 \end{cases}$

$$7x = 42 \;,\; x = 6 \;,\; y = 15 \text{ ។}$$

***ប្រតិបត្តិ :*** ចូរដោះស្រាយប្រព័ន្ធសមីការ

ក. $\begin{cases} 4x-3y = 9 \\ -3x+5y = 7 \end{cases}$ ខ. $\begin{cases} 7x+3(y-3) = 5(x+y) \\ 7(x-1)-6y = 5(x-y) \end{cases}$ ។

## 4. ចំណោទនៃប្រព័ន្ធសមីការ

***ចំណោទទី1 :*** ចតុកោណកែងមួយមានបរិមាត្រស្មើនឹង $38cm$ ។ គេដឹងថាបណ្ដោយលើស 3 ដងនៃទទឹងនិង $1cm$ ។ ចូររកប្រវែងទទឹងនិងបណ្ដោយនៃចតុកោណកែង ។

***ចម្លើយ :***




សម្មតិកម្ម :

- បរិមាត្រស្មើ $38cm$
- បណ្ដោយវែងជាង 3 ដងនៃទទឹងនិង $1cm$

សំណួរ : រកទទឹងនិងបណ្ដាយ

ការតាងអញ្ញាត : តាង $x$ ជាទទឹង ហើយ $y$ ជាបណ្ដោយ

គំនិតបន្ថែម : បរិមាត្រស្មើ $2(x+y)$

ប្រព័ន្ធសមីការ :

$$\begin{cases} 2(x+y) = 38 & (1) \\ y-3x = 1 & (2) \end{cases}$$

✍ *ដំណោះស្រាយ :*

$$\begin{cases} 2(x+y) = 38 \\ y-3x = 1 \end{cases} \text{ ឬ } \begin{cases} x+y = 19 \\ y-3x = 1 \end{cases} \text{ ឬ } \begin{cases} y+x = 19 \\ y-3x = 1 \end{cases} \text{ ឬ } \begin{cases} y+x = 19 \\ -y+3x = -1 \end{cases}$$

$$4x = 18$$

$$4x = 18 \ , \ x = \frac{9}{2} \ , \ y = 1+3x = 1+3\times\frac{9}{2} = 1+\frac{27}{2} = \frac{29}{2}$$

ដូចនេះ $x = \frac{9}{2} = 4.5cm$

$y = \frac{29}{2} = 14.5cm$ ។

*ការផ្ទៀងផ្ទាត់ :* បរិមាត្រ $2(x+y) = 2(4.5+14.5) = 2(19) = 38$

$y-3x = 14.5-3\times4.5 = 14.5-13.5 = 1$ ។

*ចំណោទទី 2 :* គេទិញសៀវភៅ 6 ក្បាលនិងប៊ិច 8 ដើមរួមគ្នា ថ្លៃ 14 000៛ ។ មួយសប្តាហ៍ក្រោយមកគេទិញសៀវភៅ 9 ក្បាលនិងប៊ិច 6 ដើមដដែលនេះទៀតរួមគ្នាថ្លៃ 13 200៛ ។ ដោយដឹងថាគេនៅរក្សាតម្លៃទំនិញដដែល ចូររកតម្លៃនៃសៀវភៅ 1 ក្បាលនិងប៊ិចមួយដើម ។

*ចម្លើយ :*

សម្មតិកម្ម :

- លើកទី 1 ទិញសៀវភៅ 6 ក្បាលនិងប៊ិច 8 ដើម អស់ប្រាក់ 14 000៛
- លើកទី 2 ទិញសៀវភៅ 9 ក្បាលនិងប៊ិច 6 ដើម អស់ប្រាក់ 13 200៛

សំណួរ : រកតម្លៃនៃសៀវភៅនិងប៊ិច

ការតាងអញ្ញាត : តាង $x$ ជាថ្លៃសៀវភៅ ហើយ $y$ ជាថ្លៃប៊ិចនីមួយៗ

គំនិតបន្ថែម : សៀវភៅ 1 ក្បាលថ្លៃ $x$ រៀល , សៀវភៅ 6 ក្បាលថ្លៃ $6x$

ប៊ិច 1 ដើមថ្លៃ $y$ រៀល , ប៊ិច 8 ដើមថ្លៃ $8y$

ប្រព័ន្ធសមីការ :

$$\begin{cases} 6x+8y = 14\ 000 & (1) \\ 9x+6y = 13\ 200 & (2) \end{cases}$$

✍ *ដំណោះស្រាយ :*

$$\begin{cases}6x+8y = 14\ 000\\9x+6y = 13\ 200\end{cases} \text{ ឬ } \begin{cases}3x+4y = 7\ 000\\3x+2y = 4\ 400\end{cases} \text{ ឬ } \begin{cases}3x+4y = 7\ 000\\-3x-2y = -4\ 400\end{cases}$$

$$2y = 2\ 600\ ,\ y = 1\ 300\ \text{៛}\ ,\ x = 600\ \text{៛}$$

សៀវភៅមួយក្បាលថ្លៃ 600៛

ប៊ិចមួយដើមថ្លៃ 1 300៛

***ផ្ទៀងផ្ទាត់ :*** $6\times 600\text{៛} + 8\times 1\ 300\text{៛} = 3\ 600\text{៛} + 10\ 400\text{៛} = 14\ 000\text{៛}$ (1)

$9\times 600\text{៛} + 6\times 1\ 300\text{៛} = 5\ 400\text{៛} + 7\ 800\text{៛} = 13\ 200\text{៛}$ (2) ។

***ចំណោទទី 3 :*** ពូសុខវិនិយោគប្រាក់ 5 លានរៀល ដើម្បីដាក់យកការប្រាក់ទៅតាមអត្រាការប្រាក់រៀងគ្នា 8% និង 6% ។ ដោយដឹងថាគាត់ទទួលបានការប្រាក់សរុប 360 000៛ក្នុងមួយឆ្នាំ ។ ចូររកដើមទុនដែលគាត់បានដាក់តាមអត្រានីមួយៗ ។

***ចម្លើយ :***

សម្មតិកម្ម :

- ប្រាក់ដើមសរុប 5 000 000៛
- អត្រាការប្រាក់មានពីរប្រភេទ 8% និង 6%
- ការប្រាក់សរុបបាន 360 000៛

សំណួរ : រកប្រាក់ដែលបានដាក់តាមអត្រា 8% និង 6%

ការតាងអញ្ញាត : តាង $x$ ជាប្រាក់ដែលដាក់តាមអត្រា 8%

តាង $y$ ជាប្រាក់ដែលដាក់តាមអត្រា 6%

គំនិតបន្ថែម : បើ $x$ ដាក់តាមអត្រា 8% នោះការប្រាក់ត្រូវជា $\frac{8x}{100}$

បើ $y$ ដាក់តាមអត្រា 6% នោះការប្រាក់ត្រូវជា $\frac{6y}{100}$

ប្រព័ន្ធសមីការ :

$$\begin{cases}x+y = 5\ 000\ 000 & (1)\\ \dfrac{8x}{100}+\dfrac{6y}{100} = 360\ 000 & (2)\end{cases}$$

✍ **ដំណោះស្រាយ :**

$$\begin{cases} x+y = 5\ 000\ 000 \\ \dfrac{8x}{100}+\dfrac{6y}{100} = 360\ 000 \end{cases} \quad ឬ \quad \begin{cases} x+y = 5\ 000\ 000 \\ 8x+6y = 36\ 000\ 000 \end{cases}$$

$$ឬ \quad \begin{cases} x+y = 5 \\ 8x+6y = 36 \end{cases}$$ ឯកតាជាលានរៀល

$$\begin{cases} -6x-6y = -30 \\ 8x+6y = 36 \end{cases}$$

$2x = 6$ , $x = 3$ , $y = 2$ , $x = 3\ 000\ 000$ ៛ , $y = 2\ 000\ 000$ ៛

ចំពោះអត្រា 8% គាត់ដាក់ 3 000 000 ៛

ចំពោះអត្រា 6% គាត់ដាក់ 2 000 000 ៛

**ផ្ទៀងផ្ទាត់ :** ការប្រាក់តាមអត្រា 8% $\dfrac{8\times 3\ 000\ 000}{100} = 240\ 000$ ៛

ការប្រាក់តាមអត្រា 6% $\dfrac{6\times 2\ 000\ 000}{100} = 120\ 000$ ៛

ការប្រាក់សរុបបាន : $240\ 000+120\ 000 = 360\ 000$ ៛ ។

**ប្រតិបត្តិ :**

ក. ផលបូកនៃពីរចំនួនស្មើនឹង 50 ផលដកនៃ 3 ដងចំនួនទី1 និង 2 ដងនៃចំនួនទី2 ស្មើនឹង 60 ។ ចូររកចំនួនទាំងពីរនោះ ។

ខ. សួនរាងចតុកោណកែងមួយមានបរិមាត្រស្មើនឹង $158m$ ។ គេដឹងថាបណ្តោយលើសទទឹង $5m$ ចូររកទទឹងនិងបណ្តោយនៃចតុកោណកែង ។

## ? លំហាត់

1. តើគូអរដោនេដែលគេឱ្យខាងក្រោមជាចម្លើយរបស់ប្រព័ន្ធសមីការឬទេ ?

ក. $\begin{cases} x-y=8 \\ x+y=-2 \end{cases}$ (3 , –5)

ខ. $\begin{cases} 2x+y=3 \\ x+2y=4 \end{cases}$ (2 , –1)

គ. $\begin{cases} y=3x \\ x+y=3 \end{cases}$ (0 , 0)

ឃ. $\begin{cases} x-y=3 \\ 2x-2y=6 \end{cases}$ (5 , 2) ។

2. ចូរដោះស្រាយប្រព័ន្ធសមីការខាងក្រោមតាមក្រាប ។

ក. $\begin{cases} x-4y=1 \\ x+y=-4 \end{cases}$

ខ. $\begin{cases} y-2=0 \\ x+3=0 \end{cases}$

គ. $\begin{cases} 2x-3y=13 \\ x-2y=8 \end{cases}$

ឃ. $\begin{cases} y=3x \\ x+y=4 \end{cases}$

ង. $\begin{cases} 2x+y=6 \\ y=8-2x \end{cases}$

ច. $\begin{cases} x+y=1 \\ \dfrac{x}{2}+\dfrac{y}{2}=2 \end{cases}$

ឆ. $\begin{cases} x+y=3 \\ y=\dfrac{7-2x}{2} \end{cases}$

ជ. $\begin{cases} y=7-x \\ x=y+3 \end{cases}$ ។

3. ចូរដោះស្រាយប្រព័ន្ធសមីការតាមវិធីបំបាត់ដោយបូក ។

ក. $\begin{cases} 2x+2y=-2 \\ 5x-2y=9 \end{cases}$

ខ. $\begin{cases} 2x+2y=8 \\ 2x-y=5 \end{cases}$

គ. $\begin{cases} 3x+3y=9 \\ 4x-3y=-16 \end{cases}$

ឃ. $\begin{cases} 8x-3y=17 \\ -7x+6y=2 \end{cases}$

ង. $\begin{cases} 7x-10y=-1 \\ 3x+2y=-13 \end{cases}$

ច. $\begin{cases} 4x-3y=15 \\ 8x+2y=-10 \end{cases}$

ឆ. $\begin{cases} 2x+8y=-1 \\ -10x+4y=16 \end{cases}$

ជ. $\begin{cases} 5x+3y+9=0 \\ 3x-4y+17=0 \end{cases}$

ឈ. $\begin{cases} 6x-5=2x-7y \\ 2x=5y-6 \end{cases}$

ញ. $\begin{cases} 4x-3y=9 \\ -3x+5y=7 \end{cases}$

ដ. $\begin{cases} 3x+4y=-1 \\ 7x+9y=0 \end{cases}$

ឋ. $\begin{cases} 4x-2y=-19 \\ -6x-3y=1.5 \end{cases}$ ។

4. ចូរដោះស្រាយប្រព័ន្ធសមីការតាមវិធីជំនួស

ក. $\begin{cases} x-2y = 16 \\ 4x+y = 1 \end{cases}$  ខ. $\begin{cases} x+2y = 6 \\ 4x+3y = 4 \end{cases}$

គ. $\begin{cases} y = -4x+5 \\ 2x-3y = 13 \end{cases}$  ឃ. $\begin{cases} 5x-y = -23 \\ 3x-y = -15 \end{cases}$

ង. $\begin{cases} -2x+y = 2 \\ 2x+3y = 6 \end{cases}$  ច. $\begin{cases} x+5y = 11 \\ 4x-y = 2 \end{cases}$

ឆ. $\begin{cases} 2x+3y = 11 \\ 3x+3y = 18 \end{cases}$  ជ. $\begin{cases} 5x+3y = 4 \\ 4x-2y = 1 \end{cases}$

ឈ. $\begin{cases} 5x+7y = -3 \\ 2x+14y = 2 \end{cases}$  ញ. $\begin{cases} 3x+6y = 6 \\ 2x = 2y \end{cases}$

ដ. $\begin{cases} x = 10y \\ \frac{1}{2}x = 3y+2 \end{cases}$  ឋ. $\begin{cases} x-7 = y \\ \frac{1}{4}x-1 = y \end{cases}$ ។

5. ក. ចូររកតម្លៃ $m$ ដើម្បីឱ្យប្រព័ន្ធសមីការខាងក្រោមគ្មានចម្លើយ ។

$\begin{cases} 4x+6y = 12 \\ 2x+my = 5 \end{cases}$ , $\begin{cases} 12x-3my = 1 \\ 4x+2y = 3 \end{cases}$

ខ. ចូររកតម្លៃ $m$ និង $n$ ដើម្បីឱ្យប្រព័ន្ធសមីការខាងក្រោមមានគូចម្លើយរាប់មិនអស់ ។

$\begin{cases} mx+ny = 10 \\ 4x-3y = 5 \end{cases}$ , $\begin{cases} 6x+y = 30 \\ (n-1)x+\frac{1}{3}y = n+m \end{cases}$ ។

6. សុខនិងសៅទិញសៀវភៅសរសេរ ។ សុខទិញសៀវភៅស្តើង 2 ក្បាលនិងសៀវភៅក្រាស់ 3 ក្បាល អស់ប្រាក់ 21 000 ៛ ។ ចំណែកសៅវិញទិញសៀវភៅស្តើង 3 ក្បាលនិងសៀវភៅក្រាស់ 2 ក្បាល អស់ប្រាក់ 19 000 ៛ ។ តើសៀវភៅទាំងពីរប្រភេទនេះ មានតម្លៃមួយក្បាលថ្លៃប៉ុន្មានរៀល ?

7. នៅក្នុងកាបូបមួយមានប្រាក់ 8 000 ៛ ។ គេរាប់ចំនួនក្រដាសប្រាក់ឃើញ 11 សន្លឹក ។ ក្រដាសប្រាក់នេះមានពីរប្រភេទ គឺប្រភេទ 500 ៛ និងប្រភេទ 1 000 ៛ ។ ចូររកចំនួនក្រដាសប្រាក់ប្រភេទនីមួយៗ ។

8. ពូសំដាក់ទឹកត្នោតដោយប្រើខ្សែពួរបង្ហូតចុះមកដី ។ បើគាត់មិនបត់ខ្សែជាពីរទេ នោះគាត់បង្ហូតបំពង់មកដល់ដី នៅសល់កន្ទុយខ្សែ $7m$ ទៀត ។ ប៉ុន្តែបើគាត់បត់ខ្សែពួរជាពីរ គាត់បង្ហូតបំពង់មកដល់ដីល្មមគ្មានសល់ខ្សែសោះ ។ បំពង់និងខ្សែបំពង់មានប្រវែង $1m$ ។ កម្ពស់ដើមត្នោតត្រូវគិតពីកន្លែងដែលគាត់អង្គុយមកត្រឹមដី ។ ចូររកប្រវែងខ្សែពួរនិងកម្ពស់ដើមត្នោត ។

9. ដីមួយកន្លែងរាងចតុកោណកែងមានបរិមាត្រ $110m$ ។ បើគេថែម $5m$ លើបណ្ដោយនិង $2m$ លើទទឹង នោះផ្ទៃក្រឡាកើនលើសពីមុន $150m^2$ ។ ចូររកប្រវែងបណ្ដោយនិងទទឹងនៃដីនោះ ។

10. គេយកក្រដាសប្រាក់ 20\$ ទៅទិញនំ $H$ និងនំ $P$ ។

បើគេទិញនំ $H$ 6 និងនំ $P$ 4 នោះគេនឹងអាប់វិញ 1.5\$

បើគេទិញនំ $H$ 2 និងនំ $P$ 5 នោះគេនឹងអាប់វិញ 1\$

បើគេទិញនំ $H$ 4 និងនំ $P$ 4 តើគេនឹងអាប់វិញប្រាក់ប៉ុន្មាន ?

11. ផលដកនៃពីរចំនួនស្មើ 22 ពីរដងនៃចំនួនធំបូកនឹងបីដងនៃចំនួនតូចស្មើនឹង 246 ។ រកពីរចំនួននោះ ។

12. ពីរចំនួនមានផលបូកស្មើនឹង 490 និងមានផលធៀបស្មើនឹង $\frac{3}{7}$ ។ ចូរគណនាចំនួនទាំងពីរនោះ ។

13. ផលធៀបនៃពីរចំនួនស្មើនឹង $\frac{5}{4}$ និងការេនៃផលដករបស់វាស្មើនឹង 324 ។ ចូរគណនាចំនួននីមួយៗ ។

14. ត្រីកោណ $ABC$ មួយមានបរិមាត្រ $192m$ ។ ចូរគណនាប្រវែងជ្រុង $BC$ , $CA$ , $AB$ ដោយដឹងថាជ្រុងទាំងនោះសមាមាត្ររៀងគ្នានឹងចំនួន 2.5 2 និង 1.5 ។

15. ផលដកនៃពីរចំនួនស្មើនឹង 36 និងការេនៃផលធៀបរបស់វាស្មើនឹង $\frac{25}{81}$ ។ ចូរគណនាចំនួននីមួយៗ ។

16. ផលធៀបបាតទាំងពីរនៃចតុកោណព្នាយមួយស្មើនឹង $\frac{3}{5}$ និងផលបូកបាតរបស់វាស្មើនឹង $64m$ ។ ចូរគណនាប្រវែងនៃបាតនីមួយៗ ។

17. បើបន្ទាត់ $Ax+By = 9$ កាត់ចំណុច $(2\ ,\ 1)$ និង $(-3\ ,\ 3)$ ចូរកំណត់ $A$ និង $B$ ។

18. ចូរដោះស្រាយប្រព័ន្ធសមីការ $\begin{cases} \frac{2}{x}-\frac{2}{y} = \frac{1}{2} \\ \frac{1}{x}+\frac{5}{y} = \frac{3}{4} \end{cases}$ ។

19. ក្រុមហ៊ុនមួយបានលក់ផលិតផលពីរមុខ $A$ និង $B$ ។ តាមការស្រាវជ្រាវនៃការលក់ទៅតាមឆ្នាំនីមួយៗមានដូចតារាងខាងក្រោម ។ ឯកតាគិតជាលានគ្រឿង ។

| | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|
| A | 2.3 | 2.7 | 3.1 | 3.5 |
| B | 2.9 | 3.3 | 3.7 | 4.1 |

បើក្រុមហ៊ុនរក្សាការលក់តាមអត្រាកំណើនដូចខាងលើ តើផលិតផល $A$ អាចលក់កើនជាង $B$ ឬទេ ? ហេតុអ្វី ?

មេរៀនទី

# 12 ទ្រឹស្តីបទពីតាគ័រ

**វត្ថុបំណង**

- ស្រាយបញ្ជាក់ទ្រឹស្តីបទពីតាគ័រ ។
- គណនារង្វាស់ជ្រុងនៃត្រីកោណកែង ។
- អនុវត្តទ្រឹស្តីបទពីតាគ័រក្នុងជីវភាពរស់នៅ ។

## 1. ទ្រឹស្តីបទពីតាគ័រ

គេឱ្យត្រីកោណកែងមួយដែលមានរង្វាស់ $a$ , $b$ , $c$




$a$ និង $b$ ជារង្វាស់នៃជ្រុងមុំកែង

$c$ ជាអ៊ីប៉ូតេនុស

គេនឹងស្រាយបញ្ជាក់ថា $c^2 = a^2 + b^2$

សម្រាយបញ្ជាក់ :




គេយកត្រីកោណកែងបួនដូចគ្នាខាងលើមកផ្គុំជាការេធំមួយដែលមានរង្វាស់ជ្រុង $a+b$ ដូចរូបខាងស្តាំ

ចតុកោណ $IJKL$ ជាការេ

ព្រោះមុំ $\hat{I} = 90°$

ផ្ទៃក្រឡានៃការេធំ ស្មើ $(a+b)^2 = a^2 + b^2 + 2ab$

ផ្ទៃក្រឡានៃ $IJKL$ ស្មើ $c^2$

ផ្ទៃក្រឡានៃត្រីកោណកែងទាំងបួនស្មើ $4 \times \frac{1}{2}ab = 2ab$

តាមរូបខាងលើគេបាន

ផ្ទៃក្រឡានៃ $IJKL$ = ផ្ទៃក្រឡានៃការេធំ - ផ្ទៃក្រឡានៃត្រីកោណកែងទាំង 4

$$c^2 = a^2 + b^2 + 2ab - 2ab$$

$$c^2 = a^2 + b^2$$

គេបានទំនាក់ទំនងរវាងរង្វាស់ជ្រុងនៃត្រីកោណកែងហៅថាទ្រឹស្តីបទពីតាគ័រ ។

| |
|---|
| ទ្រឹស្តីបទ : ក្នុងត្រីកោណកែង ការេនៃអ៊ីប៉ូតេនុសស្មើនឹងផលបូកការេនៃជ្រុងមុំកែង ។ |



បើ $\angle BAC = 90°$ នោះ $BC^2 = AB^2 + AC^2$

ច្រាសមកវិញ



បើ $BC^2 = AB^2 + AC^2$ នោះ $\angle BAC = 90°$

***ឧទាហរណ៍ :*** សង់ត្រីកោណដែលមានរង្វាស់ជ្រុង 3  4  5 ជា $cm$ និងត្រីកោណដែលមានរង្វាស់ជ្រុង 6  8  10 ជា $cm$ ។





ចំពោះត្រីកោណទាំងពីរដែលបានសង់ខាងលើគេសង្កេតឃើញថា

$3^2 + 4^2 = 9 + 16 = 25$ $\qquad$ $6^2 + 8^2 = 36 + 64 = 100$

$5^2 = 25$ $\qquad$ $10^2 = 100$

$5^2 = 3^2 + 4^2$ $\qquad$ $10^2 = 6^2 + 8^2$

$ABC$ ជាត្រីកោណកែងត្រង់ $A$

$A'B'C$ ជាត្រីកោណកែងត្រង់ $A'$

***លំហាត់គំរូទី 1 :*** តើរូបមួយណាជាត្រីកោណកែង ?







***ចម្លើយ :***

$BC^2 = 7^2 = 49$ , $AB^2 + AC^2 = 4^2 + 6^2 = 16 + 36 = 52$

$BC^2 \neq AB^2 + AC^2$ នាំឱ្យ $ABC$ ពុំមែនជាត្រីកោណកែង

$FG^2 = 7.3^2 = 53.29$

$EF^2 + EG^2 = 4.8^2 + 5.5^2 = 23.04 + 30.25 = 53.29$

$FG^2 = EF^2 + EG^2 = 53.29$

ដូចនេះ $EFG$ ជាត្រីកោណកែងត្រង់ $E$ ។

***លំហាត់គំរូទី 2 :*** គេឱ្យត្រីកោណ $ABC$ និងត្រីកោណ $ABD$ កែងត្រង់ $B$ ។ ដោយស្គាល់ $AB = 15cm$ , $BC = 8cm$ និង $AD = 20cm$ ។ ចូរគណនា $AC$ និង $BD$ ។

***ចម្លើយ :***




- គណនា $AC$

ក្នុងត្រីកោណកែង $ABC$ តាមទ្រឹស្តីបទពីតាគ័រ

$$AC^2 = AB^2 + BC^2$$
$$= 15^2 + 8^2$$
$$= 225 + 64 = 289 \quad , \quad AC = \sqrt{289} = 17cm \text{ ។}$$

- គណនា $BD$

ក្នុងត្រីកោណកែង $ABD$ តាមទ្រឹស្តីបទពីតាគ័រ

$AD^2 = AB^2 + BD^2$ នាំឱ្យ $BD^2 = AD^2 - AB^2$

$$= 20^2 - 15^2 = 400 - 225 = 175$$

$$BD = \sqrt{175} \approx 13.23cm \text{ ។}$$

*ប្រតិបត្តិ :*

ចូរគណនារង្វាស់ $x$ គិតជា $cm$ នៃរូបខាងស្តាំ ។




## 2. អនុវត្តន៍ទ្រឹស្តីបទ

### 2.1. អនុវត្តន៍ដើម្បីគណនារង្វាស់ជ្រុង

***ឧទាហរណ៍ទី 1 :*** គណនាអង្កត់ទ្រូងនៃការេដែលមានជ្រុង $a$




$$d^2 = a^2 + a^2$$
$$= 2a^2$$
$$d = a\sqrt{2}$$ ។

***ឧទាហរណ៍ទី 2 :*** គណនាកម្ពស់នៃត្រីកោណសម័ង្ស $ABC$ ជាត្រីកោណសម័ង្សដែលមានរង្វាស់ជ្រុង $a$ ។ កម្ពស់ $[AH]$ កាត់ $BC$ ត្រង់ចំណុចកណ្តាល $H$ ។




ដូចនេះ $BH = \frac{a}{2}$

ក្នុងត្រីកោណកែង $ABH$

$BH^2 + AH^2 = AB^2$ នាំឱ្យ $AH^2 = AB^2 - BH^2$

$$= a^2 - \left(\frac{a}{2}\right)^2$$

$$= a^2 - \frac{a^2}{4} = \frac{3a^2}{4}$$

$$AH = \frac{a\sqrt{3}}{2}$$ ។

***ឧទាហរណ៍ទី 3 :*** គណនាអង្កត់ទ្រូងនៃប្រលេពីប៉ែតកែង $ABCDEFGH$ ដែលមានរង្វាស់ជ្រុងរៀងគ្នា $x$ , $y$ , $z$ ហើយ $t$ ជារង្វាស់នៃអង្កត់ទ្រូង ។




ក្នុងត្រីកោណកែង $ABC$ កែងត្រង់ $B$

$$AC^2 = AB^2 + BC^2$$
$$= y^2 + z^2$$

ក្នុងត្រីកោណកែង $EAC$ កែងត្រង់ $A$

$$EC^2 = AE^2 + AC^2$$

$$t^2 = x^2 + y^2 + z^2 \ , \ t = \sqrt{x^2+y^2+z^2}$$ ។

***លំហាត់គំរូទី 1 :*** ចូរគណនាផ្ទៃក្រឡានៃត្រីកោណសម័ង្សដែលមានរង្វាស់ជ្រុងស្មើនឹង $4cm$ ។




***ចម្លើយ :*** កម្ពស់នៃត្រីកោណសម័ង្សកំណត់

$$h = \frac{a\sqrt{3}}{2} = \frac{4\sqrt{3}}{2} = 2\sqrt{3}$$

ផ្ទៃក្រឡានៃត្រីកោណ $ABC$

$$S = \frac{1}{2}h \times a = \frac{1}{2} \times 2\sqrt{3} \times 4 = 4\sqrt{3}$$

$$S = 4 \times 1.73 \approx 6.92cm^2$$ ។

***លំហាត់គំរូទី 2 :*** អង្កត់ទ្រូងនៃការេមួយមានរង្វាស់ស្មើនឹង $6\sqrt{2}dm$ ។ ចូរកំណត់រង្វាស់ជ្រុងនៃការេ ។




***ចម្លើយ :*** បើ $a$ ជារង្វាស់ជ្រុង ហើយ $d$ ជាអង្កត់ទ្រូងនោះ

$$d = a\sqrt{2}$$

$$6\sqrt{2} = a\sqrt{2} \ , \ a = 6dm$$ ។

***ប្រតិបត្តិ :*** ចូរគណនាអង្កត់ទ្រូងនៃប្រលេពីប៉ែតកែងដែលមានរង្វាស់ជ្រុងស្មើរៀងគ្នា 2 2 1 គិតជា $m$ ។

## 2.2. អនុវត្តន៍ក្នុងជីវភាពរស់នៅ

***លំហាត់គំរូទី 1 :*** នៅលើទីធ្លាមួយ $A$ ជាចំណុចនឹង ហើយ $Ax$ ជាបន្ទាត់នឹង ។ តើគេត្រូវសង់បន្ទាត់ $Ay$ យ៉ាងដូចម្តេចដើម្បីឱ្យ $Ax \perp Ay$ ។




***ចម្លើយ :*** ក្នុងការធ្វើឱ្យ $Ay$ កែងនឹង $Ax$ គេតែងតែប្រើទ្រឹស្តីបទពីតាគ័រ ។

- នៅលើបន្ទាត់ $Ax$ គេដៅចំណុច $B$ ដែល $AB = 3dm$ ហើយនៅលើបន្ទាត់ $Ay$ គេដៅចំណុច $C$ ដែល $AC = 4dm$ ។

- គេរំកិលខ្សែ $AC$ ដោយលៃយ៉ាងណាឱ្យ $BC = 5dm$ ធ្វើយ៉ាងនេះគេបាន $5^2 = 3^2 + 4^2$ មានន័យថា $BC^2 = AB^2 + AC^2$ នោះ $ABC$ ជាត្រីកោណកែងត្រង់ $A$ ។




***លំហាត់គំរូទី 2 :*** តើគេអាចលើកទូដែលមានកម្ពស់ $2.10m$ និងទទឹង $0.60m$ ឱ្យបញ្ឈរនៅឡៅតឿមួយដែលមានកម្ពស់ត្រឹម $2.16m$ ឬទេ ?

***ចម្លើយ :*** គេអាចលើកបញ្ឈរទូនោះបានលុះត្រាតែអង្កត់ទ្រូងនៃទូខ្លីជាងកម្ពស់នៃឡៅតឿក្នុងករណីនេះគេត្រូវគណនាអង្កត់ទ្រូងនៃទូសិន ។




បើ $d$ ជាអង្កត់ទ្រូងនៃទូ

$$d^2 = (2.10)^2 + (0.60)^2$$
$$= 4.41 + 0.36$$
$$= 4.77$$
$$d = \sqrt{4.77} \approx 2.18m$$

ឡៅតឿមានកម្ពស់ត្រឹមតែ $2.16m$ ខ្លីជាងអង្កត់ទ្រូងនៃទូ ដូចនេះគេមិនអាចលើកបញ្ឈរទូនោះបានឡើយ ។

***ប្រតិបត្តិ :*** គេយកជណ្តើរមួយដែលមានប្រវែង $8m$ ទៅផ្អែកនឹងជញ្ជាំងមួយ ។ បើជើងជណ្តើរឃ្លាតពីជញ្ជាំង $2m$ ចូររកកម្ពស់នៃជញ្ជាំងនោះ ។



## ? លំហាត់

1. ចូរគណនា $x$ ក្នុងរូបខាងស្តាំនេះ ។




2. ចំពោះរង្វាស់ជ្រុងនីមួយៗខាងក្រោមនេះ តើ $ABC$ ជាត្រីកោណកែងឬទេ ?

ក. $AB = 7$ , $BC = 9$ , $AC = 12$

ខ. $AB = 52.8$ , $BC = 45.5$ , $AC = 69.7$

គ. $AB = 83$ , $BC = 49$ , $AC = 67$ ។

3. ចូរគណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ។




4. រង្វង់មួយដែលមានផ្ចិត $O$ និងកាំស្មើនឹង $5cm$
$[AB]$ ជាអង្កត់ធ្នូដែលមានរង្វាស់ស្មើ $8cm$ ។
ចូរគណនាប្រវែង $OM$ ។




5. ត្រីកោណសម័ង្សមួយដែលមានកម្ពស់ស្មើនឹង $\sqrt{3}cm$ ។
ចូរគណនាផ្ទៃក្រឡានៃត្រីកោណសម័ង្សនេះ ។



6. ចូរកំណត់ $x$ និង $y$ នៃរូបខាងក្រោមគិតជា $m$ ។




7. ចូរគណនាកម្ពស់នៃកោណនៃរូបខាងស្តាំ រួចគណនាមាឌនៃកោណនោះ ។




8. គូបមួយមានរង្វាស់ជ្រុងស្មើនឹង $1cm$ ។ ចូរគណនាអង្កត់ទ្រូងនៃគូបនោះ ។

9. ចូរគណនារង្វាស់ជ្រុងនៃរូបខាងស្តាំគិតជា $cm$ ។

ក. ចូរគណនា $AB$

ខ. ចូរគណនា $AH$

គ. ចូរគណនា $BH$ និង $HC$ ។




10. យន្តហោះពីរហោះចេញពីចំណុច $O$ ដូចគ្នាតាមទិសដៅរៀងគ្នា $Ox$ និង $Oy$ ។ គេដឹងយន្តហោះទាំងពីរបើកបរដោយល្បឿនស្មើគ្នា ហើយហោះចេញពីចំណុច $O$ នៅម៉ោងតែមួយ ។ ចូរគណនាចម្ងាយចរនៃយន្តហោះនីមួយៗ នៅពេលដែលវាឃ្លាតពីគ្នាបាន $100km$ ។



មេរៀនទី

# 13 រង្វង់និងបន្ទាត់

## វត្ថុបំណង

- បង្ហាញពីលក្ខណៈនៃអង្កត់ធ្នូ ។
- បង្ហាញពីលក្ខណៈនៃបន្ទាត់ប៉ះនៃរង្វង់ ។
- អនុវត្តលក្ខណៈបន្ទាត់ប៉ះនៃរង្វង់ទៅនឹងជ្រុងឈមនៃចតុកោណចារឹកក្រៅរង្វង់ ។
- រកអង្កត់ផ្ចិតនិងកាំរង្វង់ដោយប្រើលក្ខណៈទីតាំងនៃរង្វង់ ។

## 1. លក្ខណៈនៃអង្កត់ធ្នូ

### 1.1. បន្ទាត់កែងទៅនឹងចំណុចកណ្តាលនៃអង្កត់ធ្នូ




*ឧទាហរណ៍ :* នៅក្នុងរង្វង់ផ្ចិត $O$ គេគូសបន្ទាត់មួយចេញពីផ្ចិត $O$ កែងទៅនឹងអង្កត់ធ្នូ $AB$ ត្រង់ចំណុច $M$ (ដូចរូបខាងស្តាំ) ។ បើគេបត់រង្វង់នេះតាមបន្ទាត់ $OM$ គេសង្កេតឃើញថារង្វង់នេះឆ្លុះគ្នាធៀបនឹងបន្ទាត់ $OM$ ហើយចំណុច $A$ ត្រួតស៊ីគ្នានឹង $B$ ។ ដូចនេះ $M$ ជា ចំណុចកណ្តាលនៃអង្កត់ធ្នូ $AB$ ។

*ជាទូទៅ :*

- បន្ទាត់ដែលគូសចេញពីផ្ចិតនៃរង្វង់ហើយកែង នឹង អង្កត់ធ្នូត្រូវកាត់ចំណុចកណ្តាលនៃអង្កត់ធ្នូ ។
- បន្ទាត់ដែលកែងទៅនឹងចំណុចកណ្តាលនៃអង្កត់ធ្នូត្រូវកាត់តាមផ្ចិតនៃរង្វង់ ។




***លំហាត់គំរូទី 1 :*** គេមានរង្វង់ផ្ចិត $O$ និងអង្កត់ធ្នូ $AB = 10cm$ (ដូចរូបខាងស្តាំ) ។ បើ $OC$ កែងទៅនឹង $AB$ ចូរគណនាប្រវែង $AC$ ។

***ចម្លើយ :*** ដោយ $OC$ គូសចេញពីផ្ចិត $O$ នៃរង្វង់និងកែងទៅនឹងអង្កត់ធ្នូ $AB$

គេបាន $AC = BC$

នាំឱ្យ $AC = \frac{1}{2}AB = \frac{1}{2} \times 10 = 5cm$

ដូចនេះ $AC = 5cm$ ។

***លំហាត់គំរូទី 2 :*** គេមានរង្វង់ផ្ចិត $O$ ដូចរូបខាងស្ដាំ ។

ចូរគណនាប្រវែងអង្កត់ធ្នូ $AB$ ។




***ចម្លើយ :*** $OMB$ ជាត្រីកោណកែងត្រង់ $M$

តាមទ្រឹស្ដីបទពីតាគ័រគេបាន

$$OM^2 + MB^2 = OB^2$$

$$5^2 + MB^2 = 7^2$$

$$MB^2 = 7^2 - 5^2 = 49 - 25 = 24$$

$$MB = \sqrt{24}$$

ដោយ $OM$ គូសចេញពីផ្ចិត $O$ ហើយកែងនឹង $AB$ នាំឱ្យ $OM$ កែងចំកណ្ដាលនៃ $AB$ ។

គេបាន $MB = MA$

$$AB = 2MB = 2\sqrt{24} \cong 2 \times 4.899 = 9.80cm$$ ។

***លំហាត់គំរូទី 3 :*** នៅក្នុងរង្វង់ផ្ចិត $O$ គេមាន

$\angle OXY = 30°$ , $\angle XOY = 60°$ និង $XZ = 32cm$ ។

ចូររករង្វាស់ $XY$ ។




***ចម្លើយ :*** ក្នុង $\Delta OXY$ គេមាន

$\angle OYX + \angle OXY + \angle XOY = 180°$ (ផលបូកមុំក្នុងត្រីកោណ) ។

នាំឱ្យ $\angle OYX = 180° - \angle OXY - \angle XOY$

$$= 180° - 30° - 60° = 90°$$

ដោយ $\angle OYX = 90°$ និង $O$ ជាផ្ចិតនៃរង្វង់ នោះ $OY$ ជាបន្ទាត់កែងទៅនឹងចំណុចកណ្ដាលនៃ $XZ$ ។

នាំឱ្យ $YX = \frac{1}{2} \times XZ$

$$= \frac{1}{2} \times 32 = 16$$

ដូចនេះ $XY = 16cm$ ។

*ប្រតិបត្តិ* : គេមាន $O$ ជាផ្ចិតនៃរង្វង់និង $AB = 25cm$ និង $BQ = 6.5cm$ ដូចរូបខាងស្ដាំនេះ ។ ចូរគណនាប្រវែង $AP$ និង $BC$ ។




## 1.2. អង្កត់ធ្នូស្មើគ្នា

*ឧទាហរណ៍* : គូសរង្វង់ផ្ចិត $O$ ដែលមានកាំ $4cm$ ។ គូសអង្កត់ធ្នូ $AB$ និង $CD$ ឱ្យមានប្រវែងស្មើគ្នា ។ ភ្ជាប់ $O$ ទៅ $M$ ចំណុចកណ្ដាលនៃ $AB$ និងភ្ជាប់ពី $O$ ទៅ $N$ ចំណុចកណ្ដាលនៃ $CD$ ។ បើយើងបត់រង្វង់តាមបន្ទាត់ $\Delta$ នោះយើងសង្កេតឃើញថា $AB$ ត្រួតស៊ីគ្នានិង $CD$ ហើយ $OM$ ស្ថិតនៅលើ $ON$ នាំឱ្យ $OM = ON$ ។ $OM$ , $ON$ ហៅថាចម្ងាយរៀងគ្នាពីផ្ចិត $O$ ទៅអង្កត់ធ្នូ $AB$ និង $CD$ ។




*ជាទូទៅ* : អង្កត់ធ្នូពីរមានប្រវែងស្មើគ្នានៅក្នុងរង្វង់មួយ ត្រូវមានចម្ងាយស្មើគ្នាពីផ្ចិតនៃរង្វង់នោះ ។




*ច្រាសមកវិញ* : អង្កត់ធ្នូក្នុងរង្វង់មួយដែលមានចម្ងាយស្មើគ្នាពីផ្ចិតនៃរង្វង់ជាអង្កត់ធ្នូប៉ុនគ្នា ។

*លំហាត់គំរូទី 1* : គេមានរង្វង់ផ្ចិត $O$ ដែលមានកាំ $5cm$ និងអង្កត់ផ្ចិតប្រវែង $8cm$ ដូចរូបខាងស្ដាំ ។ ចូររកចម្ងាយពីផ្ចិតនៃរង្វង់ទៅអង្កត់ធ្នូ ។

*ចម្លើយ* : គេមាន $O$ ជាផ្ចិតនៃរង្វង់និង $M$ ជាចំណុចកណ្ដាលនៃអង្កត់ធ្នូ $AB$

ដោយ $AM = MB = 4cm$

ក្នុង $\Delta OBM$ តាមទ្រឹស្ដីបទពីតាគ័រ



គេបាន $OM^2 + 4^2 = 5^2$

$$OM^2 + 16 = 25$$

$$OM^2 = 25 - 16 = 9$$

$$OM = \sqrt{9} = 3cm$$

ដូចនេះ ចម្ងាយពីផ្ចិតនៃរង្វង់ទៅអង្កត់ធ្នូគឺ $3cm$ ។

***លំហាត់គំរូទី 2 :*** ក្នុងរូបភាពខាងស្តាំនេះ $O$ ជាផ្ចិតនៃរង្វង់ដែលមានកាំ $5cm$ ហើយ $PQ = RS = 6cm$ ។ ចូររកប្រវែង $OY$ និង $OX$ ។




***ចម្លើយ :*** ក្នុងត្រីកោណកែង $OPX$

$$PX = \frac{PQ}{2} = \frac{6}{2} = 3$$

គេបាន $OX^2 + PX^2 = OP^2$

$$OX^2 + 3^2 = 5^2$$

$$OX^2 = 25 - 9 = 16$$

$$OX = 4cm$$

$PQ = RS = 6cm$ នាំឱ្យ $OY = OX = 4cm$ ។

***លំហាត់គំរូទី 3 :*** គេមានរង្វង់ផ្ចិត $O$ ដែលមានកាំ $10cm$ ហើយ $PR = QS$ និង $OC = 5cm$ ។ ចូរគណនាប្រវែង $OD$ និង $PR$ ។




***ចម្លើយ :*** យើងដឹងថាអង្កត់ធ្នូ $PR = QS$ ហើយ $OC = OD = 6cm$

ដូចនេះ $OD = 6cm$ ។

ក្នុងត្រីកោណកែង $OCR$

$$OC^2 + CR^2 = OR^2$$

$$6^2 + CR^2 = 10^2$$

$CR^2 = 100 - 36 = 64$ នាំឱ្យ $CR = 8cm$

$OC \perp PR$ , $PR = 2CR = 2 \times 8 = 16cm$ ។

*ប្រតិបត្តិ :*




នៅក្នុងរូបភាពខាងស្តាំនេះគេមាន $O$ ជាផ្ចិតនៃរង្វង់ ហើយ $OA = OB = 5.5cm$ និង $MN = 9cm$ ។ ចូររកប្រវែង $NP$ ។

## 2. បន្ទាត់ប៉ះ




*ឧទាហរណ៍ :* នៅក្នុងរង្វង់ផ្ចិត $O$ (ដូចរូបខាងស្តាំនេះ) គេមានអង្កត់ផ្ចិត $AB$ នៅលើបន្ទាត់ $l$ ។ កាលណាបន្ទាត់ $l$ រំកិលចុះពីផ្ចិត $O$ ដោយរក្សាទីតាំងស្របនឹងបន្ទាត់ $AB$ នោះចម្ងាយរវាងចំណុច $A$ និង $B$ កាន់តែតូចទៅៗ រហូតមកត្រួតស៊ីគ្នានឹងចំណុច $M$ ។ ក្នុងករណីនេះបន្ទាត់ $l$ ប្រសព្វនឹងរង្វង់ត្រង់មួយចំណុច $M$ ។ បន្ទាត់នេះហៅថា **បន្ទាត់ប៉ះទៅនឹងរង្វង់** ឬ **បន្ទាត់ប៉ះ** ។ ម្យ៉ាងទៀតចំណុច នៃបន្ទាត់ប៉ះប្រសព្វនឹងរង្វង់នឹងហៅថា **ចំណុចប៉ះ** ។

*ជាទូទៅ :* បន្ទាត់ប៉ះនៃរង្វង់ត្រូវកែងទៅនឹងកាំឬ
អង្កត់ផ្ចិតនៃរង្វង់ត្រង់ចំណុចប៉ះ ។




*លំហាត់គំរូ :* នៅក្នុងរូបខាងស្តាំ $O$ ជាផ្ចិតនៃរង្វង់ ។ $TA$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់ត្រង់ $T$ ដែល $OT = TA$ ។ ចូរគណនារង្វាស់មុំនៃត្រីកោណ $OTA$ ។




*ចម្លើយ :* $TA$ ជាបន្ទាត់ប៉ះនឹងរង្វង់ត្រង់ $T$ និង $OT$ ជាកាំនៃរង្វង់

គេបាន $\angle OTA = 90°$

ក្នុង $\Delta OTA$ មាន

$OT = TA$ នាំឱ្យ $\angle TOA = \angle TAO$ (មុំបាតនៃត្រីកោណសមបាត)

$\angle TOA + \angle TAO + \angle OTA = 180°$ (ផលបូកមុំក្នុង $\Delta$ មួយ)

ដោយ $\angle TOA = \angle TAO$

គេបាន $2\angle TOA + 90° = 180°$

$2\angle TOA = 180° - 90° = 90°$

$2\angle TOA = 90°$

នាំឱ្យ $\angle TOA = 45°$

ដូចនេះ $\angle OTA = 90°$ , $\angle TOA = 45°$ និង $\angle TAO = 45°$ ។

*ប្រតិបត្តិ :* គេមានរង្វង់មួយដែលមានផ្ចិត $O$ និងកាំស្មើនឹង $2cm$ ។ $A$ ជាចំណុចមួយនៅក្រៅរង្វង់ ។ ពីចំណុច $A$ គេគូសបន្ទាត់ប៉ះនឹងរង្វង់ត្រង់ $B$ និងបន្ទាត់មួយទៀតកាត់តាមផ្ចិត $O$ និងកាត់រង្វង់ត្រង់ $C$ ។ បើគេដឹងថា $AB = OB$ ចូរគណនារង្វាស់ $AC$ ។




## 3. លក្ខណៈនៃបន្ទាត់ប៉ះ

*ឧទាហរណ៍ទី1 :* គេឱ្យបន្ទាត់ $EF$ ប៉ះរង្វង់ផ្ចិត $O$ ត្រង់ $C$ ដែលមាន $AB \parallel EF$ ។

ស្រាយបំភ្លឺថា $\cup AC = \cup BC$ ។




*សម្រាយបញ្ជាក់ :* បន្ទាត់ $EF$ ប៉ះនឹងរង្វង់ត្រង់ចំណុច $C$

នាំឱ្យ $OC \perp EF$ តែ $AB \parallel EF$

$AB \perp OC$ នាំឱ្យ $C$ ជាចំណុចកណ្តាលនៃធ្នូ $AB$ ។ ដូចនេះ $\cup AC = \cup BC$ ។

| |
|---|
| *ជាទូទៅ :* បើបន្ទាត់ប៉ះរង្វង់ស្របទៅនឹងអង្កត់ធ្នូមួយនោះ ចំណុចប៉ះចែកធ្នូសន្ទឹងជាពីរផ្នែកប៉ុនគ្នា ។ |

*ឧទាហរណ៍ទី 2* **:** គេឱ្យបន្ទាត់ពីរ $AB$ និង $CD$ ប៉ះរង្វង់ផ្ចិត $O$ ត្រង់ចំណុចរៀង $B$ និង $C$ ។




ស្រាយបំភ្លឺថា ក. $AB = AC$

ខ. $\angle BAO = \angle OAC$

គ. $\angle BOA = \angle AOC$

ឃ. $\angle OBA = \angle OCA$ ។

*សម្រាយបញ្ជាក់* **:** ក្នុងត្រីកោណកែង $OAB$ និង $OAC$ មាន

$OA$ ជាអ៊ីប៉ូតេនុសរួម

$OB = OC$ (កាំនៃរង្វង់តែមួយ)

ដូចនេះ $\Delta AOB \cong \Delta AOC$ (អ.ជ)

**វិបាក :** $AB = AC$

$\angle BAO = \angle OAC$

$\angle OBA = \angle OCA$

$\angle BOA = \angle COA$ ។

*ជាទូទៅ* **:** បើបន្ទាត់ពីរគូសចេញពីចំណុចរួមមួយនៅក្រៅរង្វង់ហើយប៉ះរង្វង់នេះត្រង់ចំណុច $B$ និង $C$ គេបាន




1. បន្ទាត់ប៉ះនៃរង្វង់កែងទៅនឹងកាំត្រង់ចំណុចប៉ះ
   $\angle OBA = \angle OCA = 90°$
2. បន្ទាត់ប៉ះពីរទៅនឹងរង្វង់ដែលគូសចេញពីចំណុចរួមមួយនៅក្រៅរង្វង់មានប្រវែងស្មើគ្នា $AB = AC$
3. បន្ទាត់ដែលគូសចេញពីចំណុចក្រៅរង្វង់មុំឈមទៅផ្ចិតនៃរង្វង់ ជាកន្លះបន្ទាត់ពុះនៃមុំឈមដែលផ្គុំដោយបន្ទាត់ប៉ះទាំងពីរនិងមុំដែលផ្គុំដោយកាំនៃរង្វង់ ។

   $(i)$ $\angle OAB = \angle OAC$

   $(ii)$ $\angle COA = \angle BOA$ ។

***លំហាត់គំរូទី 1*** : $O$ ជាផ្ចិតនៃរង្វង់មួយ(ដូចរូបខាងស្ដាំ) ។ $PA$ និង $PB$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់ ។ បើ $\angle ABP = 63°$ ។ ចូរគណនា $\angle AOB$ និង $\angle AOP$




***ចម្លើយ*** : គេមាន

$\angle OBP = 90°$

$\angle ABO = 90° - 63° = 27°$

$\angle AOB = 180° - 27° - 27° = 126°$

$\angle AOP = \frac{1}{2}(126°) = 63°$ ។

***លំហាត់គំរូទី 2*** : $TA$ និង $TB$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់ផ្ចិត $O$ ដែលមានកាំ $9cm$ ។ បើ $\angle ATB = 110°$ ។ ចូរគណនា




ក. $\angle AOB$

ខ. ផ្ទៃក្រឡាចម្រៀកថាសតូច $AOB$ ដែល $\pi = \frac{22}{7}$ ។

***ចម្លើយ*** :

ក. $\angle OBT = \angle OAT = 90°$

នាំឱ្យ $\angle AOB = 360° - 110° - 90° - 90° = 70°$

ខ. ផ្ទៃក្រឡាចម្រៀកថាសតូច

ផ្ទៃក្រឡានៃថាសទាំងមូល $\pi R^2$ ត្រូវនឹងមុំ $360°$

ផ្ទៃក្រឡានៃចម្រៀកថាស $S_{AOB}$ ត្រូវនឹងមុំ $70°$

$$\frac{\pi R^2}{S_{AOB}} = \frac{360°}{70°} \quad , \quad S_{AOB} = \frac{70°}{360°} \times \pi R^2$$

$$= \frac{70°}{360°} \times \frac{22}{7} \times 9 \times 9$$

$$= 49.5cm^2 \text{ ។}$$

***ប្រតិបត្តិ*** : $ST$ និង $RT$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់មួយមានផ្ចិត $O$ ដែល $ST = RT = 20cm$ ។ បើ $TQO$ ជាបន្ទាត់ត្រង់មួយដែល $TQ = 10cm$ ។ ចូរគណនាកាំនៃរង្វង់ $OQ$ ។

# 4. អនុវត្តន៍លក្ខណៈជ្រុងឈមនៃចតុកោណចារឹកក្រៅរង្វង់

*ឧទាហរណ៍ :* នៅក្នុងចតុកោណ $ABCD$ (រូបខាងស្តាំ) ជ្រុងទាំងបួនជាបន្ទាត់ប៉ះរង្វង់ត្រង់ $P$ , $Q$ , $R$ និង $S$ ។ ចតុកោណ $ABCD$ ដែលមានជ្រុងទាំងបួនប៉ះរង្វង់តែមួយ ហៅថាចតុកោណចារឹកក្រៅរង្វង់ ។




បង្ហាញថា :

ក. $AP = AS$ , $BP = BQ$ , $CQ = CR$ និង $DR = DS$ ។

ខ. បង្ហាញថា $AB + CD = AD + BC$ ។

*សម្រាយបញ្ជាក់ :*

ក. $AS$ និង $AP$ ជាបន្ទាត់ប៉ះរង្វង់ត្រង់ $S$ និង $P$ ដែលគូសចេញពីចំណុចតែមួយ $A$

គេបាន $AS = AP$ ។

$BP$ និង $BQ$ ជាបន្ទាត់ប៉ះរង្វង់ត្រង់ $P$ និង $Q$ ដែលគូសចេញពីចំណុចតែមួយ $B$

គេបាន $BP = BQ$ ។

$CQ$ និង $CR$ ជាបន្ទាត់ប៉ះរង្វង់ត្រង់ $Q$ និង $R$ ដែលគូសចេញពីចំណុចតែមួយ $C$

គេបាន $CQ = CR$ ។

$DS$ និង $DR$ ជាបន្ទាត់ប៉ះរង្វង់ត្រង់ $S$ និង $R$ ដែលគូសចេញពីចំណុចតែមួយ $D$ ។

គេបាន $DS = DR$ ។

ខ. បង្ហាញថា $AB + CD = AD + BC$

តែ $AB = AP + PB$ , $AD = AS + SD$

$CD = CR + RD$ , $BC = BQ + QC$

ដូចនេះ $AB + CD = (AP + PB) + (CR + RD)$

$= AS + BQ + QC + SD$

$= AS + SD + BQ + QC$

$= AD + BC$

ដូចនេះ $AB + CD = AD + BC$ ។

តាមសម្រាយបញ្ជាក់ខាងលើគេទាញសន្និដ្ឋានបានថា ។

| |
|---|
| *ជាទូទៅ :* ក្នុងចតុកោណចារឹកក្រៅរង្វង់ ផលបូករង្វាស់ជ្រុងឈមមានរង្វាស់ស្មើគ្នា ។ |

*លំហាត់គំរូ :* រង្វង់ផ្ចិត $O$ ប៉ះនឹងជ្រុងទាំងបួននៃចតុកោណ $ABCD$ ដែល $AB = 20cm$ , $CD = 14cm$ , $BC = 11cm$ ។ ចូរគណនារង្វាស់ $AD$ ។

*ចម្លើយ :* ជ្រុងទាំងបួននៃ $ABCD$ ប៉ះរង្វង់ត្រង់ $P$ , $Q$ , $R$ និង $S$

នោះឱ្យ ចតុកោណ $ABCD$ ជាចតុកោណចារឹកក្រៅរង្វង់

គេបាន $AB+CD = AD+BC$ នាំឱ្យ $AD = (AB+CD)-BC$

$AD = (20+14)-11 = 23$

ដូចនេះ $AD = 23$ ។




*ប្រតិបត្តិ :* ក្នុងរូបខាងស្ដាំនេះ $ABC$ ជាត្រីកោណសមបាតដែលមានកំពូល $A$ ។ ចូរស្រាយបំភ្លឺថា $BR = RC$ ។

## 5. ទីតាំងរង្វង់

គេមានរង្វង់ពីរដែលមានផ្ចិត $O$ និង $O'$ និងកាំរៀងគ្នា $r$ និង $r'$ ។ ហើយ $d$ ជាចម្ងាយរវាងផ្ចិតទាំងពីរ (ដូចរូបខាងក្រោម) ។

រូបពី (1) ដល់ (5) ខាងក្រោមបង្ហាញពីទីតាំងនៃរង្វង់ដែលមានចម្ងាយ $d$ កាន់តែតូចទៅៗ ចាប់ផ្ដើមពីរូបទី (1) ទៅ ។

(1) $d > r + r'$




*រង្វង់គ្មានចំណុចរួម*

(2) $d = r + r'$




*រង្វង់មានចំណុចរួមមួយ*

(3) $r - r' < d < r + r'$




*រង្វង់កាត់គ្នាត្រង់ពីរចំណុច*

(4) $d = r - r'$




*រង្វង់មានចំណុចរួមមួយ*

*រង្វង់ទាំងពីរជារង្វង់ប៉ះក្នុង*

(5) $d < r + r'$




*រង្វង់គ្មានចំណុចរួម*

*រង្វង់តូចនៅក្នុងរង្វង់ធំ*

កាលណារង្វង់ពីរកាត់គ្នាត្រង់មួយចំណុចដូចរូប (2) និងរូប (4) គេថារង្វង់ទាំងពីរប៉ះគ្នា ។ ចំណុចប្រសព្វជាចំណុចប៉ះ ។ ក្នុងករណីទាំងពីរនេះ ចំណុចប៉ះស្ថិតនៅលើបន្ទាត់កាត់ផ្ចិតនៃរង្វង់ទាំងពីរ ។

ក្នុងរូបទី (2) គេថារង្វង់ប៉ះក្រៅនិងរូបទី (4) គេថារង្វង់ប៉ះក្នុង ។

រូបទី (3) ជាករណីដែលរង្វង់ពីរប្រសព្វគ្នា ។

ចំណុចប្រសព្វទាំងពីរឆ្លុះគ្នា ធៀបនឹងបន្ទាត់ដែលកាត់តាមផ្ចិតនៃរង្វង់ទាំងពីរ ។

***លំហាត់គំរូ :*** គេឱ្យរង្វង់ពីរដែលមានកាំរៀងគ្នា $r = 5cm$ , $r' = 3cm$ ហើយ $OO'$ ជាចម្ងាយរវាងផ្ចិតទាំងពីរដែល $OO' = 2x+1$ ។ ចូរកំណត់ $x$ ដើម្បីឱ្យ

ក. រង្វង់ពីរប៉ះក្រៅ

ខ. រង្វង់កាត់គ្នាត្រង់ពីរចំណុច ។

***ចម្លើយ :***

ក. រង្វង់ពីរប៉ះក្រៅកាលណា $d = r+r' = 8+5 = 13$ ។

$OO' = d = 2x+1$ ជាចម្ងាយរវាងផ្ចិតទាំងពីរ ។

គេបាន $2x+1 = 12$ នាំឱ្យ $x = 6$ ហេតុនេះ $x = 6cm$

ដូចនេះ រង្វង់ពីរប៉ះគ្នារួមក្រៅកាលណា $x = 6$ ។

ខ. រង្វង់ពីរកាត់គ្នាត្រង់ពីរចំណុចកាលណា $r-r' < d < r+r'$

គេបាន $8-5 < d < 8+5$

$3 < 2x+1 < 13$ ឬ $4 < 2x < 12$

$2 < x < 6$

ដូចនេះ រង្វង់កាត់គ្នាត្រង់ពីរចំណុចកាលណា $2 < x < 6$ ។

ហេតុនេះ $2cm < x < 6cm$

***ប្រតិបត្តិ :*** គេឱ្យរង្វង់ពីរ ដែលមានកាំរៀងគ្នា $r = 5cm$ , $r' = 3cm$ ។ $OO'$ កាត់រង្វង់រៀងគ្នាត្រង់ $A$ , $B$ ។ ចូរគណនាប្រវែង $AB$ ។



## ៦. បន្ទាត់ប៉ះរួម

បន្ទាត់ប៉ះរួមនៃរង្វង់ពីរផ្សេងគ្នាអាស្រ័យលើទំនាក់ទំនងទីតាំងនៃរង្វង់ទាំងពីរដូចរូបខាងក្រោម ។

### ក. រង្វង់គ្មានចំណុចរួម




- រង្វង់ទាំងពីរគ្មានចំណុចរួម $AB$ និង $CD$ ហៅថាបន្ទាត់ប៉ះរួមខាងក្រៅ ។ រង្វង់ទាំងពីរស្ថិតនៅតែម្ខាងនៃបន្ទាត់ $AB$ និង $CD$ ។




- រង្វង់ទាំងពីរគ្មានចំណុចរួម បន្ទាត់ $MN$ និង $PQ$ ហៅថាបន្ទាត់ប៉ះរួមខាងក្នុង ។ រង្វង់ទាំងពីរស្ថិតនៅសងខាងនៃបន្ទាត់ $MN$ និង $PQ$ ។

### ខ. រង្វង់ប៉ះគ្នា




- រង្វង់ពីរមានចំណុចរួមមួយ ហៅថារង្វង់ប៉ះគ្នា ។ $l$ ជាបន្ទាត់ប៉ះរួមដែលរង្វង់ទាំងពីរ ស្ថិតនៅសងខាងនៃបន្ទាត់ $l$ ។




- រង្វង់ទាំងពីរមានចំណុចរួមមួយ ។ $l$ ជាបន្ទាត់ប៉ះរួម ។ រង្វង់ទាំងពីរស្ថិតនៅតែម្ខាងនៃបន្ទាត់ $l$ ។

### គ. រង្វង់កាត់គ្នា




រង្វង់ទាំងពីរកាត់គ្នាត្រង់ពីរចំណុច ។ បន្ទាត់ $XY$ និង $ZE$ ជាបន្ទាត់ប៉ះរួមខាងក្រៅ ។ រង្វង់ទាំងពីរស្ថិតនៅតែម្ខាងនៃ $XY$ និង $ZE$ ។

### ឃ. រង្វង់តូចនៅក្នុងរង្វង់ធំ




គ្មានចំណុចប៉ះរួម ។

***លំហាត់គំរូទី 1 :*** គេមានរង្វង់ពីរ ផ្សេងគ្នាដែលមានរង្វាស់កាំ $a$ និង $b$ គិតជា $cm$ ហើយ ចម្ងាយរវាងរង្វង់ទាំងពីរស្មើ $d$ ។ ចូររកចំនួនបន្ទាត់ប៉ះរួមតាមករណីខាងក្រោម ។

| | ក | ខ | គ | ឃ |
|---|---|---|---|---|
| $a$ | 3 | 4 | 2 | 5 |
| $b$ | 5 | 3 | 3 | 3 |
| $d$ | 10 | 6 | 5 | 2 |
| បន្ទាត់ប៉ះ | | | | |

ក. $d>a+b$ នាំឱ្យរង្វង់ទាំងពីរគ្មានចំណុចរួម ។ ដូចនេះមានបន្ទាត់ប៉ះ 4 ។

ខ. $a-b<d<a+b$ នាំឱ្យរង្វង់ទាំងពីរកាត់គ្នាត្រង់ពីរចំណុច ។ ដូចនេះមានបន្ទាត់ប៉ះរួម 2 ។

គ. $d = a+b$ នាំឱ្យរង្វង់ពីរប៉ះគ្នាមានចំណុចរួមមួយ ។ រង្វង់ទាំងពីរស្ថិតនៅសងខាងនៃបន្ទាត់ប៉ះ ។ ដូចនេះមានបន្ទាត់ប៉ះរួម 3 ។

ឃ. $d = b-a$ នាំឱ្យរង្វង់ពីរប៉ះគ្នាមានចំណុចរួមមួយ ។ រង្វង់ទាំងពីរស្ថិតនៅម្ខាងនៃបន្ទាត់ប៉ះ ។ ដូចនេះមានបន្ទាត់ប៉ះរួម 1 ។

***លំហាត់គំរូទី 2 :*** $XY$ ជាបន្ទាត់ប៉ះរួមខាងក្នុងរង្វង់ផ្ចិត $O$ និង $O'$ ។ $XS$ ជាបន្ទាត់ប៉ះរង្វង់ផ្ចិត $O$ ត្រង់ $S$ ហើយ $YT$ ជាបន្ទាត់ប៉ះរង្វង់ផ្ចិត $O'$ ត្រង់ $T$ ។ ចូរបង្ហាញថា $XS = YT$ ។

***ចម្លើយ :*** គេមាន $XY = XS$ បន្ទាត់ប៉ះរង្វង់ផ្ចិត $O$ គូសចេញពីចំណុចរួម ។ $XY = YT$ បន្ទាត់ប៉ះរួម គូសចេញពីចំណុចរួម ។ ដូចនេះ $XS = YT$ ។




***ប្រតិបត្តិ :*** គេមានរង្វង់ពីរ មានទំហំខុសគ្នាដែលមានផ្ចិត $O$ និង $O'$ ។ រង្វង់ទាំងពីរនេះមានបន្ទាត់ប៉ះរួមមួយ ដែលមានចម្ងាយរវាងផ្ចិតទាំងពីរស្មើនឹង $4cm$ និងមានចម្ងាយរវាងផ្ចិតទាំងពីរស្មើនឹង $1cm$ ដូចរូបខាងក្រោម ។ ចូរគណនាកាំនៃរង្វង់ទាំងពីរ ។






## ? លំហាត់

1. ក្នុងរូបនីមួយៗខាងក្រោមនេះ គេមានរង្វង់ផ្ចិត $O$ និង $PT$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់ត្រង់ $T$ ។




ក. ចូររកតម្លៃនៃមុំ $a$




ខ. ចូររកតម្លៃនៃមុំ $a$ និងមុំ $b$




គ. ចូររកតម្លៃនៃមុំ $b$




ឃ. ចូររកតម្លៃនៃមុំ $a$ និងមុំ $b$




ង. ចូររកតម្លៃនៃមុំ $a$ , $b$ និងមុំ $c$




ច. $AOT$ និង $BOP$ ជាបន្ទាត់ត្រង់ ចូររកតម្លៃនៃមុំ $a$ និងមុំ $b$ ។

2. ក្នុងរូបនីមួយៗខាងក្រោមនេះ គេមាន $PT$ និង $PV$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់ផ្ចិត $O$ ត្រង់ $T$ និង $V$ ។រករង្វាស់មុំដែលមិនស្គាល់ ។




(ក)




(ខ)




(គ)




(ឃ)

3. គេមានរង្វង់ផ្ចិត $O$ ដែលមាន $PA$ និង $PB$ ជាបន្ទាត់ប៉ះនឹងរង្វង់រៀងគ្នាត្រង់ $A$ និង $B$ ដូចរូបខាងក្រោម ។ ចូរគណនារង្វាស់កាំ $r$ និងរង្វាស់ $d$ ។ រង្វាស់គិតជា $cm$ ។






4. នៅក្នុងរូបខាងស្តាំនេះមាន $O$ ជាផ្ចិតនៃរង្វង់ហើយ $PA$ និង $PB$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់រៀងគ្នាត្រង់ $A$ និង $B$ ។ រង្វាស់គិតជា $cm$ ។

ចូរគណនា : ក. រង្វាស់ $b$ ។

ខ. រង្វាស់ $c$ ។

គ. បរិមាត្រនៃចតុកោណ $OAPB$ ។

ឃ. ផ្ទៃក្រឡានៃចតុកោណ $OAPB$ ។




5. ក្នុងរូបខាងស្តាំនេះមាន $AB$ , $BC$ និង $AC$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់រៀងគ្នាត្រង់ $D$ , $E$ និង $F$ ។ ចូរគណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ។ រង្វាស់គិតជា $cm$ ។




6. គេមាន $PA$ និង $PB$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់ដែលមានផ្ចិត $O$ និងកាំ $3cm$ ។ គេឱ្យ $AP = 82.4cm$ និង $\angle AOB = 140°$ ។ ចូរគណនាផ្ទៃក្រឡា

ក. ចតុកោណ $APBO$ ។

ខ. ផ្ទៃក្រឡានៃចម្រៀកថាសតូច $AOB$ យក $\left(\pi = \frac{22}{7}\right)$ ។




7. ក្នុងរង្វង់ផ្ចិត $O$ គេមាន $AT$ និង $BT$ មានប្រវែង $20cm$ ។ បើ $TQO$ ជាបន្ទាត់ត្រង់ដែល $TQ = 10cm$ ។ ចូររករង្វាស់នៃកាំរង្វង់ ។




8. នៅក្នុងរង្វង់ផ្ចិត $O$ ដែលមានកាំស្មើនឹង $4.5cm$ ។ គេមាន $TA$ និង $TB$ ជាបន្ទាត់ប៉ះ នឹងរង្វង់រៀងគ្នាត្រង់ $A$ និង $B$ ដែល $TA = 9cm$ ។

ក. ចូររកបរិមាត្រនៃចតុកោណ $OATB$ ។

ខ. ចូររកផ្ទៃក្រឡានៃចតុកោណ $OATB$ ។



9. នៅក្នុងរូបខាងស្ដាំនេះគេឱ្យរង្វង់ពីរដែលមានផ្ចិត $A$ និង $B$ ហើយមានរង្វាស់កាំស្មើគ្នា $4cm$ ។ ចំពោះរង្វង់ផ្ចិត $A$ មាន $CB$ និង $CD$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់រៀងគ្នាត្រង់ $B$ និង $D$ ។ ចំពោះរង្វង់ផ្ចិត $B$ មាន $DA$ និង $DC$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់រៀងគ្នាត្រង់ $A$ និង $C$ ។ ចូររកផ្ទៃក្រឡានៃចតុកោណ $ABCD$ ។




10. $TA$ និង $TB$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់ផ្ចិត $O$ ដែលមានកាំស្មើនឹង $5cm$ ។ បើ $\angle ATB = 60°$ ចូរគណនា

ក. $\angle AOB$ ។

ខ. ផ្ទៃក្រឡានៃចម្រៀកថាសតូច $AOB$ $\left(\pi = \frac{22}{7}\right)$ ។




11. រង្វង់ពីរមានផ្ចិតរួម $O$ មានកាំ $8cm$ និង $10cm$ ។ $AB$ ជាអង្កត់ធ្នូនៃរង្វង់ធំហើយប៉ះរង្វង់តូចត្រង់ $T$ ។ ចូរគណនា $AB$ ។ (ណែនាំ : គូស $OA$ និង $OB$ )




12. គេមាន $MA$ , $MB$ និង $MC$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់ផ្ចិត $O$ និងផ្ចិត $O'$ ។ ចូរបង្ហាញថា $MA = MC$ ។




13. $EF$ និង $EG$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់ផ្ចិត $H$ ។

គេមាន $\angle JEF = 22°$ ។ ចូរគណនា ។

ក. $\angle EGH$

ខ. $\angle HGF$

គ. $\angle FGE$ ។



មេរៀនទី

# 14 លក្ខណៈមុំនៃរង្វង់

**វត្ថុបំណង**

- គណនាមុំចារឹកក្នុងរង្វង់ ។
- បង្ហាញលក្ខណៈនៃមុំចារឹកក្នុងរង្វង់ ។
- គណនាមុំឈមនៃចតុកោណចារឹកក្នុងរង្វង់ ។
- គណនាមុំក្នុង និងមុំក្រៅរង្វង់ ។
- គណនាមុំដែលកើតឡើងដោយបន្ទាត់ប៉ះរង្វង់និងអង្កត់ធ្នូ ។

## 1. មុំផ្ចិត

នៅថ្នាក់ទី 8 យើងបានសិក្សារួចមកហើយនូវមុំផ្ចិត ។




***ឧទាហរណ៍ទី 1:*** គេមានរង្វង់ផ្ចិត $O$ គេគូសកាំ $OP$ និង $OR$ គេបានមុំផ្ចិតពីរ គឺមុំលយ $\angle POR$ ស្កាត់ដោយធ្នូតូច $PR$ និងមុំឆក $\angle POR$ ស្កាត់ដោយធ្នូធំ $PR$ ។ មុំទាំងពីរនេះហៅថាមុំផ្ចិត ។




***ឧទាហរណ៍ទី 2:*** គេមានធ្នូពីរ $AB$ និង $DC$ នៅលើរង្វង់ផ្ចិត $O$ ។ ធ្នូ $AB$ ស្កាត់ដោយមុំផ្ចិត $\angle AOB$ និងធ្នូ $DC$ ស្កាត់ដោយមុំផ្ចិត $\angle COD$ ។ បើធ្នូ $AB$ និងធ្នូ $DC$ ត្រួតស៊ីគ្នានោះ ធ្នូទាំងពីរប៉ុនគ្នា គេបានមុំផ្ចិតដែលស្កាត់ធ្នូទាំងពីរក៏ប៉ុនគ្នាដែរ ។

> ***ជាទូទៅ :*** ក្នុងរង្វង់មួយធ្នូពីរប៉ុនគ្នា ស្កាត់ដោយមុំផ្ចិតពីរប៉ុនគ្នា ហើយច្រាសមកវិញ កាលណាមុំផ្ចិតពីរប៉ុនគ្នានោះធ្នូស្កាត់ទាំងពីរក៏ប៉ុនគ្នា ។

***លំហាត់គំរូ :*** នៅក្នុងរង្វង់ផ្ចិត $O$ គេឱ្យអង្កត់ផ្ចិត $AD$ ហើយ $C$ ជាចំណុចមួយនៃធ្នូ $BD$ ដែល $\overset{\frown}{AB} = 40°$ និង $\overset{\frown}{CD} = 60°$ ។ ចូរគណនារង្វាស់ $\angle AOC$ ។

***ចម្លើយ :*** $\angle AOC = \angle AOB + \angle BOC$

$\angle AOB = \widehat{AB} = 40°$ (មុំផ្ចិតស្កាត់ធ្នូ $AB$ )

$\angle BOC = 180° - \angle AOB + \angle COD$

$\angle BOC = 180° - 40° + 60° = 80°$




នាំឱ្យ $\angle AOC = 40° + 80° = 120°$ ។ ដូចនេះ $\angle AOC = 120°$ ។

***ប្រតិបត្តិ :*** គេឱ្យរង្វង់ផ្ចិត $O$ និង $B$ ជាចំណុចកណ្ដាលនៃធ្នូ $AC$ ។ ចូរបង្ហាញថា $\angle AOB = \angle COB$ ។

## 2. មុំចារឹកក្នុងរង្វង់

### 2.1. និយមន័យ

***ឧទាហរណ៍ :*** គេមានរង្វង់ផ្ចិត $O$ គេគូសអង្កត់ធ្នូពីរ $AN$ និង $NB$ កាត់គ្នាត្រង់ចំណុច $N$ មួយនៅលើរង្វង់ ។ គេបានមុំ $\angle ANB$ ជាមុំដែលស្ថិតលើរង្វង់ ហៅថាមុំចារឹកក្នុងរង្វង់ដែលស្កាត់ ដោយធ្នូ $\widehat{AQB}$ ។




> ***និយមន័យ :*** មុំចារឹកក្នុងរង្វង់ជាមុំដែលមាន
> កំពូលស្ថិតនៅលើរង្វង់ ហើយជ្រុងទាំងពីរកាត់រង្វង់ជាអង្កត់ធ្នូ ។

***លំហាត់គំរូ :*** តើមុំខាងក្រោមនេះជាមុំចារឹកក្នុងរង្វង់ ឬទេ ? ព្រោះអ្វី ?






*ចម្លើយ :*

ក. មុំ $\angle xAy$ មិនមែនជាមុំចារឹកក្នុងរង្វង់ទេព្រោះកំពូល $A$ មិនស្ថិតនៅលើរង្វង់ ។

ខ. មុំ $\angle xAy$ មិនមែនជាមុំចារឹកក្នុងរង្វង់ទេព្រោះជ្រុង $Ay$ នៅក្រៅរង្វង់ ។

*ប្រតិបត្តិ :* តាមរូបខាងស្តាំនេះ តើមានមុំចារឹកក្នុងរង្វង់ប៉ុន្មាន ?




## 2.2. មុំចារឹកក្នុងរង្វង់និងធ្នូ




*ឧទាហរណ៍ទី 1 :* គេឱ្យ $\angle ABC$ ជាមុំចារឹកក្នុងរង្វង់មានផ្ចិត $O$ ។ $BC$ ជាអង្កត់ផ្ចិត ។ បង្ហាញថា $\angle ABC = \frac{1}{2}\widehat{AC}$ ។

គូសភ្ជាប់ $OA$ គេបានត្រីកោណសមបាត $AOB$ ($OA = OB = r$ កាំរង្វង់) ។ ដូចនេះ $\angle A = \angle B$ ។ តែមុំ $\angle AOC = \angle A + \angle B$ មុំក្រៅនៃ $\Delta AOB$ ។ $\angle AOC = 2\angle B$ ឬ $\angle B = \frac{1}{2}\angle AOC$ ។ ដោយមុំ$\angle AOC = \widehat{AC}$ (មុំផ្ចិតស្កាត់ដោយធ្នូ $AC$) នាំឱ្យ $\angle B = \frac{1}{2}\widehat{AC}$ ។




*ឧទាហរណ៍ 2 :* គេឱ្យ $\angle ABC$ ចារឹកក្នុងរង្វង់ផ្ចិត $O$ ដែលស្ថិតនៅក្នុង $\angle AOB$ ។

បង្ហាញថា $\angle ABC = \frac{1}{2}\widehat{AC}$ ។

គេមាន $\angle ABC$ ជាមុំចារឹកក្នុងរង្វង់ ។

គូសអង្កត់ពីចំណុច $B$ កាត់ផ្ចិត $O$ ជួបរង្វង់ត្រង់ $D$ ។




$$\angle BAC = \angle BAD + \angle DAC$$

$$= \frac{1}{2}\widehat{BD} + \frac{1}{2}\widehat{DC} \quad \text{(តាមឧទាហរណ៍ទី 1)}$$

$$= \frac{1}{2}(\widehat{BD} + \widehat{DC})$$

$$= \frac{1}{2}\widehat{AC}$$

ដូចនេះ $\angle ABC = \frac{1}{2}\widehat{AC}$ ។

*ជាទូទៅ :* គ្រប់មុំចារឹកក្នុងរង្វង់មានរង្វាស់ស្មើនឹងកន្លះ រង្វាស់ធ្នូដែលស្កាត់មុំនោះ ។

***លំហាត់គំរូ :*** ចូរគណនាធ្នូ $AB$ , $AC$ , $BC$ តាមរូបខាងស្តាំ ។




***ចម្លើយ :***

$\overset{\frown}{BC} = 2\angle A = 2\times 40^\circ = 80^\circ$

$\overset{\frown}{AC} = 2\angle B = 2\times 60^\circ = 120^\circ$

$\overset{\frown}{AB} = 2\angle C = 2\times 80^\circ = 160^\circ$ ។

***ប្រតិបត្តិ :*** គេមាន $\angle ABC$ ចារឹកក្នុងរង្វង់ផ្ចិត $O$ ដែលមានចំណុច $O$ ឋិតនៅក្រៅ $\angle ABC$ ។ ដោយប្រើលក្ខណៈនៃឧទាហរណ៍ទី 1 ចូរបង្ហាញថា $\angle ABC = \frac{1}{2}\overset{\frown}{AC}$ (រូបខាងស្តាំ) ។




## 2.3. មុំចារឹកក្នុងរង្វង់ស្កាត់ធ្នូតែមួយ

***ឧទាហរណ៍ :*** គូសរង្វង់ផ្ចិត $O$ និងកាំ $5cm$ ។ គេដៅចំណុចពីរ $A$ និង $B$ នៅលើរង្វង់ ។ ដៅចំណុចពីរ $P$ និង $Q$ លើធ្នូធំ $\overset{\frown}{AB}$ ។ ភ្ជាប់ $AP$ , $AQ$ , $BP$ និង $BQ$ ។




**ក.** វាស់មុំ $\angle APB$ និង $\angle AQB$ តើអ្នកសង្កេតឃើញដូចម្តេច ?

**ខ.** ដៅចំណុច $R$ មួយទៀតនៅលើធ្នូធំ $\overset{\frown}{AB}$ ។ ភ្ជាប់ $AR$ និង $BR$ ។ វាស់មុំ $\angle ARB$ តើអ្នកសង្កេតឃើញដូចម្តេច ?

តាមសកម្មភាពនេះយើងសង្កេតឃើញថារង្វាស់មុំ $\angle APB = \angle AQB = \angle ARB$ ។

***ជាទូទៅ :*** គ្រប់មុំចារឹកក្នុងរង្វង់មានរង្វាស់ស្មើនឹងកន្លះរង្វាស់ធ្នូ ដែលស្កាត់មុំនោះ ។

$a = b$

$c = d$




***ឧទាហរណ៍ :*** តាមរូបខាងស្តាំនេះចូររករង្វាស់មុំ $a$ និង $b$ ។

$a = 32^\circ$ (មុំស្កាត់ធ្នូ $MN$ តែមួយ)

$b = 10^\circ$ (មុំស្កាត់ធ្នូ $PQ$ តែមួយ) ។



***លំហាត់គំរូ :*** គេឱ្យអង្កត់ធ្នូ $BD = DC, \angle ABD = 42°$ និង $\angle DBC = 65°$ (ដូចរូបខាងស្តាំ) ។




ចូរគណនា :

ក. $\angle ADC$

ខ. $\angle BAC$

គ. $\angle DAB$

ឃ. $\angle DEC$ ។

***ចម្លើយ :***

ក. ក្នុង $\Delta BDC$

គេបាន $\angle BDC + \angle DCB + \angle DBC = 180°$ (ផលបូកមុំនៃត្រីកោណមួយ)

$\angle DBC = 65°$ (សម្មតិកម្ម)

$\angle DCB = \angle DBC$ (មុំបាតនៃត្រីកោណសមបាត)

$\angle DCB = 65°$

ដូចនេះ $\angle BDC + 65° + 65° = 180°$

នាំឱ្យ $\angle BDC = 180° - 130° = 50°$

ដូចនេះ $\angle BDC = 50°$ ។

ខ. គេបាន $\angle BAC = \angle BDC$ (មុំចារឹកក្នុងរង្វង់ស្កាត់ធ្នូ $BC$ តែមួយ)

នាំឱ្យ $\angle BAC = 50°$ ។

គ. គេមាន $\angle DAB = \angle DAC + \angle BAC$

$\angle DAC = \angle DBC$ (មុំចារឹកក្នុងរង្វង់ស្កាត់ធ្នូ $DC$ តែមួយ)

$\angle DBC = 65°$ (សម្មតិកម្ម)

នាំឱ្យ $\angle DAC = 65°$ ។

តាមចំណុច ខ. $\angle BAC = 50°$

ដូចនេះ $\angle DAB = 65° + 50° = 115°$

$\angle DAB = 115°$ ។

ឃ. ក្នុង $\Delta DEC$ គេបាន

$\angle DEC + \angle EDC + \angle ECD = 180°$ (ផលបូកមុំត្រីកោណ)

$\angle EDC = \angle BDC$

$\angle EDC = 50°$ (ពីរសំនួរ ក)

$\angle ECD = \angle ACD$

$\angle ACD = \angle ABD$ (មុំចារឹកក្នុងរង្វង់ស្កាត់ធ្នូ $\widehat{AD}$ តែមួយ)

$\angle ACD = 42°$

នាំឱ្យ $\angle ECD = 42°$ ។

ដូចនេះ $\angle DEC + 50° + 42° = 180°$

$\angle DEC = 180° - 92° = 88°$

$\angle DEC = 88°$ ។

***ប្រតិបត្តិ :*** ក្នុងរូបខាងស្តាំនេះអង្កត់ធ្នូ $AC$ ប្រសព្វនឹង $BD$ ត្រង់ $I$ ។ គេឱ្យ $\angle ACB = 34°$ និង $\angle CAD = 45°$ ។ ចូរគណនា $\angle AIB$ ។




## 2.4. មុំផ្ចិតនិងមុំចារឹកក្នុងរង្វង់

នេះជាករណីពិសេសនៃទំនាក់ទំនងរវាងមុំផ្ចិតនិងមុំចារឹកក្នុងរង្វង់ដែលស្កាត់ធ្នូតែមួយ ។

***ឧទាហរណ៍ :*** គេគូសរង្វង់ផ្ចិត $O$ និងកាំ $5Cm$ ។ ដៅចំណុច $A$ , $B$ និង $C$ នៅលើរង្វង់ ។ គេបានមុំ $\angle ABC$ ជាមុំស្រួច ។ ភ្ជាប់ $OA$ , $OC$ , $AB$ និង $BC$ ។ វាស់មុំ $\angle ABC$ និង $\angle AOC$ ។ តើយើងកត់សម្គាល់ឃើញដូចម្តេច ?




កាលណាគេវាស់មុំទាំងពីរនេះទៅយើងសង្កេតឃើញថា មុំ $\angle AOC = 2\angle ABC$ ។

តាមពិត $\angle AOC = \widehat{AC}$ មុំផ្ចិតស្កាត់ធ្នូ $\widehat{AC}$

$\angle ABC = \frac{\widehat{AC}}{2}$ មុំចារឹតក្នុងស្កាត់ធ្នូ $\widehat{AC}$

ហេតុនេះ $\angle AOC = 2\angle ABC$ ។

***ជាទូទៅ :*** មុំផ្ចិតនៃរង្វង់មួយមានរង្វាស់ស្មើនឹងពីរដងមុំចារឹកក្នុងរង្វង់ដែលស្កាត់ធ្នូតែមួយ ។




$a = 2b$

***លំហាត់គំរូទី1 :*** ក្នុងរូបខាងក្រោមនេះ ចូររករង្វាស់មុំ $x$ , $y$ និង $a$ ។




*រូប(ក)*




*រូប(ខ)*




*រូប(គ)*

***ចម្លើយ :***

ក. គេមាន $\angle BOC = 2\angle BAC$ (មុំផ្ចិតស្មើនឹងពីរដងមុំចារឹកក្នុងស្កាត់ធ្នូតែមួយ)

$$76° = 2x$$

$$x = \frac{76°}{2} = 38°$$

ដូចនេះ $x = 38°$ ។

ខ. គេមាន $y = 2\angle QPR$ (មុំផ្ចិតស្មើនឹងពីរដងមុំចារឹកក្នុងរង្វង់ស្កាត់ធ្នូតែមួយ)

$$y = 2 \times 100° = 200°$$

ដូចនេះ $y = 200°$ ។

គ. $\angle WOY = 360° - 130° = 230°$

$230° = 2a$ (មុំផ្ចិតស្មើនឹងពីរដងនៃមុំចារឹកក្នុងស្កាត់ធ្នូតែមួយ)

$$a = \frac{230}{2} = 115°$$

ដូចនេះ $a = 115°$ ។

***លំហាត់គំរូទី 2 :*** រង្វង់មួយមានផ្ចិត $O$ ដែល $\angle OBC = 30°$ ។

ចូរគណនា $\angle BCO$ , $\angle BOC$ និង $\angle BAC$ ។

***ចម្លើយ :*** គេមាន $\angle BCO = \angle CBO$ (មុំបាតនៃត្រីកោណសមបាត $BOC$ ) $\angle BOC = 30°$ ។




ដូចគ្នានេះដែរគេបាន

$\angle BOC + \angle BCO + \angle CBO = 180°$ (ផលបូកមុំក្នុងត្រីកោណ)

នាំឱ្យ $\angle BOC + 30° + 30° = 180°$

ដូចនេះ $\angle BOC = 180° - 60° = 120°$ ។

$\angle BOC = 120°$

តែ $\angle BOC = 2\angle BAC$ (មុំផ្ចិតស្មើពីរដងមុំចារឹកក្នុង)

$2\angle BAC = 120°$ នាំឱ្យ $\angle BAC = \frac{120°}{2} = 60°$

ដូចនេះ $\angle BAC = 60°$ ។

***លំហាត់គំរូទី 3 :*** រង្វង់មួយមានផ្ចិត $O$ ដែល $\angle ABO = 30°$ និង $\angle ACO = 20°$ ។ ចូរគណនារង្វាស់មុំ $\angle BAC$ និង $\angle BOC$ ។

***ចម្លើយ :*** គេមាន $\angle BAC = \angle BAO + \angle CAO$




ក្នុង $\Delta BAO$ មាន $\angle BAO = \angle ABO$ (មុំបាតនៃត្រីកោណសមបាត $AOB$ )

$\angle ABO = 30°$ នាំឱ្យ $\angle BAO = 30°$ ។

ក្នុង $\Delta CAO$ មាន $\angle CAO = \angle ACO$ (មុំបាតនៃត្រីកោណសមបាត $AOC$ )

$\angle ACO = 20°$ នាំឱ្យ $\angle CAO = 20°$ ។

ដូចនេះ $\angle BAC = 30° + 20° = 50°$ ។

$\angle BOC = 2\angle BAC$ (មុំផ្ចិតស្មើពីរដងមុំចារឹកក្នុង)

$\angle BOC = 2 \times 50° = 100°$ ។

*ប្រតិបត្តិ :* រង្វង់មួយមានផ្ចិត $O$ ដែល $\angle AOB = 60°$ ។
ចូរគណនារង្វាស់មុំ $\angle ACB$ , $\angle ADB$ និង $\angle AEB$ ។
(រូបខាងស្តាំ)




## 3. មុំចារឹកក្នុងកន្លះរង្វង់

*ឧទាហរណ៍ :* គេមានរង្វង់ផ្ចិត $O$ និង $AB$ ជាអង្កត់ធ្នូកាត់តាមផ្ចិតនៃរង្វង់ ។ គេបាន




- $AB$ ជាអង្កត់ផ្ចិត
- ធ្នូ $ADB$ និងធ្នូ $ACB$ ជាកន្លះរង្វង់
- $\angle ACB$ ជាមុំស្ថិតនៅលើរង្វង់ ។

គេថា $\angle ACB$ ជាមុំចារឹកក្នុងកន្លះដែលស្មើនឹងពាក់កណ្តាលមុំផ្ចិតនោះ

$\angle ACB = \frac{1}{2}\angle AOB$ ( $\angle AOB = 180°$ ជាមុំរាប )

គេបាន $= \frac{1}{2} \times 180° = 90°$

ដូចនេះ $\angle ACB = 90°$ ។

*ជាទូទៅ :* គ្រប់មុំចារឹកក្នុងកន្លះរង្វង់ជាមុំកែង ។

$a = 90°$ ។




*លំហាត់គំរូទី 1 :* តាមរូបខាងស្តាំនេះ $AB$ ជាអង្កត់ផ្ចិត ។ ចូរគណនារង្វាស់មុំ $a$ និង $b$ ។

*ចម្លើយ :* គេបាន $a = 90°$ ជាមុំចារឹកក្នុងកន្លះរង្វង់ ។

ក្នុង $\Delta ABC$ មាន $a + 60° + b = 180°$ (ផលបូកមុំក្នុងត្រីកោណ)

$90° + 60° + b = 180°$

នាំឱ្យ $b = 180° - 150° = 30°$ ។

ដូចនេះ $b = 30°$ ។



***លំហាត់គំរូទី 2 :*** រង្វង់មួយដែលមានផ្ចិត $O$ និងអង្កត់ផ្ចិត $AB$ ។ ចូរគណនា $a$ និង $b$ (រូបខាងស្តាំ) ។




***ចម្លើយ :*** $a = \angle BAC$ (មុំចារឹកក្នុងស្ទាត់ធ្នូ $\overset{\frown}{CD}$ តែមួយ) ដូចនេះ $a = 21°$ ។

នៅក្នុង $\Delta ABC$ គេបាន

$\angle BAC + \angle ACB + b = 180°$ (ផលបូកមុំក្នុងត្រីកោណមួយ)

$\angle ACB = 90°$ (មុំចារឹកកន្លះរង្វង់)

$\angle BAC = 21°$ (សម្មតិកម្ម) ។

ដូចនេះ $21° + 90° + b = 180°$

នាំឱ្យ $b = 180° - 111° = 69°$

ដូចនេះ $b = 69°$ ។

***លំហាត់គំរូទី 3 :*** តាមរូបខាងស្តាំនេះគេមានរង្វង់ដែលមានផ្ចិត $O$ និង $PT$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់ត្រង់ $T$ បើ $\angle TAP = 35°$ ។

ចូរគណនា : ក. $\angle ATB$ ខ. $\angle APT$ គ. $\angle BTP$ ។




***ចម្លើយ :***

ក. $\angle ATB = 90°$ (មុំចារឹកក្នុងកន្លះរង្វង់)

ខ. ក្នុង $\Delta APT$ គេបាន

$\angle APT + \angle TAP + \angle TAP = 180°$ (ផលបូកមុំក្នុងត្រីកោណ $PRS$ )

$\angle TAP = 35°$ (សម្មតិកម្ម)

$\angle TAP = \angle OTA = 35°$ (មុំបាតនៃត្រីកោណសមបាត)

$\angle ATP = \angle ATO + \angle OTP$ ។

ដោយ $TP$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់និង $OT$ ជាកាំនៃរង្វង់

គេបាន $\angle OTP = 90°$

$\angle ATP = 35° + 90° = 125°$

ដូចនេះ $\angle APT + 35° + 125° = 180°$

$\angle APT = 180° - 160° = 20°$

$\angle APT = 20°$ ។

គ. $\angle ATB = \angle BTP + \angle ATP$

$90° + \angle BTP = 125°$

$\angle BTP = 125° - 90° = 35°$ ។

*ប្រតិបត្តិ :* តាមរូបខាងស្តាំនេះគេមានរង្វង់ដែលមានផ្ចិត $O$ និងអង្កត់ផ្ចិត $AC$ ហើយ $AD = DC$ ។ ចូរគណនារង្វាស់មុំ $x$ , $y$ , $z$ ។




# 4. មុំឈមនៃចតុកោណចារឹកក្នុងរង្វង់

## 4.1. និយមន័យ

ចតុកោណដែលមានកំពូលទាំងបួនស្ថិតនៅលើរង្វង់តែមួយ ហៅថាចតុកោណចារឹកក្នុងរង្វង់ ។ រង្វង់នេះហៅថារង្វង់ចារឹកក្រៅចតុកោណ ។ ក្នុងចតុកោណចារឹកក្នុងរង្វង់ $ABCD$ ។ គេមាន $\angle A$ និង $\angle C$ ជាមុំឈមនឹងគ្នាហើយ $\angle B$ និង $\angle D$ ក៏ជាមុំឈមនឹងគ្នាដែរ ។




## 4.2. លក្ខណៈមុំឈម

*ឧទាហរណ៍ទី 1 :* គូសរង្វង់ផ្ចិត $O$ និងកាំមានរង្វាស់ $5cm$ ។គេដៅបួនចំណុច $A$ , $B$ , $C$ និង $D$ តាមលំដាប់នៅលើរង្វង់ ។ ភ្ជាប់ $AB$ , $BC$ , $DC$ និង $DA$ ដើម្បីបង្កើតឱ្យបានចតុកោណ $ABCD$ មួយចារឹកក្នុងរង្វង់ផ្ចិត $O$ ។




ក. កាលណាយើងវាស់ $\angle DAB$ និង $\angle DCB$ រួចរកផលបូកនៃមុំទាំងពីរយើងបាន

$\angle DAB + \angle DCB = 180°$ ។

ខ. វាស់មុំ $\angle CBA$ និង $\angle CDA$ រួចរកផលបូកនៃមុំទាំងពីរ

យើងបាន $\angle CBA + \angle CDA = 180°$ ។

*ឧទាហរណ៍ទី 2 :* គេឱ្យចតុកោណ $ABCD$ ចារឹកក្នុងរង្វង់ដែលមានផ្ចិត $O$ ។ ចូរបង្ហាញថា ក. $\angle BAD + \angle BCD = 180°$ ខ. $\angle ABC + \angle ADC = 180°$ ។

ក. គេបាន $\angle BAD = \frac{1}{2}\overset{\frown}{BCD}$

$\angle BCD = \frac{1}{2}\overset{\frown}{BAD}$




$\angle BAC + \angle BCD = \frac{1}{2}(\overset{\frown}{BCD} + \overset{\frown}{BAD})$

$= \frac{1}{2} \times 360° = 180°$

ខ. គេបាន $\angle ABC = \frac{1}{2} \times \overset{\frown}{ADC}$

$\angle ADC = \frac{1}{2}\overset{\frown}{ABC}$

$\angle ABC + \angle ADC = \frac{1}{2}(\overset{\frown}{ADC} + \overset{\frown}{ABC})$

$= \frac{360°}{2} = 180°$ ។

**ជាទូទៅ :** មុំឈមក្នុងចតុកោណចារឹកក្នុងរង្វង់មួយជាមុំបន្ថែមគ្នា ។

$a + c = 180°$

$b + d = 180°$




**លំហាត់គំរូ :** គេឱ្យចតុកោណ $ABCD$ ចារឹកក្នុងរង្វង់ដែលមានផ្ចិត $O$ ដូចរូបខាងក្រោម ។ ចូរគណនារង្វាស់មុំ $x$ និង $y$ ។

**ចម្លើយ :**




$\angle DAB + \angle DCB = 180°$ (មុំឈមនៃចតុកោណចារឹកក្នុងរង្វង់)

$80° + y = 180°$

នាំឱ្យ $y = 180° - 80° = 100°$

ដូចនេះ $y = 100°$ ។

$\angle ABC + \angle ADC = 180°$ (មុំឈមនៃចតុកោណចារឹកក្នុងរង្វង់)

$70° + x = 180°$

នាំឱ្យ $x = 180° - 70° = 110°$ ។

***ប្រតិបត្តិ :*** តាមរូបខាងស្តាំនេះចូររករង្វាស់មុំ $a$ និង $b$ ។




## 5. មុំក្រៅនៃចតុកោណចារឹកក្នុងរង្វង់

***ឧទាហរណ៍ :*** គេមានចតុកោណចារឹកក្នុងរង្វង់ $PQRS$ ។




គេបន្លាយជ្រុងមួយនៃចតុកោណ $PS$ ទៅចំណុច $T$ ។

គេសង្កេតឃើញថា $x+y = 180°$ (មុំជាប់នៅលើបន្ទាត់មួយ)និង $y+z = 180°$ (មុំឈមនៃចតុកោណចារឹកក្នុងរង្វង់) ។

យើងទាញបាន $x+y = y+z$ , $x = z$

$x$ ជាមុំក្រៅចតុកោណ $PQRS$ ចារឹកក្នុងរង្វង់និង $z$ ជាមុំចារឹកក្នុងចតុកោណឈមទៅនឹងមុំ $x$ ។

***ជាទូទៅ :*** មុំក្រៅចតុកោណចារឹកក្នុងរង្វង់មានរង្វាស់ស្មើនឹងមុំឈមវាចារឹកក្នុងចតុកោណនោះ $p = q$ , $r = s$ ។




***លំហាត់គំរូទី1 :*** $ABCD$ ជាចតុកោណចារឹកក្នុងរង្វង់ដែលមាន $AD = AB$ និង $AD$ បន្លាយទៅ $E$ ។




បើ $\angle CDE = 70°$ និង $\angle CDB = 72°$ ។

ចូរគណនា : ក. $\angle BAD$ ខ. $\angle BCD$ ។

***ចម្លើយ :*** $\angle ADB + \angle BDC + \angle CDE = 180°$ (មុំបន្ថែមគ្នា)

$$\angle ADB + 72° + 70° = 180°$$

$$\angle ADB = 180° - 70° - 72° = 38°$$

ហើយ $\angle BAD + \angle ADB + \angle DBA = 180°$ (ផលបូកមុំក្នុងត្រីកោណមួយ)

ដោយ $\angle ADB = \angle DBA$ (មុំបាតនៃត្រីកោណសមបាត)

$\angle BAD + 38^\circ + 38^\circ = 180^\circ$

$\angle BAD = 180^\circ - 76^\circ = 104^\circ$

ដូចនេះ $\angle BCD + \angle BAD = 180^\circ$ (មុំឈមនៃចតុកោណចារឹកក្នុងរង្វង់)

$\angle BCD = 180^\circ - 104^\circ = 76^\circ$ ។

***លំហាត់គំរូទី 2 :*** គេមានចតុកោណ $ABDC$ និង $CDFE$ ជាចតុកោណចារឹកក្នុងរង្វង់ (ដូចរូបខាងស្ដាំ) ។ ចូរគណនាមុំ $a$ ។




***ចម្លើយ :*** គេមាន $CDFE$ ជាចតុកោណចារឹកក្នុងរង្វង់

$a = \angle ACD$ (មុំក្រៅចតុកោណចារឹកក្នុងរង្វង់ស្មើនឹងមុំក្នុងឈម) ក្នុងចតុកោណ $ABDC$ គេបាន

$\angle ACD + \angle ABD = 180^\circ$ (មុំឈមនៃចតុកោណចារឹកក្នុងរង្វង់)

$\angle ACD + 85^\circ = 180^\circ$

$\angle ACD = 180^\circ - 85^\circ = 95^\circ$

$a = \angle ACD = 95^\circ$ ។

***លំហាត់គំរូទី 3 :*** $EFGH$ គឺជាចតុកោណចារឹកក្នុងរង្វង់ដែលមាន $EH$ ស្របទៅនឹង $FG$ ហើយ $DG$ ជាអង្កត់ផ្ចិតនៃរង្វង់នៃផ្ចិត $O$ ។

គេឱ្យ $\angle DOH = 82^\circ$ និង $\angle DGE = 17^\circ$ ។

ចូរគណនា : ក. $\angle HEG$ ខ. $\angle HGF$ គ. $\angle FEG$ ។




***ចម្លើយ :***

ក. $\angle HOG + \angle HOD = 180^\circ$ (មុំលើបន្ទាត់មួយ)

$\angle HOG + 82^\circ = 180^\circ$

$\angle HOG = 180^\circ - 82^\circ = 98^\circ$

$2 \times \angle HEG = \angle HOG$ (មុំផ្ចិតស្មើនឹងពីរដងមុំចារឹកក្នុងរង្វង់)

$2 \times \angle HEG = 98^\circ$

នាំឱ្យ $\angle HEG = \dfrac{98}{2} = 49^\circ$ ។

ខ. $\angle EGF = \angle HEG$ (មុំឆ្លាស់ក្នុង $FG \parallel EH$)

$\angle EGF = 49°$

$\angle OGH + \angle HOG + \angle OHG = 180°$ (ផលបូកមុំក្នុងត្រីកោណ)

$\angle OGH = \angle OHG$ (មុំបាតនៃត្រីកោណសមបាត)

$2\angle OGH = 180° - \angle HOG$

$\angle OGH = \dfrac{180° - 98°}{2} = 41°$ ។

នាំឱ្យ $\angle HGF = \angle OGH + \angle DGE + \angle EGF$

$= 41° + 17° + 49° = 107°$ ។

គ. $\angle FEH + \angle HGF = 180°$ មុំឈមនៃចតុកោណចារឹកក្នុងរង្វង់

$\angle FEH = 180° - 107° = 73°$

នាំឱ្យ $\angle FEG = \angle FEH - \angle GEH$

$= 73° - 49° = 24°$ ។

***ប្រតិបត្តិ :*** គេមានចតុកោណ $ABCD$ ចារឹកក្នុងរង្វង់ដែលមាន $AB = BC$ ។ គេបន្លាយ $CD$ ដល់ $E$ ដែលមាន $\angle ACE = 27°$ និង $\angle ADE = 76°$ ។




ចូរគណនា : ក. $\angle ACB$ ខ. $\angle BAD$ ។

# 6. មុំដែលមានកំពូលមិននៅលើខ្សែ

## 6.1. មុំក្នុងរង្វង់

មុំក្នុងរង្វង់ជាមុំដែលមានកំពូលនៅក្នុងរង្វង់ ។

***ឧទាហរណ៍ :*** គេមាន $\angle AED$ ជាមុំក្នុងរង្វង់ដែលមានផ្ចិត $O$ ។ បង្ហាញថា $\angle AED = \frac{1}{2}(\overset{\frown}{AD} + \overset{\frown}{BC})$ ។




គេបាន $\angle C = \frac{1}{2}\overset{\frown}{AD}$ (មុំចារឹកស្កាត់ធ្នូ $AD$)

$\angle A = \frac{1}{2}\overset{\frown}{BC}$ (មុំចារឹកស្កាត់ធ្នូ $BC$)

តែ $\angle AED = \angle A + \angle C$ (មុំក្រៅត្រីកោណ)

$\angle AED = \frac{1}{2}(\overset{\frown}{AD} + \overset{\frown}{BC})$ ។

*ឧទាហរណ៍ទី 2 :* គូសរង្វង់ដែលមានកាំ $4cm$ ។ ដៅចំណុច $A$ និង $B$ នៅលើរង្វង់រួចភ្ជាប់បានជាត្រីកោណ $PAB$ មាន $\angle B$ ជាមុំស្រួច ។ គូសបន្ទាត់ប៉ះ $\angle XPY$ ប៉ះនឹងរង្វង់ត្រង់ $P$ ។ វាស់មុំ $\angle XPA$ និង $\angle PBA$ ។ តើអ្នកសង្កេតឃើញដូចម្តេច ? តាមសកម្មភាពនេះគេសន្និដ្ឋានថា $\angle XPA = \angle PBA$ ។




*ជាទូទៅ :* មុំដែលផ្គុំដោយបន្ទាត់ប៉ះរង្វង់និងអង្កត់ធ្នូគូសចេញពីចំណុចមួយនៅលើរង្វង់មានរង្វាស់ស្មើនឹងមុំចារឹកក្នុងរង្វង់ដែលមានអង្កត់ធ្នូនៅក្នុងនោះ ។

*សំរាយបញ្ជាក់ :* គេឱ្យរង្វាស់ផ្ចិត $O$ និង $AT$ ជាបន្ទាត់ប៉ះនៃរង្វង់ត្រង់ $A$ ហើយ $\angle ACB$ ជាមុំចារឹកក្នុងរង្វង់ដែលមានអង្កត់ធ្នូ $AB$ នៅក្នុងនោះ ។

បង្ហាញថា $\angle TAB = \angle ACB$ ។

ការស្រាយបញ្ជាក់នេះចំពោះ $\angle TAB$ ជាមុំស្រួច ។ គូសអង្កត់ផ្ចិត $AD$

យើងបាន




$$\angle TAD = 90°$$

ដូចនេះ $\angle TAB = 90° - \angle BAD$ (1)

ម្យ៉ាងទៀតនៅក្នុង $\Delta ABD$

$$\angle ABD = 90°$$

ដូចនេះ $\angle ADB = 90° - \angle BAD$ (2)




តាម (1) និង (2) និងលក្ខណៈនៃមុំចារឹកក្នុងគេបាន

$\angle TAB = \angle ADB = \angle ACB$

ដូចនេះ $\angle TAB = \angle ACB$ ។

*លំហាត់គំរូទី 1 :* ក្នុងរូបខាងស្តាំនេះគេមាន $ST$ ជាបន្ទាត់ប៉ះនៃរង្វង់ ។ ចូររករង្វាស់មុំ $a$ និង $b$ ។




*ចម្លើយ :*

គេបាន $a = 60°$ (ជាមុំដែលផ្គុំដោយបន្ទាត់ប៉ះរង្វង់និងអង្កត់ធ្នូ)

$b = 45°$ (ជាមុំដែលផ្គុំដោយបន្ទាត់ប៉ះរង្វង់និងអង្កត់ធ្នូ)

*លំហាត់គំរូទី 2 :* ក្នុងរូបខាងស្តាំនេះគេមាន $SAT$ ជាបន្ទាត់ប៉ះនៃរង្វង់ត្រង់ $A$ និង $BC$ ជាអង្កត់ផ្ចិត ។ បើ $\angle SAB = 40°$ ។

ចូរគណនា : ក. $\angle CAT$ ខ. $\angle CBA$ ។




*ចម្លើយ :*

ក. គេបាន $\angle BAC = 90°$ (មុំចារឹកកន្លះរង្វង់)

$\angle CAT = \angle SAT - \angle BAC - \angle SAB$

$\angle CAT = 180° - 90° - 40° = 50°$ ។

ខ. គេបាន $\angle CBA = \angle CTA = 50°$ (មុំដែលផ្គុំដោយបន្ទាត់ប៉ះរង្វង់និងអង្កត់ធ្នូ) ។

*លំហាត់គំរូទី 3 :* គេឱ្យរង្វង់ផ្ចិត $O$ និង $SET$ ជាបន្ទាត់ប៉ះនៃរង្វង់ត្រង់ $E$ ហើយ $SHF$ ជាបន្ទាត់ត្រង់ ។

គេឱ្យ $FG = FE$ , $\angle HES = 30°$ និង $\angle FET = 58°$ ។

ចូរគណនា : ក. $\angle GFE$ ខ. $\angle HSE$ ។




*ចម្លើយ :*

ក. គេបាន $\angle FGE = 56°$ (មុំដែលកើតឡើងដោយបន្ទាត់ប៉ះរង្វង់និងអង្កត់ធ្នូ)

ដូចនេះ $\angle GFE = 180° - \angle FGE - \angle GEF$ (ផលបូកមុំក្នុងត្រីកោណសមបាត)

$= 180° - 50° - 56° = 74°$

$\angle GFE = 74°$ ។

ខ. គេបាន $\angle HFE = 30^\circ$ (មុំដែលកើតឡើងដោយបន្ទាត់ប៉ះរង្វង់និងអង្កត់ធ្នូ)

$\angle HSE + \angle HFE = \angle FET$ (មុំក្រៅត្រីកោណ)

$\angle HSE + 30^\circ = 56^\circ$

$\angle HSE = 56^\circ - 30^\circ = 26^\circ$ ។

ដូចនេះ $\angle HSE = 26^\circ$ ។

*ប្រតិបត្តិ :* គេឱ្យរង្វង់ដែលមានផ្ចិត $O$ និង $SET$ ជាបន្ទាត់ប៉ះនៃរង្វង់ត្រង់ $E$ ។ គេឱ្យអង្កត់ $DE = DF$ និង $\angle FET = 40^\circ$ ។




ចូរគណនា :

ក. $\angle EOF$

ខ. $\angle DES$ ។

## លំហាត់

1. គេឱ្យរង្វង់ដែលមានផ្ចិត $O$ ហើយអង្កត់ធ្នូ $AC = AB$ និង $\angle ABC = 65^\circ$ ។ ចូររករង្វាស់មុំ $\angle ACB$ និង $\angle ABO$ (រូបខាងស្តាំ) ។




2. តាមរូបខាងស្តាំនេះ ចូររករង្វាស់មុំ $\angle ACD$ , $\angle BAE$ និង $\angle BDC$ ។




3. ក្នុងរង្វង់ដែលមានផ្ចិត $O$ គេឱ្យអង្កត់ធ្នូ $AB$ ស្របនឹង $CD$ ។ ចូរគណនារង្វាស់មុំ $\angle BCD$ , $\angle ADC$ និង $\angle ABC$ ។



4. តាមរូបខាងស្តាំនេះ ចូររករង្វាស់មុំ $x$ និង $y$ ។




5. គេឱ្យរង្វង់ដែលមានផ្ចិត $O$ ។ អង្កត់ធ្នូ $AC$ និង $BD$ កាត់គ្នាត្រង់ $I$ និង $\angle CAB = 40°$ , $\angle AIB = 60°$ ។ ចូរគណនារង្វាស់មុំ

ក. $\angle ACD$ ខ. $\angle CAD$ ។




6. បីចំណុច $A$ , $B$ , $C$ ឋិតនៅលើរង្វង់ដែលមានផ្ចិត $O$ ដូចរូបខាងស្តាំនេះ ។ គេឱ្យ $\angle AOC = 120°$ ។ ចូរគណនារង្វាស់មុំ $\angle ABC$ ។




7. ក្នុងរូបខាងស្តាំនេះគេមាន $O$ ជាផ្ចិតនៃរង្វង់ ។ អង្កត់ធ្នូ $AD$ ស្របនឹង $BC$ និង $\angle ACB = 45°$ , $\angle ACD = 25°$ ។ ចូរគណនារង្វាស់មុំ

ក. $\angle ADC$ ខ. $\angle OAB$ ។




8. ក្នុងរូបខាងស្តាំនេះគេមានចំណុច $A$ , $B$ , $C$ និង $D$ នៅលើរង្វង់ផ្ចិត $O$ ។ បើគេបន្លាយ អង្កត់ធ្នូ $AB$ និង $CD$ កាត់គ្នាត្រង់ $P$ ហើយ $\angle CBD = 35°$ , $\angle CAP = 70°$ និង $\angle DBP = 75°$ ។

ចូរគណនា : ក. $\angle ACD$ ខ. $\angle APC$ គ. $\angle DAB$ ។



9. ក្នុងរង្វង់ដែលមានផ្ចិត $O$ និង $AC$ ជាអង្កត់ផ្ចិត ។ គេបន្លាយអង្កត់ធ្នូ $BA$ និង $CD$ ជួបគ្នាត្រង់ $T$ ហើយ $AT = AC$ និង $\angle ATD = 20°$ ។ ចូរគណនារង្វាស់មុំ

ក. $\angle ADB$ ខ. $\angle BOC$ គ. $\angle BDC$ ។




10. ក្នុងរង្វង់ផ្ចិត $O$ ដែលមានអង្កត់ផ្ចិត $QS$ ប្រសព្វនឹងអង្កត់ធ្នូ $PR$ ត្រង់ $M$ ចំណុចកណ្ដាលនៃ $PR$ ។ គេឱ្យ $\angle POQ = 134°$ ។ ចូរគណនារង្វាស់មុំ

ក. $\angle PRQ$ ខ. $\angle RPQ$ គ. $\angle RSQ$ ។




11. គេមានរង្វង់ដែលមានផ្ចិត $O$ និង $PQ$ ជាបន្ទាត់ប៉ះរង្វង់ត្រង់ $R$ ។ $RS$ ជាអង្កត់ផ្ចិតនិង $\angle ROQ = 48°$ ។ ចូរគណនារង្វាស់មុំ ក. $\angle OQR$ ខ. $\angle RST$ គ. $\angle TRQ$ ។




12. គេមានរង្វង់ផ្ចិត $O$ និង $ABC$ ជាត្រីកោណ ។ បើរង្វង់កាត់ $BC$ ត្រង់ $C$ និង $AE$ ត្រង់ $D$ ។ ចូរគណនារង្វាស់មុំ $x$ , $y$ និង $z$ ។




13. គេមាន $ABCD$ ជាចតុកោណចារឹកក្នុងរង្វង់ដែលមាន $AB = BC$ និង $\angle ACE = 25°$ ។ គេបន្លាយ $CD$ ដល់ $E$ និង $\angle ADE = 80°$ ។

ចូរគណនារង្វាស់មុំ ក. $\angle ABC$ ខ. $\angle BAD$ ។




14. គេមាន $TKXM$ និង $SNXL$ ជាបន្ទាត់ប៉ះរង្វង់មួយដូចរូបខាងស្ដាំនេះ ។ $JKL$ ស្ថិតលើបន្ទាត់តែមួយនិង $\angle TJS = 56°$ ហើយ $\angle NJK = 40°$ ។ ចូរគណនារង្វាស់មុំ ក. $\angle MLN$ ខ. $\angle LMN$ គ. $\angle KLN$ ។



មេរៀនទី

# 15 ទ្រឹស្តីបទតាលែស

**វត្ថុបំណង**

- ប្រើបន្ទាត់ស្របដើម្បីចែកអង្កត់ជាចំណែកប៉ុនគ្នា ។
- ប្រើទ្រឹស្តីបទតាលែសដើម្បីគណនារង្វាស់អង្កត់ ។
- អនុវត្តទ្រឹស្តីបទតាលែសក្នុងត្រីកោណនិង ចតុកោណព្នាយ ។

## 1. បន្ទាត់ស្របនិងខ្នាត់




*ឧទាហរណ៍ :* គេមានបន្ទាត់ស្របបួន $(AA')$ , $(BB')$ , $(CC')$ និង $(CD)$ កាត់បន្ទាត់ពីរ $d_1$ និង $d_2$ ហៅថា ខ្នាត់ ។ នៅលើខ្នាត់ $d_1$ បើ $AB = BC = CD$ នោះគេក៏បាន $A'B' = B'C' = C'D'$ នៅលើ $d_2$ ដែរ ។

បើគេគូសអង្កត់ $AE$ , $BF$ និង $CG$ ឱ្យស្របនឹងបន្ទាត់ $d_2$ តាមលក្ខណៈជ្រុងឈមនៃប្រលេឡូក្រាម

គេបាន $AE = A'B'$ , $BF = B'C'$ , $CG = C'D'$ ។

ម្យ៉ាងវិញទៀតតាមករណីប៉ុនគ្នា (ម.ជ.ម) ត្រីកោណ $ABE$ , $BCF$ , $CDG$ ជាត្រីកោណប៉ុនគ្នា ។

វិបាកយើងបាន $AE = BF = CG$

ដូចនេះ $A'B' = B'C' = C'D'$

បន្ទាត់ស្របដែលកាត់ដោយខ្នាត់បែបនេះហៅថា បន្ទាត់ស្របស្មើចម្ងាយ ។

*ជាទូទៅ :* បើបន្ទាត់ស្របកំណត់នៅលើខ្នាត់មួយបានអង្កត់ប៉ុនគ្នានោះវាកំណត់នៅលើខ្នាត់ផ្សេងទៀតក៏បានអង្កត់ប៉ុនគ្នាដែរ ។

*លំហាត់គំរូទី 1* **:** ក្នុងរូបគេមានបន្ទាត់ $\Delta_1$ , $\Delta_2$ , $\Delta_3$ ជាបន្ទាត់ស្របគ្នា ។ បើ $AC = 4cm$ ចូរគណនាប្រវែង $AB$ និង $BC$ ។




*ចម្លើយ* **:** គណនាប្រវែង $AB$ និង $BC$ ។ ដោយ $\Delta_1$ , $\Delta_2$ , $\Delta_3$ មិនកំណត់បានអង្កត់ប៉ុនគ្នានៅលើខ្នាត់ $d_1$ ក្នុងករណីនេះគេត្រូវគូសបន្ទាត់ស្របចំនួន 3 បន្ថែមទៀតដើម្បីបង្គ្រប់ឱ្យបានបន្ទាត់ស្របស្មើចម្ងាយ ហើយនៅលើខ្នាត់ $d_2$ គេក៏បានអង្កត់ចំនួន 5 ប៉ុនគ្នាដែរដែលអង្កត់នីមួយៗមានប្រវែងស្មើនឹង $\frac{4}{5} = 0.8cm$




នាំឱ្យ $AB = 2 \times 0.8 = 1.6cm$

និង $BC = 3 \times 0.8 = 2.4cm$ ។

*លំហាត់គំរូទី 2* **:** គេមានអង្កត់ $AB$ មួយ ។ ចូរក្រិតអង្កត់ $AB$ ជាបីផ្នែកប៉ុនគ្នា ។

*ចម្លើយ* **:** ដោយគេពុំអាចប្រើម៉ែត្រដើម្បីក្រិត $AB$ ជាបីឯកតាបាន នោះគេត្រូវសង់កន្លះបន្ទាត់ $Ax$ ដោយប្រើម៉ែត្រដើម្បីក្រិតនៅលើកន្លះបន្ទាត់ $Ax$ ឱ្យបានជាបីចំណែកប៉ុនគ្នាកំណត់ដោយចំណុច $C$ , $D$ និង $E$ ។ ភ្ជាប់ $BE$ រួចគូបន្ទាត់ចេញពីចំណុច $D$ និង $C$ ឱ្យស្របនិង $(EB)$ កាត់អង្កត់ $AB$ ត្រង់ $D'$ និង $C'$ ។ យើងបាន $AC' = C'D' = D'B$ ។ ធ្វើយ៉ាងនេះមានន័យថាគេបានក្រិត $AB$ ជាបីផ្នែកប៉ុនគ្នា ។




*ប្រតិបត្តិ* **:** $P$ ជាចំណុចមួយនៃអង្កត់ $AB$ ។ ចូរសង់ $P$ ដើម្បីឱ្យបាន $\frac{AP}{AB} = \frac{2}{5}$ ។

## 2. ទ្រឹស្តីបទតាលែស

*ឧទាហរណ៍ទី 1* **:** គេមាន $(AA')$ , $(BB')$ , $(CC')$ ជាបន្ទាត់ស្របគ្នានៅលើខ្នាត់ $d_1$ ។

បើ $AB = a$ និង $BC = 3a$

នោះផលធៀប $\frac{AB}{BC} = \frac{a}{3a} = \frac{1}{3}$ ។



នោះយើងនឹងស្រាយបញ្ជាក់ថានៅលើខ្នាត់ $d_2$ ក៏មានផលធៀប $\frac{A'B'}{A'C'}=\frac{1}{3}$ ដែរ ។

ឧបមានថា $A'B'=b$ នោះគេគូសបន្ទាត់ស្របស្មើចម្ងាយពីរបន្ថែមទៀត

យើងបាន $B'C'=3b$ ហើយមានផលធៀប $\frac{A'B'}{A'C'}=\frac{b}{3b}=\frac{1}{3}$

ដូចនេះ $\frac{AB}{BC}=\frac{A'B'}{A'C'}=\frac{1}{3}$ ។

***ឧទាហរណ៍ទី 2 :*** គេមានបន្ទាត់ស្រប $(AA')$ , $(BB')$ , $(CC')$ កាត់ខ្នាត់ $d_1$ និង $d_2$ បានអង្កត់សមាមាត្រ $\frac{AB}{BC}=\frac{A'B'}{B'C'}$




បើគេប្តូរតួចុងនៃសមាមាត្រ $\frac{AB}{BC}=\frac{A'B'}{B'C'}$

គេបាន $\frac{AB}{A'B'}=\frac{BC}{B'C'}$ (1)

តាម (1) គេអាចសរសេរ

$$\frac{AB}{A'B'}=\frac{BC}{B'C'}=\frac{AB+BC}{A'B'+B'C'}=\frac{AC}{A'C'} \quad (2)$$

តាមទំនាក់ទំនង (1) និង (2) យើងបាន $\frac{AB}{A'B'}=\frac{BC}{B'C'}=\frac{AC}{A'C'}$

***ជាទូទៅ :*** បើ $(AA')//(BB')//(CC')$ គេបាន $\frac{AB}{AB'}=\frac{BC}{B'C'}=\frac{AC}{A'C'}$ ។

> ***ទ្រឹស្តីបទតាលែស :*** បើបន្ទាត់ច្រើនស្របគ្នានៅលើខ្នាត់ពីរកំណត់បានអង្កត់សមាមាត្រគ្នា ។

***លំហាត់គំរូទី 1 :*** គេឱ្យ $(AA')//(BB')//(CC')$ ដែលមាន $AB=2cm$ , $BC=3cm$ និង $A'B'=2.5cm$ ។ ចូរគណនា $B'C'$ ។




***ចម្លើយ :*** គណនា $B'C'$

តាមទ្រឹស្តីបទតាលែសគេបាន

$$\frac{AB}{BC}=\frac{A'B'}{B'C'}$$

$$\frac{2}{3}=\frac{2.5}{B'C'}$$

$$B'C'=\frac{2.5\times 3}{2}=3.75$$

ដូចនេះ $B'C'=3.75cm$ ។

***លំហាត់គំរូទី 2 :*** គេមាន $\Delta_1$ និង $\Delta_2$ ជាបន្ទាត់ស្របគ្នា ។ ចូរគណនាតម្លៃ $x$ គិតជា $cm$ ។



***លំហាត់គំរូទី 2 :*** ក្នុងត្រីកោណ $PTQ$ ដែល $PN = 6$ , $PR = 12$ , $RT = 4$ និង $NQ = 2$ ។ ចូរស្រាយបញ្ជាក់ថា $NR // QT$ ។




***ចម្លើយ :*** ស្រាយបញ្ជាក់ថា $NR // QT$

គេមាន $\frac{PN}{NQ} = \frac{6}{2} = 3$ (1)

តែ $\frac{PR}{RT} = \frac{12}{4} = 3$ (2)

តាមទំនាក់ទំនង (1) និង (2)

យើងបាន $\frac{PR}{NQ} = \frac{PR}{RT}$

យើងបាន $NR // QT$ ។

***លំហាត់គំរូទី 3 :*** គេចង់វាស់កម្ពស់ដើមឈើមួយដើម ។ គេយកបង្គោលមួយដើមមកដាក់ក្នុងម្លប់ដើមឈើនោះហើយគេរំកិលវាដោយលៃ ឱ្យស្រមោលនៃចុងបង្គោល $E$ និងស្រមោលនៃចុងដើមឈើ $A$ ត្រួតស៊ីគ្នាត្រង់ចំណុច $C$ ។ ដោយស្គាល់ប្រវែងបង្គោល $DE = 1.08m$ ប្រវែងស្រមោលបង្គោល $CD = 0.9m$ និងប្រវែងស្រមោលដើមឈើមានប្រវែង $CB = 12.45m$ ។ ចូររកកម្ពស់នៃដើមឈើនោះ ។




***ចម្លើយ :*** គេបាន $\frac{AB}{DE} = \frac{CB}{CD}$ ឬ $AB = \frac{CB \times DE}{CD} = \frac{12.45 \times 1.08}{0.9} = 14.94m$

ដូចនេះ $AB = 14.94m$ ។

***ប្រតិបត្តិ :*** គ្រូនាំសិស្សចេញមកក្រៅថ្នាក់ដើម្បីអនុវត្តវាស់កម្ពស់ដើមឈើមួយដើមដែលឋិតក្នុងទីធ្លាសាលា ។ ដោយឱ្យសិស្សម្នាក់យកបង្គោលមួយដើមដែលមានប្រវែង $1m$ មកដាក់ក្នុងម្លប់ដើមឈើនោះ ហើយរំកិលឱ្យស្រមោលនៃចុងបង្គោលនិងស្រមោលនៃចុងឈើត្រួតស៊ីគ្នា ។ ចូរគណនាកម្ពស់នៃដើមឈើ ។



## 3.2. អនុវត្តក្នុងចតុកោណព្នាយ

*ឧទាហរណ៍ទី 1 :* គេមានចតុកោណព្នាយ $ABCD$ ។ បើគេគូសបន្ទាត់ $EF$ មួយស្របទៅនឹងបាតទាំងពីរនៃចតុកោណព្នាយ ហើយកាត់ជ្រុងពីរទៀតត្រង់ $E$ និង $F$ ។







តាមទ្រឹស្តីបទតាលែស

$EF // DC // AB$ នោះគេបាន $\frac{AE}{AD} = \frac{BF}{CF}$ , $\frac{AD}{AE} = \frac{BC}{BF}$ , $\frac{AD}{DE} = \frac{BC}{CF}$ ។

*ឧទាហរណ៍ទី 2 :* គេមានអង្កត់ $EF$ កាត់តាមចំណុចកណ្ដាលនៃជ្រុងមិនស្របនៃចតុកោណព្នាយ $ABCD$ ។




គេមាន $\frac{DE}{DA} = \frac{1}{2}$ ( $E$ កណ្ដាលនៃ $AD$ )

ម្យ៉ាងទៀត $\frac{CF}{CB} = \frac{1}{2}$ ( $F$ កណ្ដាលនៃ $CB$ )

នាំឱ្យ $\frac{DE}{DA} = \frac{CF}{CB}$

តាមតាលែសគេបាន $EF // DC // AB$ ។

> *ជាទូទៅ :* បើបន្ទាត់មួយស្របទៅនឹងបាតនៃចតុកោណព្នាយកាត់ជ្រុងមិនស្រប ឬបន្លាយនៃជ្រុងមិនស្របកំណត់បានអង្កត់សមាមាត្រគ្នា ។
>
> *ច្រាសមកវិញ :* បើបន្ទាត់មួយកាត់ជ្រុងមិនស្រប ឬបន្លាយនៃជ្រុងមិនស្របនៃចតុកោណព្នាយមួយកំណត់បានអង្កត់សមាមាត្របន្ទាត់នោះត្រូវស្របនឹងបាតទាំងពីរ ។

*លំហាត់គំរូ :* គេឱ្យ $AB // XY // DC$

បើ $AX = 3dm$ , $BC = 9dm$ , $XD = 8dm$ ។

ចូរគណនា $BY$ និង $YC$ ។



**ចម្លើយ :** គណនា $BY$ និង $YC$

ដោយ $AB // XY // DC$

គេបាន $\frac{BY}{BC} = \frac{AX}{AD}$ ឬ $BY = \frac{AX \times BC}{AD}$

$= \frac{3 \times 9}{11}$ $(AD = AX + DX = 3 + 8 = 11)$

$= 2.45dm$

ដោយ $(AB) // (XY) // (DC)$

គេបាន $\frac{YC}{XD} = \frac{BC}{AD}$ ឬ $YC = \frac{XD \times BC}{AD}$

$= \frac{8 \times 9}{11}$ $(VX = WV + WX = 3 + 8 = 11)$

$= 6.54dm$

ដូចនេះ $BY = 2.45dm$ និង $YC = 6.54dm$ ។

**ប្រតិបត្តិ :** ក្នុងត្រីកោណ $ABC$ គេមាន $(DE) // (AB)$ ។

ចូរបំពេញក្នុងតារាងខាងក្រោម ។

| | $AD$ | $DC$ | $BE$ | $EC$ | | |
|---|---|---|---|---|---|---|
| ក. | 3 | 2 | 6 | … | | |
| ខ. | 7 | 3 | … | 5 | | |
| គ. | 2 | … | 3 | 4 | | |
| | $AD$ | $DC$ | $AC$ | $BE$ | $EC$ | $BC$ |
| ឃ. | … | 8 | 20 | … | … | 15 |
| ង. | 12 | … | 30 | 9 | … | … |



1. ចូរចែកអង្កត់ $AB$ ដែល $AB = 6cm$ ជា 5 ចំណែកស្មើគ្នា ។
2. ចូរចែកអង្កត់ $AB$ ដែល $AB = 11cm$ ជាអង្កត់សមាមាត្រនឹង 3 4 5 ។
3. ចូរចែកអង្កត់ $AB$ ដែល $AB = 12cm$ ជាអង្កត់សមាមាត្រនឹង 3 5 7 ។
4. គេឱ្យ $AB = 7cm$ ចូរកំណត់ចំណុច $C$ ដែលចែកអង្កត់ $AB$ តាមផលធៀប $\frac{3}{5}$ ។
5. គេឱ្យ $AB = 9mm$ ចូរកំណត់ចំណុច $C$ និង $D$ ដែលចែកអង្កត់ $AB$ តាមផលធៀប $\frac{5}{2}$ ។
6. គេមាន $AB // CD // EF // GH$ តាមរូបខាងស្តាំ ។




ក. ចូរគណនា $DF$ និង $FH$ បើ $AC = 6cm$ , $CE = 12cm$ $EG = 4cm$ និង $BD = 9cm$ ។

ខ. ចូរគណនា $BD$ , $DF$ និង $FH$ បើ $AC = 6cm$ , $CE = 12cm$ , $EG = 4cm$ និង $HB = 33cm$ ។

គ. ចូរគណនា $DF$ និង $CG$ បើ $AC = 6cm$ , $CE = 12cm$ $DB = 8cm$ និង $FH = 6cm$ ។

7. គេឱ្យ $(AB) // (MN)$ ចូរគណនាប្រវែង $x$ ក្នុងរូបនីមួយខាងក្រោម ។




8. តាមរូបខាងស្តាំគេមាន $BE // CD$ ។

ចូរគណនាប្រវែង $ED$ និង $CD$ ។

រង្វាស់គិតជា $cm$ ។




9. ចូរគណនា $a$ និង $b$ តាមរូបខាងស្តាំនេះ ។

រង្វាស់ជា $cm$ ។



***ឧទាហរណ៍ទី3 :*** គេមាន $A'B'C'$ ជាត្រីកោណដែលបានបង្រួមតូច 50 % ពីត្រីកោណដើម $ABC$ នោះគេបាន $\angle A = \angle A'$ $\angle B = \angle B'$ , $\angle C = \angle C'$ , $AC = 2A'C'$ , $AB = 2A'B'$ និង $BC = 2B'C'$ ។




គេអាចសរសេរជាផលធៀប $\dfrac{A'B'}{AB} = \dfrac{A'C'}{AC} = \dfrac{B'C'}{BC} = \dfrac{1}{2}$




គេថាត្រីកោណ $A'B'C'$ និង $ABC$ ជាត្រីកោណដូចគ្នា ដែលមានផលធៀបដំណូចស្មើនឹង $\frac{1}{2}$ ។

> ***និយមន័យ :*** ត្រីកោណពីរជាត្រីកោណដូចគ្នាកាលណាវាមាន
> - មុំទាំងបីប៉ុនរៀងគ្នា
> - ជ្រុងទាំងបីសមាមាត្ររៀងគ្នា
> - ផលធៀបសមាមាត្រហៅថា ផលធៀបដំណូច ។

***ចំណាំ :***

- គេកំណត់ត្រីកោណពីរដូចគ្នាដោយសញ្ញា $\Delta ABC \sim \Delta A'B'C'$ ។
- បើ $ABC$ និង $A'B'C'$ ជាត្រីកោណដូចគ្នាតាមផលធៀបដំណូច គេសរសេរផលធៀបសមាមាត្រនៃជ្រុងទាំងបីដោយរៀបកំពូលទៅតាមលំដាប់នៃមុំប៉ុនគ្នា ។

$$\left.\begin{matrix}\Delta A'B'C' \\ \sim \\ \Delta ABC\end{matrix}\right| \Rightarrow \frac{A'B'}{AB} = \frac{A'C'}{AC} = \frac{B'C'}{BC} = k \text{ ។}$$

***លំហាត់គំរូ :*** ក្នុងត្រីកោណ $ABC$ មានចំណុច $D$ និង $E$ ជាចំណុចកណ្ដាលរៀងគ្នានៃជ្រុង $AB$ និង $AC$ ដែល $DE // BC$ ។ ចូរបង្ហាញថា $ADE$ និង $ABC$ ជាត្រីកោណដូចគ្នា ។

***ចម្លើយ :*** បង្ហាញថា $ADE$ និង $ABC$ ជាត្រីកោណដូចគ្នា

ដោយ $DE // BC$ (សម្មតិកម្ម)

យើងបាន $\angle D = \angle B$ (មុំត្រូវគ្នា)

$\angle E = \angle C$ (មុំត្រូវគ្នា)

$\angle A$ (មុំរួមនៃត្រីកោណទាំងពីរ)



តាមទ្រឹស្តីបទតាលែសគេបាន

$$DE // BC \text{ នាំឱ្យ } \frac{AD}{AB}=\frac{AE}{AC}=\frac{DE}{BC}=\frac{1}{2}$$

ត្រីកោណ $ADE$ និង $ABC$ មានមុំបីប៉ុនរៀងគ្នា ហើយជ្រុងទាំងបីសមាមាត្ររៀងគ្នាជាត្រីកោណដូចគ្នា ។

ដូចនេះ $\Delta ADE \sim ABC$ ។

*ប្រតិបត្តិ :* ត្រីកោណ $ABC$ និង $A'B'C'$ ជាត្រីកោណដូចគ្នាដែលមានផលធៀបដំណូចស្មើនឹង $\frac{1}{4}$ ។ ចូរគណនា $x$ , $y$ , $z$ ។




## 1.2. ករណីដំណូច

ដើម្បីឱ្យត្រីកោណពីរដូចគ្នា គេគ្រាន់តែរកឱ្យឃើញមុំខ្លះៗប៉ុនគ្នា ឬជ្រុងទាំងបីសមមាត្ររៀងគ្នា តាមករណីដូចខាងក្រោម ។

### ក. ករណីដំណូចទី 1




គេឱ្យត្រីកោណ $ABC$ និង $A'B'C'$ ដែល $\angle A = \angle A'$ និង $\angle B = \angle B'$ ។

បង្ហាញថា $\Delta ABC \sim \Delta A'B'C'$ ។

នៅលើ $[AB]$ ដៅចំណុច $D$ ដែល $AD = A'B'$ រួចគូស $(DE) \parallel (BC)$

គេបាន $\Delta ABC \sim \Delta ADE$

តែ $\Delta ADE \cong \Delta A'B'C'$ (តាមករណីប៉ុនគ្នា ម.ជ.ម) ។

ដូចនេះ $\Delta ABC \sim \Delta A'B'C'$ ។

ករណីដំណូច ម.ម

*ជាទូទៅ :* ត្រីកោណពីរជាត្រីកោណដូចគ្នា កាលណាវាមានមុំពីរប៉ុនរៀងគ្នា ។

ដៅចំណុច $D \in [AB]$ ដែល $AD = A'B'$ រួចគូស $(DE) // (BC)$

គេបាន $\Delta ABC \sim \Delta ADE$ (1)

វិបាក $\frac{AB}{AD} = \frac{BC}{DE} = \frac{CA}{EA}$ ឬ $\frac{AB}{A'B'} = \frac{BC}{DE} = \frac{CA}{EA}$ (2)

តែ $\frac{AB}{A'B'} = \frac{BC}{B'C'} = \frac{CA}{C'A'}$ (3)

តាម (2) និង (3) គេទាញបាន

$\frac{BC}{DE} = \frac{BC}{B'C'}$ នាំឱ្យ $B'C' = DE$

ហើយ $\frac{CA}{EA} = \frac{CA}{C'A'}$ នោះឱ្យ $C'A' = EA$

ដូចនេះ $\Delta A'B'C' \sim \Delta ADE$ (ករណី ជ.ជ.ជ) ។

វិបាក $\Delta ABC \sim \Delta A'B'C'$

ករណីដំណូច ជ.ជ.ជ ។

> ***ជាទូទៅ :*** ត្រីកោណពីរជាត្រីកោណដូចគ្នា កាលណាវាមានជ្រុងទាំងបីសមមាត្ររៀងគ្នា ។

***ចំណាំ :*** បើ $\Delta ABC \sim \Delta A'B'C'$ គេអាចទាញបានវិបាកគឺ

| សម្មតិកម្ម | សន្និដ្ឋាន | វិបាក |
|---|---|---|
| $\frac{AB}{A'B'} = \frac{BC}{B'C'} = \frac{CA}{C'A'}$ | $\Delta ABC \sim \Delta A'B'C'$ | $\angle A = \angle A'$ , $\angle B = \angle B'$ , $\angle C = \angle C'$ |

***លំហាត់គំរូទី 1 :*** តាមរូបបង្ហាញថា $\Delta ABC$ និង $\Delta XYZ$ ដូចគ្នា ។ រួចទាញវិបាក ។




***ចម្លើយ :***

បង្ហាញថា $\Delta ABC \sim \Delta XYZ$

គេមាន $\frac{XY}{AB} = \frac{5}{15} = \frac{1}{3}$

$\frac{YZ}{BC} = \frac{7}{21} = \frac{1}{3}$

$\frac{ZX}{CA} = \frac{3}{9} = \frac{1}{3}$

ដូចនេះ $\frac{XY}{AB} = \frac{YZ}{BC} = \frac{ZX}{CA} = \frac{1}{3}$

នាំឱ្យ $\Delta ABC \sim \Delta XYZ$ (ករណីដំណូច ជ.ជ.ជ)

វិបាក $\angle A = \angle X$ , $\angle B = \angle Y$ និង $\angle C = \angle Z$ ។

**លំហាត់គំរូទី 2 :** ចូររកចម្ងាយពីចំណុច $A$ នៅមាត់ច្រាំងអូរទៅចំណុច $B$ នៅច្រាំងអូរម្ខាងទៀត តាមរូបខាងក្រោម ។




**ចម្លើយ :**

ដើម្បីរកប្រវែង $AB$ គេត្រូវជ្រើសរើសយកចំណុច $C$ មួយនៅលើច្រាំងអូរដោយយក $AC = 100m$ និង $B\hat{A}C = \alpha$ , $B\hat{C}A = \beta$ ។ បន្ទាប់មកយកក្រដាសមួយសន្លឹកមកគូសត្រីកោណ $A'B'C'$ ដែលមានជ្រុងប្រវែង $A'C' = 5cm$ , $\hat{A}' = \alpha$ , $\hat{C}' = \beta$ បន្ទាប់មកគេវាស់ប្រវែង $A'B' = 6cm$ ។ ត្រីកោណ $ABC$ និងត្រីកោណ $A'B'C'$ មានមុំពីរប៉ុនរៀងគ្នាជាត្រីកោណដូចគ្នា (ករណីដំណូច ម.ម)

$$\left.\begin{array}{r} ABC \\ A'B'C' \end{array}\right| \Rightarrow \frac{AB}{A'B'} = \frac{AC}{A'C'}$$

$$AB = \frac{AC \times A'B'}{A'C'}$$

$$= \frac{100 \times 0.06}{0.05}$$

$$= 120$$

ដូចនេះ ប្រវែង $AB = 120m$ ។

**លំហាត់គំរូទី 3 :** ចូរគណនាប្រវែងជ្រុង $AC$ នៃត្រីកោណកែង $ABC$ ។



**ចម្លើយ :**

ត្រីកោណ $ABC$ និងត្រីកោណ $DBE$

មាន $\angle ABC = \angle DBE$ (មុំទល់កំពូល)

$\angle C = \angle E$ (មុំមានជ្រុងត្រូវគ្នាកែងរៀងគ្នា)

នាំឱ្យ $\Delta ABC \sim \Delta DBC$ វិបាក $\frac{AC}{DE} = \frac{BC}{BE}$ ឬ $AC = \frac{BC \times DE}{BE}$

ដោយ $BC = 126m$ , $BE = 5m$ , $DE = 4m$

គេបាន $AC = \frac{126 \times 4}{5}$

$= \frac{504}{5}$

$= 100.8$

ដូចនេះ ប្រវែងជ្រុង $AC = 100.8m$ ។

**ប្រតិបត្តិ :** ចូររកតម្លៃ $x$ និង $y$ ។

$AE = 4cm$

$AD = 10cm$







$QR = 16cm$

$RT = 10cm$







**ចំណាំ :** តារាងប្រៀបធៀបករណីប៉ុនគ្នានៃត្រីកោណនិងករណីដំណូចនៃត្រីកោណ

| លក្ខខណ្ឌនៃត្រីកោណពីរប៉ុនគ្នា | | លក្ខខណ្ឌនៃត្រីកោណពីរដូចគ្នា | |
|---|---|---|---|
| លក្ខណៈ | ករណី | ករណី | លក្ខណៈ |
|  $\angle B = \angle B'$ , $\angle C = \angle C'$ , $BC = B'C'$ | ទី 1 ម.ជ.ម | ទី 1 ម.ម |  $\angle B = \angle B'$ , $\angle C = \angle C'$ |

| | | | |
|---|---|---|---|
|  $\angle B = \angle B'$ , $AB = A'B'$ , $BC = B'C'$ | ទី 2 ម. ជ. ម | ទី 2 ម. ជ. ម |  $\angle B = \angle B'$ , $\frac{AB}{A'B'} = \frac{BC}{B'C}$ |
|  $AB = A'B'$ , $BC = B'C$ , $BC = B'C$ | ទី 3 ជ. ជ. ជ | ទី 3 ជ. ជ. ជ |  $\frac{AB}{A'B'} = \frac{BC}{B'C} = \frac{CA}{C'A'} = k$ |

## 2. ទំនាក់ទំនងមាត្រក្នុងត្រីកោណកែង

***ឧទាហរណ៍ :***




$ABC$ ជាត្រីកោណកែងត្រង់ $A$ ដែល $AH$ ជាកម្ពស់

$AB$ និង $AC$ ជាជ្រុងនៃមុំកែង

$BC$ ជាអ៊ីប៉ូតេនុស

$BH$ ជាចំណោលកែងនៃ $AB$ មកលើអ៊ីប៉ូតេនុស

$CH$ ជាចំណោលកែងនៃ $AC$ មកលើអ៊ីប៉ូតេនុស

- ទំនាក់ទំនងទី 1

$AB^2 = BH \times BC$




សម្រាយបញ្ជាក់

ត្រីកោណកែង $ABC$ និង $ABH$

មានមុំរួម $\angle B$ ដូចគ្នា

ហេតុនេះវាជាត្រីកោណដូចគ្នា

$\left.\begin{matrix} ABC \\ HBA \end{matrix}\right| \Rightarrow \frac{AB}{BH} = \frac{BC}{AB}$ យើងបាន $AB^2 = BH \times BC$

ដូចគ្នានេះដែរ

$\left.\begin{matrix} ABC \\ HAC \end{matrix}\right| \Rightarrow \dfrac{AC}{BH} = \dfrac{BC}{AC}$ យើងបាន $AC^2 = CH \times BC$ ។

> ***ក្នុងត្រីកោណកែងរង្វាស់ជ្រុងមួយនៃមុំកែងជាមធ្យមសមាមាត្ររវាងអ៊ីប៉ូតេនុសនិងចំណោលកែងរបស់វាលើអ៊ីប៉ូតេនុស ។***

- ទំនាក់ទំនងទី 2




$AH^2 = BH \times CH$

សម្រាយបញ្ជាក់

$\angle ABH = \angle CAH$ (មុំដែលមានជ្រុងពីរកែងរៀងគ្នា)

ត្រីកោណកែង $ABH$ និង $AHC$ មានមុំស្រួចមួយប៉ុនគ្នាជាត្រីកោណដូចគ្នា

$\left.\begin{matrix} ABH \\ CAH \end{matrix}\right| \Rightarrow \dfrac{AH}{CH} = \dfrac{BH}{AH}$ យើងបាន $AH^2 = CH \times BC$

> ***ក្នុងត្រីកោណកែងរង្វាស់កម្ពស់គូរនឹងអ៊ីប៉ូតេនុសជាមធ្យមសមមាត្ររវាងអង្កត់ដែលវាកំណត់បានលើអ៊ីប៉ូតេនុស ។***

- ទំនាក់ទំនងទី 3




$AB \times AC = BC \times AH$

សម្រាយបញ្ជាក់

$\left.\begin{matrix} ABC \\ HBA \end{matrix}\right| \Rightarrow \dfrac{AC}{AH} = \dfrac{BC}{AB}$

យើងបាន $AC \times AB = BC \times AH$

> ***ក្នុងត្រីកោណកែងផលគុណរវាងជ្រុងមុំកែងទាំងពីរស្មើនឹងផលគុណរវាងអ៊ីប៉ូតេនុសនិងកម្ពស់គូរនឹងអ៊ីប៉ូតេនុស ។***

• ទំនាក់ទំនងទី 4




$AB^2 + AC^2 = BC^2$

តាមទំនាក់ទំនង 1

$$\begin{array}{rl} & AB^2 = BH \times BC \\ + & AC^2 = CH \times BC \\ \hline \end{array}$$

$$AB^2 + AC^2 = BH \times BC + CH \times BC$$

$$= BC(BH + CH)$$

$$= BC \times BC = BC^2$$

| |
|---|
| *ក្នុងត្រីកោណកែង ការេនៃអ៊ីប៉ូតេនុសស្មើនឹងផលបូកការេនៃជ្រុងមុំកែង ។* |

• ទំនាក់ទំនងទី 5




$$\frac{1}{AB^2} + \frac{1}{AC^2} = \frac{1}{AH^2}$$

សម្រាយបញ្ជាក់

តាមទំនាក់ទំនង 3

$AB \times AC = BC \times AH$ លើកជាការេ

យើងបានទំនាក់ទំនង (1)

$AB^2 \times AC^2 = BC^2 \times AH^2$ (1)

ម្យ៉ាងទៀត $AB^2 + AC^2 = BC^2$ (2)

(2) ចែកនឹង (1)

$$\frac{AB^2 + AC^2}{AB^2 \times AC^2} = \frac{BC^2}{BC^2 \times AH^2}$$

ដោយ $\dfrac{AB^2 + AC^2}{AB^2 \times AC^2} = \dfrac{1}{AB^2} + \dfrac{1}{AC^2}$

$$\frac{BC^2}{BC^2 \times AH^2} = \frac{1}{AH^2}$$

យើង $\dfrac{1}{AB^2} + \dfrac{1}{AC^2} = \dfrac{1}{AH^2}$

| |
|---|
| *ក្នុងត្រីកោណកែង ផលបូកចម្រាសការេនៃជ្រុងមុំកែងស្មើនឹងចម្រាស់ការេនៃកម្ពស់ចំពោះអ៊ីប៉ូតេនុស ។* |

***ទ្រឹស្ដីបទ :***

- ក្នុងត្រីកោណកែង រង្វាស់ជ្រុងមួយនៃមុំកែងជាមធ្យមសមាមាត្ររវាងអ៊ីប៉ូតេនុស និង ចំណោលកែងរបស់វាលើអ៊ីប៉ូតេនុស $AC^2 = BC \times HC$ ឬ $AB^2 = BC \times HB$ ។
- ក្នុងត្រីកោណកែង រង្វាស់កម្ពស់ត្រូវនឹងអ៊ីប៉ូតេនុសជាមធ្យមសមមាត្ររវាងអង្កត់ដែលវាកំណត់បានលើអ៊ីប៉ូតេនុស $HA^2 = HB \times HC$ ។
- ក្នុងត្រីកោណកែង ផលគុណរវាងជ្រុងមុំកែងទាំងពីរស្មើនឹងផលគុណរវាងអ៊ីប៉ូតេនុស និង កម្ពស់ត្រូវនឹងអ៊ីប៉ូតេនុស $AB \times AC = BC \times AH$ ។
- ក្នុងត្រីកោណកែង ការេអ៊ីប៉ូតេនុសស្មើនឹងផលបូកការេនៃជ្រុងមុំកែង $BC^2 = AB^2 + AC^2$ ។
- ក្នុងត្រីកោណកែង ផលបូកចម្រាសការេនៃជ្រុងមុំកែងស្មើនឹងចម្រាសការេនៃកម្ពស់ចំពោះអ៊ីប៉ូតេនុស $\frac{1}{AC^2} + \frac{1}{BA^2} = \frac{1}{HA^2}$ ។

**តារាងសង្ខេបរូបមន្ត**

1. $AC^2 = BC \times HC$ ឬ $c^2 = an$

   $AB^2 = BC \times HB$ ឬ $b^2 = am$
2. $HA^2 = HC \times HB$ ឬ $h^2 = nm$
3. $AB \times AC = BC \times AH$ ឬ $bc = ah$
4. $BC^2 = AB^2 + AC^2$ ឬ $a^2 = b^2 + c^2$
5. $\frac{1}{AC^2} + \frac{1}{BA^2} = \frac{1}{HA^2}$ ឬ $\frac{1}{b^2} + \frac{1}{c^2} = \frac{1}{a^2}$




***លំហាត់គំរូទី 1 :*** គេឱ្យត្រីកោណ $ABC$ កែងត្រង់ $A$ ដែល $AB = 3cm$ និង $AC = 4cm$ ។ ចូរគណនាប្រវែង $BC$ , $AH$ , $HB$ និង $HC$ ។



**ចម្លើយ :** គណនា $BC$ , $AH$ , $HB$ និង $HC$

- គណនា $BC$

ក្នុង $\Delta ABC$ តាមទ្រឹស្តីបទពីតាគ័រយើងបាន $BC^2 = AB^2 + AC^2$

ដោយ $AB = 3cm$ និង $AC = 4cm$

យើងបាន $BC^2 = AB^2 + AC^2$

$= 3^2 + 4^2 = 25$

$= 5^2$

$BC = 5$

ដូចនេះ $BC = 5cm$ ។

- គណនា $AH$

ក្នុង $\Delta ABC$ តាមទំនាក់ទំនងរវាងកម្ពស់និងជ្រុងយើងបាន

$BC \times AH = AB \times AC$ ឬ $AH = \dfrac{AB \times AC}{BC}$

យើងបាន $AH = \dfrac{AB \times AC}{BC}$ (ដោយ $AB = 3cm$ , $BC = 5cm$ និង $AC = 4cm$ )

$= \dfrac{3 \times 4}{5} = 2.4$

ដូចនេះ $AH = 2.4cm$ ។

- គណនា $HB$

ក្នុង $\Delta ABC$ តាមទំនាក់ទំនងរវាងកម្ពស់និងជ្រុងយើងបាន

$BC \times HB = AB^2$ ឬ $HB = \dfrac{AB^2}{BC}$

យើងបាន $HB = \dfrac{AB^2}{BC}$ (ដោយ $AB = 3cm$ , $BC = 5cm$ )

$= \dfrac{3^2}{5}$

$= \dfrac{9}{5}$

$= 1.8$

ដូចនេះ $HB = 1.8cm$ ។

- គណនា $HC$

ក្នុង $\Delta ABC$ តាមទំនាក់ទំនងរវាងកម្ពស់និងជ្រុងយើងបាន

$BC \times HC = AC^2$ ឬ $HC = \dfrac{AC^2}{BC}$

យើងបាន $HC = \frac{AC^2}{BC}$ (ដោយ $AC = 4cm$ , $BC = 5cm$ )

$= \frac{4^2}{5}$

$= \frac{16}{5}$

$= 3.2$

ដូចនេះ $HC = 3.2cm$ ។

***លំហាត់គំរូទី 2 :*** គេមានត្រីកោណ $ABC$ កែងត្រង់ $A$ ដែល $AH = 8cm$ , $BC = 15cm$ និង $AC = 12cm$ ។ ចូររកប្រវែង $AB$ , $HB$ និង $HC$ ។




***ចម្លើយ :*** រកប្រវែង $AB$ , $HB$ និង $HC$

- គណនា $AB$

$ABC$ ជាត្រីកោណកែងតាមទ្រឹស្តីបទពីតាគ័រយើងបាន $BC^2 = AB^2 + AC^2$

នាំឱ្យ $AB^2 = BC^2 - AC^2$

$AB = \sqrt{BC^2 - AC^2}$ (ដោយ $AC = 12cm$ និង $BC = 15cm$ )

$= \sqrt{(15)^2 - (12)^2}$

$= \sqrt{225 - 144}$

$= \sqrt{81}$

$= \sqrt{9^2}$

$= 9$

ដូចនេះ $AB = 9cm$ ។

- គណនា $HB$

ក្នុង $\Delta ABC$ តាមទំនាក់ទំនងរវាងកម្ពស់និងជ្រុងយើងបាន

$$BC \times BH = AB^2 \quad \text{ឬ} \quad BH = \frac{AB^2}{BC}$$

យើងបាន $BH = \frac{AB^2}{BC}$ (ដោយ $AB = 9cm$ និង $BC = 15cm$ )

$= \frac{9^2}{15}$

$= \frac{81}{15}$

$= 5.40$

ដូចនេះ $HB = 5.40cm$ ។

- គណនា $HC$

ក្នុងត្រីកោណកែង $ABC$ តាមទំនាក់ទំនងរវាងកម្ពស់និងជ្រុងយើងបាន

$$BC \times HC = AC^2 \quad \text{ឬ} \quad HC = \frac{AC^2}{BC}$$

យើងបាន $HC = \dfrac{AC^2}{BC}$ (ដោយ $BC = 15cm$ និង $AC = 12cm$ )

$$= \frac{12^2}{15}$$

$$= \frac{144}{15}$$

$$= 9.60$$

ដូចនេះ $HC = 9.60cm$ ។

***ប្រតិបត្តិ :*** គេឱ្យអង្កត់ពីរដែលមានប្រវែង $x$ និង $y$ ។ ចូរគណនាប្រវែង $z$ មួយដែល $z = \sqrt{x^2 - y^2}$ និងសង់រូបនោះឡើងវិញ ដែល $x$ , $y$ និង $z$ ជារង្វាស់ជ្រុងនៃត្រីកោណ ។



## ? លំហាត់

1. គូត្រីកោណខាងក្រោមជាត្រីកោណដូចគ្នា ។ ចូរសរសេរឈ្មោះ និងជ្រុងត្រូវគ្នា ។




2. តើគូត្រីកោណនីមួយៗខាងក្រោមដូចគ្នាដែរឬទេ ? ហេតុអ្វី ?




រូប(ក)




រូប(ខ)




រូប(គ)

3. ចូរប្រៀបធៀប $\Delta ABC$ និង $\Delta A'B'C'$ , $\Delta PMN$ និង $\Delta P'M'N'$ រួចសរសេរផលធៀបដំណូច (រូបខាងក្រោម) ។




រូប (•A)




រូប (•B)

4. តើគូត្រីកោណនីមួយៗ ខាងក្រោមនេះជាត្រីកោណដូចគ្នាដែរឬទេ ? ហេតុអ្វី ?




រូប (•A)




រូប (•B)




រូប (•C)

5. គេមានត្រីកោណ $ABC$ ដូចត្រីកោណ $GEF$ រូបខាងក្រោម ចូរសរសេរបំពេញផលធៀបដំណូច ។




$\frac{AB}{GE} = \frac{BC}{...?} = \frac{...?}{FG}$




$\frac{AB}{EG} = \frac{...?}{EF} = \frac{BC}{...?}$

6. ចូរស្រាយបញ្ជាក់ថាត្រីកោណខាងក្រោមជាត្រីកោណដូចគ្នារួចទាញវិបាក ។







7. គេឱ្យចតុកោណព្នាយ$ABCD$ បន្លាយជ្រុងទ្រេត $AD$ និង $BC$ កាត់គ្នាត្រង់ $F$ ដោយស្គាល់ $FD : FA = 8 : 5$ និង $FB = 2.25m$ ។ ចូរគណនាប្រវែង $BC$ ។

8. គេមានត្រីកោណដូចគ្នាពីរ ដែលមានបរិមាត្ររៀងគ្នា $35dm$ និង $56dm$ ។ ចូររកប្រវែងកម្ពស់មួយនៃត្រីកោណធំបើកម្ពស់នៃត្រីកោណតូចស្មើនឹង $10dm$ ។

9. ក្នុងត្រីកោណ $ABC$ មាន $\angle BAC = 90°$ ហើយ $RS \perp BC$ ។ ចូរស្រាយបញ្ជាក់ថា $\Delta ABC \sim \Delta SRC$ ។




10. ចូរដៅចំណុច $C$ និង $D$ ដែលចែកអង្កត់ $MN$ ខាងក្នុងនិងខាងក្រៅតាមផលធៀប $\frac{a}{b}$ ។

ក. $MN = 11dm$ , $\frac{a}{b} = \frac{3}{5}$     ខ. $MN = 6dm$ , $\frac{a}{b} = \frac{1}{3}$ ។



11. គេឱ្យត្រីកោណ $ABC$ ចារឹកក្នុងរង្វង់ដែល $AB = \alpha$ , $AC = \beta$ , $BC = \partial$ ។ កន្លះបន្ទាត់ពុះ $\angle BAC$ កាត់ជ្រុង $BC$ ត្រង់ចំណុច $I$ និងធ្នូ $BC$ ត្រង់ $J$ ។

ក. ចូរស្រាយបញ្ជាក់ថា $\Delta ABI$ និង $\Delta AJC$ ជាត្រីកោណដូចគ្នា ។

ខ. ចូរគណនាផលគុណ $AI.AJ$ ។

គ. ចូរបង្ហាញថា $\angle BAJ = \angle CBJ$

ឃ. ចូរស្រាយបញ្ជាក់ថា $JB^2 = JA.JI$ ។

12. ដើម្បីវាស់ចម្ងាយពីចំណុច $A$ ទៅចំណុច $B$ ដែលមានឧបសគ្គមួយមិនអាចទៅដល់ គេជ្រើសរើសយកចំណុច $C$ មួយ រួចវាស់ប្រវែងអង្កត់ $AC$ ។ បើ $D \in AC$ នោះវាស់អង្កត់ $CD$ តាមចំណុច $D$ គូសបន្ទាត់ $DE // AB$ រួចវាស់អង្កត់ $DE$ ។ ដោយធ្វើតាមរបៀបនេះគេអាចគណនាអង្កត់ $AB$ បាន ។




បើ $CA = 1.8km$ , $CD = 90m$ និង $DE = 150m$ ។ ចូរគណនាចម្ងាយ $AB$ ។

13. គេឱ្យត្រីកោណ $ABC$ ចារឹកក្នុងរង្វង់ ។ បន្ទាត់មួយស្របទៅនឹងបន្ទាត់ប៉ះត្រង់ $A$ កាត់អង្កត់ $AB$ និង $AC$ ត្រង់ចំណុច $M$ និង $N$ ។

ក. ចូរប្រដូចត្រីកោណ $ABC$ និងត្រីកោណ $AMN$ ។

ខ. ចូរស្រាយបញ្ជាក់ថា $AB.AM = AC.AN$ ។

14. តាមចំណុចនៃកន្លះរង្វង់គេគូសអង្កត់ $CD$ កែងទៅអង្កត់ផ្ចិត $AB$ ។

ក. បើ $AD = 4dm$ , $DB = 9dm$ ។ ចូរគណនា $CD$ ។

ខ. បើ $AB = 29dm$ , $CD = 10cm$ ។ ចូរគណនា $AD$ និង $DB$ ។

15. ស្រាយបំភ្លឺឱ្យឃើញថាក្នុងត្រីកោណមួយរង្វាស់កម្ពស់ច្រាសសមមាត្រនឹងរង្វាស់ជ្រុងគឺ $ah_a = bh_b = ch_c$ ។ ( ណែនាំ គូសកម្ពស់ពីររួចប្រដូចត្រីកោណកែងដែលមានកម្ពស់មួយជាជ្រុងនៃមុំកែង) ។

16. តាមកំពូល $A$ នៃត្រីកោណសមបាត $ABC$ គេគូសបន្ទាត់មួយដែលកាត់ជ្រុង $BC$ ត្រង់ $D$ និងកាត់រង្វង់ចារឹកក្រៅត្រីកោណត្រង់ចំណុច $E$ ។ ចូរប្រៀបធៀបត្រីកោណ $ADB$ និងត្រីកោណ $AEB$ រួចស្រាយបញ្ជាក់ថា $AB^2 = AD.AE$ ។

17. ដើមឫស្សីមួយដើមមានកម្ពស់ $10m$ ត្រូវខ្យល់វាយបាក់ត្រង់ចំណុច $P$ មួយ ហើយចុងឫស្សីប៉ះដីត្រង់ចំណុចមួយដែលមានចម្ងាយ $3m$ ពីគល់ ។ ចូរគណនាដើមឫស្សីពីគល់ទៅចំណុចបាក់ $P$ ។

18. $AB$ ជារង្វាស់ពីបាតដីដល់ផ្កាឈូក ហើយផ្នែកផុតពីទឹកមានប្រវែង $AE = 3dm$ ពេលនោះមានចាបមួយមកទុំធ្វើឱ្យផ្កាឈូកទ្រេតប្រកាន់យកស្ថានភាព $BA'$ ដែល $EA' = 9dm$ ។ ចូររកជំរៅទឹក $EB$ ។




19. តាង $b$ និង $c$ ជារង្វាស់ជ្រុងទាំងពីរនៃមុំកែងរបស់ត្រីកោណកែងមួយ ។ $h$ ជារង្វាស់កម្ពស់ចំពោះអ៊ីប៉ូតេនុស ។ ចូរគណនា $h$ ទៅតាមតម្លៃ $a$ និង $b$ ។

20. $ABCD$ ជាប្រលេឡូក្រាមដូចរូបខាងស្ដាំ ។ $I$ ជាចំណុចកណ្ដាលនៃ $AD$ ដែល $(IB)\perp(AD)$ ។

ក. ចូរគណនា $IB$

ខ. ចូរគណនាផ្ទៃក្រឡានៃប្រលេឡូក្រាម ។




21. ក្នុងរូបខាងស្ដាំនេះ $NMQ$ និង $PNQ$ ជាត្រីកោណកែង ។

ក. ចូរគណនារង្វាស់ $MQ$

ខ. ចូរគណនារង្វាស់ $NP$ ។




22. ក្នុងរូបខាងស្ដាំនេះអង្កត់ធ្នូ $CD$ និង $AB$ កាត់គ្នាត្រង់ $I$ ដែល $AI = 15cm$ , $IC = 12cm$ , $ID = 4cm$ , $IB = 5cm$ , $BD = 3cm$ ។

ក. ចូរប្រៀបធៀបត្រីកោណ $IAC$ និង $IBD$

ខ. ចូរគណនារង្វាស់ $AC$ ។



23. ក្នុងរូបខាងស្ដាំពីចំណុច $P$ គេគូសបន្ទាត់ប៉ះរង្វង់ត្រង់ $A$ ហើយគូសបន្ទាត់មួយទៀតកាត់រង្វង់ត្រង់ $C$ និង $D$ ។




ក. ចូរប្រៀបធៀបត្រីកោណ $PAC$ និង $PAD$

ខ. ចូរទាញឱ្យឃើញថា $AP^2 = PC \times PD$ ។

24. ក្នុងរូបខាងស្ដាំនេះ តើកោណទាំងពីរដូចគ្នាឬទេ ?




25. រូបខាងស្ដាំជាកោណពីរដូចគ្នា ។

ក. បង្ហាញថាបើកោណពីរដូចគ្នានោះ

$\frac{v}{V} = \left(\frac{h}{H}\right)^3 = \left(\frac{r}{R}\right)^3$ ដែល $v$ និង $V$ ជាមាឌ

ខ. បើកោណតូចមានមាឌ $v = 6.28cm^2$

ហើយ $h = 2cm$ , $H = 4cm$ ។

ចូរគណនាមាឌ $V$ នៃកោណធំ ។



មេរៀនទី

# 17 ពហុកោណ

**វត្ថុបំណង**

- កំណត់មុំនិងជ្រុងនៃពហុកោណប៉ោង ។
- រកផលបូកមុំក្នុងនិង មុំក្រៅពហុកោណ ។
- រករង្វាស់មុំនៃពហុកោណនិយ័ត ។

## 1. និយមន័យ

ពហុកោណជាផ្នែកមួយនៃប្លង់ខណ្ឌដោយខ្សែកាច់បិទជិត ។



ពហុកោណប៉ោង



ពហុកោណផត

ចំពោះពីរករណីនេះ យើងសិក្សាតែពហុកោណប៉ោង ។

គេឱ្យឈ្មោះពហុកោណទៅតាមចំនួនជ្រុងរបស់វា ។

| ឈ្មោះ ពហុកោណ | រូប | ចំនួនជ្រុង |
|---|---|---|
| ត្រីកោណ |  | 3 |
| ចតុកោណ |  | 4 |
| បញ្ចកោណ |  | 5 |
| ឆកោណ |  | 6 |

***លំហាត់គំរូទី 1 :*** ចូររាប់ចំនួននិងចំនួនជ្រុងនៃពហុកោណតាមរូបខាងក្រោម ។




***ចម្លើយ :***

| រូប | ចំនួនជ្រុង | ចំនួនមុំ |
|---|---|---|
|  | 7 | 7 |
|  | 8 | 8 |
|  | 9 | 9 |

***លំហាត់គំរូទី 2 :*** ចូរប្រាប់ចំនួនជ្រុងនិងអង្កត់ទ្រូងនៃពហុកោណរូបខាងស្តាំ ។



***ចម្លើយ :*** ពហុកោណមានជ្រុងទាំងអស់ 6 ហើយមានអង្កត់ទ្រូងចំនួន 9 ។

***ចំណាំ :*** អង្កត់ទ្រូងពហុកោណជាអង្កត់ភ្ជាប់កំពូលពីរមិនជាប់គ្នា ។

***ប្រតិបត្តិ :*** គេមាន 8 ចំណុចដែលមិនស្ថិតនៅលើបន្ទាត់តែមួយនិងមិនត្រួតស៊ីគ្នា ។ ចូរភ្ជាប់ចំណុចទាំងនោះព្រមទាំងប្រាប់ចំនួន ជ្រុងនិងអង្កត់ទ្រូង ។

## 2. ផលបូកមុំក្នុងនៃពហុកោណ

យើងដឹងថាផលបូកមុំក្នុងត្រីកោណស្មើនឹង 180°

ហេតុនេះ ដើម្បីគណនាផលបូកមុំក្នុងពហុកោណគេត្រូវភ្ជាប់អង្កត់ទ្រូងដើម្បីខណ្ឌចែកពហុកោណជាត្រីកោណ ។



ខាងក្រោមនេះជារបៀបរាប់ចំនួនត្រីកោណក្នុងពហុកោណ ។



ជ្រុង 4 កំណត់បានត្រីកោណ 2



ជ្រុង 5 កំណត់បានត្រីកោណ 3



ជ្រុង 6 កំណត់បានត្រីកោណ 4

ដូចនេះ ពហុកោណមួយដែលមាន $n$ ជ្រុងអាចមាន $(n-2)$ ត្រីកោណ ។ ដោយក្នុងត្រីកោណមួយមានផលបូករង្វាស់មុំក្នុងស្មើនឹង $180°$ នាំឱ្យពហុកោណដែលមាន $n$ ជ្រុងមានផលបូករង្វាស់មុំក្នុងស្មើនឹង $(n-2).180°$ ។

***ឧទាហរណ៍ទី4 :*** ផលបូកមុំក្នុងនៃ

- ត្រីកោណ $(3-2)\times 180° = 180°$
- ចតុកោណ $(4-2)\times 180° = 360°$
- បញ្ចកោណ $(5-2)\times 180° = 540°$
- អដ្ឋកោណ $(8-2)\times 180° = 1\ 080°$ ។

> ***និយមន័យ :*** ផលបូករង្វាស់មុំក្នុងនៃពហុកោណមួយដែលមាន $n$ ជ្រុងស្មើនឹង $(n-2)\times 180°$

***លំហាត់គំរូទី 1 :*** ចូរគណនាផលបូករង្វាស់មុំក្នុងនៃពហុកោណតាមរូបខាងស្តាំ ។



***ចម្លើយ :*** ពហុកោណនេះជាឆកោណគឺ $n = 6$

តាមរូបមន្តនៃរង្វាស់មុំក្នុង

$$(n-2)\times 180^\circ = (6-2)\times 180^\circ$$

$$= 4\times 180^\circ$$

$$= 720^\circ$$

ដូចនេះ ឆកោណមានផលបូករង្វាស់មុំក្នុងស្មើនឹង $720^\circ$ ។

***លំហាត់គំរូទី 2 :*** ចូរប្រាប់ឈ្មោះនិងគូសរូបពហុកោណមួយដែលមានផលបូករង្វាស់មុំក្នុងស្មើនឹង $1\ 080^\circ$ ។

***ចម្លើយ :*** តាមរូបមន្តនៃរង្វាស់មុំក្នុង $(n-2)\times 180^\circ$




យើងបាន $1\ 080^\circ = (n-2)\times 180^\circ$

នាំឱ្យ $n-2 = \dfrac{1\ 080^\circ}{180^\circ}$

$$n-2 = 6$$

$$= 8$$

ដូចនេះ ពហុកោណនេះមានជ្រុង 8 មានឈ្មោះអដ្ឋកោណ ។

***លំហាត់គំរូទី 3 :*** ចូររកផលបូករង្វាស់មុំក្នុងនៃពហុកោណដែលមានជ្រុង : 7 10 12 ។

***ចម្លើយ :***

- រកផលបូករង្វាស់មុំក្នុងនៃពហុកោណដែលមានជ្រុង 7

តាមរូបមន្ត : $(n-2)\times 180^\circ = (7-2)\times 180^\circ$

$$= 5\times 180^\circ$$

$$= 900^\circ$$

ដូចនេះ ផលបូករង្វាស់មុំក្នុងនៃពហុកោណដែលមានជ្រុង 7 ស្មើនឹង $900^\circ$ ។

• រកផលបូករង្វាស់មុំក្នុងនៃពហុកោណដែលមានជ្រុង 10

តាមរូបមន្ត : $(n-2)\times 180^\circ = (10-2)\times 180^\circ$

$= 8\times 180^\circ$

$= 1\ 440^\circ$

ដូចនេះ ផលបូករង្វាស់មុំក្នុងនៃពហុកោណដែលមានជ្រុង 10 ស្មើនឹង $1\ 440^\circ$ ។

• រកផលបូករង្វាស់មុំក្នុងនៃពហុកោណដែលមានជ្រុង 12

តាមរូបមន្ត : $(n-2)\times 180^\circ = (12-2)\times 180^\circ$

$= 10\times 180^\circ$

$= 1\ 800^\circ$

ដូចនេះផលបូករង្វាស់មុំក្នុងនៃពហុកោណដែលមានជ្រុង 12 ស្មើនឹង $1\ 800^\circ$ ។

*ប្រតិបត្តិ :* ចូររកចំនួនជ្រុងនៃពហុកោណដែលមានផលបូករង្វាស់មុំក្នុងស្មើនឹង $2\ 700^\circ$ , $3\ 420^\circ$ ។

## 3. ផលបូករង្វាស់មុំក្រៅនៃពហុកោណ




*ឧទាហរណ៍ទី1 :* គេឱ្យចតុកោណ $ABCD$ មួយ (រូបខាងស្តាំ)បើគេបន្លាយអង្កត់ $DA$ ខាង $A$ នោះយើងសង្កេតឃើញថាផលបូកមុំក្នុងនិងមុំក្រៅនៅត្រង់កំពូល $A$ មានរង្វាស់ស្មើនឹង $\alpha+\beta = 180^\circ$ (ព្រោះ $DAx$ ជាបន្ទាត់) ។

*ឧទាហរណ៍ទី2 :* គេមានពហុកោណមួយដែលមាន $n$ កំពូល ផលបូករង្វាស់មុំក្នុងនិងផលបូករង្វាស់មុំក្រៅស្មើនឹង $n\times 180^\circ$ ។ ដោយផលបូករង្វាស់មុំក្នុងមានរង្វាស់ស្មើនឹង $(n-2)\times 180^\circ$ ផលបូករង្វាស់មុំក្រៅនៃពហុកោណដែលមាន $n$ ជ្រុងគឺ

$$(n\times 180^\circ)-(n-2)\times 180^\circ = n180^\circ - n180^\circ + 360^\circ$$

$$= 360^\circ \text{ ។}$$

| |
|---|
| *ជាទូទៅ :* ផលបូករង្វាស់មុំក្រៅនៃគ្រប់ពហុកោណប៉ោងមានរង្វាស់ស្មើនឹង $360^\circ$ ។ |

*សំគាល់ :* ផលបូករង្វាស់មុំក្រៅនេះ មិនអាស្រ័យនឹងចំនួនជ្រុងពហុកោណទេ ។

***លំហាត់គំរូទី 1*** **:** បើផលបូកនៃរង្វាស់មុំក្នុងស្មើនឹងផលបូករង្វាស់មុំក្រៅ នៃពហុកោណមួយ ។ ចូរប្រាប់ប្រភេទពហុកោណនោះ ។

***ចម្លើយ*** **:** ប្រភេទពហុកោណ

ដោយផលបូកនៃរង្វាស់មុំក្នុងស្មើនឹងផលបូករង្វាស់មុំក្រៅនៃពហុកោណ

យើងបាន $(n-2)\times 180^\circ = 360^\circ$



$$n180^\circ - 360^\circ = 360^\circ$$

$$n = \frac{360^\circ + 360^\circ}{180^\circ}$$

$$= \frac{720^\circ}{180^\circ}$$

$$= 4$$

ដូចនេះ ពហុកោណដែលមានផលបូករង្វាស់មុំក្នុងស្មើនឹងផលបូករង្វាស់ក្រៅជាចតុកោណ ។

***លំហាត់គំរូទី 2*** **:** បើផលបូកនៃរង្វាស់មុំក្នុងស្មើនឹងពីរដងផលបូករង្វាស់មុំក្រៅនៃពហុកោណមួយ ។ ចូរបញ្ជាក់ពីប្រភេទពហុកោណ ។

***ចម្លើយ*** **:** ប្រភេទពហុកោណ

ដោយផលបូកនៃរង្វាស់មុំក្នុងស្មើនឹងពីដងនៃផលបូករង្វាស់មុំក្រៅនៃពហុកោណ



យើងបាន $(n-2)\times 180^\circ = 2\times 360^\circ$

$$n180^\circ - 360^\circ = 270^\circ$$

$$n = \frac{270^\circ + 360^\circ}{180^\circ}$$

$$= \frac{1\ 080^\circ}{180^\circ}$$

$$= 6$$

ដូចនេះ ពហុកោណនោះជាឆកោណ ។

***លំហាត់គំរូទី 3*** **:** ចូរគណនារង្វាស់មុំ $x$ នៃពហុកោណខាងស្តាំ ។



***ចម្លើយ :*** គណនារង្វាស់មុំ $x$

ដោយផលបូកមុំក្រៅនៃពហុកោណមួយមានរង្វាស់ស្មើនឹង $360°$

គេបាន $3x + x + 80° + 70° = 360°$

$$4x + 150° = 360°$$

$$4x = 360° - 150°$$

$$4x = 210°$$

$$x = 52.5°$$

ដូចនេះ $x = 52.5°$ ។

***លំហាត់គំរូទី 4 :*** ចូរគណនាតម្លៃ $\alpha$ នៃពហុកោណខាងស្តាំ ។

***ចម្លើយ :*** គណនាតម្លៃ $\alpha$

ដោយផលបូកមុំក្រៅនៃពហុកោណមួយមានរង្វាស់ស្មើនឹង $360°$

គេបាន $\alpha + 2\alpha + \alpha + 2\alpha + 2\alpha + 2\alpha + 2\alpha = 360°$

$$12\alpha = 360°$$

$$\alpha = \frac{360°}{12} = 30°$$




ដូចនេះ $\alpha = 30°$ ។

***ប្រតិបត្តិ :*** ចូរគណនាតម្លៃ $\beta$ ក្នុងពហុកោណខាងក្រោម ។




# 4. រង្វាស់មុំនៃពហុកោណនិយ័ត

***ឧទាហរណ៍ទី 1 :*** គេមានត្រីកោណសម័ង្ស $ABC$ (ដូចរូបខាងស្តាំ) ។ ដោយត្រីកោណសម័ង្សមានរង្វាស់ជ្រុងទាំងបីប៉ុនគ្នា ហើយមានមុំទាំងបីក៏ប៉ុនគ្នាដែរ នោះគេថាត្រីកោណសម័ង្ស $ABC$ ជាពហុកោណនិយ័ត ។



***ឧទាហរណ៍ទី 2*** : គេមាន ការេ បញ្ចកោណ និងឆកោណនិយ័តដូចរូបខាងក្រោម ។



យើងសង្កេតឃើញថា ពហុកោណនីមួយៗខាងលើមានមុំទាំងអស់ប៉ុនគ្នា និងជ្រុងទាំងអស់ប៉ុនគ្នាហៅថា ពហុកោណនិយ័ត ។

***ឧទាហរណ៍ទី 3*** : រង្វាស់មុំក្នុងនៃត្រីកោណសម័ង្សមួយស្មើនឹង $\frac{(3-2)180°}{3} = 60°$

(ពីព្រោះផលបូកមុំក្នុងនៃពហុកោណស្មើនឹង $(n-2)180°$ ) ។

| |
|---|
| ជាទូទៅ :<br>• ពហុកោណនិយ័តជាពហុកោណដែលមុំមានរង្វាស់ស្មើគ្នា ហើយជ្រុងទាំងអស់ប៉ុនគ្នា ។<br>• មុំក្នុងមួយនៃពហុកោណនិយ័តដែលមាន $n$ ជ្រុងមានរង្វាស់មុំស្មើនឹង $\frac{(n-2)180°}{n}$ ។ |

***លំហាត់គំរូទី 1*** : ចូររករង្វាស់មុំក្នុងនីមួយៗនៃការេ ។

***ចម្លើយ*** : រង្វាស់មុំក្នុងនីមួយៗនៃការេគឺ

$$\frac{(4-2)180°}{4} = 90°$$

ដូចនេះ រង្វាស់មុំក្នុងនីមួយៗនៃការេគឺ 90° ។

***លំហាត់គំរូទី 2*** : ចូររករង្វាស់មុំក្នុងនីមួយៗនៃអដ្ឋកោណនិយ័ត ។

***ចម្លើយ*** : រង្វាស់មុំក្នុងនីមួយៗនៃអដ្ឋកោណនិយ័ត

$$\frac{(n-2)180°}{n} = \frac{(8-2)180°}{8} = \frac{6\times 180°}{8} = 135°$$

ដូចនេះ រង្វាស់មុំក្នុងនីមួយៗនៃអដ្ឋកោណនិយ័ត $a° = 135°$ ។

***ប្រតិបត្តិ*** : ហេតុអ្វីបានជាចតុកោណកែង និងចតុកោណស្មើមិនមែនជាពហុកោណនិយ័ត ? ចូរបញ្ជាក់ ?

## ? លំហាត់

1. ចូរគណនាផលបូករង្វាស់មុំក្នុងនៃពហុកោណដែលមានជ្រុង 7  8  9  10 និង 12 ។
2. ចូររកចំនួនជ្រុងនៃពហុកោណដែលមានផលបូករង្វាស់មុំក្នុងស្មើនឹង 1 800° , 2 700° និង 4 860° ។
3. តើមានពហុកោណណាដែលមានផលបូករង្វាស់មុំក្នុងស្មើនឹង 5 130° ដែរឬទេ ?
4. នៅពេលគេធ្វើការគណនាផលបូករង្វាស់មុំក្នុងនៃពហុកោណប៉ោងមួយដែលមានរង្វាស់ស្មើនឹង 540° តើពហុកោណប៉ោងនោះមានជ្រុងប៉ុន្មាន ?
5. ចូររកតម្លៃ $x$ តាមរូបនីមួយៗ នៃពហុកោណខាងក្រោម ។



រូប ក



រូប ខ



រូប គ

6. ចូររកតម្លៃ $y$ តាមរូបនីមួយៗ នៃពហុកោណខាងក្រោម ។



រូប ក



រូប ខ



រូប គ

7. ចូរគណនាចំនួនជ្រុងនៃពហុកោណនិយ័តដោយស្គាល់រង្វាស់មុំក្នុងស្មើនឹង 150° , 160° និង 175° ។
8. ផលបូករង្វាស់មុំក្នុងនៃពហុកោណនិយ័តមួយមានរង្វាស់ស្មើនឹង 3 240° ។ ចូរគណនារង្វាស់មុំក្រៅនីមួយៗ ។
9. ផលបូករង្វាស់មុំក្នុងរួមនឹងផលបូករង្វាស់មុំក្រៅនៃពហុកោណនិយ័តមួយស្មើនឹង 900° ។ តើពហុកោណនោះមានជ្រុងប៉ុន្មាន ?
10. មុំក្នុងមួយនៃពហុកោណនិយ័តដែលមាន $n$ ជ្រុងមានរង្វាស់ស្មើនឹង 168° ។ ចូររកចំនួន $n$ ។

11. ចូរគណនារង្វាស់មុំក្រៅនីមួយៗនៃពហុកោណនិយ័តខាងក្រោម ។

ក. ឆកោណនិយ័ត $n = 6$

ខ. បញ្ចកោណនិយ័ត $n = 5$

គ. អដ្ឋកោណនិយ័ត $n = 8$

ឃ. ពហុកោណនិយ័តដែលមានជ្រុង 12 ។

12. ផលបូករង្វាស់មុំក្នុងនិងមុំក្រៅស្មើនឹង 900° ។ តើពហុកោណនោះមានជ្រុងប៉ុន្មាន ?

13. ដោយជ្រុងនីមួយៗ នៃឆកោណនិយ័ត ជាជ្រុងមួយរបស់ការេដែលគេគូសនៅខាងក្រៅឆកោណនិយ័តហើយគេភ្ជាប់ពីកំពូលការេដែលនៅជាប់ៗគ្នា ។ ចូរស្រាយបញ្ជាក់ថារូបដែលកកើតជាពហុកោណនិយ័តដែលមានជ្រុង 12 ។

14. មុំក្រៅនៃអដ្ឋកោណនិយ័តមួយមានរង្វាស់ 27° តិចជាងរង្វាស់មុំក្រៅមួយនៃពហុកោណនិយ័តមួយដែលមាន $n$ ជ្រុង ។ ចូរគណនា $n$ ។

15. ចូរស្រាយបញ្ជាក់ថាបើពហុកោណមួយដែលមាន $n$ ជ្រុងនោះចំនួនអង្កត់ទ្រូងដែលគេអាចគូសបានស្មើ $\frac{n(n-3)}{2}$ ។

**ណែនាំ :** ប្រៀបធៀបចំនួនជ្រុងពហុកោណទៅនឹងចំនួនអង្កត់ទ្រូងដែលគូសចេញពីកំពូលមួយនៃពហុកោណ ។

16. ចូរគណនាមុំក្នុងនិងមុំក្រៅនៃឆកោណនិយ័ត ។

17. មុំក្រៅនៃពហុកោណនិយ័តដែលមាន $n$ ជ្រុងមានរង្វាស់ 30° ច្រើនជាងរង្វាស់មុំក្រៅមួយនៃឆកោណនិយ័ត ។ ចូរគណនា $n$ ។

មេរៀនទី

# 18 សូលីត

**វត្ថុបំណង**

- ❑ កំណត់ផ្ទៃក្រឡាខាងនិងផ្ទៃក្រឡាទាំងអស់នៃសូលីត ។
- ❑ គណនាមាឌសូលីតតាមរូបមន្ត ទំនាក់ទំនងផ្ទៃក្រឡា និងមាឌនៃសូលីត ។
- ❑ គណនាផលធៀបផ្ទៃក្រឡានិងមាឌនៃសូលីត ។

## 1. ផ្ទៃក្រឡានិងមាឌនៃសូលីត

### 1.1. ផ្ទៃក្រឡាខាងនៃសូលីត

មុននឹងសិក្សាផ្ទៃក្រឡានៃសូលីត គេត្រូវស្គាល់ធាតុនៃសូលីតដូចខាងក្រោម ។




*កោណ*




*ពីរ៉ាមីតនិយ័ត*

សូលីតដែលគេជួបប្រទះញឹកញាប់គឺ ពីរ៉ាមីតនិយ័តដូចខាងក្រោម ។




*ពីរ៉ាមីតនិយ័តមាន បាតជាត្រីកោណ ABC*

*ពីរ៉ាមីតនិយ័តមាន បាតជាការេ ABCD*

*ពីរ៉ាមីតនិយ័តមាន បាតជាឆកោណ ABCDEF*

- $[OS]$ កែងនឹងប្លង់បាតហៅថាកម្ពស់នៃពីរ៉ាមីត
- $[SH]\perp[AB]$ ឬ $[SH]\perp[BC]$ ឬ $[SH]\perp[CD]$ ហៅថា **អាប៉ូតែម** ។

ដើម្បីគណនាផ្ទៃក្រឡានៃសូលីត គេពន្លាតពីរ៉ាមីតនិយ័តដែលមានបាតជាការេដាក់លើប្លង់មួយ ។



$$S_L = 4\times S_{ABC}$$

$$= 4\times\frac{1}{2}DC\times HS$$

$$= \frac{1}{2}\times \underbrace{4DC}_{\text{បរិមាត្របាត}}\times \underbrace{HS}_{\text{អាប៉ូតែម}}$$

*ជាទូទៅ :* ផ្ទៃក្រឡាខាងនៃពីរ៉ាមីតនិយ័តស្មើនឹងផលគុណរវាងកន្លះបរិមាត្របាតនឹងអាប៉ូតែម $S_L = \frac{1}{2}\times p\times a$ ( $p$ : បរិមាត្រពហុកោណនិយ័តបាត , $a$ : អាប៉ូតែម) ។

ដូចគ្នានេះដែរ បើគេពន្លាតផ្ទៃខាងនៃកោណដោយកាត់តាមជនេត្រណាមួយដាក់លើប្លង់ នោះគេបានចម្រៀកថាសមួយហើយធ្នូកំណត់ចម្រៀកថាសនេះមានរង្វាស់ស្មើនឹងបរិមាត្រនៃរង្វង់បាតរបស់កោណ ។ (ថាសផ្ចិត $S$ កាំ $a$ )




ចម្រៀកថាសជាផ្នែកមួយនៃថាសដែលត្រូវនឹងប្រវែងធ្នូ $2\pi R$

តាង $S$ ជាផ្ទៃក្រឡានៃចម្រៀកថាស

ផ្ទៃថាស $\pi a^2$ ត្រូវនឹងប្រវែងធ្នូ $2\pi a$

ផ្ទៃចម្រៀកថាស $S$ ត្រូវនឹងប្រវែងធ្នូ $2\pi R$

$$\frac{\pi a^2}{S} = \frac{2\pi a}{2\pi R}\ ,\ S = \frac{2\pi^2 Ra^2}{2\pi a} = \pi Ra$$






***ជាទូទៅ*** : ផ្ទៃក្រឡាខាងនៃកោណគឺ $S_L = \pi Ra$ ( $R$ កាំបាត , $a$ ជនេត្រ)

ផ្ទៃក្រឡាទាំងអស់គឺ $S_T = \pi Ra + \pi R^2 = \pi R(a+R)$

***លំហាត់គំរូទី1*** : ចូរគណនាផ្ទៃក្រឡាខាងនៃពីរ៉ាមីតនិយ័ត(តាមរូបខាងក្រោម) ។

***ចម្លើយ*** : ផ្ទៃក្រឡាខាង




$$S_L = \frac{1}{2}pa$$

$$= \frac{1}{2}(6 \times 6) \times 7$$

$$= 126$$

ដូចនេះ ផ្ទៃក្រឡាខាងនៃពីរ៉ាមីតនិយ័តគឺ $S_L = 126cm^2$ ។

***លំហាត់គំរូទី2*** : ចូរគណនាក្រឡាផ្ទៃទាំងអស់នៃពីរ៉ាមីតនិយ័ត(តាមរូបខាងក្រោម) ។

***ចម្លើយ*** : ផ្ទៃក្រឡាខាង

$$S_L = \frac{1}{2}pa$$

$$= \frac{1}{2}(15 \times 4) \times 12$$

$$= 360$$




ផ្ទៃក្រឡាបាត

$$S_B = a^2$$

$$= 15^2$$

$$= 225$$

ផ្ទៃក្រឡាទាំងអស់

$$S_T = S_L + S_B$$

$$= 360 + 225$$

$$= 585$$

ដូចនេះ ផ្ទៃក្រឡាទាំងអស់គឺ : $S_T = 585cm^2$ ។

***លំហាត់គំរូទី 3*** : ចូរគណនាផ្ទៃក្រឡាខាងនិងផ្ទៃក្រឡាទាំងអស់នៃកោណ(តាមរូបខាងស្តាំ) ។ ($\pi = 3.14$)




***ចម្លើយ*** : ផ្ទៃក្រឡាខាង

$$S_L = \pi R a$$
$$= 3.14 \times 4 \times 13$$
$$= 163.28 cm^2$$

ផ្ទៃក្រឡាទាំងអស់

$$S_T = \pi R(R + a)$$
$$= 3.14 \times 4(4 + 13)$$
$$= 213.52 cm^2 \text{ ។}$$

***ប្រតិបត្តិ*** : ចូរគណនាផ្ទៃក្រឡាខាងនិងផ្ទៃក្រឡាទាំងអស់តាមរូបខាងក្រោម ។



*រូប* (a)



*រូប* (b)



*រូប* (c)

## 1.2. មាឌនៃសូលីត

ខាងក្រោមនេះជារូបមន្តនៃមាឌសូលីត ។

| រូប | ឈ្មោះ | មាឌ ($V$) |
|---|---|---|
|   | ពីរ៉ាមីត | $V = \frac{1}{3} S_B \times h$<br>$SO = h$ ជាកម្ពស់ពីរ៉ាមីត<br>$S_B$ ផ្ទៃក្រឡាបាត |

| | | |
|---|---|---|
|  | កោណ | $V = \frac{1}{3}\pi R^2\ h$<br>$SO = h$ ជាកម្ពស់កោណ<br>$R$ កាំនៃថាសបាត |
|  | ស្វ៊ែ ឬ ប៊ូល | $S = 4\pi R^2$ , $V = \frac{4}{3}\pi R^3$<br>$O$ ហៅថា ផ្ចិតនៃប៊ូល ឬ ស្វ៊ែ<br>$[OA]$ , $[OD]$ ហៅថា កាំ<br>$OA = OB = OC = OD = R$<br>$[BC]$ ហៅថា អង្កត់ផ្ចិត<br>$BC = 2R$ |

***លំហាត់គំរូទី 1 :*** ចូររកមាឌនៃពីរ៉ាមីត(រូបខាងស្តាំ) ។




***ចម្លើយ :*** មាឌនៃពីរ៉ាមីត

ផ្ទៃក្រឡាបាត

$$S_B = 18 \times 18$$

$$= 324cm^2$$

មាឌនៃពីរ៉ាមីត

$$V = \frac{S_B \times h}{3}$$

$$= \frac{324 \times 30}{3}$$

$$= 4\ 860cm^3$$

ដូចនេះ មាឌនៃពីរ៉ាមីត $V = 4\ 860cm^3$ ។

*លំហាត់គំរូទី 2 :* កោណមួយមានកម្ពស់ $24cm$ ហើយមានមាឌ $3\ 018cm^3$ ។ ចូររកផ្ទៃក្រឡាបាតកោណ ។




*ចម្លើយ :* ផ្ទៃក្រឡាបាតកោណ

តាមរូបមន្ត $V = \dfrac{S_B \times h}{3}$ នាំឱ្យ $S_B = \dfrac{3V}{h}$

$$S_B = \frac{3\ 018 \times 3}{24}$$

$$= 377.25$$

ដូចនេះ ផ្ទៃក្រឡាបាតកោណ $S_B = 377.25cm^2$ ។

*លំហាត់គំរូទី 3 :* ចូររកផ្ទៃក្រឡាស្វ៊ែនិងមាឌប៊ូលដែលកាំមានប្រវែង $14cm$ ។

*ចម្លើយ :* ផ្ទៃក្រឡាស្វ៊ែ

$$S = 4\pi R^2$$

$$= 4 \times 3.14 \times (14)^2$$

$$= 2461.76cm^2$$

មាឌប៊ូល

$$V = \frac{4}{3}\pi R^3$$

$$= \frac{4}{3} \times 3.14 \times (14)^3$$

$$= 11488.21cm^3 \text{ ។}$$

*ប្រតិបត្តិ :* កោណមួយមានកម្ពស់ $28cm$ និង កាំនៃថាសបាតមានប្រវែង $13cm$ ។ ចូរគណនាមាឌកោណគិតជា $dm^3$ ។

# 2. ផលធៀបផ្ទៃក្រឡានិងមាឌនៃសូលីត

## 2.1. ផលធៀបផ្ទៃក្រឡា

*ឧទាហរណ៍ទី 1 :* គេមានការេ $A$ និងការេ $B$ ដូចរូបខាងក្រោម ។ តើផលធៀបផ្ទៃក្រឡារបស់វាស្មើនឹងប៉ុន្មាន ?




ផ្ទៃក្រឡាការេ $A$ ស្មើនឹង $1 \times 1 = 1cm^2$

ផ្ទៃក្រឡាការេ $B$ ស្មើនឹង $3 \times 3 = 9cm^2$

ផលធៀបរវាងជ្រុងនៃការេទាំងពីរគឺ $\frac{1}{3}$

ផលធៀបរវាងផ្ទៃក្រឡានៃការេទាំងពីរគឺ $\frac{1}{9} = \left(\frac{1}{3}\right)^2$

*ឧទាហរណ៍ទី 2 :* គេមានចតុកោណកែងពីរ(ដូចរូបខាងស្តាំ) ។




ផលធៀបរវាងបណ្តោយទាំងពីរស្មើនឹង $\frac{15}{10} = \frac{3}{2}$

ផលធៀបរវាងទទឹងទាំងពីរស្មើនឹង $\frac{6}{4} = \frac{3}{2}$

ផលធៀបរវាងផ្ទៃក្រឡាទាំងពីរស្មើនឹង

$\frac{15 \times 6}{10 \times 4} = \frac{3 \times 3}{2 \times 2} = \left(\frac{3}{2}\right)^2$ ។

*សំគាល់ :* ជ្រុងនៃចតុកោណកែងទាំងពីរសមាមាត្រនឹងគ្នាជាចតុកោណកែងដូចគ្នា ។

*ជាទូទៅ :* កាលណារូបពីរដូចគ្នាផលធៀបរវាងផ្ទៃក្រឡាស្មើនឹងការេនៃផលធៀបរវាងធាតុត្រូវគ្នាពីរ ។

*លំហាត់គំរូទី 1 :* ត្រីកោណទាំងពីរខាងស្តាំនេះជាត្រីកោណដូចគ្នា ។ ចូររកផ្ទៃក្រឡាត្រីកោណ $S$ ។




***ចម្លើយ :*** ផ្ទៃក្រឡាត្រីកោណ $S$

បើ $S$ ជាផ្ទៃក្រឡាដែលត្រូវរក

គេបាន $\frac{S}{144} = \left(\frac{12}{16}\right)^2$

$= \frac{9}{16}$

$= \left(\frac{3}{4}\right)^2$

នាំឱ្យ $S = \frac{9}{16} \times 144$

$= 81$

ដូចនេះ $S = 81cm^2$ ។

*លំហាត់គំរូទី 2 :* គេមានចតុកោណកែងពីរដូចគ្នាដែលមានផ្ទៃក្រឡារៀងគ្នាស្មើនឹង $18dm^2$ និង $8dm^2$ ។ ចូរគណនាបណ្តោយចតុកោណធំដោយដឹងថា ចតុកោណតូចមានបណ្តោយស្មើនឹង $6dm$ ។

***ចម្លើយ :*** ចូរបណ្តោយចតុកោណកែងធំ




តាង $x$ ជាបណ្តោយចតុកោណកែងធំ

គេបាន $\frac{18}{8} = \left(\frac{x}{6}\right)^2$

$$\frac{9}{4} = \frac{x^2}{36}$$

$$x^2 = \frac{9}{4}\times 36$$

$$= 81$$

នាំឱ្យ $x = \sqrt{81}$

$$= 9$$

ដូចនេះ បណ្តោយចតុកោណកែងធំ $x = 9dm$ ។

***លំហាត់គំរូទី 3 :*** នៅពេលសិក្សាមេរៀនភូមិវិទ្យាលោកគ្រូបានយកផែនទីនៃទីធ្លារបស់សាលារៀនដែលមានមាត្រដ្ឋាន $\frac{1}{2\ 500}$ ។ គេដឹងថាវិមាត្រនៃទីធ្លាសាលារៀននៅក្នុងប្លង់មានរាងចតុកោណកែងមានវង្វាស់ $3cm$ និង $2cm$ ។ ចូរគណនាផ្ទៃក្រឡាទីធ្លារបស់សាលារៀនពិត ។

***ចម្លើយ :*** ផ្ទៃក្រឡាទីធ្លាសាលារៀន

នៅក្នុងផែនទីជាប្លង់បង្រួមនៃទីធ្លាសាលារៀនដែលផលធៀបវិមាត្រស្មើនឹង $\frac{1}{2\ 500}$

បើ $S$ ជាផ្ទៃក្រឡារបស់សាលារៀន ហើយ $S'$ ជាផ្ទៃក្រឡានៅក្នុងផែនទី

គេបាន $\frac{S'}{S} = \left(\frac{1}{2\ 500}\right)^2$

នាំឱ្យ $S = S'\times(2\ 500)^2$

តែ $S' = 2\times 3$

$$= 6$$

នោះ $S = S'\times(2\ 500)^2$

$$= 6\times(2\ 500)^2$$

$S = 375\times 10^5$ ឬ $S = 3\ 750m^2$

ដូចនេះ ទីធ្លាសាលារៀនមានផ្ទៃក្រឡា $S = 3\ 750m^2$ ។

*ប្រតិបត្តិ ៖* ចូរសរសេរផលធៀបបរិមាត្រនិងផលធៀបផ្ទៃក្រឡានៃរូបដូចគ្នាខាងក្រោម ។




រូប(a)



រូប(b)

## 2.2. ផលធៀបមាឌ

*ឧទាហរណ៍ទី 1 ៖* គេមានគូបពីរ(ដូចរូបខាងស្តាំ)

មាឌរបស់គូប $(a)$ ស្មើនឹង $V_a = 1 \times 1 \times 1 = 1cm^3$

មាឌរបស់គូប $(b)$ ស្មើនឹង $V_b = 2 \times 2 \times 2 = 8cm^3$

ផលធៀបវិមាត្រស្មើនឹង $\frac{1}{2}$

ផលធៀបមាឌស្មើនឹង $\frac{1 \times 1 \times 1}{2 \times 2 \times 2} = \left(\frac{1}{2}\right)^3$ ។




រូប(a) រូប(b)

*ឧទាហរណ៍ទី 2 ៖* ចូរពិនិត្យប្រអប់ពីរដូចគ្នា(រូបខាងក្រោម) ។

ផលធៀបបណ្តោយស្មើនឹង $\frac{15}{10} = \frac{3}{2}$

ផលធៀបទទឹងស្មើនឹង $\frac{12}{8} = \frac{3}{2}$

ផលធៀបកម្ពស់ស្មើនឹង $\frac{9}{6} = \frac{3}{2}$

ផលធៀបមាឌស្មើនឹង $\frac{3 \times 3 \times 3}{2 \times 2 \times 2} = \left(\frac{3}{2}\right)^3$




ប្រអប់មានវិមាត្រសមមាត្រគ្នាជាប្រអប់ដូចគ្នា ។

> *ជាទូទៅ ៖* កាលណារូបពីរដូចគ្នាផលធៀបរវាងមាឌ ស្មើនឹងគូបនៃផលធៀបរវាងធាតុត្រូវគ្នាពីរ ។

*លំហាត់គំរូទី 1 ៖* ផលធៀបរវាងផ្ទៃក្រឡាទាំងអស់នៃគូបស្មើនឹង $\frac{16}{25}$ ។ ចូរគណនាផលធៀបរវាងជ្រុងនិងផលធៀបរវាងមាឌនៃគូបពីរដូចគ្នា ។

*ចម្លើយ ៖* យើងដឹងថាផលធៀបរវាងផ្ទៃក្រឡាស្មើនឹងការេផលធៀបរវាងជ្រុងត្រូវគ្នា

តាង $x$ ជាផលធៀបរវាងជ្រុងនោះ $x^2 = \frac{16}{25}$ , $x = \frac{4}{5}$

ដូចនេះផលធៀបរវាងមាឌស្មើនឹង $\left(\frac{4}{5}\right)^3 = \frac{64}{135}$ ។

***លំហាត់គំរូទី 2 :*** ផលធៀបរវាងបណ្ដោយនៃប្រលេពីប៉ែតកែងដូចគ្នាពីរស្មើនឹង $\frac{4}{3}$ ។ បើប្រលេពីប៉ែតកែងតូចមានមាឌ $54dm^3$ ចូររកមាឌប្រលេពីប៉ែតកែងធំ ។

***ចម្លើយ :*** មាឌប្រលេពីប៉ែតកែងធំ

តាង $V$ ជាមាឌនៃប្រលេពីប៉ែតកែងធំ

គេបាន $\frac{V}{54} = \left(\frac{4}{3}\right)^3$

$= \frac{64}{27}$

នាំឱ្យ $V = \frac{64}{27} \times 54$

$= 128dm^3$

ដូចនេះ $V = 128dm^3$ ។

***លំហាត់គំរូទី 3 :*** ផលធៀបរវាងផ្ទៃក្រឡាទាំងអស់នៃគូបស្មើនឹង 16 : 25 ។ តើគូបធំមានម៉ាសប៉ុន្មានបើគេដឹងថាគូបតូចមានម៉ាសស្មើនឹង $32g$ (គូបទាំងពីរធ្វើពីវត្ថុធាតុតែមួយ) ។ គូបទាំងពីរជាគូបដូចគ្នា ។

***ចម្លើយ :*** ម៉ាសគូបធំ

ផលធៀបរវាងផ្ទៃក្រឡាទាំងអស់ $\frac{s}{S} = \frac{16}{25} = \left(\frac{4}{5}\right)^2$

ផលធៀបរវាងមាឌ $\frac{v}{V} = \left(\frac{4}{5}\right)^3 = \frac{64}{125}$

យើងដឹងថាផលធៀបរវាងម៉ាសគូបទាំងពីរស្មើនឹងផលធៀបរវាងមាឌរបស់វា

បើ $m$ និង $M$ ជាម៉ាសនៃគូបទាំងពីរនាំឱ្យ $\frac{m}{M} = \frac{v \cdot \mu}{V \cdot \mu} = \frac{v}{V} = \frac{64}{125}$ ដែល $\mu$ ជាម៉ាសមាឌ

$M = \frac{125 \times m}{64}$

$= \frac{125}{64} \times 32$

$= 62.5$

ដូចនេះ $M = 62.5g$ ។

***ប្រតិបត្តិ :*** គេឱ្យ $(DE) // (BC)$ $AD = 3cm$ , $AB = 5cm$ ។ ដោយដឹងថាផ្ទៃក្រឡាត្រីកោណ $ADE = 6cm^2$ ។




ក. ចូររកក្រឡាផ្ទៃត្រីកោណ $ABC$

ខ. ចូររកក្រឡាផ្ទៃចតុកោណ $DECB$ ។

## ? លំហាត់

1. ចូររកផ្ទៃក្រឡាខាងនិងផ្ទៃក្រឡាទាំងអស់នៃរូបខាងក្រោម ។




រូប(a)




រូប(b)




រូប(c)

2. ចូររកមាឌកោណដែលមានកម្ពស់និងកាំបាតក្នុងករណីនីមួយៗខាងក្រោម ។

ក. $R = 5cm$ , $h = 12cm$ ខ. $R = 3.4cm$ , $h = 8.9cm$

គ. $R = 3.7cm$ , $h = 7cm$ ឃ. $R = 5.2cm$ , $h = 11cm$

ង. $R = \sqrt{5}mm$ , $h = 13.4mm$ ច. $R = 7dm$ , $h = 16dm$ ។

3. ចូររកផ្ទៃក្រឡាស្វ៊ែនិងមាឌប៊ូលក្នុងករណីនីមួយៗខាងក្រោម ។

ក. $R = 3cm$ ខ. $D = 18dm$ គ. $R = 3.7cm$ ឃ. $D = 23.2cm$ ។

4. ចូររកកាំស្វ៊ែដោយស្គាល់ផ្ទៃក្រឡាដូចខាងក្រោម ។

ក. $S = \frac{36}{25}\pi cm^2$ ខ. $S = \frac{46}{16}\pi m^2$ គ. $S = \frac{12}{5}\pi dm^2$ ឃ. $S = 1\ 764\pi cm$ ។

5. ចូររកកាំនៃប៊ូលដោយស្គាល់មាឌ

ក. $V = 288\pi cm^3$

ខ. $V = \frac{32}{16}\pi m^3$ ។

6. គេឱ្យកោណនិងកន្លះស្វ៊ែដូចរូបខាងស្តាំ ។

ក. ចូររកមាឌទាំងអស់នៃសូលីត ។

ខ. ចូររកផ្ទៃក្រឡាទាំងអស់នៃសូលីត ។




7. គេឱ្យបន្ទាត់ $AB // CD$ ដែល $\frac{BE}{CE} = \frac{1}{2}$ ។

ផ្ទៃក្រឡា $\Delta CED$ ស្មើនឹង $16cm^2$

ចូររកផ្ទៃក្រឡា $\Delta AEB$ ។



8. តើផ្ទៃក្រឡាការេ $DEFG$ តូចជាងផ្ទៃក្រឡា $ABCD$ ប៉ុន្មានដង ?




9. គេឱ្យប្រលេឡូក្រាម $ABCD$ និង $I$ ជាចំណុចកណ្ដាលនៃ $AB$ ។ បន្ទាត់ $BD$ និង $CI$ ប្រសព្វគ្នាត្រង់ $O$ ។ តើផ្ទៃក្រឡា $\Delta BIO$ តូចជាងផ្ទៃក្រឡា $\Delta DOC$ ប៉ុន្មានដង ?




10. រូបថតនៃជញ្ជាំងមួយមានកំពស់ $3cm$ និងមានផ្ទៃក្រឡាស្មើនឹង $9cm^2$ ។ គេដឹងថាជញ្ជាំងមានកម្ពស់ពិត $6m$ ។ តើវាមានផ្ទៃក្រឡាពិតប្រាកដប៉ុន្មាន $m^2$ ។

11. ផ្ទៃក្រឡានៃទីធ្លាសាលាមួយមានរង្វាស់ $144cm^2$ នៅក្នុងផែនទី 1 ហើយមានរង្វាស់ស្មើនឹង $256cm^2$ នៅក្នុងផែនទីពីរ ។ ដោយដឹងថាវិមាត្រមួយនៃទីធ្លានោះស្មើនឹង $18cm$ នៅក្នុងផែនទីទីមួយ ។ តើវិមាត្រនេះស្មើនឹងប៉ុន្មាន $cm$ នៅក្នុងផែនទីទីពីរ ?

12. ទីធ្លាមួយមានផ្ទៃក្រឡាពិត $9\ 600m^2$ ។ តើផ្ទៃក្រឡានេះមានប៉ុន្មាន $cm^2$ នៅក្នុងប្លង់មួយដែលមានមាត្រដ្ឋាន $\frac{1}{2\ 500}$ ។

13. គេកាត់កោណឱ្យស្របនឹងបាតជាបីចំណែក (ដូចរូបខាងស្ដាំ) ។ មុខកាត់មានអង្កត់ផ្ចិតរៀងគ្នា $6cm$ និង $10cm$ ។

ក. ចូរគណនា $x$

ខ. ចូររកមាឌនៃកោណនោះ ។




14. $SABCD$ ជាពីរ៉ាមីតដែលមានបាតជាការេ ។ ជ្រុងនៃការេនេះមានប្រវែង $60cm$ ។ កម្ពស់ $[SO]$ នៃពីរ៉ាមីតមានប្រវែង $80cm$ គេកាត់ពីរ៉ាមីតនេះឱ្យស្របនឹងបាត ។ គេបានការេ $EFGK$ ។ គេឱ្យ $OO' = x$ ។

ក. ចូររកជ្រុងនៃការេ $EFGK$ តាមតម្លៃ $x$ ។

ខ. បើ $x = 30cm$ គណនាមាឌនៃកំណាត់ពីរ៉ាមីតខណ្ឌដោយ $ABCD$ និង $EFGK$ ។

15. តាមរូបខាងស្ដាំនេះគេឱ្យ $BA = 6$ , $SA = 8$ , $SA' = \frac{2}{3}SA$ ។

រង្វាស់គិតជា $cm$ ។




ក. ចូរគណនា $A'B'$ ។

ខ. ចូរគណនាផ្ទៃក្រឡានៃការេ $A'B'C'D'$ រួចផ្ទៀងផ្ទាត់ ថាផ្ទៃក្រឡា $A'B'C'D' = \left(\frac{2}{3}\right)^2 \times$ ផ្ទៃក្រឡា $ABCD$ ។

គ. ចូរបង្ហាញថា $SO' = \frac{2}{3}SO$ រួចទាញបញ្ជាក់ថាមាឌ មាឌ $A'B'C'D' = \left(\frac{2}{3}\right)^3 \times$ មាឌ $SABCD$ ។

16. ក្នុងរូបខាងស្ដាំនេះគេឱ្យ $SM' = \frac{1}{2}SM$ , $SO = 10cm$ , $OM = 6cm$ ។




ក. ចូរគណនា $O'M'$ រួចផ្ទៀងផ្ទាត់ ផ្ទៃក្រឡាថាស $(O') = \left(\frac{1}{2}\right)^2$ ផ្ទៃក្រឡាថាស $(O)$ ។

ខ. ចូរបង្ហាញថា $SO' = \frac{1}{2}SO$ ។

គ. ចូរស្រាយបញ្ជាក់ថា មាឌនៃកោណនៃកំពូល $S$ និងបាត $O'$ ស្មើនឹងមាឌនៃកោណនៃកំពូល $S$ និងបាត $(O)$ គុណនឹង $\left(\frac{1}{2}\right)^3$ ។

17. អ្នកលក់ឪឡឹកម្នាក់កំណត់លក់ផ្លែឪឡឹកតូចពីរ ថ្លៃស្មើនឹងផ្លែឪឡឹកធំមួយ ។ ដោយថាកាំនៃផ្លែឪឡឹកតូចស្មើនឹង $\frac{1}{4}$ នៃកាំឪឡឹកធំ ។ តើអ្នកទិញត្រូវជ្រើសរើសមួយណាដើម្បីឱ្យបានចំណេញជាង ?

18. ឈ្មួញម្នាក់លក់ម៉ាស៊ីនបោកខោអាវពីរប្រភេទដែលមានរាងស៊ីឡាំងដូចគ្នា ។ តែវិមាត្រនៃម៉ាស៊ីនទីមួយស្មើនឹង $\frac{9}{10}$ នៃវិមាត្រម៉ាស៊ីនទីពីរ ។ តម្លៃនៃម៉ាស៊ីនតូចស្មើនឹង $\frac{7}{10}$ នៃម៉ាស៊ីនធំ ។ តើគេត្រូវជ្រើសរើសយកម៉ាស៊ីនប្រភេទណាទើបចំណេញជាង ?

19. ស៊ីឡាំងមួយមានរង្វាស់កាំ $R$ និងកម្ពស់ $h$ គេយកកោណដែលមានរង្វាស់កាំ $R$ និងកម្ពស់ $h$ ដាក់ក្នុងស៊ីឡាំងតាមរូប ។




ក. ចូរគណនាមាឌកោណនិងមាឌនៃស៊ីឡាំង

ខ. ចូរគណនាផលធៀបរវាងមាឌនៃកោណនិងមាឌនៃស៊ីឡាំង ។

20. កោណមួយមានរង្វាស់កាំ $R$ និងកម្ពស់ $h$ នៅក្នុងកោណនោះ មានស៊ីឡាំងមួយដែលមានរង្វាស់ស្មើនឹង $\frac{R}{2}$ ។




ក. ចូរគណនាមាឌនៃស៊ីឡាំងនោះ

ខ. ចូរគណនាផលធៀបរវាងមាឌនៃស៊ីឡាំងនិងមាឌនៃកោណ ។

21. គូបមួយមានរង្វាស់ជ្រុងស្មើនឹង $2a$ នៅក្នុងគូបនោះគេមានស៊ីឡាំងមួយដែលមានរង្វាស់កាំស្មើនឹង $a$ និងមានកម្ពស់ស្មើនឹង $2a$ ។




ក. ចូរគណនាមាឌនៃស៊ីឡាំង

ខ. ចូរគណនាផលធៀបរវាងមាឌនៃស៊ីឡាំងនិងមាឌនៃគូប ។

22. គូបមួយមានរង្វាស់ជ្រុង $2cm$ ហើយស្វ៊ែមួយមានកាំ $r$ ។ ចូរកំណត់កាំ $r$ ដោយដឹងថាមាឌនៃគូបស្មើនឹងពីរដងនៃមាឌស្វ៊ែ ។ គេបង្គត់ $\pi = 3$ ។



23. ផ្ទៃក្រឡានៃត្រីកោណសម័ង្សដែលមានជ្រុង $1cm$ ។ តើត្រូវជាប៉ុន្មានភាគរយនៃផ្ទៃក្រឡានៃការេដែលមានរង្វាស់ជ្រុង $1cm$ ។

